01382028

E1/467.1

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

---

**អង្គជំនុំជម្រះសាលាដំបូង**
Trial Chamber
Chambre de Premiere instance

# <u>កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី</u>
# <u>ជំនុំជម្រះក្តីនៅដំណាក់កាលពីរ</u>
## <u>សាធារណៈ</u>

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសដ

**ថ្ងៃទី៣១ ខែសីហា ឆ្នាំ២០១៦**

**ម៉ោង ០៨:៥៩នាទី**

**សវនាការលើកទី៤៤៨**

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 19-Jan-2017, 13:16
CMS/CFO: Sann Rada

ចៅក្រមសាលាដំបូង៖

ចៅក្រម យ៉ា សុខន ជាប្រធាន

ចៅក្រម ក្លូឌា ហ្វេនស៍
*(Judge Claudia FENZ)*

ចៅក្រម ហ្សង់ម៉ាក ឡាវែន
*(Judge Jean-Marc LAVERGNE)*

ចៅក្រម យូរ ឧត្តារា

ចៅក្រម ធូ មណី

ចៅក្រម ម៉ាទីន ខារ៉ុបគីន (បម្រុង)
*(Judge Martin KAROPKIN)*

ក្រឡាបញ្ជីសាលាដំបូង៖

កញ្ញា ជា ស៊ីវហ៉ាង

កញ្ញា អេវេលីន ខាំផូស សង់ចេស
*(Ms. Evelyn CAMPOS SANCHEZ)*

ការិយាល័យសហព្រះរាជអាជ្ញា៖

លោក ស្រ៊ា រតនៈ

លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល
*(Mr. Vincent de wilde d'ESTMAEL)*

លោក ឌេល លីសាក់ *(Mr. Dale Lysak)*

ជនជាប់ចោទ៖

លោក នួន ជា

លោក ខៀវ សំផន

មេធាវីការពារជនជាប់ចោទ នួន ជា៖

លោកស្រី ឌូរីន ជិន *(Mrs. Doreen CHEN)*

មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖

លោក គង់ សំអុន

កញ្ញា អង់តា ហ្គីសេ *(Ms. Anta GUISSE)*

**មេធាវីប្រចាំការលោក ខៀវ សំផន៖**

លោកស្រី ទូច វរល័ក្ស

លោក ខលវីន សោនដឺស៍
*(Mr. Calvin SAUNDERS)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោក ពេជ អង្គ

លោកស្រី ម៉ារី ហ្គីរ៉ូដ៍ *(Ms.Marie GUIRAUD)*

លោកស្រី ស៊ីន សុវ៉ន

លោក វ៉េន ពៅ

លោក ឡោ ជុនធី

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុំ អរុណ

លោកស្រី ស្វ សុទ្ធាវី

# បញ្ជីឈ្មោះអ្នកនិយាយ៖

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| **អ្នកនិយាយ** | **ភាសា** |
|---|---|
| ចៅក្រម យ៉ា សុខន (ប្រធានអង្គជំនុំ) | ខ្មែរ |
| ចៅក្រម ហ្សង់ម៉ាក ឡាវែន៍ | បារាំង |
| ចៅក្រម ក្លូឌា ហ្វែនស៍ | អង់គ្លេស |
| លោកស្រី ដូរីន ជិន | អង់គ្លេស |
| កញ្ញា អង់តា ហ្គីសសេ | បារាំង |
| លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល | បារាំង |
| លោកស្រី ម៉ារី ហ្គីរ៉ូដ៍ | បារាំង |
| លោក ឌេល លីសាក់ | អង់គ្លេស |
| លោក ឡោ ជុនធី | ខ្មែរ |
| លោក គង់ សំអុន | ខ្មែរ |
| លោកស្រី ជា ឌៀប (2-TCCP-286) | ខ្មែរ |
| លោកស្រី ផាន់ ហ៊ីម (2-TCW-914) | ខ្មែរ |

# ឧបសម្ព័ន្ធ

**ការសួរសំណួរទៅដើមបណ្តឹងរដ្ឋប្បវេណី ÷ លោកស្រី ជា ឡៀប** (2-TCCP-286)

សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៍ ផ្តើមពី ........ ទំព័រ ៣

សួរដោយលោកស្រី ដូរីន ជិន ផ្តើមពី ........ ទំព័រ ៨

សួរដោយចៅក្រម ក្លូឌា ហ្វេនស៍ ផ្តើមពី........ ទំព័រ ២៥

សួរដោយកញ្ញា អង់តា ហ្គីសសេ ផ្តើមពី........ ទំព័រ ៣០

**ការសួរសំណួរទៅសាក្សី÷ លោកស្រី ផាន់ ហ៊ីម/ ផាន់ ហ៊ីម ហៅ ធី** (2-TCW-914)

សួរដោយប្រធានអង្គជំនុំ ផ្តើមពី ........ ទំព័រ ៥៨

សួរដោយលោក ឌេល លីសាក់ ផ្តើមពី ........ ទំព័រ ៦០

សួរដោយលោកស្រី ម៉ារី ហ្គីរ៉ូដ៍ ផ្តើមពី ........ ទំព័រ ៨៧

សួរដោយលោក ឡោ ជុនធី ផ្តើមពី........ ទំព័រ ៨៩

# កិច្ចដំណើរការនីតិវិធី

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

[០៨:៥៨:៥៩]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ សវនាការនៅថ្ងៃនេះ អង្គជំនុំជម្រះនឹងបន្តស្តាប់សក្ខីកម្មដើមបណ្តឹងរដ្ឋប្បវេណី ជា ឌៀប បញ្ចប់ ហើយនិងចាប់ផ្តើមស្តាប់សក្ខីកម្មដែលមានរហស្សនាម 2-TCW-914។

ក្រឡាបញ្ជីសវនាការកញ្ញា ស៊ីវហ៊ង ឡើងរាយការណ៍អំពីស្ថានភាពវត្តមាន អវត្តមានភាគី និងបុគ្គលទាំងឡាយដែលអង្គជំនុំជម្រះកោះអញ្ជើញចូលរួមក្នុងកិច្ចដំណើរការនៅថ្ងៃនេះ។ សូមអញ្ជើញ!

**ក្រឡាបញ្ជី៖**

សូមគោរពលោកប្រធានសម្រាប់សវនាការនៅថ្ងៃនេះក្រឡាបញ្ជីកត់សម្គាល់ឃើញថា គ្រប់ភាគីទាំងអស់នៃរឿងក្តីនេះមានវត្តមាន។ លើកលែងតែលោក លីវ សុវណ្ណា មេធាវីជាតិការពារក្តីឱ្យលោក នួន ជា ដែលបានជូនដំណឹងមកថា លោកនឹងអវត្តមាននៅថ្ងៃនេះដោយសារមូលហេតុផ្ទាល់ខ្លួន។ ដោយឡែកលោក នួន ជា មានវត្តមាននៅបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការនេះ ដោយលោកស្នើសុំលះបង់សិទ្ធិមានវត្តមានដោយផ្ទាល់ពីបន្ទប់សវនាការនៅថ្ងៃនេះ។ លិខិតលះបង់សិទ្ធិរបស់លោក នួន ជា បានប្រគល់ដល់ក្រឡាបញ្ជីរួចហើយ។ ដើមបណ្តឹងរដ្ឋប្បវេណីដែលត្រូវមកផ្តល់សក្ខីកម្មបញ្ចប់នៅថ្ងៃនេះគឺលោកស្រី ជា ឌៀប។ លោកស្រី និងបុគ្គលិក ធី.ភី.អូ លោកស្រី ស៊ុន សូលីដា មានវត្តមានរួចហើយនៅក្នុងបន្ទប់សវនាការនេះ។

[០៩:០០:២៦]

ហើយសាក្សីដែលត្រូវមកផ្តល់សក្ខីកម្មបន្ទាប់ទៀតនៅថ្ងៃនេះមានរហស្សនាម 2-TCW-914។ សាក្សីបានបញ្ជាក់ថា តាមសមត្ថភាពដែលគាត់អាចដឹង គឺគាត់មិនមានទំនាក់ទំនងញាតិលោហិត ឬញាតិពន្ធជាមួយនឹងជនជាប់ចោទទាំងពីររូប គឺលោក នួន ជា ឬលោក ខៀវ សំផន និងភាគីដើមបណ្តឹងរដ្ឋប្បវេណីណាមួយដែលត្រូវបានទទួលស្គាល់នៅក្នុងរឿងក្តីនេះទេ។ សាក្សីនឹងធ្វើសម្បថនៅចំពោះលោកតាដំបងដែកនៅព្រឹកនេះ។ សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

ជាដំបូងនេះ អង្គជំនុំជម្រះសម្រេចលើសំណើសុំរបស់ជនជាប់ចោទ នួន ជា ជាមុនសិន។ អង្គជំនុំជម្រះបានទទួលលិខិតសុំលះបង់សិទ្ធិចូលរួមសវនាការដោយផ្ទាល់ ក្នុងបន្ទប់សវនាការនេះរបស់ជនជាប់ចោទ នួន ជា ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០១៦ ដែលបានបញ្ជាក់ថា ដោយគាត់មានបញ្ហាសុខភាព ឈឺក្បាល ឈឺចង្កេះ មិនអាចអង្គុយយូរបាន មិនអាចផ្ដង់អារម្មណ៍បានយូរ និងដើម្បីមានលទ្ធភាពចូលរួមសវនាការនាថ្ងៃខាងមុខឲ្យមានប្រសិទ្ធភាព ខ្លួនសុំលះបង់សិទ្ធិចូលរួម និងមានវត្តមានដោយផ្ទាល់ក្នុងបន្ទប់សវនាការនៅថ្ងៃទី៣១ ខែសីហា ឆ្នាំ២០១៦។

មេធាវីការពារក្ដីរបស់ខ្លួនបានប្រាប់អំពីផលប៉ះពាល់នៃការលះបង់សិទ្ធិនេះថា ការលះបង់សិទ្ធិនេះមិនអាចបកស្រាយថា ជាការលះបង់សិទ្ធិរបស់ខ្លួនក្នុងការកាត់សេចក្ដីដោយយុត្តិធម៌ ឬក៏សិទ្ធិក្នុងការជំទាស់ទៅនឹងភស្តុតាងក្នុងការដាក់បង្ហាញ ឬដាក់ជូនតុលាការនេះគ្រប់ពេលវេលានៃសវនាការលើរូបខ្លួនឡើយ។

[០៩:០១:៥២]

បានឃើញកំណត់ហេតុពិនិត្យសុខភាពជនជាប់ចោទ នួន ជា ដែលធ្វើឡើងដោយគ្រូពេទ្យប្រចាំការ ពិនិត្យព្យាបាលថែទាំសុខភាពជនជាប់ចោទនៅ អ.វ.ត.ក ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០១៦ បានកត់សម្គាល់ថា ស្ថានភាពសុខភាពរបស់លោក នួន ជា ថ្ងៃនេះមានអាការៈឈឺខ្នង ឈឺចង្កេះ ពិសេសពេលអង្គុយយូរ បានផ្ដល់អនុសាសន៍ថា សូមឲ្យអង្គជំនុំជម្រះអនុញ្ញាតឲ្យលោក នួន ជា ចូលរួមតាមដានកិច្ចដំណើរការសវនាការពីបន្ទប់ខាងក្រោមសាលសវនាការនេះ។

ផ្អែកលើមូលដ្ឋាននេះ និងយោងតាមបទប្បញ្ញត្តិនៃវិធាន៨១(៥) នៃវិធានផ្ទៃក្នុង អ.វ.ត.ក អង្គជំនុំជម្រះយល់ព្រម និងអនុញ្ញាតឲ្យជនជាប់ចោទ នួន ជា ចូលរួម និងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយពីបន្ទប់ឃុំខ្លួនមួយស្ថិតនៅខាងក្រោមសាលសវនាការនេះ តាមរយៈឧបករណ៍សោតទស្សន៍សម្រាប់រយៈពេលសវនាការពេញមួយថ្ងៃនេះ។

បង្គាប់ឲ្យផ្នែកសោតទស្សន៍ ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់ជនជាប់ចោទ នួន ជា អាចចូលរួម និងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយពីបន្ទប់ឃុំខ្លួនមួយ ស្ថិតនៅខាងក្រោមសាលសវនាការនេះ ក្នុងរយៈពេលនៃកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកចៅក្រម ហ្សង់ម៉ាក!

[០៩:០៣:២០]

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

សូមអរគុណលោកប្រធាន។ ខ្ញុំមានសំណួរមួយចំនួនសួរទៅកាន់ដើមបណ្ដឹងរដ្ឋប្បវេណីមុននឹងផ្ដល់វេទិកាជូនទៅសហមេធាវីការពារក្ដី។

**ការតាំងសំណួរដោយចៅក្រម**

**សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

**ស៖** លោកស្រីដើមបណ្ដឹងរដ្ឋប្បវេណី កាលពីម្សិលមិញលោកស្រីបាននិយាយថា លោកស្រីបានជួបជាមួយលោក ខៀវ សំផន ពីរដង។ លោកថា លោកស្រីឃើញគាត់ម្ដងចូលរួមនៅក្នុងសន្និបាតនៅបុរីកីឡា ហើយនិងម្ដងទៀតលោកស្រីជួបគាត់នៅវត្តឧណ្ណាលោម។ ហើយនៅវត្តនោះគឺគាត់ប្រើពេលមួយថ្ងៃពេញ ដើម្បីបង្រៀនយុវជននៅកងចល័ត គឺយុវជនដែលនឹងត្រូវធ្វើការឲ្យក្រសួងពាណិជ្ជកម្ម។ តើខ្ញុំសង្ខេបអ៊ីចឹងត្រឹមត្រូវទេលោកស្រី?

**លោកស្រី ជា ឌៀប៖**

**ឆ៖** ចាស ត្រឹមត្រូវ។

**ស៖** លោកស្រីបានបញ្ជាក់ថា ពេលដែលលោកស្រីជួបគាត់ទាំងពីរលើកហ្នឹងគឺនៅឆ្នាំ១៩៧៥។ លោកស្រីពិតជាចាំច្បាស់ទេថា លោកស្រីបានជួបលោក ខៀវ សំផន ហ្នឹងនៅឆ្នាំ៧៥ហ្នឹង។ ទាំងពីរលើកហ្នឹងគឺនៅក្នុងឆ្នាំ៧៥ហ្នឹង មែនទេ?

[០៩:០៥:០១]

**ឆ៖** ខ្ញុំសូមជម្រាបថា ខ្ញុំជួបពីរលើកហ្នឹង ខ្ញុំក៏មិនដឹងច្បាស់ត្រង់ថា ដឹងខ្ញុំនៅជំនាន់នោះ គ្មានកាឡង់យេអីមើល ដឹងខែដឹងឆ្នាំទេ ដឹងតែឆ្នាំ ប៉ុន្តែខែមិនដឹងខែទេ។ ហើយខ្ញុំតាមខ្ញុំដែលចាំចងចាំបានប្រហែលជាចុង៧៥ ដើម៧៦ ពីរដងហ្នឹង ព្រោះរឿងផ្លូនៗគ្នាដែរ ប៉ុន្តែមិនមែនក្នុង១ខែម្ដង រឿងយូរបន្តិចដែរ។ ហ្នឹងខ្ញុំជម្រាបអ៊ីចឹង។

**ស៖** បាទ សូមអរគុណ។ ឥឡូវនេះខ្ញុំនិយាយពីសន្និបាតនៅវត្តឧណ្ណាលោម។ តើសន្និបាតនេះ គឺសម្រាប់តែអ្នកធ្វើការនៅក្រសួងពាណិជ្ជកម្មទេ ឬក៏មានអ្នកផ្សេងទៀតមកចូលរួមដែរ? តើមានអ្នកណា

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ខ្លះ ដែលចូលរួមក្នុងសន្និបាតនៅវត្តឧណ្ណាលោមហ្នឹង?

**ធៈ** ចូលរួមក្នុងវត្តឧណ្ណាលោមហ្នឹង មានយុទ្ធជននារីខាងពាណិជ្ជកម្មទាំងអស់ ក្នុងទីក្រុងភ្នំពេញអ៊ីចឹង ប៉ុន្តែមិនមែនយកទាំងអស់ទេ ក្នុងមួយកងៗ យកពីរបីនាក់ បួនប្រាំនាក់អីទេ ទៅមកចូលប្រជុំនៅវត្តឧណ្ណាលោមហ្នឹង។ សុទ្ធក្រសួងពាណិជ្ជកម្មទាំងអស់ហ្នឹង អ្នករើជយភណ្ឌហ្នឹង។ ប៉ុណ្ណឹង។

**សៈ** លោកស្រីចាំទេ តើនៅពេលនោះ កុយ ធួន ត្រូវបានចាប់ខ្លួនហើយឬនៅ?

**ធៈ** ខ្ញុំកន្លែងហ្នឹង ខ្ញុំអត់ច្បាស់ដែររឿង កុយ ឃួន ហ្នឹង។ ដឹងតែគេចាប់ ប៉ុន្តែមិនដឹងចាប់ថ្ងៃណា ខែណា ខ្ញុំអត់ដឹងផង។

**សៈ** ឥឡូវខ្ញុំនិយាយអំពីការប្រជុំនៅបុរីកីឡា។ លោកស្រីបានឆ្លើយថា ក្នុងពេលប្រជុំនោះ គេនិយាយអំពីការកាត់ទោស ហ៊ូ នឹម, ហ៊ូ យន់។ លោកស្រីអាចជម្រាបឲ្យបានលម្អិតបន្តិចបានទេ លោកស្រីចង់មានន័យថាម៉េច នៅពេលដែលលោកស្រីនិយាយថា គេកាត់ទោស ហ៊ូ នឹម, ហ៊ូ យន់ នោះ? ម៉េចបានជាលោកស្រីដឹងថា អ្នកដែលគេកាត់ទោសហ្នឹងជា ហ៊ូ នឹម, ហ៊ូ យន់?

[០៩:០៧:២៥]

**ធៈ** ចាស ខ្ញុំសូមជម្រាបថា ថ្ងៃនុ៎ងដែលខ្ញុំទៅហ្នឹង ពេលខ្ញុំទៅដល់កន្លែងបុរីកីឡាហ្នឹង ឃើញថាសម្រាក១ថ្ងៃ។ ស្អែកឡើងអ៊ីចឹងទៅ បានចូលទៅប្រជុំនៅក្នុងមហោស្រពហ្នឹង ហើយដល់ពេលទៅថា គេៗប្រកាសឡើងថា ថ្ងៃនេះជាថ្ងៃដែលត្រូវកាត់ទោស ហ៊ូ នឹម, ហ៊ូ យន់។ ហើយថ្ងៃនុ៎ងគឺមាន អ៊ំ ខៀវ សំផន គាត់បានចូលរួមដែរ។ ហើយដល់ពេលពីហ្នឹងមក ដែលខ្ញុំបានស្ដាប់ហ្នឹង ស្ដាប់ត្រឹមថា នីរសារទេ ហ៊ូ នឹម, ហ៊ូ យន់ អត់ឃើញទេ។ ឃើញនីរសារទៅពីរនាក់ ហើយទៅនីរសារហ្នឹងឡើងនិយាយ និយាយពីទោស ពីកំហុសឯណា ហ៊ូ យន់, ហ៊ូ នឹម ធ្វើបាបគាត់ណា។ នីរសារដល់ទៅពីរថ្ងៃនុ៎ងនោះ នីរសារ ហ៊ូ នឹម មួយ, ហ៊ូ យន់ មួយ។ ដល់នីរសារហ្នឹងនិយាយទៅ ខ្ញុំក៏បានស្ដាប់ត្រឹមនីរសារនិយាយពីប្រវត្តិ ហ៊ូ នឹម, ហ៊ូ យន់ ថាគាត់ម៉េចៗអ៊ីចឹងទៅ ក៏ខ្ញុំគ្រុនទៅ គេយកខ្ញុំមកដេកពេទ្យ ខ្ញុំក៏មិនបានស្ដាប់ទាល់ចប់ដែរ ថ្ងៃនុ៎ងនោះ។ គ្រាន់ថាបានខ្ញុំចូលរួម បានចូលរួមមួយព្រឹកដែរ។

**សៈ** តើលោក ខៀវ សំផន ហ្នឹងគាត់មានតួនាទីអ្វីដែរ នៅពេលនុ៎ង? ហើយមានមេដឹកនាំណាខ្លះទៀតបានចូលរួម? <តើលោកស្រីមានចាំព័ត៌មានលម្អិតអីផ្សេងទៀតទេ?>

**ធៈ** ខ្ញុំអត់មានស្គាល់អ្នកណា គឺស្គាល់តែ អ៊ំខៀវ សំផន មួយតែប៉ុណ្ណឹង។ ខ្ញុំហៅគាត់អ៊ំៗហ្នឹង ស្គាល់តែអ៊ំហ្នឹងមួយហ្នឹង។ ឃើញចូលច្រើនដែរ ប៉ុន្តែមិនដឹងខាងណាខ្លះ ខ្ញុំអត់ស្គាល់ ព្រោះខ្ញុំគ្រុនទៅ ខ្ញុំ

មកវិញមក មិនបានមើលចប់ចុងចប់ដើម។

**ស៖** បើខ្ញុំយល់មិនច្រឡំទេ លោកស្រីថា គេស្តាប់ចម្លើយនីរសាររបស់ ហ៊ូ នឹម, ហ៊ូ យន់។ អ៊ីចឹង <តើខ្ញុំយល់ត្រឹមត្រូវទេ ពីអ្វីដែលខ្ញុំស្តាប់ឮជាភាសាបារាំងនេះ? លោកស្រីបាននិយាយ>ថា ពេលប្រជុំហ្នឹងមិនមែននៅបុរីកីឡាទេ គឺនៅរោងល្ខោន<> លោកស្រីចាំច្បាស់ទេ ពេលនុ៎ង នៅរោងល្ខោន ឬក៏នៅបុរីកីឡា?

[០៩:០៩:៤២]

**ឆ៖** នៅស្តាតបុរីកីឡា នៅនឹងស្តាតហ្នឹងតែម្តង។

**ស៖** ហើយអ្នកដែលចូលរួមនៅក្នុងការស្តាប់សាក្សីដែលជានីរសាររបស់ ហ៊ូ នឹម, ហ៊ូ យន់ហ្នឹង មានប៉ុន្មាននាក់ដែរ?

**ឆ៖** ច្រើនណាស់ ឡើងណែនប៉ុប ប៉ុន្តែមិនដឹងក្រសួងណា។ មានទាំងក្រសួងយោធាឡើងមកហ្នឹង មកច្រើនណាស់ ឡើងណែន។ ប៉ុន្តែមិនដឹងខាងណាខ្លះ ខ្ញុំមិនស្គាល់ដែរ។

**ស៖** ចុះលោក ខៀវ សំផន ពេលនុ៎ង គាត់មានតួនាទីអ្វីដែរឲ្យប្រាកដនោះ?

**ឆ៖** ខ្ញុំដឹងតួនាទីអីគេ ប៉ុន្តែឃើញគាត់នៅអង្គុយនុ៎ង គាត់នៅអង្គុយលើកន្លែងប្រជុំហ្នឹង។ មិនដឹងគាត់ធ្វើនាទីអី ខ្ញុំមិនសូវដឹងដែរ ព្រោះមួយរឹកហ្នឹងខ្ញុំមិនដឹងម៉េច ទីប្រឹក្សាម៉េច ស្អីម៉េចផង។ ដឹងតែចូលទៅឃើញគាត់ហ្នឹង តែប៉ុណ្ណឹង។

**ស៖** គាត់នៅលើវេទិកាហ្នឹងតែម្នាក់ឯងទេ ឬក៏មានអ្នកផ្សេងហ្នឹងនៅជាមួយគាត់ដែរ?

**ឆ៖** ឃើញមានដែរ ប៉ុន្តែខ្ញុំអត់ស្គាល់។ ឃើញមានខ្លះដែរ ប៉ុន្តែខ្ញុំអត់ស្គាល់។

**ស៖** លោក ខៀវ សំផន ហើយនិងអ្នកផ្សេងទៀតហ្នឹងមានបានចោទសំណួរទៅកាន់នីរសាររបស់ ហ៊ូ នឹម, ហ៊ូ យន់ ទេ?

**ឆ៖** ដំបូងគ្រាន់តែបានសួរ សួរដំបូងហ្នឹង ដល់នីរសារនិយាយទៅ គាត់ក៏អត់និយាយទេ ស្តាប់នីរសាររហូតទាំងអស់គ្នាហ្នឹងទៅ។ ត្រឹមហ្នឹងហើយ ដែលថាខ្ញុំចេញមក ខ្ញុំអត់បានដឹងតទៅទៀតទេ ខ្ញុំដឹងតែប៉ុណ្ណឹង។

[០៩:១១:៤១]

**ស៖** ដូច្នេះនៅពេលហ្នឹងគឺប្រកាសថា គេកាត់ទោស ហ៊ូ នឹម, ហ៊ូ យន់។ <តើ>លោកស្រីបាន<>រង់ចាំ<ពេញ>មួយថ្ងៃមុនពេលគេប្រជុំហ្នឹង ហើយ<មុននោះ តើ>គេមានប្រាប់ជាមុនថា នឹងមាន

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ការពិភាក្សាគ្នាពីរឿងអីផ្សេងទៀតទេ? <តើគេបានប្រកាសថានឹង>មានការបង្រៀនវគ្គនយោបាយអ្វីទេ? ឬក៏ពេលនុ៎ងគឺលោកស្រីភ្ញាក់ផ្អើលតែម្តង នៅពេលដែលគេប្រាប់ថា គេកាត់ទោស ហ៊ូ នឹម, ហ៊ូ យន់ ហ្នឹង?

**ឆ៖** ពេលទៅដល់សម្រាកមួយថ្ងៃហ្នឹង អត់មានឮអីនិយាយអីទាំងអស់ គឺសម្រាកតែម្តង ទាល់ស្អែកឡើងបានចូល។ ចូលទៅហ្នឹង ក៏ឮនិយាយអ៊ីចឹង ភ្លាមពេលចូលទៅហ្នឹង។ តែប៉ុណ្ណឹង ខ្ញុំដឹង បើថាពេលសម្រាកហ្នឹង អត់មាននិយាយអីទេ ពីមុនចូលប្រជុំនោះ។ ពេលចូលប្រជុំបានដឹងតែម្តង។

**ស៖** ដូច្នេះមុនពេលលោកស្រីទៅដល់ហ្នឹង លោកស្រីអត់ដឹងថា គេឲ្យលោកស្រីទៅប្រជុំហ្នឹងដើម្បីអ្វីទេ អត់ដឹងថាមូលហេតុអីទេ មែនទេ គឺថាទាល់តែពេលចូលទៅប្រជុំហើយហ្នឹង បាន<គេប្រាប់>ថាគឺមកហ្នឹង ដើម្បីស្តាប់មើលគេកាត់ទោស ហ៊ូ នឹម, ហ៊ូ យន់ ហ្នឹង?

**ឆ៖** ចាស អ៊ីចឹងមែន អត់មានដឹងទេ។ ទាល់តែចូលទៅដល់បានដឹងថា គេកាត់ទោស ហ៊ូ នឹម, ហ៊ូ យន់។

**ស៖** ចុះពេលប្រជុំហ្នឹង លោកស្រីឃើញ ហ៊ូ នឹម, ហ៊ូ យន់ មកបង្ហាញខ្លួននៅចំពោះមុខលោក ខៀវ សំផន នៅចំពោះមុខតុលាការហ្នឹងទេ?

**ឆ៖** ចាស អត់មានឃើញផង ឃើញតែនីរសារហ្នឹង។

[០៩:១៣:៥៥]

**ស៖** លោកស្រីដឹងទេថា ក្រោយមកនោះ តើមានការប្រកាសសាលក្រមទេ ក្រោយពីជំនុំជម្រះចប់ហើយហ្នឹង ពេលកាត់ទោសហើយហ្នឹង គេមានចេញសាលក្រមទេ? គេមានប្រកាសពីទោសកំហុសអីរបស់ ហ៊ូ នឹម, ហ៊ូ យន់ ទេ ក្រោយពីគេស្តាប់ចម្លើយនីរសាររបស់ ហ៊ូ នឹម, ហ៊ូ យន់ ចប់ហើយហ្នឹង? ក្រោយមកហ្នឹង តើលោកស្រីមានឃើញគេប្រកាសអីទេ?

**ឆ៖** ចាស អត់ដែលឮផង។ អត់ដែលមានឮប្រកាសអីផង ត្រឹមហ្នឹងមក បាត់ឈឹងតែម្តង។

**ស៖** ខ្ញុំសួរសំណួរទាំងអស់នេះ ពីព្រោះថាប្រហែលជាបញ្ហាបន្តិចពាក់ព័ន្ធនឹងកាលបរិច្ឆេទ។ លោកស្រីបាននិយាយថា ប្រជុំហ្នឹងកើតឡើងនៅចុងឆ្នាំ៧៥។ <ខ្ញុំជឿថា កិច្ចប្រជុំនោះគឺនៅក្រោមការគ្រប់គ្រងរបស់បក្ស> ក៏ប៉ុន្តែ ហ៊ូ នឹម ត្រូវបានចាប់ខ្លួននៅឆ្នាំ៧៧ឯណោះទេ។ អ៊ីចឹងវាមានបញ្ហាបន្តិចត្រង់ចំណុចហ្នឹង អ៊ីចឹងបានខ្ញុំសួរលោកស្រីហ្នឹង។ ឥឡូវសួរបញ្ជាក់ឲ្យច្បាស់ម្តងទៀតតែម្តង លោកស្រីច្បាស់ទេថា ការប្រជុំហ្នឹងគឺនៅឆ្នាំ១៩៧៥?

01382038



**ឆ៖** ដូចខ្ញុំបានជម្រាបលោកប្រធានថា ខ្ញុំមិនប្រាកដទេ ក្នុង៧៥ ចុងឆ្នាំ៧៥មិនដឹង ដើមឆ្នាំ៧៦ ក៏មិនដឹងដែរ ព្រោះខ្ញុំអត់ដឹងខែអីថ្ងៃអីទេ ជំនាន់នោះ។ ធ្វើការចេះតែធ្វើការទៅ គ្មានដឹងថ្ងៃណា ខែណាទេ ប៉ុន្តែថាខ្ញុំបានទៅប្រជុំ ឮអីចឹងមែន ប៉ុន្តែមិនដឹងជា៧៥ ចុង៧៥មិនដឹង ដើម៧៦មិនដឹង។ ត្រង់ចាប់ខ្លួន ចាប់អី ក៏ខ្ញុំអត់ដែលដឹងដែរ។ ហ្នឹងខ្ញុំសូមជម្រាបលោកប្រធានអ៊ីចឹង។

**សៈ** ឥឡូវនិយាយអំពីទស្សនកិច្ចរបស់ ប៉ុល ពត។ តើពេលដែលគាត់ទៅទស្សនកិច្ចហ្នឹង គឺថាជារឿងចៃដន្យទេ ឬក៏គេប្រាប់លោកស្រីមុនថា<បុគ្គលសំខាន់ម្នាក់នឹងមកទស្សនកិច្ចនៅកន្លែងធ្វើការ>?

[០៩:១៦:០៣]

**ឆ៖** ខ្ញុំអត់ដែលដឹងថា ប៉ុល ពត ទៅទស្សនកិច្ចនៅប្រទេសកូរ៉េផង ទាល់ណា ឃើញស្រាប់តែកុនមកបញ្ចាំងហើយ បានឃើញ។ ទាល់តែគាត់វិលមកវិញ បានឃើញយកកុនមកបញ្ចាំងឲ្យមើល។ ខ្ញុំឃើញតែប៉ុណ្ណឹង។

**សៈ** លោកស្រីបានឃើញ ប៉ុល ពត មកកន្លែងដែលលោកស្រីធ្វើការ អ៊ីចឹងមែនទេ? តាមរយៈចម្លើយលោកស្រីអម្បាញ់មិញ ខ្ញុំដឹងហើយថា លោកស្រីឃើញ ប៉ុល ពត នៅក្នុងខ្សែភាពយន្តថា គាត់ទៅទស្សនកិច្ចនៅកូរ៉េ ប៉ុន្តែខ្ញុំមិនចង់ដឹងរឿងហ្នឹងទេ។ លោកស្រីម្សិលមិញ លោកស្រីថា លោកស្រីបានឃើញ ប៉ុល ពត ដោយផ្ទាល់។ អ៊ីចឹងហើយបានជាខ្ញុំសួរថា មុនពេលលោកស្រីឃើញ ប៉ុល ពត ហ្នឹង គេមានបានប្រាប់លោកស្រីជាមុនទេថា <មានបុគ្គលសំខាន់ម្នាក់>នឹង<>ចុះមកមើលកន្លែងរបស់លោកស្រីធ្វើការហ្នឹង?

**ឆ៖** អត់មានអ្នកណាប្រាប់ផង ឃើញដោយចៃដន្យតែម្តង។ ខ្ញុំកំពុងអង្គុយដេរៗ ឈ្ងោកដេរអ៊ីចឹង ស្រាប់ឃើញគាត់មកឈរពីមុខ។ រួចឈរពីមុខ គាត់សួរ ក៏សួរខ្ញុំតែម្តងទៅ គាត់សួរថា "មិត្តនារីនំប៉័ងមួយថ្ងៃមួយហូបឆ្អែតដែរ មួយកំណាត់មួយពេល?" ខ្ញុំថា "អំអើយ ហូបអត់ឆ្អែតទេ! ជួនកាលសម្លម្ជូរត្រកួន ជួនកាលអត់បន្លែ ចុចនឹងប្រហុកទេ នំប៉័ងនោះ។" គាត់សួរតែប៉ុណ្ណឹង គាត់ក៏មិនថាអីដែរ គាត់ក៏ដើរទៅកងផ្សេងទៅលិចទៅ រួចខ្ញុំក៏ដេរតទៅទៀតទៅ។ ស្រាប់ស្អែកឡើង ស្រាប់នំប៉័ងមួយថ្ងៃពីរ ព្រឹកមួយ ល្ងាចមួយ ឈប់ឲ្យហូបមួយកំណាត់ហើយ តែប៉ុណ្ណឹង។ ខ្ញុំជួបគាត់ គាត់សួរតែប៉ុណ្ណឹង។ គាត់គ្មានអង្គរក្ស គ្មានណាច្រើនទេ ឃើញគាត់មកគ្នាពីរបីនាក់ទេ ប៉ុន្តែស្គាល់តែគាត់ច្បាស់ជាងគេហ្នឹង។ រួចទៅគាត់ចូលទៅសួរហ្នឹង គាត់ឈរពីមុខខ្ញុំតែម្តងហ្នឹង។

[០៩:១៧:៥៨]

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

បាទ សូមអរគុណលោកស្រីដើមបណ្តឹងរដ្ឋប្បវេណី ដែលបានឆ្លើយបញ្ជាក់នូវសំណួររបស់ខ្ញុំ។ លោកប្រធាន ខ្ញុំអស់សំណួរហើយ។

**ប្រធានអង្គជំនុំ៖**

អរគុណលោកចៅក្រម។ សូមអញ្ជើញលោកមេធាវីការពារលោក នួន ជា។ សូមអញ្ជើញ!

**លោកស្រី ដូរីន ជិន៖**

សូមជម្រាបសួរលោកប្រធាន លោក លោកស្រីចៅក្រម សូមជម្រាបសួរភាគី។

**ការតាំងសំណួរដោយសហមេធាវីការពារក្តី**

**សួរដោយលោកស្រី ដូរីន ជិន៖**

**ស៖** សូមជម្រាបសួរលោកស្រីដើមបណ្តឹងរដ្ឋប្បវេណី។ ថ្ងៃនេះខ្ញុំនឹងសួរសំណួរដែលបានពិភាក្សារួចមកហើយកាលពីម្សិលមិញ ប៉ុន្តែខ្ញុំនឹងសួរទៅលើផ្នែកផ្សេងមួយទៀត។ ឥឡូវនេះខ្ញុំនឹងជួយរំឭកដល់អ្វីដែលលោកស្រីបានឆ្លើយកាលពីម្សិលមិញ។ ដោយសារតែពេលវេលាមានកំណត់ ដូច្នេះខ្ញុំនឹងពិភាក្សាអំពីអ្វីដែលទាក់ទងនឹងការរៀបការរបស់លោកស្រី <ក៏ប៉ុន្តែជាបឋមនេះ ខ្ញុំសូមចាប់ផ្តើមពី> បទពិសោធន៍<ផ្សេងទៀតដែល>លោកស្រី<បានរៀបរាប់>។ ដូច្នេះជាដំបូង ខ្ញុំសូមសួរទាក់ទងទៅនឹងការងាររបស់លោកស្រី នៅក្នុងកង<ដឹកជញ្ជូនជយភណ្ឌ>។ កាលពីម្សិលមិញ លោកស្រីបាន<ឆ្លើយទៅនឹងមេធាវីដើមបណ្តឹងរដ្ឋប្បវេណី> នៅម៉ោង <១៣:៤៤> លោកស្រីបាននិយាយថា ក្រុម<ធំ> របស់លោកស្រីទទួលខុសត្រូវដឹកជយភណ្ឌ។ <ថ្ងៃមួយ នៅពេលលោកស្រីប្រមូល>ជយភណ្ឌទាំងអស់នោះ <អ្នកខ្លះបានដឹកគ្រឿងប្រាក់>ចេញពីរាជវាំង ប៉ុន្តែលោកស្រីមិនបានទៅវាំងទេ គ្រាន់តែលោកស្រីរៀបចំក្រោយពេលដែលគេប្រមូលយកមកដល់។ មានការប្រមូលរូបចម្លាក់នៅរោងចក្រផងដែរ។ <មានរូបចម្លាក់ជាច្រើនប្រភេទខុសៗគ្នា។> ហើយរូបចម្លាក់ខ្លះ ត្រូវបានគេយកមកដាក់ទុកនៅឃ្លាំង។ ដូច្នេះខ្ញុំចង់សួរលោកស្រី ទាក់ទងទៅនឹងចំណុចនេះ។ លោកស្រីនិយាយអំពីរូបចម្លាក់អប្សរា <និងគ្រឿងប្រាក់> តើ<លោកស្រីចាំថា>មានជយភណ្ឌអ្វីផ្សេងទៀត ដែលលោកស្រីប្រមូលបានដែរ?

[០៩:២០:០៣]

**លោកស្រី ជា ឌៀប៖**

**ឆ៖** ខ្ញុំសូមជម្រាបថាជយភណ្ឌដែលខ្ញុំប្រមូលមកហ្នឹង គឺមានរូបអប្សរា ប៉ុន្តែរូបហ្នឹង គ្រឿង

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ហ្នឹងសុទ្ធតែប្រាក់ទាំងអស់។ មានរូបអប្សរា មានរូបដូចថាផ្ដែឈើគ្រប់មុខទាំងអស់ ប៉ុន្តែច្រើនរាប់ឡាន មកដាក់ឡើងមួយឃ្លាំងធំ ដាក់ឡើងពេញលើផ្ទះហ្នឹង។ ហើយអប្សរាធំៗប៉ុនៗមនុស្សហ្នឹង ៗឯអប្សរា។ ហើយក្រៅពីប្រមូលជយភណ្ឌហ្នឹងហើយ ក៏ខ្ញុំដើរទៅ ដើរប្រមូលតាមផ្ទះមានខោអាវ មានចានមានឆ្នាំង គឺប្រមូលយកមកដាក់ឃ្លាំង ហើយឡានមកដឹកយកទៅ ថាយកទៅសហករណ៍ ហ្នឹងខ្ញុំដឹងតែប៉ុណ្ណឹង។

**ស៖** តើលោកស្រីចាំទេ ថាគេមានប្រមូលវត្ថុបុរាណដែលជាជយភណ្ឌនោះដែរទេ?

**ឆ៖** វត្ថុបុរាណខ្ញុំដឹងតែនេះហ្នឹង ដឹងតែគ្រឿងមាស ហើយគ្រឿង -- អ៎! គ្រឿងប្រាក់ហ្នឹង អត់ឃើញមានមាស មានប្រាក់ យកមកសុទ្ធតែប្រាក់តែម្ដង ឃើញតែប៉ុណ្ណឹង។

**ស៖** តើលោកស្រីដឹងទេ ថាគេធ្វើអីជាមួយជយភណ្ឌហ្នឹងនៅពេលដែលគេប្រមូលយកមកដាក់ឃ្លាំងរួចហើយ?

**ឆ៖** អត់ដឹងឃើញធ្វើអីដែរ ខ្ញុំដាក់តែឃ្លាំង រៀបតែរួចទៅ បិទឃ្លាំង ខ្ញុំពួកខ្ញុំទៅធ្វើការងារផ្សេងទៀតទៅ មិនដែលដឹងថាគេយកទៅណាមកណាទៀត អត់ដែលដឹងផង។

[០៩:២១:៣៤]

**ស៖** ឥឡូវនេះខ្ញុំបន្តទៅសំណួរទី២ ខ្ញុំនឹងនិយាយអំពីបទពិសោធន៍របស់លោកស្រី ក្រោយពេលលោកស្រីចូលភ្នំពេញភ្លាមៗក្រោយថ្ងៃ១៧ មេសា ៧៥។ ម្សិលមិញនៅម៉ោង១៤:២៩ នៅពេលព្រះរាជអាជ្ញាសួរលោកស្រី លោកស្រីនិយាយថា <ដំបូង>លោកស្រីចូលក្នុងកង<វរសេនាតូច>៤០១ ប៉ុន្តែលោកស្រីមិនដឹងថាតើកងហ្នឹងនៅក្នុង<វរសេនា>ធំលេខប៉ុន្មានទេ ព្រោះ<មានតែមួយ>កង<វរសេនាតូច>ស្ត្រី។ តើលោកស្រីអាចប្រាប់បានទេ ថាតើកងរបស់លោកស្រីហ្នឹងស្ថិតនៅក្នុងកងពលមួយណាដែរ?

**ឆ៖** អត់ដែលដឹងដែរ ដឹងចូលកងពលណាផង បើសុទ្ធតែនារីទាំងអស់។ មានតែមួយវរសេនាតូចហ្នឹង មិនដឹងចូលនៅកងពលណា អត់ដឹងផង ព្រោះខ្ញុំក្មេងខ្ចៅគេដែរ។

**ស៖** តើលោកស្រីចាំឈ្មោះមេបញ្ជាការទេ ឧទាហរណ៍ដូចថាឈ្មោះមេបញ្ជាការកងពលធំ កងពលតូចអីដែរទេ?

**ឆ៖** ខ្ញុំចាំបានកងវរសេនាតូចខ្ញុំហ្នឹង ខ្ញុំស្គាល់។ មាន បងជុំ ប្រធាន, បងសឿ អនុ, បងថាន់ សមាជិក។ ខ្ញុំស្គាល់បានបីនាក់ហ្នឹង គាត់ប្រធានវរសេនាតូចខ្ញុំហ្នឹងតែម្ដង។

**ស៖** ម្សិលមិញនៅម៉ោង<១៣:៤៤> នៅពេលមេធាវីដើមបណ្ដឹងសួរលោកស្រី ៗឆ្លើយថានៅ

ពេលដែលលោកស្រីចូលភ្នំពេញ លោកស្រីស្នាក់នៅខាងជើងវត្តភ្នំ ហើយលោកស្រីស្នាក់នៅក្នុងផ្ទះដែលគេបោះបង់ចោល។ លោកស្រីនិយាយអំពីវត្តភ្នំ តើលោកស្រីដឹងទេថាកងវរសេនាតូចរបស់លោកស្រីហ្នឹងមានបោះទីតាំងនៅវត្តភ្នំទេ?

[០៩:២៣:២២]

**ឆ៖** ពួកខ្ញុំនៅជុំគ្នាទាំងអស់តាមហ្នឹង តាមផ្ទះទាំងអស់គ្នាហ្នឹង។ ដល់ក្រោយមកបានចែកគ្នាទៅនៅខាងជើង ខាងត្បូងវត្ត -- ដែលពេទ្យកាល់ម៉ែត។ ដល់ត្រឹមពេទ្យកាល់ម៉ែតហ្នឹងបានចែកគ្នាត្រឹមហ្នឹង ដកមួយកងធំទៅខាងឃោធា មួយកងធំទៅកំពង់សោម មួយកងធំខ្ញុំចូលពាណិជ្ជកម្មហ្នឹង។ តែប៉ុណ្ណឹង ខ្ញុំដឹង។

**ស៖** អ៊ីចឹងបានន័យថា លោកស្រីហើយនិងសមាជិកកងរបស់លោកស្រី ហើយនិងមេបញ្ជាការទាំងអស់ស្នាក់នៅក្នុងតំបន់ នៅជុំវិញវត្តភ្នំ អ៊ីចឹងមែនទេ?

**ឆ៖** ចាស អ៊ីចឹងមែន។

**ស៖** លោកស្រី ឥឡូវនេះ ខ្ញុំនឹងអានន្ធូវសក្ខីកម្មរបស់សាក្សីដទៃទៀត ដែលបានផ្ដល់សក្ខីកម្មនៅក្នុងសាលសវនាការនេះ ហើយគាត់និយាយអំពីការស្នាក់នៅជុំវិញវត្តភ្នំ។ លោកប្រធាន គឺប្រតិចារឹកឯកសារ E1/320.1 គឺជាប្រតិចារឹកមកពីថ្ងៃ២៣ មិថុនា ២០១៥ ហើយឈ្មោះសាក្សីគឺ សែម <ហឿន>។ លោកស្រីដើមបណ្ដឹងរដ្ឋប្បវេណីនៅម៉ោង០៩:៥២ នៅថ្ងៃ២៣ មិថុនា ឆ្នាំ២០១៥គឺ <សែម> ហឿន បាននិយាយអំពីកងពល៣១០ដែលមានមន្ទីរនៅវត្តភ្នំ។ គាត់បាននិយាយអំពីមន្ទីររបស់គាត់នៅវត្តភ្នំ ដែលជារបស់កងពល៣១០។ តើវាធ្វើឲ្យលោកស្រីនឹកឃើញដែរទេ អំពីឈ្មោះកងពលធំដែលកងវរសេនាតូចរបស់លោកស្រីស្ថិតនៅក្រោមហ្នឹង តើធ្វើឲ្យលោកស្រីនឹកឃើញឈ្មោះដែរទេ?

**ឆ៖** ខ្ញុំអត់នឹកឃើញផង។ ខ្ញុំអត់ដឹងផង មិនដែលដឹង មិនដែលឮសោះ។

[០៩:២៥:៣១]

**ស៖** ឥឡូវនេះខ្ញុំសួរលោកស្រីម្យ៉ាងវិញទៀត លោកប្រធាន គឺថាប្រតិចារឹក E1/317.1 គឺប្រតិចារឹកថ្ងៃទី<១៧> មិថុនា ២០១៥ គឺសាក្សីដដែលនេះ គឺសាក្សី សែម ហឿន។ លោកស្រីដើមបណ្ដឹងនៅម៉ោង១៥:៤៨ គឺគាត់បាននិយាយ<ថា "អឿន ជា>មេបញ្ជាការរបស់កងពល។" លោកស្រីគ្រាន់តែបញ្ជាក់ថា ចាំឈ្មោះមេបញ្ជាការ<ជុំ និង ចាន់> ប៉ុន្តែ<>តើឈ្មោះ អឿន ធ្វើឲ្យលោកស្រីនឹកឃើញអ្វីដែរឬទេ?

**ឆ៖** អត់នឹកឃើញផង។

**ស៖** មិនអីទេលោកស្រី។ ឥឡូវនេះ ខ្ញុំនឹងសួរអំពីតួនាទីរបស់លោកស្រីនៅក្នុងកង<ទ័ព>។ បន្ថែមពីការងារជយភណ្ឌ លោកស្រីក៏បញ្ជាក់ថា លោកស្រីមានតួនាទីមួយទៀតផងដែរ គឺខ្ញុំសូមដកស្រង់អ្វីដែលលោកស្រីបាននិយាយ គឺលោកស្រីឆ្លើយនៅម៉ោង១៣:៤៣ លោកស្រីបាននិយាយថា លោកស្រីនៅ<តំបន់ក្រៅក្រុង។ លោកស្រីបាន>ដឹកជញ្ជូនគ្រាប់ <ជញ្ជូនសាកសពទាហាន និងទាហានត្រូវរបួស ប៉ុន្តែលោកស្រីក៏ចូលរួមក្នុងចម្បាំងជាមួយយុទ្ធជនផ្សេងទៀតដែរ>។ ហើយក្រោយបន្តិចមកមុនពេលដែលលោកព្រះរាជអាជ្ញាសួរនៅម៉ោង<១៤:២៦ នាទី> លោកស្រីបាន<និយាយថា នៅពេលលោកស្រី>ចូល<បដិវត្តន៍ លោកស្រី>នៅក្នុងកងយុទ្ធជននារី។ ហើយលោកស្រីស្ថិតនៅក្នុងកងស្នែងដឹកជញ្ជូនអាវុធ ក៏ដូចជាដឹកជញ្ជូនអ្នករបួស និងអ្នកស្លាប់ត្រឡប់មកសមរភូមិក្រោយវិញ។ នៅពេលដែលលោកស្រីនិយាយថា ដឹកជញ្ជូនអាវុធគ្រាប់រំសេវ ដឹកជញ្ជូនអ្នករបួស អ្នកស្លាប់នោះ តើលោកស្រីមានដឹកជញ្ជូនអ្វីផ្សេងទៀតទេ? តើមានដឹកជញ្ជូនអាវុធ ឬក៏អ្វីបន្ថែមទៀតទេ?

[០៩:២៧:២៨]

**ឆ៖** ខ្ញុំសូមជម្រាបថា នៅតាមសមរភូមិ ខ្ញុំបានដឹកជញ្ជូនគ្រាប់ទៅមុខ ហើយនិងក្រោយ ពេលមកក្រោយជញ្ជូនអ្នករបួស អ្នកពលីមកក្រោយវិញ។ ត្រង់អាវុធ ចំណែកជាកាំភ្លើងអី ខ្ញុំមិនដែលបានជញ្ជូនទេ ដែលបានជញ្ជូនតែគ្រាប់យកទៅមុខ។ មកក្រោយវិញ អត់មានជញ្ជូនអីផ្សេងក្រៅពីគ្រាប់ ហើយនិងអ្នករបួស អ្នកពលីទេ។ ជម្រាបប៉ុណ្ណឹង។

**ស៖** ឥឡូវនេះ លោកស្រីនិយាយអំពីសមរភូមិ ហើយនិងសមរភូមិមុខ។ ចង់ឲ្យលោកស្រីបញ្ជាក់លម្អិតបន្តិចទាក់ទងទៅនឹងការដឹកជញ្ជូនគ្រាប់រំសេវ។ តើលោកស្រីដឹកជញ្ជូនគ្រាប់រំសេវពីទីណាទៅទីណាដែរ? តើលោកស្រីអាចបញ្ជាក់អំពីទីតាំងបានទេ?

**ឆ៖** ខ្ញុំសូមជម្រាបថា នៅដឹកជញ្ជូនហ្នឹង គឺដឹកពីខាងក្រោយ គឺកន្លែងខាងជើងម្តុំខាងជើងវត្តភ្នំប្រសិទ្ធិ៍មកមុខ។ គ្មានដឹកកន្លែងណា មានម្តុំ ប៉ុន្តែមិនដឹងភូមិអី ឃុំអី អត់ដឹងទេ គឺនៅតែក្នុងព្រៃតាមវាលស្រែហ្នឹង នៅក្រោមដើមឫស្សីដើមអីហ្នឹង។ មានដែលដឹងថាភូមិហ្នឹងអី ស្រុកហ្នឹងស្រុកអី ក៏អត់ដែលដឹងដែរ។

**ស៖** តើលោកស្រីអាចប៉ាន់ប្រមាណមើល ថាតើការដឹកជញ្ជូនគ្រាប់ពីកន្លែងរបស់លោកស្រីទៅសមរភូមិមុខនុ៎ង វាចំណាយពេល<>ប៉ុន្មាន<>ដែរ?

[០៩:២៩:០២]

**ឆ៖** ពេលដឹកជញ្ជូនហ្នឹង មិនជាយូរទេ ពេលជញ្ជូនទៅហ្នឹង ល្ងាចឡើងចាប់ជញ្ជូន យប់ចូល។ ចូលទៅដាក់កន្លែងស្នាក់ការគេ មានស្នាក់ការគេមួយអត់ដល់សមរភូមិមុខទេ នៅត្រឹមខាងក្រោយអ្នកវ៉ៃ អ្នកត្រៀមទេ។ ទៅជញ្ជូនដាក់កន្លែងហ្នឹង គេចមកវិញមក ផ្នែកនារីៗគេចមកវិញ តែជញ្ជូនដល់កន្លែងគឺគេចមកក្រោយវិញហើយ។ មិនយូរថ្ងៃ មិនយូរខែអីទេ គឺតែមួយល្ងាច ពេលម៉ោងពីរដណ្តប់យប់អឹមកដល់វិញហើយ តែល្ងាចព្រលប់ៗជញ្ជូនទៅ ម៉ោងវាពីរដណ្តប់យប់អឹមកដល់កន្លែងវិញហើយ អត់មាននៅសំកុកនៅនុ៎ងទេ។

**ស៖** តើលោកស្រីចាំទេ លោកស្រីដឹកជញ្ជូនគ្រាប់ប្រភេទអ្វីដែរ?

**ឆ៖** គ្រាប់ដែលដឹកជញ្ជូនទៅមានអាបេ មានអាហាស់ មានគ្រាប់កាំភ្លើងតូចៗហ្នឹងវីតាមីន អ៎ ដែលអាគ្រាប់តូចៗ មីតាយើ, ៤១, ៤២អីហ្នឹង ជញ្ជូនគ្រាប់អស់ហ្នឹង ហើយគ្រាប់អា៦០, គ្រាប់អា៨០អីហ្នឹង ជញ្ជូនទៅដាក់ខាងមុខ ដាក់នៅស្នាក់ការគេខាងមុខណោះ។ តែដាក់រួចនាំ គ្នាមកកន្លែងវិញអស់ហើយ។

**ស៖** តើលោកស្រីចាំទេថា តើមន្ទីរហ្នឹងនៅទីតាំងកន្លែងណាដែរ?

**ឆ៖** ខ្ញុំដឹងថាកន្លែងហ្នឹងនៅខាងជើង គេហៅត្រពាំងកក់ ត្រពាំងព្រាយនៅខាងជើងភ្នំប្រសិទ្ធិនេះ ខាងត្បូងភ្នំអង្គរស្ស តែមិនដឹងថាគេហៅភូមិអី អត់ដឹងផង ព្រោះនៅសុទ្ធតែក្នុងព្រៃដឹកជញ្ជូនទៅដាក់ក្នុងព្រៃទេ អត់មានភូមិឃុំគេទេ។

**ស៖** សំណួរចុងក្រោយសម្រាប់ប្រធានបទនេះ គឺថា តើលោកស្រីធ្លាប់ដឹកគ្រាប់រំសេវឆ្ងាយទេ ឧទាហរណ៍ថាឆ្លងខេត្ត ឆ្លងស្រុកអីទេ? តើឧទាហរណ៍ថា លោកស្រីធ្លាប់ជញ្ជូនគ្រាប់រំសេវហ្នឹងទៅដល់ខេត្តកំពង់ចាម ឬក៏អីដែរទេ?

[០៩:៣១:២៣]

**ឆ៖** ខ្ញុំអត់ដែលផង វ៉ៃកន្លែងណាជញ្ជូនកន្លែងនុ៎ង អត់ដែលទៅជញ្ជូនឆ្ងាយៗ ដឹកឡានដឹកអីទេ ដឹកតែនឹងស្មាហ្នឹង។ ម្ល៉ោះហើយលីទៅតែនឹងស្មាហ្នឹង បន្តិចៗម្នាក់ទៅ តាមអ្នកណាយករួច យកប៉ុណ្ណឹងទៅ។ តែប៉ុណ្ណឹងទេ។

**ស៖** ឥឡូវនេះខ្ញុំនឹងបន្តទៅប្រធានបទមួយទៀត ហើយខ្ញុំសួរអំពីបទពិសោធន៍របស់លោកស្រីក្នុងការប្រជុំក្នុងកង<វរសេនាតូច>របស់លោកស្រី។ កាលពីម្សិលមិញជាមួយមេធាវីដើមបណ្តឹងនៅ

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ម៉ោង១៣:៤៤ លោកនិយាយថា នៅពេលដែលលោកស្រីចូលមកភ្នំពេញ <លោកស្រីស្នាក់នៅខាងជើង>វត្តភ្នំ។ លោកស្រីស្នាក់នៅផ្ទះដែលគេបោះបង់ចោល ហើយបន្ទាប់មកទៀតលោកស្រីប្ដូរទៅកាល់ម៉ែត។ ក្នុងពេលដែលលោកស្រីស្នាក់នៅ វត្តភ្នំ ហើយក្រោយមកទៅកាល់ម៉ែត តើលោកស្រីធ្លាប់ចូលរួមក្នុងការប្រជុំរបស់កងវរៈរបស់លោកស្រីដែរឬទេ?

**ឆ៖** អត់ដែលមានអីប្រជុំផង។ តាំងពីទៅហ្នឹង ក៏មិនដែលមានប្រជុំអី គ្រាន់តែប្រជុំផ្លាស់កន្លែងផ្លាស់កន្លែងអីចឹង ប្រជុំអីទៀតអត់មាន។ ទាល់តែថ្ងៃបំបែក ថាដកចេញពី ដកមួយវរសេនាតូចហ្នឹងចែកជាបីកន្លែងហ្នឹង បានខ្ញុំដឹងថ្ងៃនុំង ដកចែកគ្នាមកកន្លែងរៀងខ្លួនទាំងអស់តែម្ដង អត់មានប្រជុំអីធំដុំ អត់មានទេ។

**ស៖** អីចឹងបានន័យថា លោកស្រីចូលរួមក្នុងការប្រជុំដែលគេពិភាក្សាអំពីការផ្លាស់ប្ដូរទីកន្លែងអីចឹងមែនទេ?

[០៩:៣៣:១០]

**ឆ៖** ចាស គ្រាន់ប្រជុំតែប៉ុណ្ណឹង ប្រជុំទាំងអស់គ្នាហ្នឹង ប្រជុំទាំងមួយវរសេនាតូចហ្នឹង ប្រាប់ថាថ្ងៃស្អែកអីចឹងត្រូវៗដកចេញ ផ្លាស់ ចែកកម្លាំងគ្នា។ ទៅឃោធាមួយកងធំ ទៅកំពង់សោមមួយកងធំមកពាណិជ្ជកម្មមួយកងធំ តែប៉ុណ្ណឹង។ ស្អែកឡើងគេចែកបែកគ្នាអស់ទៅ សូម្បីតែមួយកងធំខ្ញុំហ្នឹងក៏មិនមកជុំគ្នាដែរ ខ្លះនៅផ្សារអូរឫស្សីទៅ ខ្លះផ្សារដើមគទៅ ខ្លះផ្សារទួលទំពូង ខ្លះផ្សារកម្ពុជាក្រោមអីចឹងគ្រប់ពេញមួយនេះហ្នឹង។ ដាក់តែមួយកន្លែងតែមួយក្រុម មួយកន្លែងមួយក្រុមទេ នៅក្នុងទីក្រុងភ្នំពេញចែកគ្នាទាំងអស់ បំបែកគ្នាទាំងអស់ហ្នឹងមួយកងធំខ្ញុំហ្នឹង ប៉ុណ្ណឹង។

**ស៖** តើលោកស្រីចាំទេថា គេមានពិភាក្សាប្រធានបទអីផ្សេងទៀតដែរនៅក្នុងកិច្ចប្រជុំនោះ?

**ឆ៖** អត់មានអីផង គ្រាន់តែថ្ងៃប្រជុំហ្នឹង គ្រាន់ប្រជុំថាចែកកម្លាំងគ្នាតែប៉ុណ្ណឹង អត់មាននិយាយអីទៀតផង។

**ស៖** ឥឡូវនេះខ្ញុំបន្តទៅប្រធានបទមួយទៀត ហើយខ្ញុំនឹងពិភាក្សាអំពីបទពិសោធន៍ដែលលោកស្រីនិយាយកាលពីម្សិលមិញ ដែលថាត្រូវគេសួរចម្លើយ។ នៅម៉ោង១៥:៤៨នៅពេលដែលព្រះរាជអាជ្ញាសួរ គឺគេសួរថាតើលោកស្រីមាន<ជាប់>ខ្សែ លន់ នល់ ឬក៏ខ្សែ កុយ ធួន ហៅ ធុច ទេ? លោកស្រីនិយាយថាលោកស្រីអត់ដឹងទេ។ គឺថាគ្រាន់តែគេថាលោកស្រីមានខ្សែមេដឹកនាំ។ <វាមិនមែនមានតែលោកស្រីម្នាក់ឯងទេ។ អ្នកទាំងអស់ដែលគេដឹកតាមឡាននោះទៅ> ត្រូវគេចោទថាមានទំនាក់ទំនង ឬ

---

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ក៏មានខ្សែ។ <ខ្ញុំចាប់អារម្មណ៍នឹងអ្វីដែល>លោកស្រីនិយាយថា គេចោទថាលោកស្រីមាន<ជាប់>ខ្សែមេដឹកនាំ។ តើអ្នកសួរចម្លើយលោកស្រី គេមានបញ្ជាក់លម្អិតទេ <អំពីអ្វីដែល>គេចោទប្រកាន់<លោកស្រីនោះ>?

[០៩:៣៥:១៧]

**ឆ៖** ខ្ញុំអត់ដឹងផង អត់ដឹងថាមានខ្សែមានអីដឹកនាំអី ខ្ញុំអត់មានដឹងទេ។

**ស៖** ឥឡូវនេះ<ឆ្លើយនឹងសំណួរ>ថា <តើមានអ្វីកើតឡើង>ក្រោយពេលដែលសួរចម្លើយ។ លោកស្រីប្រាប់ព្រះរាជអាជ្ញា គឺប្រហែលម៉ោង<១៥:៤៥ នាទី ម្សិលមិញ>ថា លោកស្រីស្នាក់នៅកន្លែងនោះមួយរយៈ ហើយបន្ទាប់មកលោកស្រីទៅវត្តស្លែង ហើយនៅទីនោះ គេឲ្យលោកស្រីជីកប្រឡាយ លើកទំនប់។ តើគេមានប្រាប់ទេ ហេតុអីបានជាគេបញ្ជូនលោកស្រីទៅវត្តស្លែង ក្រោយពេលគេសួរចម្លើយលោកស្រីហើយនោះ?

**ឆ៖** ពេលសួរចម្លើយហ្នឹង គេបញ្ជូនខ្ញុំទៅ ខ្ញុំថាទៅស្ទឹងកន្ទួត គេសួរថា ដែលមកពី គេដកពីក្រសួង តើមានរឿងអី ទោសអី? ហើយខ្ញុំ ពួកខ្ញុំឆ្លើយទាំងអស់គ្នា គ្នា១២ឡានណោះ ឆ្លើយទាំងអស់គ្នាថា ខ្ញុំអត់ដឹងដែរ គេដកមកអត់ដឹងផង។ រួចដល់ទៅ គេអ្នកដឹក -- គេអ្នកធ្វើការកន្លែងនុ៎ង គេថាឥទ្ធពលពីអ្នកដឹកនាំ។ រួចអ្នកដឹកនាំ មិនដឹងអ្នកដឹកនាំណា បើអ្នកដឹកនាំពេញតែប្រទេស ដឹងអ្នកដឹកនាំណា។ រួចបើខ្ញុំមានតែស្គាល់អ្នកដឹកនាំណា។ ខ្ញុំស្គាល់តែប្រធានក្រុម ប្រធានកងខ្ញុំហ្នឹង អស់ហើយ។ អ្នកដឹកនាំធំៗមានស្គាល់ផង។

**ស៖** ឥឡូវនេះខ្ញុំនឹងបន្តបន្តិចទៀត នៅម៉ោង១៥:៤៨ លោកស្រីឆ្លើយថា "អ្នកទាំងអស់ដែលគេបញ្ជូនទៅទីនោះ គឺត្រូវបានចោទប្រកាន់ថាមានខ្សែ ឬក៏មានទំនាក់ទំនង។" អ្វីដែលខ្ញុំចង់សួរ ថាតើអ្នកដែលគេបញ្ជូន<ពី>វត្តស្លែង ទៅស្ទឹងកន្ទួតហ្នឹង តើពួកគេទាំងអស់ត្រូវបានគេចោទប្រកាន់គ្រប់គ្នាថាមានខ្សែ ឬក៏មានជាប់ទាក់ទងអ៊ីចឹងដែរឬទេ?

**ឆ៖** គេអត់ថាអ៊ីចឹងផង គេគ្រាន់ថាជាប់ឥទ្ធិពលអ្នកដឹកនាំ គេដាក់ខ្លួនគេអ៊ីចឹង។ ពួកខ្ញុំថាអត់ដឹង ពេលបញ្ជូនទៅហ្នឹង ពួកខ្ញុំឆ្លើយថាអត់ដឹងទាំងអស់គ្នា។ ហើយទៅគេដាក់ថាជាប់ឥទ្ធិពលអ្នកដឹកនាំ ហើយដឹងអ្នកដឹកនាំមួយណា ព្រោះខ្ញុំអត់ដឹងដែរ។ ចាស តែប៉ុណ្ណឹង។

[០៩:៣៧:៤៦]

**ស៖** អ៊ីចឹងបានន័យថា គេមិនបញ្ជាក់ថាអ្នកដឹកនាំហ្នឹងឈ្មោះអីទេ គេចោទថាទូទៅថាអ្នក

ដឹកនាំអ៊ីចឹងមែនទេ?

**ឆ៖** ចាស គេគ្រាន់តែថាជាប់ឥទ្ធិពលពីអ្នកដឹកនាំ គេអត់មានថា មានឈ្មោះមួយណាផង។ គេឆ្លើយមកតែប៉ុណ្ណឹង។

**ស៖** ឥឡូវនេះខ្ញុំបន្តទៅប្រធានបទថ្មីមួយទៀត និយាយអំពីការរៀបការ។ ម្សិលមិញលោកស្រីបាននិយាយអំពីឈ្មោះ ផាន់ៗ គឺលោកស្រីបានឆ្លើយថា អ្នកដែលរៀបចំអាពាហ៍ពិពាហ៍របស់លោកស្រី គឺ ផាន់ -- ផន។ ដូច្នេះខ្ញុំចង់សួរថាតើ ផន ហ្នឹង -- ផាន់ ហ្នឹងគឺជាមេផ្ទាល់របស់លោកស្រី ឬក៏ជាមេកងរបស់លោកស្រីមែនទេ?

**ឆ៖** ឈ្មោះ ផាន់ ហ្នឹងមេកងប្រុសទេ ពូផាន់ ហ្នឹង។ គាត់ប្រធានកងទាំងយុទ្ធជន ទាំងនារីមួយកន្លែងមុខព្រួញជញ្ជូនជយភណ្ឌហ្នឹង គឺឈ្មោះ ផាន់។ ហើយដល់ដឹកនាំទៅឲ្យរៀបការ គឺគាត់ហ្នឹងអ្នកសួរខ្ញុំ គាត់អ្នកសួរខ្ញុំផ្ទាល់តែម្តង។

**ស៖** ហើយលោកស្រីឆ្លើយថា គាត់ជាមេផ្ទាល់ បានន័យថា គាត់គឺជាអ្នកដែលលោកស្រីត្រូវរាយការណ៍រាល់ថ្ងៃ ហើយជាអ្នកបញ្ជាផ្ទាល់មកលោកស្រី អ៊ីចឹងមែនទេ?

[០៩:៣៩:២៤]

**ឆ៖** ចាស ខ្ញុំៗនៅក្នុងក្រុមគេ បើមានក្រុមប្រជុំអ៊ីចឹងទៅ ប្រជុំទៅ ដល់ទៅប្រធានៗគេ គេប្រជុំៗប្រធានទៅ។ រួចខ្ញុំអត់ដែលដឹងថាគេប្រជុំអី ខ្ញុំមិនដែលដឹងទេ។ ប៉ុន្តែបើធ្លាប់ដឹងមក បើប្រជុំទាំងអស់គ្នា គ្រាន់តែប្រជុំថាឲ្យ ដូចថាធ្វើការអីខុសៗអីត្រូវអ៊ីចឹង គេគ្រាន់តែណែនាំតែប៉ុណ្ណឹងទៅ គេអត់នៅប្រជុំអីខុសឆ្គងអីខ្លាំង ហើយក៏មិនអ៊ីចឹងទេ កសាងគ្នាតែប៉ុណ្ណឹងទេ។ បើអ្នកណាខុស អ្នកណាត្រូវ អ្នកខុសហ្នឹង អ្នកត្រូវហ្នឹងគេកសាងទៅ។ គ្រាន់តែប៉ុណ្ណឹង ខ្ញុំអត់ដែលមានអីប្រជុំធំដុំផង។

**ស៖** ហើយការចាត់តាំងការងារប្រចាំថ្ងៃហ្នឹងគឺ ផាន់ ជាអ្នកបញ្ជាឲ្យលោកស្រីធ្វើការមែនទេ?

**ឆ៖** ចាស ទូទៅតែ ផាន់ ហ្នឹងគេថា ឥឡូវឲ្យទៅរើកន្លែងណា ទៅកន្លែងនុ៎ងទៅ តែប៉ុណ្ណឹង។

**ស៖** ម្សិលមិញយើងបាននិយាយច្រើនអំពីការដែលលោកស្រីបដិសេធមិនរៀបការ<ជាច្រើនដង>។ ឥឡូវនេះ ខ្ញុំចង់សួរបន្ថែមទៀតអំពីចំណុចនេះ។ នៅម៉ោង១៥:២២ នៅពេលដែលលោកស្រីឆ្លើយជាមួយព្រះរាជអាជ្ញាគឺថា នៅពេលលោកស្រីបដិសេធដំបូង គឺលោកស្រីប្រាប់<ប្រធានកន្លែងដែលលោកស្រីរស់នៅ។ ប៉ុន្មានថ្ងៃ>មកទៀត គេ<បាន>សួរ<>លោកស្រី<ម្តងទៀត>។ ហើយប្រហែលជាបីបួនថ្ងៃក្រោយមកទៀត គេសួរលោកស្រីបន្ថែម។ ហើយក្រោយមកទៀត គេសួរលោកស្រីបន្ថែម

ទៀត។ ហើយមេភូមិបញ្ជូនលោកស្រីទៅជួបអ៊ំមួយនៅក្នុងមន្ទីរ។ ហើយនៅម៉ោង<១៥:២៦> លោកស្រីឆ្លើយថា បន្ទាប់ពីបដិសេធច្រើនដង <លោកស្រីគិត>ថា <ដោយសារមិនមាននរណាហ៊ានបដិសេធទេ។ លោកស្រីមិនហ៊ាន ព្រោះ>លោកស្រីខ្លាចថាគេចោទប្រកាន់លោកស្រីថាមានបញ្ហាអីមួយ។ ដំបូងបំផុតគេចោទថា លោកស្រីមានគូដណ្តឹង ហើយម្តងទៀតគេចោទថា លោកស្រីមានសង្សារនៅក្នុងក្រសួងមួយ។ ហើយលោកស្រីគិតថា ដោយសារតែអង្គការមានភ្នែកម្នាស់ គេអាចដឹងអំពីបញ្ហានេះ។ ជាដំបូងខ្ញុំចង់សួរថា អ្វីដែលខ្ញុំយល់ គឺខ្ញុំយល់បានត្រឹមត្រូវឬក៏អត់? ថាតើជាការត្រឹមត្រូវទេ ដែលថានៅពេលដែលលោកស្រីបដិសេធមិនរៀបការលើកទី១ គេចោទនៅពេលនោះថា លោកស្រីមានគូដណ្តឹង តើអ៊ីចឹងមែនទេ?

[០៩:៤១:៥៣]

**ឆះ** ចាស មែន។ លើកទី១ គាត់ហៅខ្ញុំទៅសួរ ថ្ងៃហ្នឹងខ្ញុំទៅធ្វើការ ទៅគាត់ប្រើនីរសារឲ្យទៅហៅខ្ញុំមក។ មកគាត់សួរខ្ញុំម្តងថា មិត្តអ្នា! មុននឹងសួរហ្នឹង គាត់សុទ្ធតែលើកទឹកចិត្តសិន សុទ្ធថា មិត្តធ្វើការល្អឯណា ឲ្យអង្គការបានល្អ ស្អីៗ គ្មានអីសងគុណមិត្តទេ មានតែឲ្យមិត្តរៀបគ្រួសារ។ ហ្នឹងគាត់លើកនិយាយអ៊ីចឹងមុនដំបូង។ ដល់និយាយរឿងរៀបគ្រួសារ ខ្ញុំថា ពូអើយ ខ្ញុំអត់ទាន់យកទេ ព្រោះខ្ញុំនៅក្មេងណាស់ ចាំឲ្យរៀបចាស់ៗមុនទៅ ទុកខ្ញុំនៅក្រោយទៅ។ ដល់គាត់និយាយលើកចុះឡើង ចុះឡើងថាខ្ញុំហ្នឹងមានគូដណ្តឹងនៅឯផ្ទះ។ ខ្ញុំថាអត់មានទេ ៣ឆ្នាំមកហើយដែលខ្ញុំមក បើមានគូដណ្តឹង ខ្ញុំមិនទៅរកគូដណ្តឹងខ្ញុំ។ បើខ្ញុំមិនដែលស្គាល់ផ្ទះម៉េច ស្គាល់ម៉េចឪម៉ែចផង តាំងពីខ្ញុំចេញមក៣ឆ្នាំហ្នឹង ពីរបីឆ្នាំហ្នឹង។ ដល់ពេលលើកទី២ គាត់សួរទៀត ខ្ញុំមិនព្រមទៀត។ គាត់ថា ខ្ញុំហ្នឹងមានសង្សារនៅនឹងកន្លែងក្រសួង។ ខ្ញុំថាបើពូឯងមិនជឿទេ តាមដានខ្ញុំមើលទៅ បើខ្ញុំមានសង្សារមែន ហ្នឹងលើកទី២។ ដល់លើកទី៣ គាត់ថា គាត់ឈប់សួរហើយ។ ឥឡូវមិត្តឯងទៅមន្ទីរទៅ ៗជួបអ៊ំទៅ។ ក៏ពីរបីថ្ងៃក្រោយមក គាត់ប្រាប់ខ្ញុំឲ្យមកជួបអ៊ំ ខ្ញុំក៏មកមែន ខ្ញុំមកផ្សារអូរឫស្សី។ មកដល់អត់ជួប អ៊ំគុណ ប្រធានហ្នឹង ខ្ញុំជួប អ៊ំមុញ និង បងឈុំ គាត់អនុ សមាជិកនៅកន្លែងហ្នឹងដែរ។ ដល់ទៅគាត់ពីរនាក់ហ្នឹង គាត់និយាយ។ ថ្ងៃនុ៎ងក៏មិនមែនតែខ្ញុំមួយដែរ គឺអ្នករៀបគ្រួសារមកហ្នឹងប៉ុន្មានគូដែរទេ តែខ្ញុំមិនសូវស្គាល់គេដែរ ព្រោះសួរនៅកន្លែងហ្នឹងទាំងគ្នាហ្នឹង។ រួចដល់សួរទៅ ខ្ញុំក៏ថា ខ្ញុំឈប់ប្រកែក បើប្រកែកក៏មិនដឹងប្រកែកម៉េចទៀតដែរ ពីរបីដងហើយ។ ខ្ញុំរាងខ្លាចខ្លួនដែរ ដល់តែបីដងហើយ។ គេរាល់គ្នា គេមិនប្រកែក ៗអីតែខ្ញុំ។ ខ្ញុំក៏បណ្តោយ ខ្ញុំថាធ្វើម៉េចក៏ធ្វើទៅ តែប៉ុណ្ណឹង។

[០៩:៤៣:៤៥]

**ស៖** ខ្ញុំនឹងនិយាយទៀត។ ឥឡូវនេះចង់សួរបន្តិចបែបនេះវិញ អ៊ីចឹងបានន័យថា មេរបស់លោកស្រី ចោទថាលោកស្រីមានគូដណ្តឹង បន្ទាប់មកទៀតថាមានសង្សារ ហើយលោកស្រីប្រាប់ថាឲ្យតាមដានទៅ តើអ៊ីចឹងមែនទេ?

**ឆ៖** ចាស អ៊ីចឹងមែន។ ខ្ញុំថា អង្គការភ្នែកម្នាស់តើ បើសិនខ្ញុំមានសង្សារ ពូតាមដានមើលទៅ។ បើឃើញខ្ញុំមាន ធ្វើម៉េចក៏ធ្វើទៅ។ ខ្ញុំនិយាយជាមួយគាត់តែប៉ុណ្ណឹង។ គាត់ក៏ឈប់និយាយ មកក្រោយទៀតគាត់លែងនិយាយជាមួយខ្ញុំទៀត។ គាត់ប្រគល់ឲ្យមកមន្ទីរម្តង។

**ស៖** អ៊ីចឹង ថាតើមេរបស់លោកស្រីគាត់ឆ្លើយថាម៉េចដែរ នៅពេលលោកស្រីប្រាប់ថាឲ្យតាមដានទៅនោះ?

**ឆ៖** ដល់ខ្ញុំប្រាប់ថាឲ្យតាមដាន គាត់លែងនិយាយ គាត់អត់មាននិយាយថាម៉េចទេ ថាម៉េចក៏គាត់មិននិយាយដែរ ព្រោះខ្ញុំប្រាប់ថាឲ្យតាមដានមើលទៅ បើឃើញខ្ញុំខុសសីលធម៌មែន ធ្វើម៉េចខ្ញុំធ្វើទៅ។ ខ្ញុំនិយាយតែប៉ុណ្ណឹង គាត់ក៏ចប់ត្រឹមហ្នឹង គាត់ក៏គ្មាននិយាយអីដែរ គាត់ឈប់និយាយតែម្តង។

[០៩:៤៥:០៣]

**ស៖** ឥឡូវនេះ យើងនិយាយអំពីការប្រជុំជាមួយនឹងអ៊ំទាំងពីរ ទាំងបីនាក់នោះ។ កាលពីម្សិលមិញ លោកស្រីនៅម៉ោង១៥:១៥នាទី លោកស្រីបាននិយាយអំពីការប្រជុំជាមួយអ៊ំទាំងពីរគឺ ម៉ុញ ហើយនិងឈុំ។ លោកស្រីបានឆ្លើយប្រាប់ព្រះរាជអាជ្ញាដូចតទៅ នៅពេលដែលលោកស្រីមកដល់ អ៊ំទាំងពីរហ្នឹងអត់គំរាមទេ គឺគេនិយាយល្អជាមួយលោកស្រី។ គាត់ឆ្លើយថា <>មិនត្រឹមតែ<លោកស្រីទៅដែល> ត្រូវរៀបការទេ កម្មាភិបាលដទៃទៀតក៏ត្រូវរៀបការដែរ។ ហើយ<មួយ>នាទីក្រោយមកទៀតនៅម៉ោង <១៥:២៦> គឺលោកស្រីនិយាយថា បន្ទាប់ពីលោកស្រីបដិសេធច្រើនដង លោកស្រី<គិតថា ដោយសារមិនមានអ្នកណាហ៊ានបដិសេធទេ។> លោកស្រីមិន<ហ៊ាន ព្រោះលោកស្រី>ភ័យខ្លាចគេចោទប្រកាន់ <>។ ដូច្នេះខ្ញុំចង់សួរលោកស្រីថា តើអ្វីធ្វើឲ្យលោកស្រីភ័យ ថាគេចោទប្រកាន់លោកស្រីបែបនេះទៅវិញ?

**ឆ៖** ខ្ញុំគេសួរហ្នឹង ខ្ញុំគ្មានភ័យអីទេ នឹកឃើញថាភ័យ បើគេចោទប្រកាន់ ក៏ខ្ញុំអត់ភ័យ ព្រោះខ្ញុំមិនបានធ្វើផង។ គាត់និយាយមកទាំងប៉ុន្មាន ព្រោះខ្ញុំអត់បានអនុវត្តខ្លួនខ្ញុំផង ខ្ញុំអត់មានភ័យ មានខ្លាចអីផង បានខ្ញុំហ៊ានតហ្នឹង ខ្ញុំមិនភ័យ មិនខ្លាចទេ។

**សៈ** ហើយម្សិលមិញ នៅម៉ោង១៥:២៦ លោកស្រីឆ្លើយថា លោកស្រីជួបអ៊ំទាំងពីរ ហើយពួកគេនិយាយល្អជាមួយលោកស្រី ហើយលោកស្រីដឹងថា លោកស្រីមិនអាចបដិសេធបានទៀតទេ។ ដែលថាលោកស្រីថា អ៊ំៗហ្នឹងនិយាយល្អ ហើយឥឡូវនេះលោកស្រីនិយាយថា លោកស្រីមិនខ្លាចពួកគាត់។ ប៉ុន្តែដោយសារហេតុផលអ្វី ទើបលោកស្រីបានសន្និដ្ឋានថា លោកស្រីមិនអាចបដិសេធបានទៀតទេនៅពេលដែលជួបពួកគាត់នោះហើយ?

[០៩:៤៧:០៧]

**ឆៈ** ខ្ញុំមិនអាចបដិសេធបាន ព្រោះពីរដង ដល់ចូលទី៣ដង -- លើកទី៣ហើយ ហើយខ្ញុំមិនដឹងបដិសេធម៉េចទៀត។ ហើយបើឃើញគេរាល់គ្នា គេមិនតវ៉ាផង រួចខ្ញុំតវ៉ាតែខ្ញុំ ម៉្លោះហើយខ្ញុំក៏ខ្លាចខ្លួនដែរក៏ខ្ញុំបណ្ដោយទៅតាមគាត់ទៅ។ គាត់និយាយមក ខ្ញុំថា ធ្វើម៉េចក៏ធ្វើទៅ ក៏រៀបក៏រៀបទៅ តាមតែចំណង់របស់អង្គការទៅ។ ខ្ញុំនិយាយអ៊ីចឹងតែម្ដងហ្នឹង គ្មានពាក្យអីតវ៉ាជាមួយគាត់ទៀត។

**សៈ** ឥឡូវនេះនិយាយអំពីឪពុកម្ដាយលោកស្រីបន្តិចវិញ។ ម្សិលមិញ នៅម៉ោង<១៣:៥៤> នៅពេលដែលលោកស្រីឆ្លើយសំណួរ<របស់មេធាវីដើមបណ្ដឹងរដ្ឋប្បវេណី> អំពី<ឪពុកម្ដាយ ឬក៏> សាច់ញាតិរបស់លោកស្រី ថា<តើបានពិភាក្សាក្នុងការសម្រេចរៀបការលោកស្រី>ឬក៏អត់។ លោកស្រីនិយាយថា លោកស្រីមិនដែលប្រឹក្សា មិនដែលសួរឪពុកម្ដាយ<បងប្អូន>ទេ ព្រោះលោកស្រីនៅឆ្ងាយពីគេ។ លោកស្រីចង់សុំអនុញ្ញាតទៅលេងឪពុកម្ដាយដែរ តែគេមិនអនុញ្ញាត។ ឥឡូវនេះ ខ្ញុំចង់បញ្ជាក់ថា ខ្ញុំយល់ច្បាស់<ឬទេ> បន្ទាប់ពីគេស្នើឲ្យលោកស្រីរៀបការ តើលោកស្រីមានស្នើសុំទៅជួបឪពុកម្ដាយទេ?

**ឆៈ** ខ្ញុំសុំដែរ សុំថាជួបឪពុកម្ដាយ បងប្អូនសិន ឲ្យបងប្អូនឪពុកម្ដាយដឹង រួចទៅអង្គការឆ្លើយថា "មិនបាច់ទេ នៅជាមួយអង្គការ អង្គការរៀបចំដូចឪពុកម្ដាយដែរ អត់ឲ្យទៅទេ។" រួចកាលនោះ វាអ៊ីចឹងមែន គ្មានអ្នកណាងាយបានសុំទៅលេងទេ មិនបានទៅលេងផ្ទះទេ។ អ្នកណាពីរបីឆ្នាំ បួនប្រាំឆ្នាំតាំងពីសង្គ្រាមលើកទី១មករហូត ទល់មក៧៥, ៧៦ គ្មានពីណាទាន់បានទៅលេងផង។ សូម្បីតែប្ដីរបស់ខ្ញុំផ្ទាល់ដែលគាត់ធ្វើយោធាតាំងពីឆ្នាំ៧១, ៧២ហ្នឹង ក៏គាត់មិនដឹងបាន ដែលបានទៅលេងផ្ទះផង។ គ្មានពីណាដែលទៅស្គាល់ ទៅជួបម៉ែឪមុខអាម៉េចផង។ យើងខ្លះមកអ៊ីចឹង ទៅស្លាប់បង ស្លាប់ប្អូនអស់ ទៅវិញបានដឹងថាបាត់។

[០៩:៤៩:៣៧]

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ស៖** ខ្ញុំសូមសួរបន្តពីចំណុចនេះ។ ម្សិលមិញនៅម៉ោង<១៣:៥៦> នៅពេលលោកឆ្លើយទៅសហមេធាវីនាំមុខ លោកស្រីបានរៀបរាប់ថា មានគូរៀបការ១២គូ។ <ក្នុងចំណោម១២គូនោះ> លោកស្រី<ស្គាល់បីគូ។ ហើយខ្ញុំបានកត់ឈ្មោះមាន សាយ, ថា, សៅ, វី, ជី និង លាង>។ នៅក្នុងចំណោមគូស្វាមីភរិយាទាំងបីគូ តើលោកដឹងថាអ្នកដែលរៀបការទាំងបីគូដែលលោកស្រីស្គាល់នេះ មានបានពិគ្រោះយោបល់អីជាមួយនឹងឪពុកម្ដាយរបស់ពួកគាត់ទេមុននឹងរៀបការ?

**ផ៖** អត់! ជួបនិយាយគ្នាទៅ អត់ដូចគ្នាទាំងអស់ហ្នឹង គ្មានអ្នកណាបានទៅទេ គ្មានបានទៅជួបម៉ែឪ ទៅពិភាក្សាជាមួយម៉ែឪបងប្អូន អត់មានទាំងអស់គ្នា។ ថាទូទៅទាំង១២គូហ្នឹង គ្មានអ្នកណាបានជួបម៉ែឪទេ ទាំងអស់។ សួរគ្នាទៅសុទ្ធតែអ៊ីចឹងទាំងអស់គ្នា។

**ស៖** សូមអរគុណ។ សំណួរខ្ញុំបន្ទាប់មកទៀតនេះ គឺពាក់ព័ន្ធទៅនឹងការរៀបការរបស់លោកស្រីឥឡូវនេះខ្ញុំសួរអំពីអាយុរបស់លោកស្រីសិន។ នៅពេលឆ្លើយជាមួយនឹងសហមេធាវីនាំមុខ<នៅម៉ោង១៤:០២នាទី> លោកស្រីបានឆ្លើយថា នៅពេលដែលរៀបការនោះ គឺលោកស្រីមានអាយុ១៩ឆ្នាំ ប្ដីរបស់លោកស្រីមានអាយុ២៦ឆ្នាំ។ លោកដើមបណ្ដឹងរដ្ឋប្បវេណី អត្តសញ្ញាណប័ណ្ណរបស់លោកស្រីនេះ គឺកើតនៅថ្ងៃទី០៧ ខែមេសា ឆ្នាំ១៩៥៤ ត្រឹមត្រូវដែរឬទេ លោកស្រីអាចបញ្ជាក់អំពីអាយុកំណើតនេះបានទេ?

**ផ៖** ខ្ញុំដឹងថាកើតឆ្នាំ១៩៥៤ ប៉ុន្តែត្រង់ថាពេលខ្ញុំរៀបការនេះ ក៏ខ្ញុំមិនចេះរាប់ខែឆ្នាំខ្ញុំផងទេ ខ្ញុំថាបើមិន១៩, ២០អាយុខ្ញុំ អ៊ីចឹងខ្ញុំស្មានមើលទេ។ បើខ្ញុំមិនដឹង មិនចេះរាប់ មិនដឹងរាប់ពីណាទៅណា មកម៉េចឲ្យដឹងថាអាយុប៉ុន្មានផង ប៉ុន្តែខ្ញុំស្មានថាអាយុខ្ញុំ បើមិន១៩, ២០ប៉ុណ្ណឹង អាហ្នឹងអាយុរបស់ខ្ញុំពេលរៀបការ។

**ស៖** ដូច្នេះដើម្បីឲ្យច្បាស់លាស់បញ្ហានេះ តាមការចងចាំរបស់លោកស្រី តើលោកស្រីបានរៀបការនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យមែនទេ?

[០៩:៥២:១៣]

**ផ៖** ចាស ខ្ញុំរៀបការក្នុងកម្ពុជាប្រជាធិបតេយ្យហ្នឹង។

**ស៖** សូមអរគុណ។ ខ្ញុំសូមចូលទៅសំណួរបន្ទាប់មកទៀត។ ចំណុចនេះគឺពាក់ព័ន្ធទៅនឹងយុទ្ធជនពិការដែលលោកស្រីបានលើកឡើងពីម្សិលមិញ នៅម៉ោង១៣:៥៩ នៅពេលឆ្លើយទៅសហមេធាវីនាំមុខ លោកស្រីបាននិយាយអំពីប្ដីរបស់លោកស្រី ៗថាគាត់មានបញ្ហានៅជើងមួយចំហៀង គឺថាពិបាក

ដើរ។ <លោកស្រីក៏ថាគាត់ជាទាហានផងដែរ។> តើលោកស្រីដឹងទេថា ជើងគាត់ដែលបានរងរបួសនេះ គឺរងរបួសដោយសារតែសង្គ្រាមនៅពេលដែលគាត់ធ្វើជាកងទ័ពហ្នឹង ឬក៏យ៉ាងណា?

**ឆ៖** ចាស ជើងគាត់របួសហ្នឹងរបួសពីសង្គ្រាមហើយ បាន១មកនៅកន្លែងកងទ័ព ជនពិការហ្នឹង។ ដែលជនពិការ សុទ្ធដកមកពីកងទ័ព អ្នកណាដែលពិការ១ដកមកដាក់មួយកន្លែង។ ដាក់មួយកន្លែង ដើម្បីឲ្យធ្វើការស្រាល១។ អាហ្នឹងអ្នកពិការទាំងអស់ហ្នឹង។

**ស៖** ឥឡូវនិយាយអំពីកងយុទ្ធជនពិការ អង្គភាពយុទ្ធជនពិការ។ តើយុទ្ធជនពិការទាំងអស់ហ្នឹងនិយាយជារួមទៅ គឺមកពីកងពលជាមួយលោកស្រីដែរឬទេ?

**ឆ៖** មកពីកងពលភូមិភាគឧត្តរទាំងអស់ហ្នឹង ខាងភូមិភាគឧត្តរ។

[០៩:៥៣:៤៦]

**ស៖** សំណួរមួយទៀត សួរភ្ជាប់ទៅនឹងចំណុចនេះ។ នៅម៉ោង១៣:៥៧ នៅពេលឆ្លើយទៅសហមេធាវីនាំមុខ លោកស្រីក៏បានឆ្លើយសង្ខេបអំពីយុទ្ធជនពិការនោះដែរ។ <សូមដកស្រង់៖> "ក្នុងចំណោមប្តីប្រពន្ធ១២គូនេះ គឺខាង<នារី ក៏ជានារីយុទ្ធនារីដែរ ហើយខាងបុរស ក៏ជា>យុទ្ធជន<ដែរ> ប៉ុន្តែខាងប្រុសគឺថា<សុទ្ធតែ>ជាជនពិការ ហើយលែងអាចឡើងទៅប្រយុទ្ធ<>តទល់នឹងខ្មាំងបានហើយ។ <ពួកគេត្រូវបាននាំយកមករៀបការ។> អ្នកខ្លះខ្វាក់ភ្នែកមួយចំហៀង អ្នកខ្លះខ្វិចជើង អ្នកខ្លះខ្វិចដៃមួយចំហៀង ទាំងអស់ហ្នឹងសុទ្ធតែជាជនពិការ។" សំណួររបស់ខ្ញុំ លោកស្រីដើមបណ្តឹងរដ្ឋប្បវេណី ថាធ្វើម៉េចបានជាលោកស្រីដឹងថា យុទ្ធជនពិការត្រូវបានគេនាំយកមកឲ្យរៀបការនេះ? តើធ្វើដូចម្តេចទើបលោកស្រីដឹងថា យុទ្ធជនពិការទាំងអស់នេះ គឺថាត្រូវបានគេយកមកផ្សំផ្គុំរៀបការនេះដោយសារថាលែងអាចប្រយុទ្ធជាមួយខ្មាំងបានទៀតហើយ ធ្វើម៉េចបានលោកស្រីដឹង?

**ឆ៖** ខ្ញុំអត់ដឹងថាអ្នករៀបហ្នឹងសុទ្ធពិការដែរ ខ្ញុំគ្រាន់តែដឹងថាពិការឃើញនៅម្តុំខាងម្តុំខាងផ្សារចាស់ហ្នឹងដែរ ប៉ុន្តែមិនដែលស្គាល់ មិនដែលឃើញទេ គ្រាន់តែដឹង។ ហើយដល់ពេលរៀបនេះ អត់ដឹងថាយុទ្ធជនហ្នឹងសុទ្ធពិការ អត់ដឹងផង។ ស្រាប់ដល់ពេលថ្ងៃរៀបបានចូលទៅឃើញ ស្គាល់ខ្លះ ដែលពេលដែលគាត់មកដឹកជយភណ្ឌនោះ គាត់មកតាមឡានអ៊ីចឹង ជញ្ជូនជយភណ្ឌដាក់ឡានអ៊ីចឹង ឃើញបានឃើញស្គាល់ខ្លះ។ ទាល់ថ្ងៃរៀបហើយបានឃើញ ពីមុនមកអត់ដឹងថា យុទ្ធជនដែលត្រូវរៀបហ្នឹង សុទ្ធតែពួកពិការ អត់ដឹងផង។

[០៩:៥៥:៣៣]

**ស៖** សំណួររបស់ខ្ញុំប្រហែលជាមិនច្បាស់ហើយមើលទៅ សូមទោសលោកស្រី។ អ្វីដែលលោកបានឆ្លើយទៅសហមេធាវីនាំមុខនៅម៉ោង<១៣:៥៧> លោកស្រីថា "ដោយសារពួកគេគឺយុទ្ធជនពិការនេះ មិនអាចវាយប្រយុទ្ធជាមួយខ្មាំងតទៅទៀតបាន ទើបគេយកយុទ្ធជនពិការទាំងនោះមករៀបការឲ្យ។" សំណួររបស់ខ្ញុំសួរថា តើធ្វើដូចម្ដេចបានជាលោកស្រីដឹងថា ដោយសារមូលហេតុពួកគាត់មិនអាចប្រយុទ្ធបានទៅទៀត ទើបគេនាំយកមកឲ្យរៀបការនេះ?

**ឆ៖** ខ្ញុំអត់ដឹងដែរ។ អត់ដឹងថា ប្រយុទ្ធកើតមិនកើតទៀតមិនដឹងទេ ប៉ុន្តែឃើញតែពួកហ្នឹង ឃើញតែមកនៅកន្លែងមន្ទីរពិការហ្នឹង ទាំងអស់ហ្នឹង។ ហើយដល់ស្រាប់ដល់ពេលថ្ងៃរៀប ឃើញសុទ្ធតែពួកពិការហ្នឹងមករៀបហ្នឹង។ បើខ្ញុំអត់ដឹងដែរ អត់បានដឹងថា ពិការហ្នឹងអាម៉េចៗទេ ខ្ញុំអត់ដឹងទេ។ ប៉ុន្តែថាពិការហ្នឹង ខ្ញុំដឹងថា សុទ្ធពិការខាងមកពីភូមិភាគឧត្តរទាំងអស់ យោធានៅតាមក្រសួង -- តាមវរៈនីមួយៗហ្នឹង អ្នកណាពិការប្រយុទ្ធមិនកើត គឺយកមកដាក់តែមួយកន្លែងហ្នឹងតែម្ដង។ ប៉ុនប៉ុណ្ណឹងក៏មិនទាន់អស់ដែរ ទុកតែរៀបមួយស្រុករខ្ញុំហ្នឹង ក៏មិនទាន់អស់ដែរ នៅទៀត យុទ្ធជនពិការនៅច្រើនទៀត។

**ស៖** តើលោកស្រីដឹងអ្វីខ្លះទៀតដែរ អំពីអង្គភាពយុទ្ធជនពិការនេះ? តើអង្គភាពនេះមានទីតាំងនៅកន្លែងណាដែរ?

[០៩:៥៧:០១]

**ឆ៖** ខ្ញុំដឹងថាកន្លែងពួកពិការហ្នឹងនៅម្តុំខាងជើង -- ខាងកើតផ្សារចាស់ ខាងជើងផ្លូវ គឺផ្ទះម្តុំត្រង់ហ្នឹង ឃើញនៅពិការ ប៉ុន្តែមិនដឹងនៅប៉ុន្មាននាក់ ខ្ញុំអត់ដឹងទេ។ ប៉ុន្តែក្រោយមកទៀត អ្នកពិការហ្នឹងគេដកយកមកដាក់តាមក្រសួងពាណិជ្ជកម្មខ្លះ គេដាក់ដូចថា ខាងរោងជាងខ្លះទៅ អ្នកណាជួសជុលម៉ាស៊ីនកើត ដាក់ខាងជួសជុលម៉ាស៊ីនទៅ អ្នកណាធ្វើផ្ទះកើត ដកដាក់ខាងធ្វើផ្ទះទៅ ហ្នឹងពិការ។ ដូចគ្រួសារខ្ញុំផ្ទាល់ ក៏គេដាក់ខាងធ្វើផ្ទះដែរ គេដាក់ខាងជួសជុលផ្ទះអីអីចឹងទៅ។ អ្នកណាធ្វើកើតខាងណាគេដាក់ទៅខាងនុ៎ង។

**ស៖** លោកស្រីប្រហែលជាមិនដឹងពីចំណុចនេះ ប៉ុន្តែខ្ញុំព្យាយាមសាកសួរមើល។ តើអង្គភាពយុទ្ធជនពិការនេះ មានលេខកូដហ្នឹងលេខប៉ុន្មានដែរ?

**ឆ៖** អត់ដឹងផង។

**ស៖** ខ្ញុំសូមចូលទៅសំណួរបន្ទាប់ទៀត គឺពាក់ព័ន្ធទៅនឹងពិធីរៀបការរបស់លោកស្រី។ សំណួរដំបូងរបស់ខ្ញុំសួរថា ក្នុងចំណោមប្ដីប្រពន្ធដែលបានរៀបការ ដែលលោកស្រីបានលើកឡើង តើលោកស្រី

មានបានដឹងថា មានឪពុកម្ដាយរបស់អ្នកដែលរៀបការណាខ្លះបានមកចូលរួមដែរឬទេ?

**ឆ៖** ចាស អត់មានទេ។ ទូទៅគ្មានម្នាក់សោះហើយ។

**ស៖** ហើយសំណួរបន្ទាប់របស់ខ្ញុំ ពាក់ព័ន្ធចំណុចនេះដែរ តើលោកស្រីធ្លាប់បានឃើញដោយផ្ទាល់ភ្នែកនូវពិធីរៀបការណាមួយក្រៅពីពិធីរៀបការរបស់លោកស្រីនេះដែរឬទេ?

**ឆ៖** អត់ដែលផង មិនដែលចូលរៀបការនៅកន្លែងណាផង អត់ដឹង។

[០៩:៥៩:១៦]

**ស៖** សូមអរគុណ។ ឥឡូវខ្ញុំចូលទៅសំណួរវគ្គទី២ និយាយអំពីសីលធម៌នៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ។ ម្សិលមិញនៅម៉ោង១៥:០៨ នៅពេលឆ្លើយទៅសហព្រះរាជអាជ្ញា លោកស្រីបានឆ្លើយថា "នៅក្នុងរបបខ្មែរក្រហម វិន័យតឹងរ៉ឹងណាស់ គឺថាគេមិនឲ្យចូលរួមពាក់ព័ន្ធនៅក្នុងបញ្ហាសីលធម៌ណាមួយទេ។ បើថាប្រព្រឹត្តខុសសីលធម៌ ហើយបើសិនណាជាវាជាកំហុសសីលធម៌តូចតាច គេអាចចាត់វិធានការ<ដើម្បីការពារកុំឱ្យកើតឡើងបែបនេះ>។" សំណួររបស់ខ្ញុំ សួរថាតើ<លោកស្រីធ្លាប់ឮថា> បក្ស<>មានវិន័យ ឬក៏ច្បាប់ទម្លាប់<អំពីការខុសសីលធម៌>ដែរឬទេ<>?

**ឆ៖** មានមែន ផ្នែកសីលធម៌មួយសម័យនោះ គឺស្អាតស្អំណាស់ គ្មានសីលធម៌ គ្មានអី។ ប៉ុន្តែបើមានអីចឹងទៅ មានមែន មានម្នាក់ គឺគេជាកូនអ្នកធំ កូនមេ ប៉ុន្តែមិនដឹងមេខាងណាទេ។ ទៅគេបំបែកគ្នាអាហ្នឹងខ្ញុំគ្រាន់បានដឹងទេ។ ដល់បំបែកគ្នាទៅ ដូចថាមួយយកដាក់ខាងណេះ មួយដាក់ខាងណោះទៅ ដល់គេថាតាមដានទៅ មើលទៅមិនជ្រួលជ្រើមអីទេ គេអាចយកមករៀបការឲ្យវិញ។ ហ្នឹងខ្ញុំឃើញម្នាក់ហ្នឹង ខ្ញុំឮ ឃើញម្នាក់ហ្នឹងមែន។ ប៉ុន្តែគេកូនអ្នកធ្វើការថ្នាក់លើ ប៉ុន្តែមិនដឹងថ្នាក់ជំនាន់ ជាន់ណាទេ។ អាហ្នឹងខ្ញុំដឹងតែប៉ុណ្ណឹង។

**ស៖** ឥឡូវនេះ ខ្ញុំសូមសួរអំពីវិន័យសីលធម៌នេះ<ដែលបោះពុម្ពនៅក្នុងទស្សនាវដ្ដីទង់បដិវត្តន៍> គឺជាឯកសារចុះខែតុលា ឆ្នាំ១៩៧៨ ឯកសារ E3/765, ERNជាអង់គ្លេសគឺ 00539994, ខ្មែរ 00376493 ដល់ 94, បារាំង 00540024 ដល់ 25។ លោកស្រីដើមបណ្ដឹងរដ្ឋប្បវេណី ព្រឹត្តិបត្រនេះនិយាយអំពីគោលការណ៍សីលធម៌របស់បក្សកុម្មុយនីស្តកម្ពុជា។ គោលការណ៍៦នោះគឺថា "មិនត្រូវបង្ហាញឥរិយាបថណាមួយដែលបំពារបំពានដល់ស្ត្រីនោះទេ។" ចំណុចនេះ ប្រការ៦នេះ លោកស្រីធ្លាប់ឮទេ នៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ?

[១០:០១:៥៦]

*ប្រតិចារិកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារិកក្នុងភាសាទាំងបី។ ប្រតិចារិកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារិកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ឆៈ** អត់ធ្លាប់ឮអីទេ គ្រាន់ថាគ្រាន់តែឮថា រឿងថាហាមរឿងសីលធម៌ ខុសសីលធម៌ខុសអីតែប៉ុណ្ណឹង ដឹងទៅស្អីទៀត ខ្ញុំអត់ដែលឮ ដែលដឹងដែរ។ គ្រាន់អង្គការហាមឃាត់រឿងសីលធម៌ កុំឲ្យមានហ្នឹង។

**សៈ** ហើយចំណុចនេះ តើមេកងរបស់លោកស្រី ជាអ្នកប្រាប់លោកស្រីឬ?

**ឆៈ** ចាស សូម្បីតែប្រជុំថ្នាក់ណា ក៏គេលើកដែររឿងសីលធម៌ ហាមយុទ្ធជន សីលធម៌ -- នារីយុទ្ធជនកុំឲ្យមានសីលធម៌តែអ៊ីចឹង។ ទាំងប្រជុំអី ធ្វើអី ក៏ត្រូវតែមានដែរ ពាក្យហ្នឹងអត់មានចោលទេ។

**សៈ** សូមអរគុណ។ ឥឡូវនេះខ្ញុំចូលទៅសំណួរបន្ទាប់របស់ខ្ញុំ ខ្ញុំជិតចប់ហើយ។ សំណួរបន្ទាប់នេះ ពាក់ព័ន្ធទៅនឹងការរួមសង្វាស ការរួមភេទនៅក្រោយពេលអាពាហ៍ពិពាហ៍នេះ។ ម្សិលមិញនៅម៉ោង<១៤:០៧> នៅពេលឆ្លើយទៅនឹងសហមេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណី ដំបូងសួរថាតើជម្រើសមួយណាដែលត្រូវរួមភេទជាមួយ អ្នកណាជាអ្នករួមភេទសម្រេចនោះ? លោកស្រីឆ្លើយថា ប្តីរបស់លោកស្រី។ តើ<លោកស្រីអាចរៀបរាប់លម្អិតបានទេ? តើ>ប្តីរបស់លោកស្រីមាននិយាយមកកាន់លោកស្រីថាម៉េចដែរ មុននឹងចាប់ផ្តើមរួមសង្វាស រួមភេទគ្នាជាលើកដំបូងនោះ?

**ឆៈ** គេនិយាយទេ គេនិយាយថា បើយើងនៅតែមិនព្រមត្រូវគ្នាហ្នឹង ក៏នាំឲ្យ វរ១ គេដឹងគេឮ គេធ្វើបាបគេ។ អ៊្លោះហើយគាត់និយាយតែប៉ុណ្ណឹង គាត់អត់មាននិយាយអីទេ។

[១០:០៣:៣៩]

**សៈ** តើគាត់មាននិយាយប្រាប់លោកស្រីថា គាត់ដឹងរឿងនេះដោយរបៀបណាដែរទេ?

**ឆៈ** គាត់ដឹងតាមពេលដែលសម្រាកថ្ងៃដំបូងដែលរៀបការរួច ថ្ងៃដំបូងហ្នឹង គាត់សម្រាករឿងដឹងគេតាមដានហ្នឹង។ បើគាត់អង្គុយស្តាប់ដែរ គាត់អង្គុយស្តាប់ឮសម្រិបជើងដើរ សម្រិបជើងឡើងលើផ្ទះ សម្រិបជើងចុះ គាត់ដឹងតែទាំងអស់ហើយ។ គាត់ដឹងដោយខ្លួនគាត់ដែរទុំង ប៉ុន្តែខ្ញុំ ក៏គេបានប្រាប់ខ្ញុំឲ្យដឹងខ្លួនមុនដែរ។

**សៈ** ម្សិលមិញនេះនៅម៉ោង១៤:០៤ នៅពេលឆ្លើយទៅសហមេធាវីនាំមុខ លោកស្រីបាននិយាយអំពីអ្វីដែលកើតឡើងក្រោយពិធីរៀបការ។ លោកស្រីឆ្លើយថា នៅពេលលោកស្រីទៅសម្រាកនៅឯ<ផ្សារ>ទួលទំពូង មនុស្សម្នាក់បានប្រាប់លោកស្រីថា ឲ្យប្រយ័ត្នប្រយែងខ្លួន ពីព្រោះគេកំពុងតែតាមដានហើយ។ ហើយលោកស្រី<រៀបរាប់នូវអ្វីដែលលោកស្រីទើបតែនិយាយនេះ>ថា ប្តីប្រពន្ធបីគូស្នាក់នៅក្នុងផ្ទះតែមួយ ហើយ<នៅពេលយប់លោកស្រី>បានស្តាប់ឮសម្រិបជើងដើរ គេឡើងមកជណ្តើរ

<ដើម្បីលបស្ដាប់លោកស្រី។ ពួកគេបានឡើងជណ្ដើរដោយស្ងាត់ៗ។ ហើយលោកស្រីផ្ទាល់ហ្នឹងអត់មានបញ្ចេញសំឡេងអីទេ>។ <>ម្សិលមិញលោកស្រីឆ្លើយថា មានគេម្នាក់ប្រាប់ឲ្យលោកស្រីថា ប្រុងប្រយ័ត្នខ្លួន។ តើអ្នកដែលប្រាប់លោកស្រី ជាអ្នកណា?

**ឆ៖** អ្នកដែលប្រាប់ខ្ញុំ គឺបងស្រីដាំបាយនៅប្រចាំកន្លែងហ្នឹងតែម្ដងហ្នឹង។ បងស្រីហ្នឹងគាត់ដាំបាយនៅនឹងកន្លែងមុខព្រួយខ្ញុំហ្នឹង។ រួចទៅគាត់ប្រាប់ខ្ញុំថា “មិត្តអ្នំា ប្រយ័ត្នខ្លួនណ៎ា ព្រោះគេតាមហើយពួកមិត្តនោះ ថាពួកមិត្តហ្នឹងអត់ពេញចិត្តនឹងគ្រួសារទេ” និយាយប្រាប់អ៊ីចឹង។ ដល់អ៊ីចឹងទៅ ដល់យល់ឡើងខ្ញុំចាប់ស្ដាប់មើល អ៊ីចឹងមែន។ សម្រិបជើងដើរទៅ ជណ្ដើរប៉ុន្មានកាំ ខ្ញុំឮទាំងអស់។ ខ្ញុំរាប់មើល ឮទាំងអស់។ ទៅដល់សំងំអ៊ីចឹង ខ្ញុំសំងំចាំស្ដាប់។ សំងំអ៊ីចឹងទៅ ខ្ញុំអង្គុយចាំស្ដាប់មើល។ សំងំមួយសន្ទុះធំអ៊ីចឹងទៅ បានស្រាប់ឮស្នូរសម្រិបជើងដើរចុះមកវិញ។ គឺខ្ញុំរាប់តាមកាំជណ្ដើរ ដឹងទាំងអស់ សម្រិបជើង។

[១០:០៥:៥០]

**ស៖** តើលោកស្រីមានបានដឹងថា អ្នកដែលមកតាមដានលោកស្រីហ្នឹងជាអ្នកណាដែរទេ?

**ឆ៖** អត់ដឹងផង ងងឹតឈឹង មានទៅហ៊ានបើកទ្វារមើលផង គិតតែសំងំឡើងញ័រ រួញខ្លួនណោះ មានបានមើលទេ មានហ៊ានបើកធ្វើផងហ្នឹង អត់ដឹងអ្នកណា ជាអ្នកតាមដានផង។

**ស៖** សំណួរចុងក្រោយរបស់ខ្ញុំ។ តើលោកស្រីធ្លាប់ដែលឮបញ្ជាឲ្យមកតាមឃ្លាំមើល តាមលបស្ដាប់អ្នកដែលគេរៀបការថ្មីៗឲ្យហ្នឹង ដើម្បីចង់ដឹងថារួមដំណេកជាមួយគ្នា រួមភេទជាមួយគ្នាឬអត់ទេ?

**ឆ៖** ខ្ញុំក៏ធ្លាប់ឮគេនិយាយហែៗមកដែរ ប៉ុន្តែចំពោះខ្លួនខ្ញុំផ្ទាល់ ទើបមកប្រទះខ្លួនឯងហ្នឹង រឿងគេតាមដានហ្នឹង។ ប៉ុន្តែពីដើមមកឮតែគេនិយាយដែរថា អ្នករៀបគ្រួសារច្រើនមានឈ្លបតាមដាន។ រួចខ្ញុំគ្រាន់តែឮៗហ្នឹង ប៉ុន្តែខ្ញុំមិនដែលឃើញផង។ ដល់ទើបខ្លួនខ្ញុំផ្ទាល់ បានដឹងថាគេតាមដានមែន។

**ស៖** លោកស្រីទើបតែនិយាយអំពីឈ្លប។ តើឈ្លបដែលនៅ -- តើនៅទីតាំង<ផ្សារ>ទួលទំពូងដែលលោកស្រីស្នាក់នៅហ្នឹងមានឈ្លបនៅទីនោះដែរ?

**ឆ៖** មានពួកអង្គ -- ពួកអង្គរក្សដែលប្រធានមុខព្រួញហ្នឹង គាត់មានតើ។ គាត់មានកូនចៅគាត់អ៊ីចឹង សម្រាប់គាត់ប្រើទៅណាទៅណីអី តាមដានអី កូនចៅគាត់ហ្នឹង។ ប៉ុន្តែខ្ញុំមិនបាន មិនស្គាល់ខាងយុទ្ធជន អត់ដែលស្គាល់ ព្រោះនៅកន្លែងបែកគ្នា។ គាត់គ្រាន់តែដឹកនាំ គាត់ដឹកនាំរួម ៗខាងនារីផង យុទ្ធជនផង ហើយយុទ្ធជននៅផ្សេង នារីនៅផ្សេង មិនបានស្គាល់ មិនដឹងអ្នកណាៗផង។

[១០:០៧:៤៤]

**ស៖** អ៊ីចឹងលោកស្រី<បានរៀបរាប់ពីតួនាទីមួយចំនួននៅទីនោះ ដូចជា>យាមការពារមេ <និងត្រួតពិនិត្យការងារប្រចាំថ្ងៃ>។ ចុះលោកស្រីដឹងថា ឈ្លបទាំងអស់ហ្នឹងមានភារកិច្ចទូទៅអីត្រូវធ្វើដែរឬទេ ក្រៅពីអារឿងហ្នឹង មានភារកិច្ចផ្សេងត្រូវធ្វើទេ?

**ឆ៖** ពួកហ្នឹងនៅជញ្ជូនជយភណ្ឌអីដូចគ្នាដែរតើ ដើរប្រមូលជយភណ្ឌតាមផ្ទះ តាមអីដូចតែគ្នាហ្នឹង។ ប៉ុន្តែគ្រាន់ថាការងារគេមានអីផ្សេងទៅ គេចាត់តាំងទៅផ្សេងទៀតទៅ ប៉ុន្តែការងាររួមគ្នាជាមួយនារី យុទ្ធជនហ្នឹងទាំងអស់គ្នាហ្នឹងទេ។

**ស៖** អ៊ីចឹងតាមអ្វីដែលលោកស្រីដឹងគឺថា គេមានភារកិច្ចយាមដទៃទៀតដែរឬទេ?

**ឆ៖** ជាទូទៅ គេមិនដែលយាមអីផងពួកហ្នឹង មិនដឹងឃើញយាមអីផង។ ឃើញថ្ងៃៗធ្វើការធម្មតា។ ប៉ុន្តែដល់ពេលមានអ៊ីចឹងទៅ បែបគេចាត់តាំងដឹង អីមិនដឹង ខ្ញុំមិនដឹងដែរ បើខ្ញុំទើបឮសម្រិបជើងពេលហ្នឹង បានខ្ញុំដឹង។ ពីមុនមកខ្ញុំមិនដឹងថាមានអ្នកតាមដានផង។ ឮតែគេនិយាយនៅក្រសួង -- នៅកន្លែងគេផ្សេងៗ ឮគេនិយាយដែរ ប៉ុន្តែគ្រាន់ថាមិនដែល ចំពោះខ្លួនខ្ញុំផ្ទាល់មិនដែលឃើញ ទើបមកឃើញខ្លួនឯងផ្ទាល់ហ្នឹង។

**ស៖** ខ្ញុំសូមសួរបញ្ជាក់ពីចំណុចចុងក្រោយមួយ។ លោកស្រីបានឆ្លើយថា លោកស្តាប់ឮសម្រិបជើង ប៉ុន្តែលោកស្រីមិនដឹងថា អ្នកដែលមកលបស្តាប់ហ្នឹងជាអ្នកណាមែនទេ អ៊ីចឹងមែនឬ?

**ឆ៖** ចាស អ៊ីចឹងមែន អត់ដឹងអ្នកណាផង។

[១០:០៩:៣៤]

**លោកស្រី ដូរីន ជិន៖**

សូមអរគុណចំពោះការអត់ធ្មត់ឆ្លើយទៅនឹងសំណួររបស់ខ្ញុំ លោកស្រីដើមបណ្តឹងរដ្ឋប្បវេណី។ លោកប្រធាន ខ្ញុំអស់សំណួរហើយ។

**ប្រធានអង្គជំនុំ៖**

អរគុណលោកមេធាវី។ សូមអញ្ជើញលោកចៅក្រម ហ្វេនស៍ មានសំណួរ!

**សួរដោយចៅក្រម ក្លូឌា ហ្វេនស៍៖**

**ស៖** សូមអរគុណ។ ខ្ញុំមានសំណួរតែពីរបីសំណួរទេ សួរបន្តពីមេធាវីការពារក្តី។ គឺវាពាក់ព័ន្ធទៅនឹងការប្រព្រឹត្តខុសសីលធម៌។ លោកស្រីបានជម្រាបថា នៅក្នុងអង្គប្រជុំលើកទី១នេះ <ដែលនាំទៅ

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ដល់ការរៀបការរបស់លោកស្រីជាយថាហេតុនោះ កម្មាភិបាលដែលមានចិត្តស្លូតបូតបានមកជួបលោកស្រី ហើយ>គេចោទប្រកាន់លោកស្រី គេចោទប្រកាន់ថា លោកស្រីមិនព្រមរៀបការ ដោយថាលោកស្រីមានសង្សារ។ <ពេល>នេះ<លោកស្រីចង់បញ្ជាក់ថា រឿងនេះមិនពិតទេ ហើយនិយាយថា “អត់ទេ វាមិនត្រឹមត្រូវទេ សូមឆែកខ្ញុំមើលទៅ។ លោកអាចឆែកមើលបាន”>។ តើលោកស្រីមានបានដឹងទេ មានអ្វីកើតឡើងចំពោះអ្នកណាដែលមានសង្សារ នារីៗណាដែលមានសង្សារ<ដែលបក្សមិនបានរៀបចំឱ្យ>?

[១០:១០:៥៤]

**លោកស្រី ជា ឌៀប៖**

**ឆ៖** ដូចខ្ញុំបានជម្រាបអ៊ីចឹងថា អ្នកដែលមានសីលធម៌ គឺមួយកន្លែងខ្ញុំ ខ្ញុំឃើញមានមួយមែន ប៉ុន្តែដូចខ្ញុំនិយាយប្រាប់ថា អ្នកដែលសីលធម៌ហ្នឹងគឺកូនគេអ្នក ដូចថាកូនគេកូនមេណ៎ា គេគ្រាន់តែបំបែកទៅ គ្រាន់បំបែកគ្នាទៅមួយរយៈទៅ គេយកមករៀបការវិញ។ ហ្នឹងខ្ញុំដឹងតែប៉ុណ្ណឹង តែមួយហ្នឹងទេ។ បើក្រៅពីហ្នឹង ខ្ញុំមិនដែលឃើញ មិនដែលឮដែរ មិនដែលឃើញមានដែរ។

**ស៖** តើហេតុអ្វីដែលលោកស្រីត្រូវតែបង្ហាញឱ្យគេឃើញថា នេះជាករណីរបស់លោកស្រីផ្ទាល់ តើហេតុអ្វីបានលោកស្រីត្រូវតែបង្ហាញឱ្យឃើញថា លោកស្រីនេះមិនដែលប្រព្រឹត្តខុសសីលធម៌អីទេ ហេតុអី?

**ឆ៖** ចុះចំពោះខ្លួនខ្ញុំផ្ទាល់ ខ្ញុំមិនដែលខុសសីលធម៌មែន ខ្ញុំមិនដែលទៅប៉ះពាល់អ្នកណា ទៅលេងសើចអ្នកណាឱ្យមានគេចាប់អារម្មណ៍ ខ្ញុំមិនមានផង។ ប៉ុន្តែដល់ពេលប្រធានហ្នឹង គាត់សួរខ្ញុំ គាត់ចេះតែចុច ចង់សម្លុតខ្ញុំហ្នឹង ប៉ុន្តែខ្ញុំនៅតែ ខ្ញុំរឹង។ បើកុំតែខ្ញុំរឹង គាត់សម្លុតបានហ្នឹង។ អ៊ីចឹងខ្ញុំរឹង ថាខ្ញុំអត់អ៊ីចឹងទៅ បើខ្ញុំអត់មែន។

**ស៖** ខ្ញុំយល់ហើយចំណុចនេះ។ ខ្ញុំបានស្ដាប់ឮពីមេធាវីការពារក្ដីហើយថា កំហុសខុសសីលធម៌នេះ ជារឿងមួយធ្ងន់ធ្ងរណាស់ក្នុងរបបនោះ។ លោកស្រីមានអារម្មណ៍ថា គេគំរាមកំហែងលោកស្រី។ ហើយហេតុអីបានចាំបាច់គេគំរាមកំហែងលោកស្រី? ហេតុអី<បានវាជាការគំរាមកំហែង បើបញ្ហាតែមួយដែលបានកើតឡើងគឺ លោកស្រីត្រូវបានគេ>បំបែក<ពីប្ដីលោកស្រីមួយរយៈ ហើយបន្ទាប់មកគេអនុញ្ញាតឱ្យជួបគ្នាវិញ>? <តើមានបញ្ហាអ្វីកើតឡើងទៀតទេ ក្នុងករណីប្រព្រឹត្តិខុសសីលធម៌នេះ?>

[១០:១២:៥២]

*ប្រតិចារិកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឱ្យមានភាពស្របគ្នារវាងប្រតិចារិកក្នុងភាសាទាំងបី។ ប្រតិចារិកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារិកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ឆ៖** ខ្ញុំពិបាកថាដែរ សម័យនុ៎ង ជួនកាលអ្នកខុសសីលធម៌អ៊ីចឹង តែខុស គេច្រើនយកទៅបាត់តែម្តងហ្នឹង។ តែយកទៅ យកទៅបាត់។ ខ្ញុំឃើញតែមួយហ្នឹងទេ ឃើញបានយកមករៀបការវិញ។ បើក្រៅពីហ្នឹង ក៏ខ្ញុំដូចមិនសូវដែលឃើញ មិនដែលឃើញផង។ គ្រាន់តែឮៗគេនិយាយ ប៉ុន្តែគ្រាន់ថា ឲ្យឃើញ ខ្ញុំមិនបានឃើញ ខ្ញុំឃើញតែមួយហ្នឹង គេបំបែកមែន។ បានថាដឹងបំបែក ខាងស្រីបំបែកយកមកដាក់កន្លែងខ្ញុំ បើខាងប្រុសថា បំបែកយកទៅណា ទៅច្រាំងចំរេះ។ ខ្ញុំឮតែគេនិយាយ ប៉ុន្តែខាងស្រីនៅកន្លែងខ្ញុំមែន។ ដល់ក្រោយមកអ៊ីចឹងទៅ ដល់ស្រាប់តែឃើញគេមកយកខាងស្រីហ្នឹងទៅ គេយកខាងប្រុសទៅ គេថាយកទៅរៀបការ។ រួចខ្ញុំ ក៏ខ្ញុំមិនថាម៉េចដែរ ខ្ញុំក៏អត់បានទៅដែរ គេគ្រាន់តែប្រាប់អ៊ីចឹង។

**សៈ** <តើខ្ញុំយល់ត្រឹមត្រូវ>ទេ ប្រតិកម្មជាធម្មតា ពាក់ព័ន្ធទៅនឹងកំហុសសីលធម៌នោះ <>គឺច្រើនតែបាត់ខ្លួន <ប៉ុន្តែលោកស្រីដឹងករណីមួយ គឺ>ថា <អ្នក>ខុសសីលធម៌ហើយ ត្រូវបានគេផ្សំផ្គុំឲ្យរៀបការ<>។ ខ្ញុំយល់អ៊ីចឹង ត្រឹមត្រូវទេ?

**ឆ៖** ចំពោះខ្លួនខ្ញុំផ្ទាល់ ក៏ទើបនឹងឃើញមួយដឹងដែរ ទើបនឹងឃើញមួយគូហ្នឹង។ ពីដើមមកខ្ញុំមិនដែលដឹង មិនដែលឃើញ ទើបនឹងឃើញមួយគូហ្នឹងតែម្តងហ្នឹង។ ហើយរៀបការ គេរៀបការយកទៅពេលយប់ទៀត យកទៅរៀបការហ្នឹង។

[១០:១៤:១៧]

**សៈ** ឥឡូវខ្ញុំសូមចូលទៅចម្លើយទី១ របស់លោកស្រីសិន។ អ្នកដែលប្រព្រឹត្តខុសសីលធម៌ លោកស្រីថា ក្រោយមកគឺបាត់ខ្លួនហើយ។ ឥឡូវទុកគូដែលគេខុសសីលធម៌ ហើយក្រោយមកគេយកមកផ្សំផ្គុំរៀបការឲ្យហ្នឹង ទុកមួយអន្លើសិនចុះ។ <ម៉េចបានលោកស្រីដឹងថា អ្នកប្រព្រឹត្តិខុសសីលធម៌បាត់ខ្លួន?> តើ<នេះជាអ្វីដែលលោកស្រី>បានស្តាប់ឮគេនិយាយ<>? <ពិតណាស់ លោកស្រីមិនបានឃើញរឿងនេះទេ វាជាអ្វីដែលលោកស្រី>បានឮ បាន<អាន ហើយមនុស្សបាននិយាយអំពីរឿងនេះ តើលោកស្រី>បាន<ដឹងរឿងនេះ>មកពីណាដែរ ថាកាលណាខុសសីលធម៌ ហើយបាត់ខ្លួននេះ?

**ឆ៖** ខ្ញុំអត់ដែលឃើញដែរ។ តាំងពី សួរហ្នឹងឮថាសីលធម៌ តែសីលធម៌ បាត់ខ្លួន។ ចំពោះខ្លួនខ្ញុំផ្ទាល់ ក៏មិនបានឃើញដែរ គ្រាន់តែឮៗ គេថាតែសីលធម៌ បាត់ខ្លួនហើយ។

**សៈ** ខ្ញុំយល់ហើយ។ ឥឡូវនេះខ្ញុំចូលសួរសំណួរបន្ទាប់មកទៀត។ នៅពេលដែលគេសួរលោកស្រី<ថា ហេតុអ្វីបានជា>លោកស្រីព្រមរៀបការក្រោយបដិសេធពីរដងរួចមក លោកស្រីថា "ដោយសារ<តែអ្នកផ្សេងទៀតមិនហ៊ានប្រកែក"> ហើយលោកស្រីថា "ខ្ញុំខ្លាចគេចោទប្រកាន់ខ្ញុំមកពីកំហុស

អ្វីមួយ"។ <ប៉ុន្តែ>លោកស្រីមិនបានបញ្ជាក់បន្ថែមពីហេតុផលអីទេ។ តើបើសិនណាជាលោកស្រីមិនព្រមរៀបការនៅពេលគេសំណូមពរជាលើកចុងក្រោយ តើលោកស្រីភ័យខ្លាចគេចោទប្រកាន់ថាខុសសីលធម៌ ឬក៏យ៉ាងម៉េចបានជាលោកស្រីព្រមនោះ?

**ឆ៖** ចំពោះខ្លួនខ្ញុំផ្ទាល់ខ្លាចដែរហ្នឹង ព្រោះវាចេះតែរកចំណុច ដូចថាមនុស្សក្នុងជួរវាច្រើនតែមានខ្លះកាច់គ្នាដែរហ្នឹង។ ដល់យើងដូចថាគេប្រដៅយើងមិនបាន និយាយយើងមិនបានទៅ តែគេថាទៅតែមេថា មេលើនុ៎ងច្បាស់ជឿហើយ គេមិនមកជឿយុទ្ធជននារីទេ។ បានខ្ញុំនឹកឃើញខ្លាច បានខ្ញុំថាព្រមរៀបការទៅ។

[១០:១៦:៣៦]

**ស៖** ខ្ញុំព្យាយាមសួរជាចុងក្រោយ។ ខ្ញុំដឹងថាលោកស្រីឆ្លើយថា ខ្លាចគេចោទប្រកាន់ថាកំហុសអ្វីមួយ។ ប៉ុន្តែ<តើ>លោកស្រីអាចលើកអំពីការចោទប្រកាន់<ឲ្យច្បាស់លាស់បានទេ តើលោកស្រីខ្លាច>គេចោទប្រកាន់ពីកំហុសអី? លោកស្រីអាចរកកំហុសណាមកបញ្ជាក់មួយ ពីរ បីបានទេ <ឬក៏កំហុសជាក់លាក់តែមួយក៏បានដែរ ឬក៏វាគ្រាន់តែជាការភ័យខ្លាចបែបស្រពិចស្រពិលថា "បើខ្ញុំមិនរៀបការទេនោះគេនឹងរកកំហុសអ្វីមួយមកចោទប្រកាន់ខ្ញុំ">?

**ឆ៖** ខ្ញុំសូមជម្រាបថាកំហុសនៅសម័យនោះ ពិបាកថាណាស់។ ទី១ ដូចថាសីលធម៌អ៊ីចឹងទៅ។ រួចបើខ្ញុំមិនបានសីលធម៌ផង ឲ្យគេចោទសីលធម៌។ រួចតែបើសិនថាគេចោទថាខ្ញុំសីលធម៌ រួចចោទសីលធម៌គេដែលសួររកឫសរកគល់ពីខ្ញុំ គេមិនសួរទេ គេសុខចិត្តបញ្ជូនទៅថ្នាក់លើនោះ។ រួចថ្នាក់លើតែប្រធានក្រុម ប្រធានកងទេ ដែលប្រាប់ហើយគេជឿហើយ គេមិនមែនថាឥឡូវមកសួរសមាជិកទាំងអស់ តើមិត្តហ្នឹងអ៊ីចឹងមែនអីអត់ គេអត់មានសួរទេ។ រឿងសីលធម៌ហ្នឹងមួយ កំហុសអីក៏ដោយ គេមិនសួរទេ។ គេសុខថាឲ្យតែថ្នាក់លើរាយការណ៍ទៅហើយ ទៅហើយទៅតាមខ្សែហើយ។ ហ្នឹងខ្ញុំជម្រាបអ៊ីចឹង ថាគេមិនមកសួរយើងវិញទេ។ គេមិនថា ឥឡូវមិត្តឯងនេះ ឥឡូវគេថាមិត្តឯងសីលធម៌មែនអ្អីមិនមែន? គេអត់មានមកសួរទេ គេមានយកកំហុសយើងទៅតាមហ្នឹងហើយ ម្ល៉ោះហើយគេដកទៅតាមហ្នឹងហើយ។

**ស៖** អ៊ីចឹងតើលោកស្រីកំពុងនិយាយថា កាលណាគេចោទប្រកាន់ថាអ្នកណាម្នាក់ខុសសីលធម៌ហើយ គឺគ្រប់គ្រាន់ហើយ អាចឲ្យគេដកអ្នកហ្នឹង ឬក៏បញ្ជូនអ្នកហ្នឹងទៅណាហើយ អ៊ីចឹងឬ?

[១០:១៨:២០]

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ឆ៖** ចាស អ៊ីចឹងមែនហ្នឹង។ តែថាខុសហើយ តែមានគេរាយការណ៍ទៅហើយ គេជឿហើយ អ្នកលើគេជឿហើយ គេអត់មានសួរយើងទៀតទេ មិនមែនថាដកយើងយកទៅសួរនាំអីអត់ទេ តែដកយកទៅៗតែម្តងហ្នឹង ត្រង់គេយកទៅណាទៀត មិនដឹងទេ។ ប៉ុន្តែគ្រាន់តែខ្ញុំ អាហ្នឹងត្រង់ថានៅកន្លែងខ្ញុំផ្ទាល់មិនទាន់មានដកទេ គ្រាន់ខ្ញុំបានឮគេនិយាយទេ កន្លែងខ្ញុំអត់មានទេ។

**ស៖** ជាថ្មីម្តងទៀត សំណួរបញ្ជាក់ម្តងទៀត។ ចុះអ៊ីចឹង តើលោកស្រីខ្លាចគេចោទប្រកាន់អ៊ីចឹង មានរឿងអ៊ីចឹងកើតមកលើលោកស្រីឬ?

**ឆ៖** ចាស ខ្ញុំខ្លាចដែរហ្នឹង ខ្លាចមានរឿងចោទប្រកាន់មក ក្រែងលោដឹងរឿងសីលធម៌ដឹងរឿងអី ថាខ្ញុំក្បត់ខ្ញុំអីទៀតទៅ។ អាហ្នឹងខ្ញុំវាមិនប៉ានសន្និដ្ឋានដែរ បានខ្ញុំមិនប៉ានតវ៉ាជាមួយគេតទៅទៀតហ្នឹង។

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

សូមអរគុណ។ លោកប្រធានអស់សំណួរហើយ។

**ប្រធានអង្គជំនុំ៖**

អរគុណលោកចៅក្រម។ ឥឡូវដល់ពេលសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាក២០នាទី ចាប់ពីនេះតទៅ។

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១០:១៩ នាទី ដល់ម៉ោង ១០:៣៨ នាទី)*

[១០:៣៨:០០]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយ!

ជាបន្តសូមអញ្ជើញមេធាវីលោក ខៀវ សំផន ឡើងមានសំណួរចំពោះដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ។

**កញ្ញា អង់តា ហ្គីសសេ៖**

សូមអរគុណលោកប្រធាន ជម្រាបសួរភាគីទាំងអស់។

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**សួរដោយកញ្ញា អង់តា ហ្គីសសេ៖**

**ស៖** ជម្រាបសួរលោកស្រីដើមបណ្តឹងរដ្ឋប្បវេណី ខ្ញុំឈ្មោះ អង់តា ហ្គីសសេ។ ខ្ញុំជាសហមេធាវីអន្តរជាតិរបស់លោក ខៀវ សំផន។ អ៊ីចឹងក្នុងឋានៈជាមេធាវីនេះហើយ ដែលខ្ញុំនឹងចោទសំណួរបន្ថែមទៅលោកស្រី។ សំណួរបន្តទាក់ទងទៅនឹងសំណួរដំបូងដែលលោកចៅក្រម ឡាវែន៍ សួរទៅលោក<ស្រី>ហ្នឹង ខ្ញុំសូម<រំឭកឡើងវិញនូវអ្វីដែលគាត់បានលើកឡើង ហើយនិង>និយាយអំពីកាលប្បវត្តិដែលលោកស្រីបានលើកឡើង។ លោកស្រីបានមកដល់នៅទីក្រុងភ្នំពេញនៅថ្ងៃទី១៧ ឬក៏ក្រោយថ្ងៃទី១៧ មេសា បន្តិចបន្តួច ហើយគេបានចាត់តាំងលោកស្រីឲ្យធ្វើការច្រើនកន្លែង។ លោកស្រីបាននិយាយថា លោកបានឃើញ ខៀវ សំផន នៅទីក្រុងភ្នំពេញពីរដង។ កាលនោះគឺលោកស្រីបានឆ្លើយលើកទី១ថា ឃើញលើកទី១ នៅវត្តឧណ្ណាលោម។ ហើយបន្ទាប់មកទៀត ឃើញនៅបុរីកីឡា។ ហើយកាលពីម្សិលមិញនេះ នៅម៉ោង១៥:០៣នាទី លោកស្រីបានកែតម្រូវ លោកស្រីថា លោកស្រីច្រឡំ តាមពិតនៅឆ្នាំ១៩៧៥ទេ ក៏ប៉ុន្តែនៅលើកទី២ នោះ គឺនៅវត្តឧណ្ណាលោម ហើយលោកទី១នោះ គឺនៅស្តាតបុរីកីឡាទេ។ តើលោកស្រីអាចបញ្ជាក់ពីចំណុចនេះបានដែរឬទេ?

[១០:៣៨:៥៤]

**លោកស្រី ជា ឌៀប៖**

**ឆ៖** ចង់ឲ្យខ្ញុំនិយាយថាម៉េច? និយាយខ្ញុំស្តាប់វាមិនបាន។

**ស៖** ខ្ញុំគិតថា ប្រហែលជាខ្ញុំនិយាយវែងបន្តិច ឥឡូវខ្ញុំកាត់ឲ្យខ្លីៗ។ លោកស្រីបានមកដល់ទីក្រុងភ្នំពេញនៅថ្ងៃ១៧ មេសា ឆ្នាំ១៩៧៥ ឬក៏ក្រោយថ្ងៃទី១៧ មេសាហ្នឹងបន្តិច។ តើខ្ញុំយល់អ៊ីចឹងត្រឹមត្រូវទេ?

**ឆ៖** ចាស ខ្ញុំចូលនៅទីក្រុងភ្នំពេញក្រោយថ្ងៃ១៧ មេសា យូរដែរ ប៉ុន្តែនៅក្នុងថ្ងៃ ខែមេសា ប៉ុន្តែមិនដឹងជាថ្ងៃប៉ុន្មានទេ ខ្ញុំចូលមកដល់ទីក្រុងហ្នឹង។

**ស៖** ខ្ញុំមិនបញ្ហាអីទេ គឺថាខែមេសា ឆ្នាំ១៩៧៥ ហ្នឹងអាចទទួលយកបាន។ កាលពីម្សិលមិញលោកស្រីបាន<បញ្ជាក់ថា លោកស្រីបាន>កែចម្លើយដំបូងរបស់លោកស្រីហ្នឹង នៅម៉ោង១៥:០៣នាទី លោកស្រីបានកែតម្រូវដូចតទៅនេះ។ ពេលនោះលោកស្រីនិយាយពី ខៀវ សំផន លោកស្រីបាននិយាយថា៖ “ខ្ញុំបានឃើញគាត់លើកទី១ នៅបុរីកីឡា គឺនៅឆ្នាំ១៩៧៥ ហើយមុនហ្នឹងខ្ញុំច្រឡំទេ។ តាមពិតលើកទី២ ដែលខ្ញុំបានជួបគាត់នោះ គឺនៅវត្តឧណ្ណាលោម។ កាលនុំងគាត់ធ្វើជាអធិបតីនៃកិច្ចប្រជុំមួយដែល

មាន<យុវជន>ចូលរួមនៅទីនោះ។ <អង្គប្រជុំនោះមានរយៈពេលពេញ១ថ្ងៃ។>" សូមបញ្ចប់ការដកស្រង់។ សំណួរទី១ របស់ខ្ញុំ តើលោកស្រីនៅចាំដែរឬទេ ថាលោកស្រីមកដល់ភ្នំពេញបានប៉ុន្មាន រយៈពេលប៉ុន្មានហើយបានលោកស្រីរៀបការ?

[១០:៤១:៤៨]

**ឆ៖** ខ្ញុំមកដល់ទីក្រុងភ្នំពេញរយៈ ខ្ញុំវាមិនចាំបានរឿងខែឆ្នាំ ថ្ងៃហ្នឹង ប៉ុន្តែថា មិនដឹងជាឆ្នាំ៧៥ ឬ៧៦ ប៉ុន្តែតាមតែស្មានមើលហ្នឹង ដូច ព្រោះខ្ញុំដូច ខ្ញុំជម្រាបមុនៗថា ខ្ញុំអត់សូវដឹងខែថ្ងៃទេ មិនដឹងថ្ងៃអីមិនដឹងខែអីទេ នៅក្នុងទីក្រុងភ្នំពេញមួយជំនាន់ខ្មែរក្រហមនេះ។ ហ្នឹងខ្ញុំជម្រាបអ៊ីចឹង។

**ស៖** នៅក្នុងចម្លើយរបស់លោក<ស្រី> នៅទម្រង់បែបបទ<ជនរងគ្រោះលើក>ទី១ របស់លោក<ស្រី> គឺឯកសារ <E3319/45.4.8> គឺជាទម្រង់បែបបទជនរងគ្រោះលើកទី១ ដើម្បីសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី គឺថ្ងៃទី១៤ តុលា ឆ្នាំ២០០៩។ អង្គាល់នោះ ប្រហែលជាលោកស្រីនៅចាំច្រើនជាឥឡូវនេះ។ លោកស្រីបានលើកឡើងដូចតទៅនេះ ហើយខ្ញុំសូមដកស្រង់ជាភាសាអង់គ្លេស 01139644, ERN ជាភាសាខ្មែរគឺ 01049379 ហើយមិនមានការបកប្រែជាភាសាបារាំងទេ។ លោកស្រីបាន<បាននិយាយ>ពីការមកដល់ទីក្រុងភ្នំពេញ<នៅឆ្នាំ១៩៧៥>របស់លោកស្រី លោកស្រីបាននិយាយដូចតទៅនេះ ជាភាសាអង់គ្លេស៖ "៦ខែ<>ក្រោយពីធ្វើការនៅទីនោះមក គេឲ្យខ្ញុំរៀបការ<ជាមួយ ស ធឿន ដែលនៅពេលនោះអាយុ២៦ឆ្នាំ>។" អ៊ីចឹងខ្ញុំសួរថា លោកស្រីនៅចាំទេ ថាការរៀបការរបស់លោកស្រីនោះ គឺថា ៦ខែ<ក្រោយ>ពេលមកដល់ភ្នំពេញហើយហ្នឹង បានគេចាត់ឲ្យលោកស្រីរៀបការ?

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្សាឯល៖**

លោកប្រធាន?

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកព្រះរាជអាជ្ញា!

[១០:៤៤:០៥]

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្សាឯល៖**

បាទ សូមអរគុណលោកប្រធាន។ ខ្ញុំជំទាស់ទៅនឹងសំណួរនេះ ពីព្រោះខ្ញុំយល់ឃើញថា ការដកស្រង់អម្បាញ់មិញនេះ វាទាក់ទងទៅនឹងថា ធ្វើការរយៈពេល៦ខែនៅកន្លែងមួយជាក់លាក់។ <វា>មិន

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

មែន<មានន័យ>ថា ធ្វើការ៦ខែនៅភ្នំពេញទេ។ អ៊ីចឹងប្រហែលជាសក្ខីកម្មរបស់គាត់បានផ្ដល់ឲ្យនោះច្បាស់ជាងនេះ។ <ប៉ុន្តែគាត់ធ្វើការយោងទៅនឹងអង្គហេតុដែល>ថា គាត់ធ្វើការនៅផ្សារអូរឫស្សី <ហើយសម្រង់>ដែលមេធាវីលើកឡើងហ្នឹង គឺថាក្រោយពី<>នោះ <ដោយបាននិយាយថា "ក្រោយពីធ្វើការ៦ខែនៅទីនោះ ពួក>គេ<បានរៀបចំ>ឲ្យខ្ញុំរៀបការជាមួយនឹង ស ធឿន។" អ៊ីចឹង<គាត់>មិន<>បាននិយាយថា <វាគឺ>៦ខែ<ក្រោយការមកដល់ភ្នំពេញនោះ>ទេ។ <ប៉ុន្តែគឺ៦ខែ> ក្រោយពី<បានចាប់ផ្ដើម>ធ្វើការនៅផ្សារអូរឫស្សីហើយទេ។ អ៊ីចឹងសូមឲ្យលោកស្រីមេធាវីកែសម្រួល។

**សួរដោយកញ្ញា អង់តា ហ្គីសសេ៖**

**ស៖** លោកស្រីដើមបណ្ដឹងរដ្ឋប្បវេណី តើលោកស្រីនៅចាំដែរឬទេថា នៅពេលដែលលោកស្រីមកដល់ភ្នំពេញនេះ ចន្លោះពេលមកដល់ភ្នំពេញ ហើយនិងពេលដែលលោកស្រីទៅធ្វើការនៅផ្សារអូរឫស្សីហ្នឹងមានរយៈពេលប៉ុន្មានដែរ?

**លោកស្រី ជា ឌៀប៖**

**ឆ៖** ខ្ញុំចាំអត់បានផង។

**ស៖** អត់ចាំក៏ដោយចុះ តើលោកស្រីមកដល់ភ្នំពេញនេះយូរហើយដែរទេ ឬក៏មកដល់<រយៈពេលខ្លះក្រោយពីប្រហែលជាមួយ ឬ>ពីរ<>សប្ដាហ៍ <ឬក៏មួយខែ ឬ>ពីរ<>ខែ ក្រោយពេលដែលដល់ភ្នំពេញហើយហ្នឹង?

**ឆ៖** មករៀងយូរដែរ ខ្ញុំមកដល់ទីក្រុងភ្នំពេញហ្នឹង ធ្វើការបានយូរដែរនុ៎ង ដើរឡើងស្គាល់កន្លែងនេះកន្លែងនោះចង់ពេញភ្នំពេញហើយនុ៎ង មានភ្លាមៗណា ពេលរៀបការនេះ គឺមកយូរដែរ ប៉ុន្តែខ្ញុំមិនដឹងខែណាថ្ងៃណា។

[១០:៤៦:១១]

**ស៖** ហើយនៅពេលដែលលោកស្រីនិយាយថា "យូរដែរហើយហ្នឹង" តើ<វាមានន័យថាម៉េច? តើវាមាន>រយៈពេលប៉ុន្មាន <បួនប្រាំ>សប្ដាហ៍ ឬក៏<មួយខែឬ>ពីរ<>ខែ<>? លោកស្រីអាចបញ្ជាក់បានទេ លោកស្រីចង់បានន័យថា<ថាម៉េច> "រយៈពេល<យូរដែរ">ហ្នឹង?

**ឆ៖** ប្រហែលជាតាំងពីចូលមកដល់ទីក្រុងភ្នំពេញ តាមស្មានមើលដែលខ្ញុំបានធ្វើការ មើលខ្ញុំមកសម្រាកជើងផងអីផង ទម្រាំធ្វើការ ប្រហែលចូលទៅប្រាំមួយប្រាំពីរខែហ្នឹងបានពេលខ្ញុំរៀបការ។ អាហ្នឹងតាមខ្ញុំស្មានមើល ខ្ញុំអត់ដឹងការខែប៉ុន្មាន ថ្ងៃប៉ុន្មានផង។

**ស៖** អ៊ីចឹងបើតាមរយៈចម្លើយរបស់លោកស្រីហ្នឹង គឺថាប្រាំមួយប្រាំពីរខែក្រោយពេលលោកស្រីមកដល់ភ្នំពេញហើយហ្នឹង បានលោកស្រីរៀបការ។ អ៊ីចឹងបានន័យថា វាត្រូវគ្នានឹងចម្លើយរបស់លោកស្រីមុនហ្នឹង ដែលថាលោកស្រីថាលោកស្រីរៀបការនៅឆ្នាំ១៩៧៥។ សំណួររបស់ខ្ញុំហ្នឹង គឺមានរយៈពេលជាក់លាក់មួយច្បាស់ គឺខ្ញុំចង់ដឹងថាតើលោកស្រីមានចាំដែរឬទេ ថាតើលើកទី១ ដែលលោកស្រីបានជួបលោក ខៀវ សំផន នោះ បើតាមចម្លើយរបស់លោកស្រីគឺថានៅវត្តឧណ្ណាលោមនោះ តើជួបគាត់ហ្នឹងនៅមុនពេលរៀបការ ឬក៏ការហើយៗបានជួបលោក ខៀវ សំផន?

**ឆ៖** ចាស ខ្ញុំជួបគាត់មុនរៀបការ។

[១០:៤៧:៤៩]

**ស៖** លើកទី២ លោកស្រីថាបានជួបលោក ខៀវ សំផន លើកទី២នៅបុរីកីឡា ពេលដែលកាត់ក្ដី ហ៊ូ នឹម, ហ៊ូ យន់ នោះ តើលោកស្រីអាច<និយាយបានទេថាវាមុន ឬក្រោយពេល>លោកស្រី<>រៀបការ<>?

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្បាឯល៖**

លោកប្រធាន?

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកព្រះរាជអាជ្ញា!

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្បាឯល៖**

បាទ សូមអរគុណលោកប្រធាន។ ខ្ញុំអត់ជំទាស់នឹងសំណួរនេះទេ ក៏ប៉ុន្តែ<>ខ្ញុំជំទាស់<ចំពោះការប្រើពាក្យ> ពីព្រោះអម្បាញ់មិញនេះ គាត់ខំអានកំណត់ត្រាប្រតិចារឹកកាលពីម្សិលមិញ ដែលលោកស្រីដើមបណ្ដឹងរដ្ឋប្បវេណី គាត់និយាយថាគាត់បានជួបលោក ខៀវ សំផន ពីដំបូងនៅបុរីកីឡា ហើយបន្ទាប់មកទៀត ជួបនៅវត្តឧណ្ណាលោម។ អ៊ីចឹងដល់ថាឥឡូវនេះ ស្រាប់ទៅឃើញថា ផ្ដល់ព័ត៌មានបញ្ច្រាស់វិញ។ អ៊ីចឹងខ្ញុំមិនដឹងថាមេធាវី គាត់មានចេតនា<ឬក៏អចេតនា>នោះទេ។ <ប្រហែលជាយើងត្រូវការឱ្យ>បញ្ជាក់<ឡើងវិញ។ ប៉ុន្តែនៅក្នុងសំណួរពីខាងដើមនោះ គឺនិយាយ>ថាលើកទី១<ដែលលោកស្រីបានឃើញគាត់>នោះ <គឺ>បានជួបនៅវត្តឧណ្ណាលោម <ហើយបន្ទាប់មកលើកទី២នៅបុរីកីឡា ដូច្នេះខ្ញុំគិតថា ប្រហែលជាយើងត្រូវប្រុងប្រយ័ត្នលើចំណុចនេះ។ សូមអរគុណ>។

[១០:៤៩:០៩]

**កញ្ញា អង់តា ហ្គីសសេះ**

ខ្ញុំច្រឡំទេ អម្បាញ់មិញ។ ខ្ញុំសួរម្ដងទៀត។

**សួរដោយកញ្ញា អង់តា ហ្គីសសេះ**

**សៈ** លោកស្រី តើលោកស្រីនៅចាំថាកាលលើកទី១ លោកស្រីបានជួបគាត់នៅ<ពេល>ណា? ព្រោះលោកស្រីបានថា ជួបលើកទី១នៅឧណ្ណាលោម វត្តឧណ្ណាលោម -- អូ្ហ! នៅបុរីកីឡា (សូមទោស) ។ តើលោកស្រីអាចបញ្ជាក់បានទេថា បើធៀបនឹងពេលដែលលោកស្រីការនោះ ថាមុនពេលរៀបការ ឬក៏ក្រោយរៀបការ ពេលដែលលោកស្រីជួបគាត់នៅបុរីកីឡាហ្នឹង?

**លោកស្រី ជា ឌៀបៈ**

**ឆៈ** ខ្ញុំជួបគាត់មុនរៀបការ។ ជួបមុនហើយ យូរហើយ បានរៀបការក្រោយ។ ចុះមិនយូរ មិនដឹងប៉ុន្មានខែប៉ុន្មានថ្ងៃ ខ្ញុំអត់ដឹងថ្ងៃខែហ្នឹង ហ្នឹង។

**សៈ** តើខ្ញុំច្រឡំ ឬក៏យ៉ាងណា? បើសិនខ្ញុំសន្និដ្ឋានថា ទាំងពីរដងដែលលោកស្រីទំនងដែលបានជួបលោក ខៀវ សំផន ហ្នឹងគឺថាជួបគាត់ហ្នឹងមុនពេលដែលលោកស្រីរៀបការ។ តើខ្ញុំសន្និដ្ឋានអ៊ីចឹងខុសឬត្រូវ?

**ឆៈ** ចាស ត្រូវហើយ មុនរៀបការទាំងពីរដងហ្នឹង ខ្ញុំជួបគាត់មុនរៀបការ។

[១០:៥០:៤១]

**សៈ** ខ្ញុំព្យាយាមកំណត់កាលប្បវត្តិដដែលគឺថា ចន្លោះពេលលើកទី១ដែលលោកឃើញលោក ខៀវ សំផន ហើយនិងលើកទី២ហ្នឹង តើលោកស្រីអាចវាស់វែងពេលវេលាបានដែរឬទេ <រវាងពេលវេលាទាំងពីរ> ដែលលោកស្រីជួបគាត់ <គឺ>នៅបុរីកីឡាដែលកាលនោះគេកាត់ក្ដី ហ៊ូ យន់, ហ៊ូ នឹម ហ្នឹងហើយនិងលើកទី២ លោកស្រីបានជួបគាត់ដែរនៅវត្តឧណ្ណាលោមនោះ? តើរយៈពេល ចន្លោះពេលទាំងពីរលើកហ្នឹង លោកស្រីបានឃើញគាត់ហ្នឹងរយៈពេលហ្នឹងមានរយៈពេលប៉ុន្មានដែរ?

**ឆៈ** ខ្ញុំចាំអត់បានទេ មិនដឹងរយៈពេលប៉ុន្មានទេ។ កាលនោះដែលខ្ញុំជួបគាត់ ខ្ញុំនៅផ្សារចាស់នៅឡើយទេ។ ដល់ពេលខ្ញុំជួបគាត់លើកទី២នៅវត្តឧណ្ណាលោម ខ្ញុំទៅនៅផ្សារទួលទំពូង តែមិនដឹងជារយៈប៉ុន្មានថ្ងៃប៉ុន្មានខែ ខ្ញុំអត់ដឹងដែរ អត់បានចាំ។

**សៈ** ឥឡូវនេះខ្ញុំសុំចាប់អារម្មណ៍ទៅហេតុការណ៍ទី១។ លោកចៅក្រម ឡាវែន៍ បានសួរលោកស្រីពីរបីសំណួរដែរ ទាក់ទងនឹងប្រធានបទនេះ។ អ៊ីចឹងខ្ញុំសុំឲ្យលោកស្រីឆ្លើយបំភ្លឺបន្ថែម។ សំណួរទី១

របស់ខ្ញុំ គឺថា ទាក់ទងនឹងកិច្ចប្រជុំនៅវត្តឧណ្ណាលោមដែលក្នុងកិច្ចប្រជុំនោះ លោកស្រីបាននិយាយថាជាការកាត់សេចក្ដីលើ ហ៊ូ យន់, ហ៊ូ នឹម។ អ៊ីចឹងខ្ញុំសួរលោកស្រីថា អ្នកណាជាអ្នកអញ្ជើញលោកស្រីឱ្យទៅចូលរួមការជំនុំជម្រះហ្នឹង ឬក៏កិច្ចប្រជុំដែលគេកាត់សេចក្ដីហ្នឹង?

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវីនាំមុខដើមបណ្ដឹងរដ្ឋប្បវេណី!

**លោក ពេជ អង្គ៖**

បាទ សូមគោរពលោកប្រធាន។ សំណួររបស់លោកស្រីមេធាវីអម្បាញ់មិញ ហាក់ដូចជាមានការភ័ន្តច្រឡំ។ ពេលដែលលោកស្រីបានជួបលើកទី១ គឺគេបាននិយាយអំពី -- លោក ខៀវ សំផន បាននិយាយអំពីការកាត់ទោស ហើយបានលើកទី២ បាននិយាយអំពីការរៀបការ។

[១០:៥៣:១២]

**សួរដោយកញ្ញា អង់តា ហ្គីសសេ៖**

**ស៖** ការពិត ខ្ញុំតែចាប់ផ្ដើមច្រឡំ ឥឡូវច្រឡំទៀតហើយ។ ឥឡូវខ្ញុំបញ្ជាក់ម្ដងទៀតគឺថានៅកិច្ចប្រជុំទី១ ដែលលោកស្រីបានចូលរួមនោះ ថានៅបុរីកីឡាហ្នឹង និយាយអំពីការកាត់សេចក្ដីលើ ហ៊ូ យន់, ហ៊ូ នឹម។ <តើត្រឹមត្រូវទេ?> តើលោកស្រីអាចជម្រាបជូនតុលាការបានដែរឬទេ ថាតើអ្នកណាជាអ្នកអញ្ជើញលោកស្រីទៅចូលរួមក្នុងកិច្ចប្រជុំនៅបុរីកីឡា? នេះបើតាមចម្លើយដែលលោកស្រីបានផ្ដល់ជូនតុលាការនៅទីនេះៗ។

**លោកស្រី ជា ឌៀប៖**

**ឆ៖** ខ្ញុំ ថ្ងៃនុំងខ្ញុំមិនដឹងអ្នកណាដែលប្រាប់ខ្ញុំផង។ ស្រាប់តែក្រែងលោទៅដល់ពេលព្រឹកឡើង ស្រាប់ឃើញឡានមកឈប់មុខផ្ទះ។ ឡានមកឈប់មុខផ្ទះ ក៏ហៅខ្ញុំហ្នឹងឱ្យឡើងឡានទៅ។ ខ្ញុំទៅទាំងភ័យផង ទៅហ្នឹង។ ប៉ុន្តែទៅដល់ឃើញគេឃើញឯងទៅ ក៏អត់អីដែរ។ គ្មានគេប្រាប់មុនផង អត់មានប្រាប់មុខ ស្រាប់ឃើញព្រឹកឡើង ឃើញឡានហៅនៅនឹងផ្ទះតែម្ដង ថ្ងៃទៅបុរីកីឡានុំង។

**ស៖** ហើយលោកស្រីស្ថិតនៅអង្គភាពណាដែរ នៅពេលដែលគេទៅកោះហៅលោកស្រីឱ្យមកចូលរួមកិច្ចប្រជុំហ្នឹង?

**ឆ៖** ខ្ញុំនៅពាណិជ្ជកម្មផ្សារចាស់ហ្នឹង នៅជញ្ជូនអីវ៉ាន់នៅឡើយ។

**ស៖** ហើយអង្គាល់នោះអ្នកណាជាមេផ្ទាល់របស់លោកស្រី?

**ឆ៖** មេផ្ទាល់របស់ខ្ញុំនៅមុខព្រួញផ្សារចាស់ហ្នឹងគឺឈ្មោះ អ៊ំមុញ។

[១០:៥៥:៣៨]

**ស៖** លោកស្រីជាមនុស្សតែម្នាក់ឯងគត់ទេឬ ដែលទៅចូលរួមកិច្ចប្រជុំហ្នឹង ឬក៏មានអ្នកផ្សេងដែរ?

**ឆ៖** មុខព្រួញហ្នឹងទៅតែខ្ញុំម្នាក់ឯងគត់ អត់មានអ្នកណាទៅសោះ។

**ស៖** ចុះប្រធានអង្គភាព ឬក៏ប្រធានកងរបស់លោកស្រីហ្នឹង មានវត្តមាននៅក្នុងកិច្ចប្រជុំហ្នឹងទេ?

**ឆ៖** គាត់អត់ទៅផង។ ដូចខ្ញុំប្រាប់ថាអត់មានអ្នកណាទៅ ទៅតែម្នាក់ខ្ញុំគត់។ ខ្ញុំទៅដំបូងខ្ញុំភ័យតើ ប៉ុន្តែទៅដល់ឃើញគេឯងច្រើនទៅ បានឈប់ភ័យ។

**ស៖** នៅក្នុងក្រុមខាងអ្នកប្រមូលជយភណ្ឌហ្នឹង តើលោកស្រីមានតួនាទី ឬក៏មុខងារអីជាក់លាក់ទេ?

**ឆ៖** ខ្ញុំនៅតែមួយក្រុមហ្នឹង ខ្ញុំជាសមាជិកគេទេ ខ្ញុំអត់មានធ្វើអីផងហ្នឹង។ ប៉ុន្តែគាត់ច្រើនឃើញខ្ញុំថាខ្ញុំច្រើនរឹងប៉ឹងជាងគេ ទៅណាគាត់ច្រើនតែដេញខ្ញុំឲ្យទៅហើយ។

**ស៖** ចុះ<មេរបស់លោកស្រីឈ្មោះ> មុញ មានបានប្រាប់លោកស្រីទេ <នៅពេលដែល> លោកស្រី<ជាមនុស្ស>តែម្នាក់<គត់> ដែលត្រូវទៅចូលរួមប្រជុំហ្នឹង ហើយហេតុអីក៏ មុញ ខ្លួនឯងផ្ទាល់ហ្នឹងអត់មានបានទៅចូលរួមក្នុងកិច្ចប្រជុំហ្នឹងជាមួយលោកស្រីដែរ?

**ឆ៖** គាត់អត់មាននិយាយប្រាប់ខ្ញុំផង ហើយខ្ញុំក៏គ្មានបានសួរគាត់ដែរ។ គ្រាន់ថាឲ្យខ្ញុំ គ្រាន់តែឃើញឡានមក ទៅហៅឈ្មោះខ្ញុំឲ្យទៅ ខ្ញុំក៏ឡើងឡានទៅៗ។ រួចគាត់អត់ទៅ ដឹងអាម៉េច ខ្ញុំក៏មិនបានសួរនាំគាត់ដែរហ្នឹង។ ឲ្យទៅៗ ឲ្យមកៗៗ មានអត់ដឹងទេ អត់ដឹងរឿងម៉េច អត់ដឹង។

[១០:៥៨:០៥]

**ស៖** តើកិច្ចប្រជុំហ្នឹង ឬក៏ការកាត់សេចក្ដីនៅបុរីកីឡាហ្នឹងមានរយៈពេលប៉ុន្មានដែរ? តាមចម្លើយរបស់លោកស្រីពីព្រឹកមិញហ្នឹងគឺថា លោកស្រីបានចេញមុនពេលប្រជុំហ្នឹងចប់។ អ៊ីចឹងខ្ញុំសួរម្ដងទៀត តើលោកស្រីនៅចូលរួមប្រជុំហ្នឹងអស់រយៈពេលប៉ុន្មានដែរ?

**ឆ៖** ខ្ញុំចូលប្រជុំហ្នឹងគ្រាន់តែចូលទៅរៀបចំកម្មវិធីហ្នឹង គ្រាន់គេប្រកាសថាឲ្យនីរសារមកនិយាយហ្នឹង ក៏ខ្ញុំញាក់ទៅ គេយកខ្ញុំមកក្រៅ។ ចំណែកអ៊ំ ខៀវ សំផន នោះគាត់មិនទាន់បាននិយាយអីទេ

គាត់គ្រាន់តែអង្គុយនៅធ្វើទីប្រឹក្សាហ្នឹងទេ។ គាត់មិនទាន់បាននិយាយអី គ្រាន់តែនីរសារអ្នកនិយាយទេ។ ដល់និយាយនីរសារហ្នឹងនិយាយទៅ ខ្ញុំក៏គ្រុនញាក់ទៅ គេយកខ្ញុំមកដេកពេទ្យមក ខ្ញុំក៏អត់បានស្តាប់តទៅទៀតដែរ។ រយៈពេលប្រហែលមិនទាន់បានមួយព្រឹកទេ គ្រាន់តែប្រហែលម៉ោងប្រាំបី, ប្រាំបួនហ្នឹង ប្រហែលមួយម៉ោងហ្នឹង ខ្ញុំចេញមកវិញមក។

**ស៖** អ៊ីចឹងលើកទី១ ដែលលោកស្រីបានឃើញ ខៀវ សំផន នោះ ហេតុអីបានជាលោកស្រីដឹងថាអ្នកដែលអង្គុយនៅលើវេទិកាហ្នឹងជា ខៀវ សំផន?

**ឆ៖** ខ្ញុំស្គាល់គាត់ច្បាស់ណាស់ អត់មានស្រពេចស្រពិល។

**ស៖** ហើយមុនពេលដែលជួបគាត់ជាលើកទី១នៅបុរីកីឡាហ្នឹង តើលោកស្រីបានជួបគាត់ពីមុនមកនៅកន្លែងណាផ្សេងទៀតទេ?

[១០:៥៩:៥៥]

**ឆ៖** ខ្ញុំមិនដែលបានជួបគាត់ទេ ប៉ុន្តែខ្ញុំទៅហ្នឹង ខ្ញុំក៏ស្គាល់ គ្រាន់តែថាខ្ញុំឃើញគាត់ ខ្ញុំស្គាល់គាត់តែម្តង។ រួចទោះគេអ្នកផ្សេងទៀត ក៏គេប្រាប់ខ្ញុំដែរថា ហ្នឹងលោក អ៊ំខៀវ សំផន ហើយ។ គេប្រាប់ខ្ញុំអ៊ីចឹង រួចខ្ញុំក៏ស្គាល់ដែរ ប៉ុន្តែខ្ញុំមិនដែលបានជួបកន្លែងណាផង។

**ស៖** អ៊ីចឹងបើខ្ញុំយល់មិនច្រឡំទេ គឺថាលោកស្រីឆ្លើយថា ដោយសារអ្នកនៅអង្គុយជិតលោកស្រីហ្នឹង ប្រាប់លោកស្រីថា នុ៎ងហើយ ម្នាក់នុ៎ងជា ខៀវ សំផន ហើយ។ អ៊ីចឹងហើយបានលោកស្រីយល់ថាគាត់ហ្នឹងជា ខៀវ សំផន ឬក៏យ៉ាងម៉េច?

**ឆ៖** ចាស ខ្ញុំយល់ដែរ ខ្ញុំនឹកឃើញថា ខ្ញុំក៏រាងធ្លាប់ប្រហែល ប៉ុន្តែមិនដឹងប្រហែលកន្លែងណា ខ្ញុំមិនហ៊ានថា ព្រោះខ្ញុំមិនប្រាកដ។ ដល់ខ្ញុំប្រហែលទៅ ដល់ខ្ញុំមកឃើញពិតប្រាកដ គឺខ្ញុំដឹងថា មុខតែអ៊ំខៀវ សំផន ហើយ។ រួចដល់គេប្រកាសមក ក៏អ៊ីចឹងមែន។ គេប្រកាស ក៏គេប្រកាសតាមថា អ៊ំខៀវ សំផន ហ្នឹងដែរ។

**ស៖** ហើយអ្នកណាជាអ្នកប្រកាសហ្នឹង?

**ឆ៖** អត់ស្គាល់ផង។ មុនរៀបកម្មវិធី មានអ្នកប្រកាសកម្មវិធីហ្នឹង ប៉ុន្តែខ្ញុំអត់ស្គាល់គេផង។

**ស៖** តើបុគ្គលរូបហ្នឹង គាត់មានបានប្រកាសថា ខៀវ សំផន ហ្នឹងគាត់មានមុខតំណែងអ្វីដែរឬទេ?

**ឆ៖** គាត់ប្រកាសថា លោកអ៊ំ ខៀវ សំផន ជាទីប្រឹក្សា ថាអ៊ីចឹង។ ដឹងស្អី ទីប្រឹក្សាហ្នឹង ខ្ញុំក៏មិន

ដឹងដែរ។

[១១:០១:៤៦]

**ស៖** តើគេមានប្រើពាក្យ "ទីប្រឹក្សា" តែមួយហ្នឹងគត់ ប៉ុណ្ណឹងតែម្តង អត់មានបញ្ជាក់ថា ទីប្រឹក្សាផ្នែកអី ផ្នែកអីទេឬ?

**ឆ៖** អត់មានបញ្ជាក់ផង គ្រាន់តែប្រាប់តែប៉ុណ្ណឹង។ ហើយគេនិយាយអីផ្សេងទៀតទៅ ក៏ខ្ញុំមិនដឹងដែរ ខ្ញុំអត់ដឹងដែរ។

**ស៖** ក្នុងចម្លើយរបស់លោកស្រីកាលពីព្រឹកមិញហ្នឹង លោកស្រីបាននិយាយថា មានអ្នកផ្សេងទៀតដែរ ដែលមានវត្តមាននៅបុរីកីឡាហ្នឹង ដែលនៅលើវេទិកាដែរ។ អ៊ីចឹងខ្ញុំសួរលោកស្រីថា តើគេមានធ្វើឧទ្ទេសនាមអ្នកដទៃទៀតទេ ដែលមានវត្តមាននៅលើវេទិកាដែរហ្នឹង ដែរឬទេ?

**ឆ៖** គេឧទ្ទេសនាមដែរ ប៉ុន្តែខ្ញុំមិនស្គាល់គេ ប៉ុន្តែខ្ញុំក៏ភ្លេចដែរ។ មិនដឹងឈ្មោះអី ឈ្មោះអីទេ។ មានហើយ ឃើញអង្គុយលើនុ៎ង ប៉ុន្តែមិនដឹងអ្នកណាៗ ខ្ញុំមិនដឹងដែរ ចាំឈ្មោះមិនបាន។

**ស៖** ទោះបីលោកស្រីមិនចាំឈ្មោះគាត់ក៏ដោយចុះ ក៏ប៉ុន្តែសួរថា តើគេមានប្រាប់ពីតួនាទី ឬក៏មុខងាររបស់មនុស្សទាំងអស់នុ៎ងដែរឬទេ?

**ឆ៖** អត់ដឹងផង។ អត់បានចាំ ដឹងគេប្រាប់ម៉េច អីម៉េចផង ខ្ញុំកំពុងតែអត់ស្រួលខ្លួនដែរ។ ចាំបានតែគាត់ម្នាក់ហ្នឹង។

**ស៖** ដូច្នេះលោកស្រីនៅទីនោះរយៈពេលមួយម៉ោង។ អ៊ីចឹងតើលោកស្រីអាចបញ្ជាក់បានដែរឬទេ ថានៅពេលដែលលោកស្រីនិយាយថា នៅស្តាតបុរីកីឡានោះ តើនៅកន្លែងណា នៅក្នុងបន្ទប់ នៅក្នុងសាលមួយ ឬក៏នៅកណ្តាលវាល?

[១១:០៣:៤០]

**ឆ៖** នៅក្នុងសាលហ្នឹង នៅជុំគ្នាទាំងអស់ហ្នឹង មនុស្សឡើងណែនប៉ែស ប៉ុន្តែមិនដឹងខាងណាៗខ្លះ មានតាំងពីយោធាឡើង។

**ស៖** តើលោកស្រីអាចជម្រាបជូនតុលាការបានដែរឬទេ ថាលោកស្រីអង្គុយនៅកន្លែងណា នៅក្នុងសាលហ្នឹង? ថាលោកស្រីនៅខាងមុខ នៅចំកណ្តាល ឬក៏នៅខាងក្រោយសាល? នៅក្រោយគេ នៅមុខគេ ឬក៏នៅកណ្តាលរោងហ្នឹងតែម្តង?

**ឆ៖** ខ្ញុំនៅចំកណ្តាលហ្នឹង មើលទៅឃើញគាត់ច្បាស់ថែសហ្នឹង នៅពីៗមុខចំកណ្តាលហ្នឹង ខ្ញុំ

ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។

មើលឃើញគាត់ច្បាស់ហ្នឹង។ សូម្បីតែនីរសារមកនិយាយ ក៏ខ្ញុំមើលឃើញដែរ ប៉ុន្តែគ្រាន់ថា ខ្ញុំឈឺទៅ ខ្ញុំគេដកយកមកដេកពេទ្យទៅ ក៏ខ្ញុំមិនដឹងរឿងអីតទៅទៀតទេ។

**ស៖** ទាក់ទងទៅនឹងនីរសារទាំងអស់នោះៗ តើលោកស្រីលែងចាំឈ្មោះពួកគាត់ហើយ ឬក៏យ៉ាងណា?

**ឆ៖** អត់មានចាំឈ្មោះមួយសោះហើយខ្ញុំនោះ។ ភ្លេចអស់ហើយ។

**ស៖** ហើយនៅលើវេទិកាហ្នឹង តើនីរសារទាំងពីរនាក់ហ្នឹង គាត់នៅលើវេទិកាហ្នឹងដែរ ឬក៏គេឱ្យគាត់ឈរនៅកន្លែងណាផ្សេង?

**ឆ៖** ឈរនៅមុខវេទិកាហ្នឹង។

**ស៖** ហើយនៅពេលដែលគេប្រកាសហ្នឹង បានលោកស្រី -- ពេលដែលគេប្រកាសហ្នឹងហើយ បានលោកស្រីដឹងថា អ្នកទាំងពីរនាក់ហ្នឹងជានីរសាររបស់ ហ៊ូ យន់ និង ហ៊ូ នឹម ឬក៏យ៉ាងម៉េច?

[១១:០៥:៥៧]

**ឆ៖** ចាស គេប្រកាសថាពីរនាក់ហ្នឹងនីរសារ ហ៊ូ នឹម, ហ៊ូ យន់ អ៊ីចឹងហ្នង បានខ្ញុំដឹង បើកុំគេប្រកាស ក៏ខ្ញុំអត់ដឹងដែរ។

**ស៖** តើក្រៅពីលោកស្រីនេះ ដែលលោកស្រីមកពីខាងប្រមូលជយភណ្ឌនោះ តើលោកស្រីមានដឹងដែរឬទេ ថាអ្នកដែលមានវត្តមាននៅក្នុងកិច្ចប្រជុំដែរហ្នឹងមកពីអង្គភាពណាដែរ?

**ឆ៖** អ្នកដែលចូលរួមក្នុងពិធីហ្នឹង បើផ្នែកខ្ញុំខាងជយភណ្ឌ ប៉ុន្តែដឹងមុខព្រូញៗគេផ្សេងៗមានទៅទៀតក៏អត់ ខ្ញុំអត់ដឹងដែរ។

**ស៖** បើសិនជាខ្ញុំមិនច្រឡំទេ គឺថាអត់មានការប្រកាសណាមួយអំពីអង្គភាពផ្សេងៗដែលមកចូលរួមក្នុងកិច្ចប្រជុំហ្នឹងទេ អ៊ីចឹងមែនទេ?

**ឆ៖** ចាស អត់មានប្រកាសផង។

**ស៖** តាមចម្លើយរបស់លោកស្រីកាលពីព្រឹកមិញនេះ ខ្ញុំយល់ឃើញថានីរសារទាំងពីរនាក់ហ្នឹងបាននិយាយអំពីប្រវត្តិរូបរបស់ ហ៊ូ យន់ និង ហ៊ូ នឹម។ អ៊ីចឹងនៅពេលដែលលោកស្រីនិយាយថាគាត់ហ្នឹងបាននិយាយពីប្រវត្តិរូបរបស់ ហ៊ូ នឹម, ហ៊ូ យន់ ហ្នឹង លោកស្រីអាចជម្រាបជូនតុលាការបានដែរឬទេ ថាកាលដែលគាត់និយាយពីប្រវត្តិរូបហ្នឹង គាត់និយាយយ៉ាងម៉េចខ្លះ?

**ឆ៖** ចាស ដល់ពេលដែលខ្ញុំនៅស្តាប់បានខ្លះហ្នឹង គ្រាន់តែថានីរសារមួយហ្នឹងមិនទាន់ចប់ផង

គ្រាន់តែថា គាត់ធ្វើបាបស្អីៗខ្លះទេនិយាយហ្នឹង គ្រាន់ថា គ្រាន់សួរថាគាត់ធ្វើបាប តែប៉ុណ្ណឹង ខ្ញុំស្តាប់បានហ្នឹង។ រួចគេនិយាយច្រើនទៀត ប៉ុន្តែខ្ញុំវាភ្លេច ខ្ញុំចាំមិនបានទេ និយាយតែរឿងធ្វើបាបទេ ខ្ញុំនៅចាំបានតែប៉ុណ្ណឹង។

[១១:០៨:២១]

**ស៖** ឥឡូវខ្ញុំសូមចូលនិយាយអំពីលើកទី២ ដែលលោកស្រីថាបានឃើញលោក ខៀវ សំផន នៅវត្តឧណ្ណាលោមម្តង។ សំណួរដូចដែលសំណួរខ្ញុំសួរពីមុនដែរ អ៊ីចឹងគឺខ្ញុំសួរលោកស្រីថាតើអ្នកណាជាអ្នកអញ្ជើញលោកស្រីឱ្យចូលរួមក្នុងកិច្ចប្រជុំលើកទី២ហ្នឹង?

**ឆ៖** នៅតាមប្រធានមុខព្រួញខ្ញុំហ្នឹងណា ឈ្មោះ បងផាន់ ហ្នឹងគាត់ប្រធានមុខព្រួញខ្ញុំដែលនៅខ្ញុំនៅផ្សារទួលទំពូងហ្នឹង គាត់ឱ្យមក ប៉ុន្តែមកហ្នឹង ក៏មកតាមគ្រប់មុខព្រួញទាំងអស់។ គ្រប់មុខព្រួញទាំងអស់ ពេញមួយសាលាហ្នឹង មួយសាលានៅវត្តឧណ្ណាលោមហ្នឹង គ្នារាប់រយនាក់។

**ស៖** ហើយលើកហ្នឹងគឺថា អ្នកដែលធ្វើការនៅក្នុងអង្គភាពរបស់លោកស្រីទាំងអស់ហ្នឹង គឺទៅចូលរួមប្រជុំទាំងអស់គ្នា ឬក៏មានតែលោកស្រីម្នាក់ទេដែលទៅចូលរួមប្រជុំហ្នឹង?

**ឆ៖** ពេលទៅប្រជុំហ្នឹងមួយមុខព្រួញៗមានប្អូនដប់នាក់ ប្អូនដប់នាក់មួយមុខព្រួញនោះ ទៅគ្រប់មុខព្រួញទាំងអស់ ហើយមុខព្រួញច្រើនដែរ។ ទៅពេញមួយសាលាដែរនុ៎ង។

**ស៖** តើលោកស្រីអាចពិពណ៌នាអំពីវត្តហ្នឹងបានទេ <លោកស្រីថានៅក្នុងវត្ត> តើគេរៀបចំយ៉ាងម៉េចដែរនៅពេលដែលគេប្រជុំហ្នឹង?

**ឆ៖** ប្រជុំហ្នឹងនៅក្នុងវិហារ ប៉ុន្តែនៅអាជាន់ក្រោម វិហារនៅពីលើ ប្រជុំនៅជាន់ក្រោម។ ហើយការៀបចំហ្នឹង គឺសុទ្ធតែមានតុ មានអីអង្គុយឡើងពេញមួយក្នុងសាលាហ្នឹង ក្នុងក្រោមវិហារហ្នឹង ប៉ុន្តែវិហារមានពីរជាន់។ ប្រជុំជាន់ក្រោម។

[១១:១០:២៩]

**ស៖** ហើយកាលនោះ មានវាគ្មិនប៉ុន្មាននាក់ដែរ? បើតាមខ្ញុំស្តាប់បាននោះគឺថាកិច្ចប្រជុំនោះបានប្រព្រឹត្តទៅពេញ១ថ្ងៃតែម្តង អ៊ីចឹងខ្ញុំចង់សួរលោកស្រីថា មានវាគ្មិនប៉ុន្មាននាក់ដែរ ដែលឡើងនិយាយ?

**ឆ៖** ខ្ញុំអត់ដឹងដែរ រឿងវាគ្មិនម៉េច អត់ស្គាល់ផង អត់ដែលដឹងផង។ ប៉ុន្តែគ្រាន់ថា គាត់ប្រជុំហ្នឹងប្រជុំ គាត់និយាយខ្លះអ៊ីចឹងទៅ មានដែលអ្នកនៅ ទៅរៀនហ្នឹង និយាយរយៈកាលនុ៎ង គាត់ច្រើនៗមានអ្នកបកប្រែទៀត ព្រោះទៅប្រជុំ ទៅរៀនហ្នឹងមានជនជាតិភាគតិចច្រើនដែរ។ ដល់ពេលគាត់

និយាយខ្លះអ៊ីចឹងទៅ មានអ្នកបកប្រែទៅជនជាតិនុ៎ងផង ក្នុងរយៈ១ថ្ងៃហ្នឹង។ គាត់និយាយបានខ្លះអ៊ីចឹង ជនជាតិគេបកប្រែខ្លះ បានមិនបាន ដូចគ្នានបានពីណានិយាយផង ឃើញតែគាត់និយាយខ្លះ ហើយនិង ពួកបកប្រែខ្លះហ្នឹង។

**ស៖** លោកស្រីនិយាយថា មានវត្តមានអ្នកផ្សេងទៀតដែរនុ៎ង។ អ៊ីចឹងខ្ញុំសួរលោកស្រីថា តើលោកមានចាំថា អ្នកផ្សេងទៀតហ្នឹង គេមានបានណែនាំឈ្មោះ ឬក៏មុខងារអីពួកអ្នកផ្សេងទៀតហ្នឹងឲ្យស្គាល់ទេ ឲ្យគេដឹងទេ? ហើយបើមិនចាំឈ្មោះទេ តើមាននៅចាំមុខងារពួកគាត់ទេ?

**ឆ៖** អ្នកចូលរួមមានអ្នកណាផ្សេង មានតែអ្នកតាមប្រធាន១មុខព្រួញហ្នឹង ហើយជាមួយគាត់ហ្នឹង អត់មានអ្នកណាអមទៀតផង។

**ស៖** ហើយកាលនុ៎ង ផាន់ ហ្នឹងគាត់មានវត្តមានទេ?

**ឆ៖** គាត់មាន បងផាន់ ក៏មាន អ៊ំមុញ ហ្នឹងក៏គាត់មានវត្តមាននៅកន្លែងនុ៎ងដែរ ប៉ុន្តែគាត់អត់មាននិយាយអីទេ គ្រាន់តែគាត់ទៅអង្គុយទេ។

[១១:១២:៣៨]

**ស៖** ឥឡូវនេះខ្ញុំសូមចូលទៅនិយាយពីចំណុចទី៣ ដែលលោកស្រីបានលើកឡើងជាមួយនឹងសហព្រះរាជអាជ្ញា។ លោកស្រីបាននិយាយអំពីការដែលលោកស្រីទៅដល់វត្តជ្រៃដុំ នៅចោមចៅ។ ខ្ញុំអស់សួរយល់ថា អំពីការដែលលោកស្រីចូលទៅវត្តស្រីដុំនុ៎ងណ៎ា -- ជ័យឧត្តម។ កាលពីម្សិលមិញនៅម៉ោង ក្រោយម៉ោង<១៥:៥១:៤១>នាទីបន្តិចនោះ លោកស្រីបាននិយាយថា លោកស្រីបានរត់ចេញពីសំរោងទងទៅវត្តជ័យឧត្តម។ តើខ្ញុំត្រូវយល់យ៉ាងម៉េចដែរ លោកស្រីរត់នេះ លួចរត់នេះ តើមានន័យយ៉ាងម៉េចលោកស្រីអាចបញ្ជាក់បានទេ?

**ឆ៖** ចាស ដូចខ្ញុំបញ្ជាក់នូវរឿងដែលខ្ញុំរត់ពីវត្ត -- ពីស្រុកសំរោងទងមក គឺពួកខ្ញុំពីដើមនៅវត្តស្លែង។ ដល់នៅវត្តស្លែងគេចាប់មេដឹកនាំទៅ ចាប់មេដឹកនាំបាត់ទៅ គេដកពួកខ្ញុំហ្នឹងទាំងអស់គ្នាក្នុងមួយកន្លែងវត្តស្លែងហ្នឹង ទៅនៅតាមសហករណ៍នៅស្រុកសំរោងទង។ ទៅនៅបានមួយរយៈ ឃើញថាពួកខ្ញុំទៅមិននៅជុំគ្នាទេ ក្នុងមួយភូមិដាក់បួនប្រាំនាក់ ដាក់បួនប្រាំនាក់ បួនប្រាំនាក់ ប្រាំមួយនាក់អីអ៊ីចឹងទេ។ ហើយដល់ទៅនៅកន្លែងនុ៎ងថ្ងៃមួយ ឃើញបាត់គ្នាខ្ញុំនៅភូមិមួយ ប៉ុន្តែភូមិនៅឆ្ងាយពីខ្ញុំដែរ។ គេយកទៅថាយប់ឡើងគេហៅទៅ ក៏ទៅបាត់ទៅ។ ថ្ងៃក្រោយមកឮថា បាត់មួយទៀតនៅភូមិផ្សេងពីខ្ញុំហ្នឹងទៀត បាត់មួយទៀត។ ដល់មើលទៅសភាពការណ៍មិនស្រួល ខ្លាចពួកសហករណ៍យកសម្លាប់ចោល ពួកខ្ញុំក៏

សម្រេចចិត្តថា រត់មកវត្តជ័យឧត្តម។ មកវត្តជ័យឧត្តមហ្នឹង ខ្ញុំសូមនិយាយថា ខ្ញុំមិនប្រាកដក្នុងខ្លួន ដូចខ្ញុំបាននិយាយប្រាប់ពីម្សិលមិញអ៊ីចឹងថា ខ្ញុំឮតែគេថា វត្តជ័យឧត្តមហ្នឹងក្រោមការដឹកនាំរបស់លោក ខៀវ សំផន ប៉ុន្តែដល់ពេលខ្ញុំរត់មកពីស្រុកសំរោងទងមកនៅហ្នឹង ខ្ញុំមិនដែលឃើញគាត់ទេ។ ខ្ញុំមកនៅហ្នឹងបានប្រហែលកន្លះខែទេ ប៉ុន្តែខ្ញុំមិនដែលឃើញគាត់ទេ។ ហ្នឹងខ្ញុំគ្រាន់តែឮគេនិយាយទេ ក្រោមការគ្រប់គ្រងរបស់លោក តាខៀវ សំផន អ៊ីចឹង។ ខ្ញុំគ្រាន់ឮគេនិយាយ ក៏ខ្ញុំរត់មកនៅហ្នឹងបានប្រហែលកន្លះខែ ក៏គេបញ្ជូនខ្ញុំទៅនៅពេជ្រនិលទៅ។ ពួកៗរត់មកទាំងអស់ហ្នឹង គេបញ្ជូនទៅពេជ្រនិលទាំងអស់។ រត់មកគ្នាជាង១០នាក់។

**ស៖** សំណួរទី១ របស់ខ្ញុំ គឺចង់ដឹងថា តើនៅវត្តជ័យឧត្តមហ្នឹង គេឲ្យលោកស្រីធ្វើការអីដែរ?

**ឆ៖** នៅវត្តជ័យឧត្តមមួយចំនួនគេឲ្យទៅដកស្ទូង មួយចំនួនទៀតឲ្យដាំបន្លែសម្រាប់ផ្គត់ផ្គង់នៅកន្លែងអង្គភាពហ្នឹង។ ចំពោះខ្ញុំផ្ទាល់ គេឲ្យនៅដាំបន្លែនៅនឹងមុខវត្តជ័យឧត្តមហ្នឹង។

[១១:១៦:១០]

**ស៖** តើអ្នកណាជាអ្នកប្រាប់លោកស្រីថា នៅវត្តហ្នឹងគេដាំបន្លែ ហើយស្ថិតនៅក្រោមការគ្រប់គ្រងរបស់ ខៀវ សំផន អ្នកណាអ្នកប្រាប់?

**ឆ៖** អ្នកដែលកាន់កាប់កន្លែងហ្នឹង គឺឈ្មោះបង អីទេអំមិញទេ ភ្លេចឈ្មោះគាត់ហើយ គាត់កំបុតដៃមួយចំហៀង ភ្លេចទាំងឈ្មោះគាត់ទៀតនេះ។ គាត់ហ្នឹងកំបុតដៃមួយចំហៀងត្រឹមលើកែងដៃនេះ រួចទៅគាត់នៅគ្រប់គ្រងកន្លែងហ្នឹង។ ប៉ុន្តែបានពួកហ្នឹង បញ្ឆោះឲ្យខ្ញុំរត់ បានខ្ញុំហ៊ានរត់មក បើគេមិនបញ្ឆោះ ក៏ខ្ញុំមិនហ៊ានរត់ដែរ។ ប៉ុន្តែថ្ងៃចូលឆ្នាំ ខ្ញុំនាំគ្នាមកលេងនៅវត្តហ្នឹង ដល់លេងវត្តហ្នឹងទៅ បានជួបពួកមិត្តនៅកន្លែងហ្នឹងទៅ គេប្រាប់ថាបើពិបាកពេក ឲ្យរត់មកណេះមក។ រួចទៅ គេនិយាយប្រាប់ខ្ញុំ ដូចខ្ញុំបាននិយាយពីមុនអ៊ីចឹង។ ដល់ទៅ ទាល់ថ្ងៃចូលឆ្នាំថ្ងៃបង្ហើយ គឺខ្ញុំនាំគ្នារត់មែន។ ម៉ោង១២យប់ ខ្ញុំរត់កាត់តាំងពីស្រុកសំរោងទង មករហូតដល់វត្តជ័យឧត្តម។ ដល់វត្តជ័យឧត្តម ជិតភ្លឺ។

**ស៖** ដូច្នេះបើសិនជាខ្ញុំមិនច្រឡំទេ គឺប្រធានវត្តជ័យឧត្តមហ្នឹងហើយដែលជំរុញឲ្យលោកស្រីរត់ចេញពីកន្លែងដែលលោកស្រីធ្វើការហ្នឹង។ អ៊ីចឹងខ្ញុំសួរបញ្ជាក់ ថាតើជាប្រធានវត្តជ័យឧត្តមហ្នឹងហើយដែលបញ្ឆោះឲ្យរត់មកនៅហ្នឹង ឬក៏អ្នកផ្សេងទៀត?

[១១:១៧:៤៥]

**ឆ៖** ប្រធានហ្នឹងតែម្តងហ្នឹង គាត់ឲ្យខ្ញុំរត់មក គាត់បញ្ឆោះឲ្យខ្ញុំរត់មក។ រហូតដល់ពេលខ្ញុំរត់មក

ដល់យប់ហ្នឹង ព្រលឹមឡើងមាននីរសារពីរនាក់មកតាមទៀត។ មកតាម មកសួរប្រធានហ្នឹងថា ឃើញមីងៗរត់មកប្អូនប្រាំនាក់ ប្អូនដប់នាក់ដែរ? រួចទៅប្រធានហ្នឹង គាត់ថារួចចុះបើឃើញ អ្អែងយកធ្វើម៉េចយកទៅរួច? គាត់និយាយលេងអ៊ីចឹងទៀត។ រួចទៅខ្ញុំនោះភ័យខុកខាក់ៗហើយ។ ទៅថា បើឃើញ អ៊ំថាឲ្យទៅវិញ មកប្រាប់អ៊ីចឹង។ អាហ្នឹងខ្ញុំឃើញផ្ទាល់នឹងភ្នែកខ្ញុំតែម្តង ប៉ុន្តែខ្ញុំនៅសំងំក្នុងផ្ទះដែលប្រធាននៅហ្នឹង ខ្ញុំនៅអង្គុយសំងំនៅនុ៎ង។ រួចគាត់ឆ្លើយថាអត់ឃើញទេ។ ដំបូងគាត់និយាយលេង ក្រោយមកគាត់ប្រាប់ថាអត់ឃើញមកទេ។

**ស៖** នៅ<ពេលលោកស្រីពិភាក្សាគ្នា>មុនពេលដែលលួចរត់ហ្នឹង គឺថានៅថ្ងៃចូលឆ្នាំនៅវត្តហ្នឹង ហើយពេលនោះមេហ្នឹងប្រាប់បញ្ឆេះឲ្យរត់នេះ តើប្រធានវត្តជ័យឧត្តមហ្នឹងមានប្រាប់ ពន្យល់ប្រាប់លោកស្រីថាមករវត្តជ័យឧត្តមហ្នឹងមក ព្រោះអីនៅហ្នឹងជីវភាពវាគ្រាន់បើជាង ឬក៏យ៉ាងម៉េច?

**ឆ៖** គាត់ប្រាប់ដែរ គាត់ថាបើមកណេះមក គ្មានការកាប់សម្លាប់អីទេ កុំភ័យ ឲ្យតែចូលមកដល់ហើយ គេទទួលហើយ។ រួចកុំខ្លាចថា គេយកទៅសម្លាប់ចោលទៅអី អត់អីទេ គេប្រាប់អ៊ីចឹង បានប៉ានមកហ្នឹង។

**ស៖** ឥឡូវខ្ញុំសូមត្រឡប់មកនិយាយអំពីឯកសារ ដែលយើងមាននៅក្នុងដៃ គឺជាពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់លោកស្រី គឺទម្រង់បែបបទទី១ ចុះថ្ងៃទី១៤ តុលា ឆ្នាំ២០០៩ គឺឯកសារ <E319/45.4.8>។ ERN ជាភាសាខ្មែរគឺ 01049379, ERN ជាភាសាអង់គ្លេសគឺ 01139644 គឺជាឯកសារដែលចុះនៅថ្ងៃទី១៤ ខែតុលា ឆ្នាំ២០០៩។ អ៊ីចឹងសំណួរទី១របស់ខ្ញុំដូចតទៅនេះ តើលោកស្រីនៅចាំថា កាលដែលឆ្នាំ២០០៩នោះ គឺលោកស្រីបំពេញសំណុំបែបបទហ្នឹងដើម្បីចូលរួមជាភាគីនៅក្នុងការកាត់សេចក្តី? លោកស្រីមានចាំថា ខ្លួនឯងបានបំពេញសំណុំបែបបទហ្នឹងទេ?

**ឆ៖** ខ្ញុំបានបំពេញដែរ ប៉ុន្តែមិនដឹងធ្វើថ្ងៃប៉ុន្មានខែប៉ុន្មាន ខ្ញុំអត់ដឹង ប៉ុន្តែបានធ្វើ។

[១១:២០:៥០]

**ស៖** យើងក៏មានទម្រង់បែបបទមួយទៀត គឺជាទម្រង់បែបបទព័ត៌មានបន្ថែមដែលចុះនៅថ្ងៃទី២៩ មិថុនា ២០១៣ គឺឯកសារ E319/45.4.8។ ERN ជាភាសាខ្មែរគឺ 01049384, ERN ជាភាសាអង់គ្លេសគឺ 01139647 មិនមាន ERN ជាភាសាបារាំងទេ។ អ៊ីចឹងនៅក្នុងឯកសារហ្នឹង លោកស្រីបានផ្តល់ព័ត៌មានបន្ថែមអំពីរឿងរ៉ាវរបស់លោកស្រី គឺថ្ងៃទី២៩ មិថុនា ឆ្នាំ២០១៣។ តើលោកស្រីនៅចាំថាកាលពីឆ្នាំ២០១៣ហ្នឹង លោកស្រីបានផ្តល់ព័ត៌មានបន្ថែមមកតុលាការយើងនេះដែរឬទេ?

**ឆ៖** ខ្ញុំភ្លេចហើយ មិនដឹងផ្ដល់ មិនផ្ដល់ផង ខ្ញុំអត់ដឹងផងនេះ ដូចវាក់ វាភ្លេច អត់ចាំផង។

**ស៖** *(គ្មានការបកប្រែ)*

**លោក ពេជ អង្គ៖**

សុំទោសលោកប្រធាន សុំឲ្យលោកស្រីមេធាវីផ្ដល់លេខឯកសារសាជាថ្មី ខ្ញុំតាមអត់ទាន់។ សូមអរគុណ។

[១១:២២:៣២]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកស្រីមេធាវីផ្ដល់លេខឯកសារសាជាថ្មី។

**សួរដោយកញ្ញា អង់តា ហ្គីសសេ៖**

**ស៖** អត់បញ្ហាអីទេ។ <បើ>ខ្ញុំ<មានការយល់>ច្រឡំ ជាភាសាខ្មែរគឺ 01049384, ជាភាសាអង់គ្លេសគឺ <01139647>។ ខ្ញុំសុំបញ្ជាក់ថា <ហត្ថលេខារបស់>ដើមបណ្ដឹងរដ្ឋប្បវេណីនេះមាននៅលេខ ERN ជាភាសាខ្មែរហ្នឹងគឺបញ្ចប់នៅលេខ 85។ <>ព័ត៌មានបន្ថែម<នេះត្រូវបានផ្ដល់>នៅឆ្នាំ២០១៣។ ហើយយើងមានទម្រង់បែបបទព័ត៌មានបន្ថែមមួយទៀត គឺនៅថ្ងៃទី២៨ ឧសភា ឆ្នាំ២០១៤គឺឯកសារ E3/5010a។ សំណួរទី១របស់ខ្ញុំ គឺចង់ដឹងថា <នៅពេលដែល>លោកស្រីបានផ្ដល់ព័ត៌មាន <បឋមនៅ>ឆ្នាំ២០០៩ <និង>ព័ត៌មានបន្ថែមនៅឆ្នាំ២០១៣ម្ដងទៀត<> ហេតុអ្វីបានជាលោកស្រី <ទើបតែ>និយាយអំពីលោក ខៀវ សំផន <ជាលើកទី១>នៅខែឧសភា ឆ្នាំ២០១៤នេះ<>?

**លោកស្រី ជា ឌៀប៖**

**ឆ៖** ខ្ញុំអត់ដឹងដែររឿងព័ត៌មាន រឿងផ្ដល់មក ខ្ញុំអត់ដឹងនេះ។ មិនដឹងប៉ុន្មានដង ប៉ុន្មានដង ខ្ញុំអត់ដែលដឹងផង។ ប៉ុន្តែក្រែងមុនខ្ញុំធ្វើមិនអស់ ម៉េចមិនដឹង ហើយក្រោយថែមទៀតម៉េចមិនដឹង ខ្ញុំអត់បានដឹង ខ្ញុំភ្លេចអស់ហើយ។

**ស៖** ចំពោះលោកស្រីហ្នឹង កាលសម័យនោះ ពេលលោកស្រីជួបអ្នកដឹកនាំដូចជា ខៀវ សំផន អីជាដើមនេះ។ តើជារឿងដែលកើតឡើងញឹកញាប់ដែរឬទេ ឬក៏កម្រនឹងជួបថ្នាក់ដឹកនាំណាស់កាលសម័យនោះ?

[១១:២៥:១១]

**ឆ៖** កម្រជួបអ្នកដឹកនាំណាណាស់សម័យនុំង មានអ្នកដឹកនាំណាមកសួរសុខទុក្ខឯណាដើរចុះ

ដើរឡើង គឺគ្មានទេ។ ទាល់តែមានរវល់អី អាហ្នឹងបានៗឃើញតែម្តង។

**ស៖** អ៊ីចឹងសំណួររបស់ខ្ញុំនេះ គឺវាមានសារៈសំខាន់ថែមទៀត ក្នុងស្ថានភាពបែបនេះ។ អ៊ីចឹង ហេតុអ្វីបានជាលោកស្រីមិនបាននិយាយអំពីការជំនួបរបស់លោកស្រីជាមួយ លោក ខៀវ សំផន នេះ ដែលលោកស្រីបាននិយាយថា គាត់<បានលើកទឹកចិត្ត>ឲ្យស្ត្រី<អាយុ>១៩<ឆ្នាំ> ហើយលើសពីហ្នឹង ផងឲ្យរៀបការ? <ហេតុអ្វីបានជា>លោកស្រី<មិនបាន>និយាយ<យោងទៅដល់បញ្ហានេះ នៅពេល ដែលលោកស្រីនិយាយ>អំពីការ<>រៀបការ<របស់លោកស្រី នៅក្នុងចម្លើយដំបូងដែលធ្វើ>នៅ<មុន> ឆ្នាំ២០១៤<>?

**ឆ៖** ខ្ញុំអត់ដឹងដែរ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវីដើមបណ្តឹងរដ្ឋប្បវេណី!

[១១:២៦:២៩]

**លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

សូមអរគុណ។ <ខ្ញុំសោកស្តាយ>ដែលបានកាត់ផ្តាច់សហភាតារបស់ខ្ញុំ។ គ្រាន់តែសូមបំភ្លឺទេ។ ព្រោះថានៅក្នុងឯកសារនេះពិបាកនឹងរកឃើញ គឺថាឯកសារ E319/45.4.8នេះ ដែលជាព័ត៌មាន បន្ថែមចុះខែមិថុនា ឆ្នាំ២០១៣ ដែលមេធាវីបានលើកឡើងនេះ។ <តាមពិត>គឺជាឯកសារដែលបញ្ជូន មកពីសំណុំរឿងផ្សេងទេ គឺសំណុំរឿង<០០៤> <ហើយកូនក្តីរបស់គាត់មិនជាប់ពាក់ព័ន្ធនឹងការស៊ើប អង្កេតនេះទេ ប៉ុន្តែនេះគឺជាឯកសារបន្តទៀត ហើយឯកសារទាំងអស់មិនមែនសុទ្ធតែចេញមកពី> សំណុំរឿង<នោះ>ទេ។ <>ឯកសារមួយចំនួននោះ<ត្រូវបានបង្ហាញដោយការិយាល័យសហព្រះរាជ អាជ្ញា ហើយឯកសារទាំងនោះ>ចេញពីសំណុំរឿង០០៤ <ដែល>ជនសង្ស័យ<កំពុងត្រូវបានស៊ើប អង្កេតក្នុងសំណុំរឿងផ្សេង។ ខ្ញុំគ្រាន់តែចង់ជូនដំណឹងដល់អង្គជំនុំជម្រះអំពីលំដាប់លំដោយ ដែលឯក សារផ្សេងទៀតត្រូវបានផ្តល់ឲ្យ។ យើងមានសន្លឹកព័ត៌មានជនរងគ្រោះ ដូច្នេះការដាក់ពាក្យសុំធ្វើជាដើម បណ្តឹងរដ្ឋប្បវេណីសម្រាប់វគ្គសវនាការលើកទី២ ហើយបន្ទាប់មកយើងមានឯកសារទី២ មកពី>ឆ្នាំ ២០១៣នេះ <ដែលជាព័ត៌មានបន្ថែម> ដែលបញ្ជូនមកដោយព្រះរាជអាជ្ញាចេញពីសំណុំរឿង០០៤។ ហើយបន្ទាប់មកទៀតមានព័ត៌មានបន្ថែមមួយទៀត ដែលចុះឆ្នាំ២០១៤ហ្នឹង គឺមាននៅក្នុងសំណុំរឿង ០០២ស្រាប់ហើយ។

**កញ្ញា អង់តា ហ្គីសសេ៖**

គេប្រាប់ខ្ញុំថាឯកសារ<ឯកសារទី២ គឺមានលេខE3ដាក់លាក់ ដែលបានផ្តល់ឲ្យដោយអង្គជំនុំជម្រះ គឺឯកសារ> E3/5010bនេះ <ដើម្បីជាប្រតិចារឹក>។

[១១:២៨:២០]

**សួរដោយកញ្ញា អង់តា ហ្គីសសេ៖**

**ស៖** អ៊ីចឹងខ្ញុំចង់សួរលោកស្រីថា <ក្នុងផ្នែកនៃព័ត៌មានបន្ថែមដែលលោកស្រីបានផ្តល់ជូន ហើយជាពិសេស ទម្រង់បែបបទព័ត៌មានបឋមដែលលោកស្រីបានផ្តល់ឲ្យនោះ> ហេតុអ្វី<បានជាលោកស្រីមិន<និយាយអំពីព្រឹត្តិការណ៍>កម្រ<នេះ ដោយសារតែលោកស្រីនិយាយថា លោកស្រីមិនបាន>ជួប<មេដឹកនាំជាទៀងទាត់>នោះ? ចុះហេតុអី<បានជាទើបតែនៅខែឧសភា ឆ្នាំ>២០១៤នេះ<លោកស្រីនិយាយអំពី<កិច្ចប្រជុំនោះជាលើកដំបូង>?

**លោកស្រី ជា ឌៀប៖**

**ឆ៖** ខ្ញុំមិនដឹងធ្វើម៉េចផង ខ្ញុំអត់ដឹងដែរ។

**កញ្ញា អង់តា ហ្គីសសេ៖**

លោកប្រធាន បើតាមការគណនាពេលវេលារបស់ខ្ញុំ ព្រោះថាឃើញចៅក្រម ឡាវែន៍ គាត់បានសួរសំណួរផងដែរ ហើយចៅក្រម ហ្វេនស៍ ក៏បានសួរសំណួរដែរ ខ្ញុំឃើញថាខ្ញុំនៅសល់ពេលវេលាបន្តិចបន្តួចដែរ ប៉ុន្មាននាទីដែរ។ អ៊ីចឹងតើលោកប្រធានអនុញ្ញាតឲ្យខ្ញុំសួរក្រោយពេលអាហារថ្ងៃត្រង់ហើយទេ លោកប្រធាន បន្តសួរបន្តិចទៀត?

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

តើលោកស្រីថាពីរបីនាទីហ្នឹង តើប៉ុន្មានឲ្យច្បាស់ទៅ?

**កញ្ញា អង់តា ហ្គីសសេ៖**

បើតាមការគណនារបស់ខ្ញុំគឺថា ខ្ញុំនៅសល់ពេលវេលាយ៉ាងហោចក៏១៥នាទីទៀតដែរ លោកស្រីចៅក្រម។

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោកមេធាវីបន្តសំណួរដល់បញ្ចប់!

[១១:២៩:៥៨]

**សួរដោយកញ្ញា អង់តា ហ្គីសសេ៖**

**ស៖** ដូច្នេះលោកស្រីបានឆ្លើយថា លោកស្រីមិនដឹងទេ។ ឥឡូវចំណុចមួយទៀតដែលខ្ញុំចង់និយាយជាមួយលោកស្រី។ លោកស្រីបាននិយាយជាលោកដំបូងនៅចំពោះមុខអង្គជំនុំជម្រះថា លោកស្រីបានជួប អៀង សារី ក៏ដូចជា ប៉ុល ពត ផងដែរ បន្ថែមពីលើលោក ខៀវ សំផន ដែលលោកបានស្រីបានបញ្ជាក់នៅក្នុងឯកសាររបស់លោកស្រី នៅខែឧសភា ឆ្នាំ២០១៤ <ជាលើកដំបូងនោះ>។ អ៊ីចឹងសំណួរខ្ញុំនៅតែដដែល ហេតុអីបានជាលោកស្រីទើបតែនិយាយ<អំពីការប្រជុំទាំងនេះជាលើកទី១នៅថ្ងៃនេះក្នុងឆ្នាំ២០១៦>នៅសវនាការនេះនៅពេលនេះ? <ដោយសារលោកស្រីនិយាយថា វាជាព្រឹត្តិការណ៍កម្រ ហើយ>ហេតុអីបានជា<លោកស្រីមិនបញ្ជាក់>នៅក្នុង<>ទម្រង់បែបបទព័ត៌មានជនរងគ្រោះ<បឋមរបស់>លោកស្រី <ដែល>លោកស្រី<បានផ្ដល់ឲ្យនោះ>?

**លោកស្រី ជា ឌៀប៖**

**ឆ៖** ខ្ញុំធ្វើ -- ខ្ញុំនិយាយដែរ ប៉ុន្តែមិនដឹងធ្វើហ្នឹង មិនដឹងថ្ងៃប៉ុន្មាន ខែប៉ុន្មានមក ខ្ញុំក៏អត់បានដឹងដឹងបានដាក់ មិនបានដាក់ ខ្ញុំអត់ដែលបានដឹងដែរ។ ប៉ុន្តែខ្ញុំចាំបាន តាមដែលខ្ញុំនិយាយថ្ងៃហ្នឹង គឺខ្ញុំចាំៗបានដោយខ្លួនខ្ញុំផ្ទាល់ ក៏ចាំបានដែរ។

[១១:៣១:៣៦]

**ស៖** នៅក្នុងទម្រង់បែបបទទី១ ដែលខ្ញុំបានលើកឡើងអម្បាញ់មិញនេះគឺERN ជាភាសាខ្មែរ 010 49379, ជាភាសាអង់គ្លេស 01139644 និងទំព័របន្ទាប់ទៅទៀត គឺឯកសារដដែល E319/45.4.8។ លោកស្រីមិនបាននិយាយអំពី ខៀវ សំផន, អៀង សារី ឬក៏ ប៉ុល ពត ទេ ហើយលោកស្រីក៏មិនបាននិយាយអំពីការដែលគេសួរចម្លើយលោកស្រី<នៅក្នុងបន្ទប់>ដែលមានអាវុធ ហើយនិងមានសម្ភារៈផ្សេងៗ<ផងដែរ ហើយ>ដែល<ក្នុងអំឡុងពេលនោះ>គេសួរលោកស្រី <អំពីការជាប់ពាក់ព័ន្ធរបស់លោកស្រី។> លោកស្រីមិនបាននិយាយ<អំពីបញ្ហានេះទាល់តែសោះ>។ អ៊ីចឹងខ្ញុំចង់សួរបញ្ជាក់ឲ្យច្បាស់ថា ហេតុអ្វីបានជានៅក្នុងឯកសារដំបូងរបស់លោកស្រីហ្នឹង នៅពេលដែលលោកស្រីសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីហ្នឹង ម៉េចក៏លោកស្រីមិនរៀបរាប់រឿងទាំងអស់ហ្នឹង នៅក្នុងពាក្យសុំហ្នឹង?

**ប្រធានអង្គជំនុំ៖**

ដើមបណ្ដឹងរដ្ឋប្បវេណី កុំទាន់អាលឆ្លើយ!

សូមអញ្ជើញលោកស្រីមេធាវីនាំមុខដើមបណ្ដឹងរដ្ឋប្បវេណី!

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

[១១:៣៣:១១]

**លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

សូមអរគុណលោកប្រធាន។ ខ្ញុំមិនមែនជំទាស់ទេ លោកប្រធាន ខ្ញុំដឹងថា ដើមបណ្ដឹងរដ្ឋប្បវេណី អាចឆ្លើយបានដោយខ្លួនឯង ក៏ប៉ុន្តែគ្រាន់តែជាការជម្រាបព័ត៌មានជូនសាធារណជន <ភាគី> និងអង្គជំនុំជម្រះថា ទម្រង់ព័ត៌មាននេះ ជាទូទៅ ត្រូវបានប្រមូលដោយអង្គការក្រៅរដ្ឋាភិបាល មិនមែនបុគ្គលិករបស់តុលាការ ឬក៏អ្នកស៊ើបអង្កេតរបស់តុលាការទេ។ ដូច្នេះតាមព័ត៌មានហ្នឹង វាប្រែប្រួលទៅតាមអង្គការផ្សេងៗ ដែលជាអ្នករៀបចំ។ ហើយខ្ញុំដឹងថា អង្គជំនុំជម្រះក៏ជ្រាបច្បាស់អំពីភាពខុសគ្នារវាងពាក្យសុំតាំងខ្លួនដើមបណ្ដឹងរដ្ឋប្បវេណីនីមួយៗហ្នឹង អាស្រ័យទៅតាមថាតើអង្គការណាជាអ្នកចុះទៅប្រមូលព័ត៌មានទាំងអស់ហ្នឹង នៅពេលដែលអង្គការទាំងអស់ហ្នឹង ចុះទៅជួបជនរងគ្រោះនោះ។ ខ្ញុំដឹងថា អង្គជំនុំជម្រះជ្រាបអំពីរឿងហ្នឹងច្បាស់ហើយ ហើយអង្គជំនុំជម្រះយល់អំពីករណីនេះ។ ហើយខ្ញុំគិតថា ដើមបណ្ដឹងរដ្ឋប្បវេណី គាត់អាចពន្យល់បានថា ហេតុអីបានជាគាត់មិននិយាយអំពីការជួបលោក ខៀវ សំផន និងអ្នកផ្សេងទៀតនៅក្នុងពាក្យសុំតាំងខ្លួនរបស់គាត់ ដែលមានការជួយជ្រោមជ្រែងពីអង្គការក្រៅរដ្ឋាភិបាលនៅឆ្នាំ២០០៩នោះ។

[១១:៣៤:៣០]

**កញ្ញា អង់តា ហ្គីសសេ៖**

ខ្ញុំស្ដាប់ឮអំពីការពន្យល់ហើយ ខ្ញុំដឹងថា មិនមែនជាលើកទី១ទេ។ <ខ្ញុំយល់ តែយ៉ាងណា រាល់ពេល>ដែលមានបញ្ហាជាមួយពាក្យសុំទាំងអស់ហ្នឹង <គឺមិនមែនបែបនេះទេ។ នេះគឺជាអ្វីដែលត្រូវបានចុះហត្ថលេខាដោយភាគីជនរងគ្រោះ។ ដូច្នេះខ្ញុំគិតថា សំណួររបស់ខ្ញុំគឺវាសមរម្យណាស់ ព្រោះរួមទាំងទម្រង់ព័ត៌មានបន្ថែមនៅខែឧសភា ឆ្នាំ២០១៤ ដែលយើងសន្និដ្ឋានថា មិនមានបញ្ហានៃការជាប់ពាក់ព័ន្ធរបស់>អង្គការក្រៅរដ្ឋាភិបាល<នោះទេ ហើយភាគីដើមបណ្ដឹងរដ្ឋប្បវេណី ត្រូវបានគេ>ជួយបំពេញព័ត៌មានបន្ថែម<> នៅខែឧសភា ឆ្នាំ២០១៤នោះ <ពេលនោះដើមបណ្ដឹងរដ្ឋប្បវេណី>មិននិយាយអំពីអៀង សារី ពី ប៉ុល ពត <នៅពេលនោះដែរទេ>។

**សួរដោយកញ្ញា អង់តា ហ្គីសសេ៖**

**ស៖** អ៊ីចឹងខ្ញុំសួរដដែល គឺថានៅក្នុងទម្រង់ព័ត៌មានបន្ថែមដំបូង ហើយនិងឯកសារនៅខែឧសភា ២០១៤នោះ ម៉េចក៏បានជាលោកស្រីមិនលើកឡើងអំពីការដែលលោកស្រីបានជួបជាមួយនឹងមេដឹកនាំ

---

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ផ្សេងទៀតនៃរបបកម្ពុជាប្រជាធិបតេយ្យនោះ?

**លោកស្រី ជា ឌៀប៖**

**ឆ៖** រឿងសំណុំបែបបទហ្នឹង ខ្ញុំជម្រាបថា ខ្ញុំច្រើនធ្វើច្រើនដងដែរ ប៉ុន្តែមិនដឹងខាងណា ខាងណាទេទៅធ្វើនោះ ខ្ញុំអត់បានដឹងទេ។ ប៉ុន្តែដឹងធ្វើហ្នឹងយ៉ាងម៉េចអីយ៉ាងម៉េច ខ្ញុំក៏ភ្លេចដែរ យូរណាស់ហើយនោះ ខ្ញុំអត់ដឹងដែរ។

[១១:៣៦:០៩]

**ស៖** មូលហេតុដែលខ្ញុំសួរសំណួរទាំងអស់នេះ លោកស្រីដើមបណ្តឹងរដ្ឋប្បវេណី ដោយសារតែនៅថ្ងៃនេះ <នៅក្នុងអង្គជំនុំជម្រះនេះ និងនៅក្នុងឆ្នាំ២០១៤ផងដែរ> លោកស្រីបានផ្តល់ព័ត៌មានបន្ថែមថ្មីច្រើន <ដូច្នេះយើងឆ្ងល់អំពីភាពត្រឹមត្រូវ ថាតើយើងអាចនិយាយថា>វាចេញពីការចងចាំរបស់លោកស្រី<ឬយ៉ាងណា>។ <ខ្ញុំនិយាយដូច្នេះព្រោះថា>ដូចជាព្រឹកមិញនេះ ពេលដែលលោកស្រីឆ្លើយទៅនឹងសំណួររបស់លោកចៅក្រម ឡាវ៉ែន៍ លោកស្រីថា ប៉ុល ពត មកលេងហ្នឹងមិនមានអង្គរក្ស មិនមានកងការពារអីទេ ក៏ប៉ុន្តែម្សិលមិញនៅម៉ោង១៥:៥៧:០១វិនាទីហ្នឹង លោកស្រីថា មិនមានអ្នកណាមកជាមួយ ប៉ុល ពត ទេ លើកលែងតែអង្គរក្សរបស់គាត់។ ដូច្នេះពេលដែលលោកស្រីជួប អៀង សារី, ខៀវ សំផន, ប៉ុល ពត...។ល។ហ្នឹង លោកស្រីមានគិតទេថា ដោយសារតែពេលវេលាហ្នឹង វាវែង វាយូរណាស់មកហើយហ្នឹង គឺលោកស្រីអាចនឹកមិនឃើញ អ៊ីចឹងហើយបានជានៅក្នុងទម្រង់ព័ត៌មានទី១របស់លោកស្រីហ្នឹង លោកស្រីមិនបាននិយាយអំពីរឿងទាំងអស់ហ្នឹង។ ក៏ប៉ុន្តែខ្ញុំគិតថាបើកាលនុ៎ង ២០០៩ហ្នឹង វាហាក់ដូចជាកៀកជាងឥឡូវឆ្ងាយណាស់ ម៉េចក៏បានជាលោកស្រីមិននឹកឃើញ ទាល់តែឥឡូវ ២០១៦ហើយ ទើបតែនឹកឃើញទៅវិញ?

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោកព្រះរាជអាជ្ញា!

**លោក វាំងសង់ វ៉ាយដ៍ ដេស្សាឯល៖**

លោកប្រធាន ខ្ញុំគិតថាសំណួរនេះជាសំណួរវែងណាស់។ ហើយ<សំណួរដើមនោះគឺវាផ្ទុយទៅនឹងអ្វីដែលសហមេធាវីជឿថា> គាត់<ប្រហែលជាបាន>សង្កេត<ចំពោះ>ទស្សនកិច្ចរបស់ ប៉ុល ពត។ គាត់គួរតែបំបែកឲ្យបានច្រើន ឲ្យខ្លីៗបន្តិចសំណួរគាត់ហ្នឹង។ គាត់គួរតែសួរថាតើមានអង្គរក្សមកជាមួយ ប៉ុល ពត ឬក៏អត់? អ៊ីចឹងគាត់ធ្វើសេចក្តីសន្និដ្ឋានវែងឆ្ងាយទៅលើការចងចាំរបស់ដើមបណ្តឹងរដ្ឋ

ប្បវេណី។ យើងដឹងថានៅក្នុងទម្រង់ព័ត៌មានរបស់គាត់ ព័ត៌មានគឺច្បាស់ហើយ។ ហើយសំណួរមួយទៀតដែលខ្ញុំគិតថាមេធាវីការពារក្ដីគួរតែសួរហ្នឹង គឺសួរ--

[១១:៣៨:៣២]

**កញ្ញា អង់តា ហ្គីសសេ៖**

លោកប្រធានសូមអភ័យទោស!

**លោក វ៉ាំងសង់ វ៉ាយឌ័ ដេស្មាឯល៖**

*(គ្មានការបកប្រែ)*

**កញ្ញា អង់តា ហ្គីសសេ៖**

*(គ្មានការបកប្រែ)*

**លោក វ៉ាំងសង់ វ៉ាយឌ័ ដេស្មាឯល៖**

អ៊ីចឹងគួរតែសួរគាត់ឲ្យច្បាស់ទៀត ថាគាត់ចេះអាន ចេះសរសេរអត់។ <នេះជាសំណួរដែលមិនបានសួរ ហើយខ្ញុំគិតថា វាមានសារៈសំខាន់>ដើម្បីយល់ថាតើ<បុគ្គលនេះ> -- <មិនបានចុះហត្ថលេខាទេ ព្រោះ>ហត្ថលេខា<នោះបានបញ្ជាក់ហើយ ប៉ុន្តែគាត់គ្រាន់តែ>ផ្ដិតមេដៃ<នៅលើនោះតែប៉ុណ្ណោះ>។ អ៊ីចឹង<ខ្ញុំគិតថា នៅពេលដំបូងនោះ វាមានប្រយោជន៍ក្នុងការដឹងថាតើបុគ្គលនេះ>ចេះអាន <>ចេះសរសេរអត់? ហើយសំណួរហ្នឹងគួរតែបំបែកឲ្យខ្លីបន្តិចៗដើម្បីឲ្យគាត់ងាយស្រួលយល់។

**កញ្ញា អង់តា ហ្គីសសេ៖**

ខ្ញុំគិតថាអន្តរាគមន៍ហ្នឹង គឺវាមិនត្រឹមត្រូវទេ។ ការធ្វើហ្នឹងមិនមែនជាការជំទាស់ទេ គាត់និយាយអ៊ីចឹង ដូចជាគាត់សន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោលអ៊ីចឹង។ ខ្ញុំជាមេធាវីការពារក្ដីលោក ខៀវ សំផន ខ្ញុំមានសិទ្ធិក្នុងការសួរដេញដោល <ព្រោះថា>ដើមបណ្ដឹងរដ្ឋប្បវេណី<>មិនដែលនិយាយ<នៅក្នុងចម្លើយរបស់គាត់នៅឆ្នាំ២០០៩>អំពី<>វត្តមាន <ឬការ>ជួប ខៀវ សំផន<ទេ ហើយនៅខែឧសភាឆ្នាំ២០១៤ ទើបតែ>ក្រោយពីមានការកំណត់វិសាលភាពនៃសំណុំរឿង០០២/០០២ហ្នឹង ទើបគាត់បានបញ្ជាក់អំពីការដែលគាត់ជួបលោក ខៀវ សំផន<>នោះ។ <វាជាការធម្មតាសម្រាប់ខ្ញុំក្នុងការសួរសំណួរ> អ៊ីចឹងមិនមែនមេធាវីដើមបណ្ដឹងរដ្ឋប្បវេណី ឬក៏សហព្រះរាជអាជ្ញាទេដែលត្រូវឆ្លើយជំនួសដើមបណ្ដឹងរដ្ឋប្បវេណីនោះ។ គាត់នៅទីនេះហើយ អ៊ីចឹងឲ្យគាត់ឆ្លើយទៅ កុំកាត់ផ្ដាច់ខ្ញុំអ៊ីចឹង។ ខ្ញុំៗសួរ<ដើមបណ្ដឹងរដ្ឋប្បវេណីនូវ>សំណួរ<ដែលជាប់ទាក់ទងគ្នា ហើយខ្ញុំមិនដឹងមូលហេតុអ្វីដែលថ្ងៃនេះ

គេ>បង្គាប់<ឲ្យ>ខ្ញុំ<សួរសំណួរផ្សេង ក្រៅពីអ្វីដែលខ្ញុំចង់សួរទៅវិញ>។

[១១:៤០:០៨]

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

ខ្ញុំមិន<គិត>ថា មានអ្នកណាម្នាក់រារាំងលោកស្រីឡើយ។ <ខ្ញុំ>គ្រាន់តែ<ឆ្ងល់>ថា <តើដើមបណ្ដឹងរដ្ឋប្បវេណីបានតាមដានអ្វីមួយដែលបានកើតឡើងក្នុងរយៈពេលប្រាំពីរប្រាំបីនាទីចុងក្រោយនេះទេ>។ ឥឡូវនេះខ្ញុំព្យាយាមបញ្ជាក់បន្តិច។ មេធាវីបានបង្ហាញថា កន្លងមកលោកស្រីអត់បាននិយាយអំពីការជួបជាមួយ ខៀវ សំផន ទេ ទើបមកឆ្នាំ២០១៤ ទើបនិយាយ។

**សួរដោយចៅក្រម ក្លូឌា ហ្វេនស៍៖**

**ស៖** ដូច្នេះខ្ញុំចង់សួរថា តើ<>លោកស្រី<ច្បាស់ទេថា>ពិត<>ជា<មានការជួបប្រជុំទាំងអស់នោះមែន>?

**លោកស្រី ជា ឌៀប៖**

**ឆ៖** ខ្ញុំពិតបានជួបគាត់មែនហ្នឹងណ៎ា។ ពីរដង ខ្ញុំជួបគាត់ទាំងពីរដង។

**ស៖** លោកស្រីអាចប្រាប់បានទេ ហេតុអ្វីបានលោកស្រីមិននិយាយអំពីការជួប ខៀវ សំផន ហ្នឹងនៅមុនឆ្នាំ២០១៤? ប្រសិនបើលោកស្រីមិនដឹងហេតុផលទេ លោកស្រីបញ្ជាក់សាមញ្ញថា អ្នីខ្ញុំមិនដឹងហេតុផលទេ ប្រសិនបើលោកស្រីមានហេតុផល សូមបញ្ជាក់ឲ្យច្បាស់។

[១១:៤១:១៥]

**ឆ៖** ខ្ញុំដឹងខាងណាទៅធ្វើផង កាលនោះខ្ញុំក៏អត់ដឹងដែរហ្នឹង មិនដឹងម៉េចអីម៉េច ខ្ញុំអត់ដឹងផង។ ខ្ញុំដឹងតែត្រឹមមេធាវីខ្ញុំនេះ ធ្វើជាមួយខ្ញុំផ្ទាល់តែម្ដង ពីមុនមកខ្ញុំអត់ដឹង។

**ស៖** មិនមែនអ្វីដែលខ្ញុំចង់សួរ<ទេ។ សំណួរខ្ញុំ>គឺថា តើលោកស្រីអាចប្រាប់បានទេ ហេតុអ្វីលោកស្រីមិនបាននិយាយអំពីការជួប ខៀវ សំផន ហ្នឹង? ហេតុអ្វីបានជាលោកស្រីមិននិយាយនៅមុនឆ្នាំ២០១៤ ទើបមកក្រោយឆ្នាំ២០១៤ លោកស្រីនិយាយអំពីការជួបជាមួយ ខៀវ សំផន នោះ?

**ឆ៖** ខ្ញុំដូចវាក់ដែរ មិនដឹងជាអ្នកណាធ្វើកាលនុ៎ង ខ្ញុំអត់ដឹងដែរ ដូចវាក់ដែរកន្លែងហ្នឹង ប៉ុន្តែបើខ្ញុំធ្វើ ខ្ញុំដាក់ហើយ ប៉ុន្តែក្រែងលោខ្ញុំ ដឹងបានធ្វើ មិនបានធ្វើ ខ្ញុំវាអត់ដែលដឹង វាភ្លេចទៅ ខ្ញុំភ្លេចទៅនេះ។ អត់ដឹងផង ដឹងតែធ្វើជាមួយមេធាវីខ្ញុំតែម្ដងហ្នឹង។ ប៉ុន្តែអ្នកទៅធ្វើខ្ញុំ ឃើញធ្វើច្រើនណាស់។

**ស៖** ខ្ញុំគ្រាន់តែសួរ តើលោកស្រីមានប្រាប់មេធាវីដែរឬទេ ថា<លោកស្រី>បានជួបជាមួយ

ខៀវ សំផន ឬមួយក៏លោកស្រី<មិនដែលលើកបញ្ហានេះមកនិយាយទេ> ទើបតែនឹកឃើញនៅក្រោយឆ្នាំ២០១៤ ដែលបានប្រាប់មេធាវី?

**ឆ៖** ខ្ញុំប្រាប់តាំងពី២០១៤ហ្នឹង បានខ្ញុំធ្វើៗជាមួយមេធាវីខ្ញុំហ្នឹង បានខ្ញុំប្រាប់គាត់ហូរហែហ្នឹងមកៗ។ បើមុនៗខ្ញុំអត់ដឹងទេ ខ្ញុំភ្លេចក៏មិនដឹង ខ្ញុំមិនដឹង មិនបានធ្វើក៏មិនដឹង ខ្ញុំធ្វើក៏មិនដឹង ខ្ញុំភ្លេចក៏មិនដឹង អាហ្នឹងខ្ញុំអត់ប៉ាានថាដែរ។

**ស៖** អ៊ីចឹងនិយាយឲ្យខ្លីទៅ លោកស្រីមិនដឹងហេតុអ្វីទើបលោកស្រីមិនបាននិយាយមុន២០១៤<ទេ តើត្រឹមត្រូវទេ?> ឬក៏ថា លោកស្រីមិនចាំថា លោកស្រីបាននិយាយ ឬក៏អត់ផង អ៊ីចឹងមែនទេ?

**ឆ៖** ចាស ខ្ញុំនិយាយអ៊ីចឹង ដឹងបាននិយាយ ដឹងបានអត់ផង។ ខ្ញុំអត់ ខ្ញុំភ្លេចអស់ហើយ។

[១១:៤៣:២៩]

**សួរដោយកញ្ញា អង់តា ហ្គីសសេះ**

**ស៖**ចំណុចចុងក្រោយចេញពីចម្លើយមុននេះរបស់លោកស្រី។ លោកស្រីបានឆ្លើយថា លោកស្រីបានបញ្ជាក់ជូនមេធាវីរបស់លោកស្រី ពេលដែលលោកស្រីធ្វើពាក្យទម្រង់បែបបទព័ត៌មានបន្ថែមនៅខែឧសភា ឆ្នាំ២០១៤នោះ ក៏ប៉ុន្តែ<ទើបតែនៅពេលនេះ នៅមុខអង្គជំនុំជម្រះនេះ គឺជាលើកទី១ ដែលលោកស្រីបាន>និយាយអំពីកិច្ចប្រជុំលើកទី២ ដែលលោកស្រី<ថា បាន>ឃើញលោក ខៀវ សំផន នៅបុរីកីឡាហ្នឹង ទើបតែនៅក្នុងសវនាការនៅពេលនេះហើយទេ។ នៅខែឧសភា ឆ្នាំ២០១៤ហ្នឹងអត់មានទេការប្រជុំទី២ ជាមួយលោក ខៀវ សំផន ហ្នឹង។ អ៊ីចឹងខ្ញុំសួរដដែលម្តងហើយម្តងទៀតថា លោកស្រីចាំច្បាស់អំពីការប្រជុំហ្នឹងទេ? <>លោកចៅក្រម ឡាវែន៍<បានសួរសំណួរនេះ ហើយយើងបានឮលោកស្រីថា លោកស្រីបានចូលរួមស្តាប់ការ>ការកាត់ទោស ហ៊ូ នឹម, ហ៊ូ យន់ នៅឆ្នាំ៧៥ ក៏ប៉ុន្តែនៅក្នុងសំណុំរឿងយើងនេះ នៅក្នុងសំណុំឯកសារ គឺឯកសារ E3/8463 មានលេខរៀងទី២ហ្នឹង គឺនៅក្នុងបញ្ជីហ្នឹងមានឈ្មោះ ហ៊ូ នឹម ដែលត្រូវបានចាប់ខ្លួនបញ្ជូនទៅស-២១ នៅថ្ងៃទី១០ ខែមេសា ឆ្នាំ១៩៧៧ ហើយយើងមានឯកសារមួយទៀតរបស់សហចៅក្រមស៊ើបអង្កេត គឺឯកសារ E3/10604 ដែល ហ៊ូ នឹម គាត់មាននៅលេខរៀងទី១៩៥៩ ជារដ្ឋមន្ត្រីក្រសួងឃោសនាការមុនពេលចាប់ខ្លួន។ ដូច្នេះការកាត់ទោស ហ៊ូ នឹម នៅ<មុនដំណាច់>ឆ្នាំ៧៥ហ្នឹង គឺមិនអាចទៅរួចទេ។ ដូច្នេះលោកស្រីដើមបណ្តឹងរដ្ឋប្បវេណី ខ្ញុំសួរដដែលថា តើលោកស្រីចាំច្បាស់ត្រឹមត្រូវទេ ឬក៏លោកស្រីមានការភ័ន្តច្រឡំពាក់ព័ន្ធនឹងហេតុការណ៍ហ្នឹង?

ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។

[១១:៤៥:៤៣]

**លោកស្រី ជា ឡៀប៖**

**ឆ៖** ខ្ញុំបាននិយាយតើ ខ្ញុំថាមិនដឹងជា៧៥ មិនដឹងជា៧៦ ព្រោះខ្ញុំអត់ដឹងខែដឹងថ្ងៃទេ។ ខ្ញុំនិយាយអ៊ីចឹង។ ខ្ញុំបានប្រាប់ហើយថា ខ្ញុំមិនដឹងខែមិនដឹងថ្ងៃណាៗទេ ប៉ុន្តែមិនដឹង៧៥, ៧៦ទេ។ គ្រាន់តែកាត់ទោសហ្នឹង កាត់ទោសឃើញតែនីរសារមកទេ មិនមែនឃើញ ហ៊ូ នឹម, ហ៊ូ យន់ ទេ។ ខ្ញុំមានតែប៉ុណ្ណឹង។

**ស៖** ខ្ញុំយល់ថា លោកស្រីមិនចាំថ្ងៃខែឆ្នាំច្បាស់ទេ។ ក៏ប៉ុន្តែលោកស្រីនិយាយច្រើនដងដែរថា ការប្រជុំហ្នឹងគឺនៅឆ្នាំ៧៥ ហើយលោកស្រីបានកំណត់ថា លោកស្រីការនៅមុនឆ្នាំ៧៥។ <ហើយលោកស្រីកំណត់ថា ការជួបនោះគឺមុនពេលលោកស្រីរៀបការ> ដូច្នេះទោះបីជាលោកស្រីមិនចាំច្បាស់ក៏ដោយ ក៏លោកស្រីឱ្យតម្រុយពេលវេលាហ្នឹងគឺហាក់វាចោទជាបញ្ហា បើធៀបទៅនឹងឯកសារដែលខ្ញុំលើកឡើងនោះ។

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

*(គ្មានការបកប្រែ)*

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកព្រះរាជអាជ្ញា!

[១១:៤៦:៥៤]

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

ខ្ញុំមិនជំទាស់ទៅនឹងសំណួរនេះទេ ក៏ប៉ុន្តែ<ខ្ញុំគិតថា ខ្ញុំឃើញ>បញ្ហា<មួយនៅក្នុង>ឯកសារទី១ដែលបានដកស្រង់។ ខ្ញុំគិតថាមិនមែនលេខរៀងទី២ទេ ឈ្មោះ ហ៊ូ នឹម នោះ។ បើឯកសារ E3/8463 បញ្ជីរបស់ស-២១មែននោះគឺ ជាបញ្ជីអ្នកទោសដែលត្រូវកម្ទេចនៅថ្ងៃទី<២៧> ឧសភា ឆ្នាំ<៧៨> គឺឈ្មោះនោះមិនមែន ហ៊ូ នឹម ទេគឺឈ្មោះ សួស <សាខិន>។ អ៊ីចឹង<ប្រហែលជាមេធាវីអាចប្រាប់យើងពីឯកសារយោងឱ្យបានត្រឹមត្រូវ ដែល>មានឈ្មោះ ហ៊ូ នឹម <>នៅ<លើ>នោះ។

**កញ្ញា អង់តា ហ្គីសសេ៖**

ឯកសារដែលខ្ញុំបោះពុម្ពចេញពី*ហ្សាយឡេប*ហ្នឹងគឺឯកសារ E3/8463, ERN ជាភាសាបារាំង 01302439, ERN ជាភាសាខ្មែរ 00015997។ <មិនមានការបកប្រែជាភាសាបារាំងទេ។> អម្បាញ់មិញខ្ញុំនិយាយថា ERN <>ជាភាសាបារាំង តាមពិតគឺជា ERN ជាភាសាអង់គ្លេសទេ។ អ៊ីចឹង<នៅ

ត្រង់លេខ២ នៅលើបញ្ជីនេះ ក្នុង>ឯកសារ<ដែល>ខ្ញុំព្រីនមក<*ហ្សាយឡេប*>ឃើញអ៊ីចឹង E3/8463 ហ្នឹង ឃើញលេខរៀងទី២ហ្នឹងឃើញមានឈ្មោះ ហ៊ូ នឹម។ ហើយខ្ញុំសូមរំឭកថានៅក្នុងឯកសារ E3/1502 ដែលជាឯកសាររបស់ ហ្វេសប៊ីស គឺគេលើកឡើងអំពីសេចក្ដីប្រកាសព័ត៌មានដែលលើកឡើងដោយ ហ៊ូ នឹម នៅថ្ងៃទី១៤ ខែមេសា ឆ្នាំ៧៦។

ដូច្នេះសំណួរខ្ញុំនៅតែដដែល គឺលោកស្រីដើមបណ្ដឹងរដ្ឋប្បវេណី គាត់កំណត់ថា ការប្រជុំនុ៎ងវាកើតឡើងគឺនៅមុនឆ្នាំ៧៥ ព្រោះថាវាកើតឡើងនៅមុនពេលដែលគាត់រៀបការ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវីដើមបណ្ដឹងរដ្ឋប្បវេណី!

[១១:៤៨:៥៧]

**លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

សូមអរគុណលោកប្រធាន។ ខ្ញុំមិនជំទាស់ទេ ខ្ញុំគ្រាន់តែធ្វើការកត់សម្គាល់ ដើម្បីឲ្យព័ត៌មានមានភាពពេលលេញ។ នៅពេលដែលចៅក្រម ឡាវ៉ែន៍ សួរដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះនៅព្រឹកមិញនេះ គាត់កំណត់ថាការប្រជុំហ្នឹងគឺចុងឆ្នាំ៧៥ <ឬ>ដើមឆ្នាំ៧៦។ ពីព្រឹកហ្នឹងគាត់និយាយថានៅដើមឆ្នាំ៧៦ ហើយក្រោយមក ពេលដែលមេធាវីការពារក្ដីបានសួរនាំចុះឡើងទៅ គាត់គិតថាការប្រជុំហ្នឹងគឺនៅឆ្នាំ៧៥។ ដូច្នេះយើងដឹងថា ដើមបណ្ដឹងរដ្ឋប្បវេណីគាត់ច្រឡំកាលបរិច្ឆេទ។ គាត់ប្រាប់លោកចៅក្រម ឡាវ៉ែន៍ ថា ចុង៧៥ ដើម៧៦ ក៏ប៉ុន្តែក្រោយមក គាត់ក៏បាន<ពង្រួញរយៈពេល ប៉ុន្តែគាត់ក៏បានបញ្ជាក់ដែរ -- ដើម្បីបញ្ជាក់ឲ្យច្បាស់ និងភាពពេញលេញនៃការពិភាក្សា គឺ>គាត់<ក៏>និយាយ<ដែរ>ថា ឆ្នាំ៧៦<អាចជាពេលដែលជួបនោះ។ នេះគឺគាត់បានឆ្លើយជូនលោកចៅក្រម ឡាវ៉ែន៍ នៅព្រឹកមិញនេះ>។

**ប្រធានអង្គជំនុំ៖**

លោកមេធាវីដល់ពេលសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះទៅ រហូតដល់ម៉ោងមួយកន្លះរសៀល សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

បង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនលោក ខៀវ សំផន ទៅកាន់បន្ទប់រង់ចាំខាងក្រោមសាលសវនាការ និងបង្គាប់ឲ្យនាំខ្លួនគាត់ត្រឡប់ចូលរួមសវនាការ ក្នុងបន្ទប់សវនាការវិញនៅរសៀលនេះ ឲ្យបានមុនម៉ោងមួយកន្លះ។

សូមអញ្ជើញសម្រាក!

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

*(សវនាការសម្រាកពីម៉ោង ១១:៥០ នាទី ដល់ម៉ោង ១៣:៣១ នាទី)*

[១៣:៣១:១៧]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយ!

អង្គជំនុំជម្រះប្រកាសបន្តសវនាការ។ មេធាវីការពារក្តីអស់ លោកអស់ម៉ោងហើយ។ លោកស្រីដើមបណ្តឹងរដ្ឋប្បវេណី លោកស្រីក្នុងឋានៈលោកស្រីជាដើមបណ្តឹងរដ្ឋប្បវេណីនៅចំពោះមុខអង្គជំនុំជម្រះនេះ លោកស្រីអាចថ្លែងរៀបរាប់ប្រាប់ដល់អង្គសវនាការស្តាប់អំពីរឿងហេតុទំនាក់ទំនងទៅនឹងបទឧក្រិដ្ឋដែលត្រូវបានចោទប្រកាន់ទៅលើជនជាប់ចោទទាំងពីររូប លោក នួន ជា និង ខៀវ សំផន ដែលបានប៉ះពាល់ចំពោះលោកស្រីក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ ពីថ្ងៃទី១៧ មេសា ឆ្នាំ១៩៧៥ រហូតដល់ថ្ងៃទី០៦ មករា ឆ្នាំ១៩៧៩ និងអំពីស្ថានភាពព្យសនកម្ម គឺការខូចខាតដែលកើតមានឡើងចំពោះលោកស្រីជាអាទិ៍ ខូចខាតខាងរាងកាយ សម្ភារៈ ឬផ្លូវចិត្ត ហើយជាផលប៉ះពាល់ ផលវិបាកដោយផ្ទាល់ពីបទឧក្រិដ្ឋ ព្យសនកម្មផ្ទាល់ខ្លួន និងបានកើតមានឡើងពិតប្រាកដរហូតមកដល់បច្ចុប្បន្ននេះ ដែលនាំលោកស្រីតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ប្តឹងទាមទារសំណង និងជាសមូហភាពពីជនជាប់ចោទ។ បើសិនជាលោកស្រីមានបំណងធ្វើដូច្នេះ គឺលោកស្រីអាចថ្លែងរៀបរាប់អំពីស្ថានភាពទុក្ខសោកវេទនា និងព្យសនកម្មចំពោះអង្គជំនុំជម្រះបាន ឬអាចតាំងសំណួរទៅជនជាប់ចោទតាមរយៈអង្គជំនុំជម្រះ។

[១៣:៣៣:០៣]

**លោកស្រី ជា ឡៀប៖**

ខ្ញុំសូមគោរពលោកប្រធាន។ ខ្ញុំសូមរ៉ាយរ៉ាប់ពីការឈឺចាប់របស់ខ្ញុំ តាំងពីឆ្នាំ ១៧ មេសា ១៩៧៥ រហូតមកដល់ឆ្នាំ១៩៧៩។ ការឈឺចាប់របស់ខ្ញុំ គឺមានច្រើនលើពេលរៀបអាពាហ៍ពិពាហ៍ ការឈឺចុកចាប់ដែលខំថែខ្លួនតាំងពីក្មេង រហូតដល់ពេលធំវ័យ។ អ៊ីចឹងហើយបានជាខ្ញុំនិយាយថា បើសិនជាខ្ញុំលាម៉ែលាឪមកធ្វើបដិវត្តន៍ដើម្បីកសាងប្រទេសជាតិ ផ្ទុយស្រឡះមកយកគ្រួសារដោយម៉ែឪមិនដឹង នេះ“ខ” ទី១។ “ខ”ទី២ ចំពោះខ្លួនខ្ញុំផ្ទាល់ ក៏ខ្ញុំឈឺចុកចាប់ចំពោះបង ប្អូនដែលបានស្លាប់ទៅជំនាន់ខ្មែរក្រហមដែរ។ ខ្ញុំសូមជម្រាបលោកប្រធានថា ខ្ញុំឈឺចាប់ណាស់ សូម្បីតែបងស្រីបង្កើតរបស់ខ្ញុំដែលធ្លាប់បីបមថ្នាក់ថ្នមបំពេ ម៉ែឪទៅស្រែបាត់ៗមានតែបងបង្កើតហ្នឹងហើយដែលនៅបម្រើប្អូន ថែទាំងប្អូន ដាំបាយ

ដាំទឹក ស្រោចទឹកប្អូន បញ្ចុកបាយប្អូនគ្រប់លើក ទៅណាមកណាយកប្អូនតាម បានជំនួសម្ដាយឪពុករបស់ខ្ញុំជាកូនអ្នកក្រីក្រ ដែលរកពេលបច្ចុប្បន្ននេះ បងស្រីខ្ញុំគាត់ត្រូវបាត់ជីវិត។ ពេលបាត់ជីវិតក៏មិនតែអ្នកឯងទេ សូមជម្រាបលោកប្រធាន ពេលមានគាត់មានគ្រួសារហើយកូនប្រាំនាក់ ពោះធំគ្រប់ខែ គេដឹកទាំងឡានយកទៅចាក់ចោលនៅស្រឡៅទង នៅព្រំប្រទល់ខេត្តកំពង់ធំលោកប្រធាន។ ខ្ញុំឈឺចុកចាប់ណាស់លោកប្រធានអើយ ខ្ញុំឆ្អែតណាស់ ខ្ញុំនិយាយដោយខ្លី។

[១៣:៣៥:០៨]

ចំណែកប្អូនប្រុសទី៣ របស់ខ្ញុំផ្ទាល់ ប្អូនប្រុសបន្ទាប់ខ្ញុំ ទៅធ្វើការនៅចម្ការកប្បាសមកដល់ជួបពួកម៉ាក់ ៗគេហៅចូលទៅកន្លែងសង្កាត់ គេកាប់ដូង កាប់ដូងឡើងទៅលើផ្ទះគេ មិនឡើងដល់ត្រឹមជណ្ដើរបត់ ឡើងទៅរហូតដល់លើផ្ទះគេ ទៅដល់ឃើញគេសីលធម៌នឹងគ្នា ចុះមកវិញរត់មកផ្ទះ មកដល់ប្រាប់ម៉ែខ្ញុំថា ម៉ែអើយកូនមុខជាស្លាប់ហើយ។ ម្ដាយខ្ញុំសួរថាម៉េចបានអ៊ីចឹងកូន? រួចទៅប្អូនខ្ញុំក៏ឆ្លើយថា ខ្ញុំឃើញគេសីលធម៌ម៉ែអើយ។ តាំងពីពេលនោះមកប្អូនខ្ញុំត្រូវគេចាប់យកទៅចងដាក់ក្នុងវត្តស្វាយទាបក្នុងព្រះវិហារ។ យប់ថ្ងៃមួយ ពូមួយគាត់ជាប់ចំណងដែរ គាត់រំកិលទៅជិត គាត់ស្រាយប្អូនខ្ញុំឲ្យរត់ ប្អូនខ្ញុំថាស្រាយឲ្យគាត់វិញ គាត់ថាមិនបាច់ទេ ព្រោះគាត់ៗចាស់ហើយ មិនបាច់ស្រាយគាត់ទេ ក្មួយឯងនៅក្មេងរត់ទៅ។ ដល់ពេលនោះ ប្អូនខ្ញុំក៏រត់ ៗទៅណា រត់ទៅជ្រកនៅផ្ទះអ៊ំខ្ញុំ យប់ឡើងនៅក្នុងបង្គន់ ថ្ងៃឡើងចូលដេកជាមួយតាខ្ញុំអាយុ៩០ជាង នៅរៀននៅក្នុងខ្ទមតូចមួយ។ ដល់នៅយូរៗទៅខ្លាចគេដឹង គេចាប់ទាំងបងប្អូនអ៊ំមីងមាទៀត ក៏រត់ចេញទៅ។ ចេញទៅ ៗមួយតិចតួច ទៅរហូតស្រុកស្ទឹងត្រង់ ទៅឯឪពុកមាខ្ញុំនៅស្ទឹងត្រង់។ លួនផង ក្រាបទៅ ទៅដល់ឪពុកមាខ្ញុំថា ខោអាវរហែកអស់រលីងឡើងរយ៉ៃ។ គ្រាន់តែទៅដល់យប់ហ្នឹង ព្រលឹមឡើងក៏គេទៅចាប់យកមកវិញ។

ជម្រាបលោកប្រធានហើយចាប់យកមកវិញ គេមកស្រាតខោអាវអស់ គេចងនឹងដើមអម្ពិល គេយោលបុកនឹងដើមអម្ពិល។ ក្មេងនៅសាច់ឡើងសខ្ចីទៅជាខ្មៅអ៊្វិញអស់រលីង បែរទៅមុខវ៉ៃសុទ្ធតែនឹងស្បែកជើងកង់ឡាន។ វ៉ៃនឹងស្បែកជើងកង់ឡាន ប្អូនខ្ញុំមុខឡើងខ្មៅអ៊្វិញអស់ ម្ដាយខ្ញុំស្រែកទ្រហោយំ មិនដឹងធ្វើម៉េចជួយកូនបាន។ ក្រោយមកគេយកទៅទម្លាក់អណ្ដូងទៀត គេគ្រាន់តែនិយាយថា លោតចូលអណ្ដូងល្អមើលណាស់ ប៉ុន្តែសួរគេថា នៅកន្លែងណាៗ ក៏គេមិនប្រាប់ដែរ គ្រាន់តែឮគេនិយាយអ៊ីចឹង។

ចាប់ពីពេលនោះមក ខ្ញុំមានការឈឺចាប់គ្រាំគ្រា ឆ្នាំ១៩៧៩ មកដល់ពេលបច្ចុប្បន្ន សូមជម្រាបលោកប្រធានអ៊ីចឹង។ សព្វថ្ងៃនេះខ្ញុំធ្វើការ សូម្បីតែខ្ញុំដកស្ទូង ក៏ខ្ញុំនឹកឃើញបងប្អូនខ្ញុំ ទឹកភ្នែកធ្វើការមិន

កើត។ ពេលខ្ញុំជម្រះចម្ការ ខ្ញុំទៅឃើញបងប្អូនខ្ញុំៗជម្រះចម្ការមិនកើត។

[១៣:៣៧:៣៦]

ខ្ញុំឈឺចុកចាប់ណាស់ ដូច្នេះខ្ញុំសូមសំណូមពរ តាំងពីរបបនេះបានបញ្ចប់ទៅ ខ្ញុំទទួលតែទុក្ខទោស និងការលំបាកវេទនាគ្រាំគ្រារីងរៃរហូតមកដល់សព្វថ្ងៃនេះ។ ទុក្ខលំបាកវេទនាដែលខ្ញុំមានពីដើមមក ខ្ញុំចាំទល់ថ្ងៃខ្ញុំស្លាប់ ក៏ខ្ញុំមិនភ្លេចដែរ សូមជម្រាបលោកប្រធានប៉ុណ្ណឹង។ ប៉ុន្តែជាចុងបញ្ចប់ ក៏ខ្ញុំសូមមានសំណួរសួរទៅលោកខាងចុងចោទថា ខ្ញុំឆ្ងល់ថា ជំនាន់ខ្មែរក្រហមធ្វើប្រើប្រជាជនធ្វើស្រែចម្ការដូចគោដូចក្របី ចុះដល់ពេលបានផលមកស្រូវអង្ករគរគោក ទៅណាអស់ទៅ បានគេឲ្យហូបអត់ ហូបអត់ឃ្លានខ្លះរហូតដល់ស្លាប់ ដាច់ពោះស្លាប់ក៏មានដែរ? នេះខ្ញុំសូមជម្រាបលោកប្រធានអ៊ីចឹង។

ហើយដល់មួយទៀត ខ្ញុំសូមសួរសំណួរមួយទៀតថា កាលពីជំនាន់ខ្មែរក្រហម ខ្ញុំរស់នៅក្នុងទីក្រុងភ្នំពេញ ខ្ញុំប្រជុំកន្លែងណា រៀនកន្លែងណាក៏ដោយ ឮតែមេដឹកនាំថា អ្នកដែលកើតមកជំនាន់ខ្មែរក្រហមសុទ្ធតែជាប់ សុទ្ធតែគ្មានជាប់ឥទ្ធិពលអីទាំងអស់ គ្មានជាប់និន្នាការអីទាំងអស់។ ហេតុអីដល់ពេលសម័យនេះ ខ្ញុំទើបនឹងឃើញ ពីដើមមកខ្ញុំអត់ដឹង អត់ឃើញ ទើបសម័យនេះខ្ញុំឃើញ នៅជើងឯកគុក ទួលស្លែង ឃើញតែក្បាលកូនក្មេងត្រមែង។ ហ្នឹងខ្ញុំចង់សួរថា មូលហេតុអីបើកូនទាំងអស់ហ្នឹងវាមានៗមូលហេតុអីបានជាសម្លាប់វាទាំងនៅក្មេងខ្ចីមិនទាន់ដឹងអីផងនោះ? ហ្នឹងសំណួរខ្ញុំមានតែប៉ុណ្ណឹង សូមអរគុណ។

[១៣:៣៩:១៣]

**ប្រធានអង្គជំនុំ៖**

អរគុណលោកស្រីដើមបណ្តឹងរដ្ឋប្បវេណី។ អង្គជំនុំជម្រះសូមជម្រាបដល់លោកស្រីថា រហូតមកដល់ពេលនេះ ជនជាប់ចោទទាំងពីររូបនៅតែអនុវត្តនូវសិទ្ធិនៅស្ងៀមមិនឆ្លើយតប ហេតុដូច្នេះសូមលោកស្រីជ្រាប។

សវនាការស្តាប់សក្ខីកម្មដើមបណ្តឹងរដ្ឋប្បវេណី ជា ឡៀប ដល់ទីបញ្ចប់ហើយ អង្គជំនុំជម្រះអរគុណលោកស្រី ដែលបានចំណាយពេលវេលាមកផ្តល់សក្ខីកម្មចំពោះមុខអង្គជំនុំជម្រះ ក្នុងឋានៈជាដើមបណ្តឹងរដ្ឋប្បវេណី។ លោកស្រីអាចត្រឡប់ទៅវិញបានហើយ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលជាមួយបុគ្គលិកនៃអង្គភាពគាំពារសាក្សី និងអ្នកជំនាញក្នុងការជូនដើមបណ្តឹងរូបនេះវិលត្រឡប់ទៅលំនៅដ្ឋានវិញ។

*(ដើមបណ្ដឹងរដ្ឋប្បវេណីចាកចេញពីបន្ទប់សវនាការ)*

មន្ត្រីរដ្ឋបាលតុលាការ អញ្ជើញសាក្សីដែលមានរហស្សនាម 2-TCW-914 ចូលមកកាន់កន្លែងផ្ដល់សក្ខីកម្មនៅមុខអង្គជំនុំជម្រះ។

*(សាក្សីចូលក្នុងបន្ទប់សវនាការ)*

[១៣:៤១:៤៣]

**ការតាំងសំណួរដោយចៅក្រម**

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** ជម្រាបសួរលោកស្រីសាក្សី តើលោកស្រីឈ្មោះអីដែរ?

**លោកស្រី ផាន់ ហ៊ឹម៖**

**ផ៖** ខ្ញុំឈ្មោះ ផាន់ ហ៊ឹម។

**ស៖** លោកស្រីកើតនៅខែ នៅថ្ងៃណា ខែណា ឆ្នាំណាដែរ? ហើយនៅកន្លែងណា?

**ផ៖** ខ្ញុំកើតនៅភូមិបាគ្រង ស្រុកគោក -- ឃុំគោករវៀង ស្រុកជើងព្រៃ ខេត្តកំពង់ចាម។

**ស៖** លោកស្រីចាំទេ ថាលោកស្រីកើតនៅខែណា ឆ្នាំណាដែរ?

**ផ៖** ភ្លេចហើយលោកពូ។

**ស៖** ចុះលោកស្រីសព្វថ្ងៃមានអាយុប៉ុន្មានហើយ?

**ផ៖** អាយុ៦០ឆ្នាំ។

**ស៖** តើបច្ចុប្បន្នលោកស្រីរស់នៅកន្លែងណាដែរ?

**ផ៖** បច្ចុប្បន្នរស់នៅភូមិបាគ្រង ឃុំគោករវៀង ស្រុកជើងព្រៃ ខេត្តកំពង់ចាម។

**ស៖** លោកស្រីប្រកបមុខរបរអ្វី?

**ផ៖** ខ្ញុំសព្វថ្ងៃ អត់មានស្រែភ្លឺនឹងគេទេ លក់ដូរបន្តិចបន្តួច ហើយនិងរត់ ទិញកង់បីរត់។

[១៣:៤៣:១២]

**ស៖** ឪពុកម្ដាយរបស់លោកស្រីឈ្មោះអី?

**ផ៖** ឪពុកនាងខ្ញុំឈ្មោះ ព្រែង ផាំ, ម្ដាយខ្ញុំឈ្មោះ ស៊ឹម យ៉ែម។

**ស៖** ប្ដីលោកស្រីមានឈ្មោះអី? ហើយមានកូនប៉ុន្មាននាក់?

**ផ៖** ប្ដីខ្ញុំឈ្មោះ គង់ ឈឿន (ឈ្មោះដើម), ឈ្មោះបដិវត្តន៍កាលជំនាន់ ប៉ុល ពត គាត់ឈ្មោះ

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

គង់ សារ៉ាត់ អូ! ផាន់ សារ៉ាត់។ កូនខ្ញុំប្រាំមួយនាក់ តែស្លាប់ប្រុសបងមួយហើយ នៅឆ្នាំ២០០០។

**ស៖** អរគុណលោកស្រី។ តាមរបាយការណ៍របស់ក្រឡាបញ្ជីកាលព្រឹកមិញ បានបញ្ជាក់ថា តាមសមត្ថភាព និងលទ្ធភាពដែលលោកស្រីអាចដឹង លោកស្រីមិនមានជាប់ចំណងញាតិលោហិត ឬក៏ញាតិពន្ធជាមួយនឹងជនជាប់ចោទទាំងពីររូប លោក នួន ជា និង ខៀវ សំផន និងបុគ្គលដែលត្រូវបានទទួលជាដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿងនេះទេ។ តើពិតមែនទេ?

**ផ៖** ពិតមែន ចាស លោកតុលាការ។

**ស៖** តើលោកស្រីបានធ្វើសម្បថរួចហើយឬនៅ នៅចំពោះមុខលោកតាដំបងដែក មុននឹងចូលមកចំពោះមុខអង្គជំនុំជម្រះនេះ?

**ផ៖** ខ្ញុំបានពាក្យសម្បថនៅមុខលោកតាដំបងដែករួចហើយ។

[១៣:៤៤:៤៨]

**ស៖** អរគុណលោកស្រី។ ជាបន្តនេះ យើងប្រាប់អំពីសិទ្ធិ និងករណីយកិច្ចដល់លោកស្រី ក្នុងឋានៈលោកស្រីជាសាក្សីនៅចំពោះមុខអង្គជំនុំជម្រះ។ អំពីសិទ្ធិ លោកស្រី ផាន់ ហ៊ីម ក្នុងឋានៈលោកស្រីជាសាក្សីក្នុងកិច្ចដំណើរការនីតិវិធីសវនាការចំពោះមុខអង្គជំនុំជម្រះនេះ លោកស្រីអាចបដិសេធក្នុងការឆ្លើយតបទៅនឹងសំណួរ ឬការដែលលោកស្រីធ្វើអត្ថាធិប្បាយមួយ ឬច្រើនដែលនាំឲ្យដាក់ពិរុទ្ធភាពលើខ្លួនឯង សិទ្ធិមិនធ្វើសក្ខីកម្មប្រឆាំងនឹងខ្លួនឯង។

អំពីករណីយកិច្ចក្នុងឋានៈលោកស្រីជាសាក្សី លោកស្រីត្រូវតែឆ្លើយតបរាល់សំណួរទាំងឡាយដែលភាគី ឬចៅក្រមនៃអង្គជំនុំជម្រះសួរចំពោះលោកស្រី លើកលែងតែសំណួរណាដែលនាំឲ្យចម្លើយតបរបស់លោកស្រី ឬការធ្វើអត្ថាធិប្បាយរបស់លោកស្រីនាំឲ្យដាក់ពិរុទ្ធភាពលើខ្លួនឯង ដូចយើងប្រាប់អំពីសិទ្ធិរបស់ស្រីរួចហើយអម្បាញ់មិញនេះ។ ក្នុងឋានៈជាសាក្សី លោកស្រីត្រូវតែឆ្លើយឲ្យការណ៍ណាដែលពិត ដែលលោកស្រីបានដឹង បានឮ បានឃើញ បានចងចាំ ឬធ្លាប់មានបទពិសោធន៍ជួបប្រទះ ឬបានធ្វើការសង្កេតដោយផ្ទាល់នូវព្រឹត្តិហេតុ ឬហេតុការណ៍ទាំងឡាយដែលពាក់ព័ន្ធនឹងសំណួរដែលភាគីសួរចំពោះលោកស្រី។

លោកស្រី ផាន់ ហ៊ីម តើលោកស្រីបានផ្តល់សក្ខីកម្ម ឬផ្តល់កិច្ចសម្ភាសន៍ជាមួយអ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេតដែរឬទេពេលកន្លងមក? ហើយប្រសិនបានធ្វើ តើធ្វើប៉ុន្មានដងធ្វើនៅកន្លែងណា?

**ឆ៖** បានធ្វើម្ដងនៅនឹងផ្ទះខ្ញុំតែម្ដងលោកតុលាការ។

[១៣:៤៦:៣១]

**ស៖** អរគុណលោកស្រី។ ហើយនៅមុនពេលចូលមកចំពោះអង្គជំនុំជម្រះនេះ តើលោកស្រីបានពិនិត្យមើល ឬបានអាននូវកំណត់ហេតុដែលលោកស្រីបានផ្ដល់ចម្លើយកាលពីពេលមុនជាមួយនឹងអ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេតដើម្បីរំឭកការចងចាំដែរឬទេ?

**ឆ៖** បានមើលហើយ តែប៉ុនមិនសូវជាចាំ ៗខ្លះ ភ្លេចខ្លះ។

**ស៖** ហើយតាមសមត្ថភាពដែលលោកស្រីអាចដឹងបាន តើលោកស្រីអាចបញ្ជាក់បានទេថា កំណត់ហេតុស្ដាប់ចម្លើយដែលលោកស្រីបានអានដើម្បីរំឭកការចងចាំហ្នឹង វាពិតជាត្រឹមត្រូវ វាស៊ីចង្វាក់គ្នាស្របទៅនឹងចម្លើយដែលលោកស្រីបានផ្ដល់កិច្ចសម្ភាសន៍ជាមួយនឹងអ្នកស៊ើបអង្កេតកាលពីពេលមុនហ្នឹងដែរឬទេ?

**ឆ៖** ខ្ញុំពិនិត្យមើលតាមរបាយការណ៍ដែលខ្ញុំបានអានពីកាលខ្ញុំសម្ភាសពីឆ្នាំមុនហ្នឹង ខ្ញុំអាចបានដឹងពីដំណើរការរបស់ខ្ញុំដែលខ្ញុំសម្ភាសហ្នឹង ខ្ញុំបានចាំខ្លះៗ។

**ប្រធានអង្គជំនុំ៖**

អរគុណលោកស្រី។ ក្នុងការសួរដេញដោលសាក្សីរូបនេះ អនុវត្តតាមបញ្ញត្តិ៩១ស្ទួន នៃវិធានផ្ទៃក្នុងអ.វ.ត.ក អង្គជំនុំជម្រះផ្ដល់វេទិកាជូនទៅលោកសហព្រះរាជអាជ្ញាសួរដេញដោលសាក្សី ផាន់ ហ៊ីម នេះមុនភាគីដទៃទៀត។ ហើយសូមបញ្ជាក់ថាភាគីសហព្រះរាជអាជ្ញា រួមទាំងសហមេធាវីដើមបណ្ដឹងរដ្ឋប្បវេណីមានរយៈពេលពីរវគ្គ។

សូមអញ្ជើញលោកព្រះរាជអាជ្ញា!

**លោក ឌេល លីសាក់៖**

សូមអរគុណលោកប្រធាន។ សូមជម្រាបសួរលោក លោកស្រីមេធាវី។

**ការតាំងសំណួរដោយសហព្រះរាជអាជ្ញា**

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** សូមជម្រាបសួរលោកស្រីសាក្សី។ ខ្ញុំមកពីការិយាល័យសហព្រះរាជអាជ្ញា ហើយខ្ញុំនឹងធ្វើការសាកសួរលោកស្រីនៅពេលរសៀលនេះ។ ជាដំបូងខ្ញុំសូមចាប់ផ្ដើមដោយសាកសួរលោកស្រីអំពីប្រវត្តិមួយចំនួន ក៏ដូចជាតួនាទីនៅមុន និងក្នុងរបបខ្មែរក្រហម។ លោកប្រធាន ខ្ញុំសូមអនុញ្ញាតដើម្បី

បង្ហាញកិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា អំពីប្រវត្តិរូបនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ គឺឯកសារ E3/9318 ខ្មែរមានលេខ 00057998 <ដល់លេខ 58000>គឺមានតែឯកសារជាភាសាខ្មែរប៉ុណ្ណោះ។ ដូច្នេះខ្ញុំសូមអនុញ្ញាតលោកប្រធានដើម្បីផ្តល់នូវប្រវត្តិរូបរបស់គាត់ជូនទៅគាត់ សូមលោកប្រធានអនុញ្ញាត។

**ប្រធានអង្គជំនុំ៖**

*(មីក្រូហ្វូនមិនទាន់ប្រតិបត្តិការ)*

**សួរដោយលោក ឌេល លីសាក់៖**

សៈ លោកស្រីសាក្សី តើលោកស្រីអាចអានអក្សរបានដោយខ្លួនឯងទេនៅថ្ងៃនេះ?

**ប្រធានអង្គជំនុំ៖**

លោកស្រីដើមបណ្តឹងរដ្ឋប្បវេណី លោកស្រីអាចអានខ្លួនឯងបានទេ?

**លោកស្រី ផាន់ ហ៊ឹម៖**

*(មីក្រូហ្វូនមិនទាន់ប្រតិបត្តិការ)*

[១៣:៥១:៤៣]

**ប្រធានអង្គជំនុំ៖**

បាន។

លោកស្រីសាក្សីកុំទាន់អាលឆ្លើយ! ចាំមីក្រូហ្វូនលោកស្រីប្រតិបត្តិការសិន ចេញពណ៌ក្រហម។

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

លោកស្រី ខ្ញុំចង់សួរថា លោកស្រីអាចអាន ឬក៏អាចសរសេរអក្សរបានដែរឬទេ?

**លោកស្រី ផាន់ ហ៊ឹម៖**

សរសេរមិនសូវបានទេ។

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

ចុះអាន លោកស្រីអានអក្សរបានទេ?

**លោកស្រី ផាន់ ហ៊ឹម៖**

តិចៗដែរ ចេះ។

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** សូមអរគុណលោកស្រីសាក្សី។ នៅក្នុងផ្នែកដែលខ្ញុំចង់ឲ្យលោកស្រីពិនិត្យមើល គឺតារាងនៅក្នុងទំព័រទី២ គឺខ្មែរមានលេខ 00057998 ហើយនៅក្នុងតារាងនេះ គឺមានតួនាទីដែលលោកស្រីមាន គឺចាប់ពីឆ្នាំ៧៣ រហូតដល់ខែ១០ ឆ្នាំ៧៧។ ហើយលោកស្រីបានឆ្លើយនៅក្នុងការសម្ភាសរបស់មជ្ឈ-មណ្ឌលឯកសារកម្ពុជា ហើយខ្ញុំចង់សួរលោកស្រីនូវសំណួរមួយចំនួន ដើម្បីបញ្ជាក់អំពីពេលវេលាដែលលោកស្រីបំពេញការងារនៅក្នុងរបបនោះ។ ទី១ តាមប្រវត្តិរបស់លោកស្រី គឺថាលោកស្រីចូលបដិវត្តន៍នៅថ្ងៃទី២៨ ខែ៩ ឆ្នាំ<៧៣> ហើយនៅពេលនោះ លោកស្រីធ្វើការនៅឃុំឈូក នៅការិយាល័យពាណិជ្ជកម្ម។ តើអ៊ីចឹងមែនទេ?

[១៣:៥៤:២១]

**លោកស្រី ផាន់ ហ៊ីម៖**

**ផ៖** អ៊ីចឹងមែនហើយលោកគ្រូ។ នៅភូមិឈូក ឃុំគោករវៀង។

**ស៖** ប្រសិនបើយើងមើលនៅក្នុងតារាងដដែលនេះ គឺថា<>ប្រវត្តិ<របស់លោកស្រីបញ្ជាក់ថា> គឺនៅ<ខែ>មករា ៧៥ គឺគេចាត់តាំងលោកស្រីចូលយោធាទៅក្នុងកង<វរសេនាតូច>៣០៦។ តើវាស្របទៅតាមអ្វីដែលលោកស្រីចាំដែរឬទេ គឺនៅ<ខែ> មករា ៧៥ គឺជាគេចាត់តាំងឲ្យលោកស្រីចូលទៅក្នុងយោធាក្នុងកង<វរសេនាតូច>៣០៦?

**ផ៖** ខ្ញុំបានចាំ លោកគ្រូ ថ្ងៃទី០៨ ៧៥ហ្នឹង ខ្ញុំបានមកឡើងមកសមរភូមិធ្វើយោធា នៅត្រៀមស្ទែង ចាំសែងអ្នករបួស។

**ស៖** ហើយនៅទំព័រដដែលនេះ គឺនិយាយអំពីតួនាទីដំបូងរបស់លោកស្រី ក្រោយពេលដែលលោកស្រីចូលការងារនៅរបបខ្មែរក្រហម។ គឺនៅថ្ងៃ២៧ ខែឧសភា ៧៥ គឺគេចាត់តាំងលោកស្រីឲ្យទៅខាងឃ្លាំង គឺនៅក្នុងផ្នែកពាណិជ្ជកម្មក្រុង។ តើលោកស្រីអាចប្រាប់បានទេ គឺក្រោយថ្ងៃ១៧ មេសា ៧៥នោះ តើលោកស្រីបន្តស្នាក់នៅក្នុងទីក្រុងភ្នំពេញ ហើយបន្ទាប់មកទៀត គេឲ្យលោកស្រីទៅធ្វើការនៅពាណិជ្ជកម្មក្រុងរយៈពេលប្រហែលជាប៉ុន្មាន -- ប្រហែលជា២ឆ្នាំហ្នឹង តើមែនទេ?

[១៣:៥៦:៣១]

**ផ៖** តាំងពីឆ្នាំ៧៥ដែលដាច់ទៅ គេបញ្ជូនខ្ញុំឲ្យឡើងទៅនៅសម្អាតនៅផ្សារថ្មី។ ដល់ពេលសម្អាតហើយ ស្អាតបាតដឹកជយភណ្ឌកម្ទេចកម្ទីហ្នឹងស្អាតអស់ទៅ គេឲ្យខ្ញុំហ្នឹងកាន់ឃ្លាំងចែកចាយកម្មករ ចែកចាយម្ហូបអាហារកម្មករ នៅឆ្នាំ៧៥ ថ្ងៃ ខែ៥ហ្នឹង។

**ស៖** ហើយតាមប្រវត្តិរូបរបស់លោកស្រី បានបង្ហាញថា នៅខែ០៨ <ឆ្នាំ>៧៥ លោកស្រីចាប់ផ្ដើមធ្វើការនៅហាងធ្វើនំ នៅកន្លែងធ្វើនំហៅថាក-១៩ ដែលនៅក្នុងការសម្ភាស លោកស្រីបានរៀបរាប់។ ដូច្នេះខ្ញុំចង់សួរលោកស្រីអំពីតួនាទីបន្ត ដែលបញ្ជាក់ថានៅថ្ងៃទី២៣ ខែ៣ ៧៦ គឺគេចាត់តាំងលោកស្រីទៅផ្នែកពាណិជ្ជកម្មក្រុង ប៉ុន្តែគេហៅថា ផ្នែកផ្គត់ផ្គង់ស្បៀង។ តើលោកស្រីអាចបញ្ជាក់បានទេថា ក្រោយពេលដែលលោកស្រីចេញពីកន្លែងធ្វើនំ ក-១៩ទៅហ្នឹង តើលោកស្រីចេញទៅផ្នែកផ្គត់ផ្គង់ស្បៀងហ្នឹងនៅទីកន្លែងណាដែរ?

**ឆ៖** កាលដែលខ្ញុំកាន់ឃ្លាំងពាណិជ្ជកម្មហ្នឹងរួច ដល់ពេលមនុស្សច្រើនពេកទៅ គេដកខ្ញុំហ្នឹងទៅឱ្យទៅធ្វើនំនៅក-១៩ នៅផ្លូវក្បែរស្ពានចាស់។ ដល់ពេលធ្វើបានរយៈប្រហែលយូរដែរ ទៅក៏គេខ្វះខាតមនុស្សផ្គត់ផ្គង់ស្បៀង ដឹកជញ្ជូនស្បៀងចែកកម្មករ ក៏ដកមកចូលកន្លែងផ្សារថ្មីវិញ។

[១៣:៥៨:៤៩]

**ស៖** ហើយនៅក្នុងផ្នែកបន្ទាប់នៃប្រវត្តិរូបរបស់លោកស្រីគឺ<នៅខែឧសភា គឺហាក់ដូចជានៅថ្ងៃទី២៣ ឬ> ថ្ងៃទី១៣ ខែឧសភា ៧៧ គឺពេលនោះលោកស្រីធ្វើការងារនៅ<ក្រសួង>ពាណិជ្ជកម្ម<> ប៉ុន្តែនៅផ្នែកអប់រំកុមារ។ នៅក្នុងការសម្ភាសរបស់លោកស្រី ក៏លោកស្រីនិយាយអំពីចំណុចនេះដែរ។ អ្វីដែលខ្ញុំចង់សួរលោកស្រីគឺថា នៅក្នុងការសម្ភាសរបស់លោកស្រី គឺលោកស្រីរៀបរាប់ថា មុនពេលដែលគេបញ្ជូនទៅផ្នែកអប់រំកុមារហ្នឹង គឺគេបញ្ជូនលោកស្រីទៅជំរំ<លត់ដំ>មួយនៅពោធិ៍ចិនតុង<អស់មួយរយៈពេល>។ ប៉ុន្តែប្រសិនបើយើងមើលទៅតាមប្រវត្តិរូបរបស់លោកស្រី តើលោកស្រីអាចប្រាប់បានទេថា តើគេបញ្ជូនលោកស្រីទៅ<ការដ្ឋានលត់ដំ>នៅពោធិ៍ចិនតុងហ្នឹងនៅពេលណាដែរ?

**ឆ៖** កាលដែលខ្ញុំនៅកន្លែងផ្គត់ផ្គង់ស្បៀងអាហារហ្នឹង ជំនាន់ហ្នឹងគេអត់ទាន់ចាប់ពួកឧត្តរក្បត់ទេ។ គេឱ្យពួកខ្ញុំហ្នឹងទៅលត់ដំហ្នឹង ទៅដឹកប្រឡាយ លើកទំនប់នៅពោធិ៍ចិនតុងហ្នឹង នៅខាងជើងម៉ាស៊ីនត្រជាក់នៅមុខរោយចក្រ"អ" អំបោះដេរអ-១។ ខ្ញុំទៅនៅកន្លែងហ្នឹងនៅទៅ គេឱ្យលត់ដំផង ហូបក៏មិនគ្រប់គ្រាន់ ហើយធ្វើការទាំងយប់ទាំងថ្ងៃ ជីកប្រឡាយលើកផ្លូវភ្លឺហ្នឹងនៅទាល់សព្វថ្ងៃហ្នឹងភ្លឺលើកហ្នឹង។ ដល់លើកៗទៅ មានថ្ងៃមួយស្រាប់តែមានគេមកយកឡានមកយក។ មកដល់ឡានហ្នឹងឃ្លុប។ មកដល់ស្រាប់តែមកហៅ ឡើងដាក់ ឡើងដាក់ទៅខ្ញុំចេះតែឆ្ងល់ ក៏ដឹកទៅបាត់ទៅ ដឹកទៅលិចបាត់ទៅ។ រំលងបានប្រហែលបួនដប់ថ្ងៃ ឃើញឡានហ្នឹងមកទៀត។ ដល់ឡានហ្នឹងមកទៀត ពួកខ្ញុំនេះឆ្ងល់ក៏មិនហ៊ានសួរដែរ រួចចេះតែសួរគ្នាឯង។ ស្រាប់តែថ្ងៃមួយ ស្រាប់តែវាបញ្ជាឱ្យពួកហ្នឹងកាត់បន្លែ បន្លែហ្នឹង

ទើបបាញ់ថ្នាំរួច វាកាត់យកមកស្លឲ្យពួកខ្ញុំហូប។ វាយកលេសត្រង់ហ្នឹង។ ដល់ពេលស្លហូបទៅស្រាប់តែពុលអស់មួយអង្គភាពហ្នឹង ពុលនាំគ្នាយកទៅដេកនៅពេទ្យកាល់ម៉ែត អូ៎! ពេទ្យ មិនមែនកាល់ម៉ែតទេ ពេទ្យហ្នឹង ពេទ្យៗកាល់ម៉ែតអីចឹងហើយកន្លែងនុ៎ង ខ្ញុំអត់សូវស្គាល់ ពេទ្យហ្នឹងមានកន្លែងកុមារសម្រាលកូនអីហ្នឹង។

[១៤:០១:២២]

ដល់ពេលពួកខ្ញុំចេញមកវិញ វាចោទពួកខ្ញុំហ្នឹង ថាពួកខ្ញុំហ្នឹងថាពួកខ្ញុំហ្នឹងអ្នកបំពុល។ ដល់ពេលហ្នឹង ក៏ពួកខ្ញុំចេះតែសង្ស័យ មិនដឹងរឿងអីសោះ ធ្វើតែការវាល់ៗល្ងាច មួយយប់ទល់ៗណាណី នាំគ្នាងូតទឹកហើយដេក ម៉េចក៏ទៅបំពុលគេវិញ ក៏នាំគ្នាចេះតែឆ្ងល់។ រំលងបានពីរបីថ្ងៃ វាមកដឹកទៀត។ មកដឹកទៀតខ្ញុំចេះតែនេះ ខ្ញុំចេះតែតាមដានចេះតែលួចចាំស្ដាប់មើល។ វាមកដល់ វាហៅឈ្មោះអ្នកនេះៗៗរៀបចំអីវ៉ាន់លឿនៗមកឡើងឡាន។ ដល់ពេលឡើងពេញទៅ ក៏វាដឹកទៅបាត់ទៀតទៅ។ រួចខ្ញុំចេះតែឆ្ងល់ អើ!យើងចេះអស់គ្នាទៅហើយនេះ រួចអត់មានរឿងហេតុអី ស្រាប់មកហៅដឹក ហៅដឹក។ ដល់ថ្ងៃមួយមកដឹកខ្ញុំទៅលួចសួរថា “មិត្តបង យកពួកខ្ញុំទៅហ្នឹង យកទៅខាងណា?” គាត់ឆ្លើយថា “យកទៅទួលកំពង់កន្ទួត” ខ្ញុំថា “អ្ហ៎! ម៉េចយកទៅកំពង់កន្ទួតធ្វើអី?” “អ្ហឺ! ទៅដល់កន្លែងហ្នឹងគេឲ្យយើងនៅកន្លែងហ្នឹងបន្តិចទៀត គេដឹកទៅឲ្យជួបពុកម៉ែហើយ។” ខ្ញុំក៏ឈប់សួរទៅ។ ដល់ថ្ងៃក្រោយទៀត ស្រាប់តែយកឡានមកទៀត មកដឹកមួយឡានទៀត ហៅចំឈ្មោះខ្ញុំអីហ្នឹងដែរ ប៉ុន្តែខ្ញុំនេះអាល័យរៀបចំទៅក្រោយគេ ទៅដល់គេថាពេញឡានហើយ ត្រឡប់ទៅវិញទៅ ចាំឡានក្រោយ។ ដល់ពេលថ្ងៃក្រោយទៀតឡានហ្នឹងមកទៀត ហៅចំឈ្មោះពួកខ្ញុំហ្នឹងទៅទៀត ដល់ខ្ញុំទៅដល់ឡានហ្នឹងពេញទៀត គាត់ក៏ច្រានខ្ញុំ ថាទៅចាំស្អែកចាំឡើងឡានទៅ។ ដល់ពេលដល់ថ្ងៃស្អែក ទទួលគេចាប់ពួកឧត្តរក្បត់ ក៏រួចខ្លួនពួកខ្ញុំហ្នឹងទៅ អត់បានដឹកយកទៅកំពង់កន្ទួតហ្នឹងទៅ។

[១៤:០៣:១០]

ដល់ពេលឈប់នេះទៅ ដល់គេចាប់ឧត្តរក្បត់ទៅ ក៏គេរំសាយកន្លែងហ្នឹង គឺគេដឹកពួកខ្ញុំមកចូលកន្លែងផ្សារថ្មីវិញ។ មកឡើងរៀនថ្កោលទោស គេឲ្យយើងទៅរៀនថ្កោលទោសនៅសាលា ក្រុងមួយនៅនឹងក្បែរផ្សារចាស់។ ដល់ទៅរៀនត្រង់ហ្នឹង រៀនថ្កោលទោសពីពួកក្បត់ពីអី សុទ្ធឧត្តរក្បត់ឧត្តរអីហ្នឹងទៅដល់ក៏គេឲ្យពួកអ្នកនៅៗនឹងផ្សារចាស់ហ្នឹង ពួកក្រុមអា កុយ ឃួន ក្រុមសិល្បៈ គេហៅឈ្មោះ មិត្តខេង ឲ្យ មិត្តខេង ហ្នឹងអ្នកឡើងថ្កោលទោស។ ដល់ មិត្តខេង ហ្នឹងគ្នាឡើងទៅ គ្នាសូមប្រាប់ដល់អង្គការ

ថា ឈ្មោះ អាកុយ ឃួន ហ្នឹងកាលដែលគាត់ធ្វើប្រធានសិល្បៈ គ្នាជាឡាវនៅក្នុងក្រុមសិល្បៈហ្នឹង វាហៅ មិត្តខេង ហ្នឹងទៅរំលោភ។ ដល់រំលោភរួចបានម្តង ពីរដងទៅ វារៀបគ្រួសារឲ្យ។ រៀបគ្រួសារឲ្យមិត្តខេង ហ្នឹង។ ដល់រៀបឲ្យទៅ ក៏វាបញ្ជូនអាប្តីហ្នឹងទៅនៅខាងកំពង់សោម។ ដល់ពេលប្រហែលរយៈមួយខែបានឲ្យប្តីហ្នឹងមកលេង មករួមដេករស់នៅលេងជាមួយគ្នាអ៊ីចឹង។ ដល់ពេលមក មិត្តខេង ហ្នឹងគ្នាឃើញប្តីមក វាដូចតូចចិត្តខ្លួនឯងគ្នាយំ។ ដល់យំទៅ ប្តីក៏សួរថា "អូនឯងយំអី អូនឯងស្អប់ខ្ញុំឬមួយយ៉ាងម៉េច បានជាអូនឯងយំ?" ក៏ មិត្តខេង ហ្នឹងគ្នាមិនហ៊ាននិយាយព្វៗដែរទេ។ ប៉ុន្តែ អាកុយ ឃួនហ្នឹងវា១ចាត់តាំងពី មីកាម៉ៃ មីអ្នកចំរៀងហ្នឹងជា មីហ្នឹងវាយកធ្វើជាជំនិតរបស់វា។ វាចាត់តាំង មីកាម៉ៃហ្នឹងឲ្យតាមដាន មិត្តខេង ហ្នឹង វាឃើញប្តីគ្នាមកនុំង។ ដល់គ្នាលួចប្រាប់ថា "អ្នំបង! ខ្ញុំអាណិតបងព្រោះថាកាលពីខ្ញុំនៅលីវ នៅក្រមុំ ខ្ញុំមិនថាទេ ហៅខ្ញុំទៅរំលោភពីរបីដង តែដល់រៀបខ្ញុំឲ្យទៅបងឯងហើយ នៅតែហៅខ្ញុំទៅរំលោភទៀត។" និយាយប្រាប់ប្តីអ៊ីចឹង ទៅក៏--

[១៤:០៥:១៦]

**ស៖** លោកស្រីសាក្សីសូមទោស ខ្ញុំសូមកាត់បន្តិច។ ខ្ញុំដោយសារ ខ្ញុំនឹងត្រូវសួរលោកស្រីអំពីវគ្គទិតៀន ស្វ័យទិតៀនហ្នឹងនៅពេលក្រោយ។ ប៉ុន្តែឥឡូវនេះខ្ញុំចង់និយាយអំពីពេលដែលលោកស្រីនៅជំរំអប់រំកែប្រែនោះ គឺនៅទីនោះលោកស្រីត្រូវ<លើក>ទំនប់ ជីកប្រឡាយនៅជិតពោធិ៍ចិនតុង។ តើលោកស្រីអាចប្រាប់បានទេថា លោកស្រីនៅជំរំអប់រំកែប្រែហ្នឹងប្រហែលជាប៉ុន្មានខែដែរ?

**ឆ៖** បួនប្រាំខែដែរហ្នឹងលោកគ្រូ។ នៅកន្លែងហ្នឹងលត់ដំឲ្យស៊ីតែបបរលាយពោត បើដាំបាយឲ្យហូបអ៊ីចឹងលាយជាមួយសណ្តែកបាយឲ្យហូបនៅហ្នឹង។ រួចធ្វើការនៅកន្លែងហ្នឹង ជីកទំនប់ ជីកប្រឡាយ ដឹងជីកធ្វើអីទេ ខ្ញុំចេះតែនាំគ្នាធ្វើទៅ យើងនៅក្រោមបង្គាប់គេ ចេះតែបញ្ជាឲ្យធ្វើអី ចេះតែធ្វើហ្នឹងទៅ។

**ស៖** លោកស្រីបានបញ្ជាក់ថា លោកស្រីត្រឡប់មកពីជំរំអប់រំកែប្រែនេះវិញ គឺត្រឡប់មកភ្នំពេញ ដើម្បីចូលរួមវគ្គទិតៀន ស្វ័យទិតៀន។ ប៉ុន្តែនៅក្នុងការសម្ភាសរបស់លោកស្រីថា ក្រោយពេលត្រឡប់មកភ្នំពេញភ្លាម១ហ្នឹង គេបញ្ជូនលោកស្រីទៅអប់រំកុមារ។ ប្រសិនបើយើងមើលប្រវត្តិរូបរបស់លោកស្រី គឺបញ្ជាក់អំពីកាលបរិច្ឆេទដែលលោកស្រីទៅផ្នែកអប់រំកុមារ គឺនៅថ្ងៃទី<២០ ឬទី>១៣ ឧសភា ឆ្នាំ៧៧។ តើវាត្រូវជាមួយនឹងការចងចាំរបស់លោកស្រីដែរឬទេ ដែលថានៅក្នុងខែឧសភា ថ្ងៃទី ១៣ ឧសភា ៧៧ ហ្នឹង គឺគេបញ្ជូនលោកស្រីពីជំរំអប់រំកែប្រែបញ្ជូនមកខាងអប់រំកុមារវិញនេះ តើវា

ត្រឹមត្រូវទេ?

[១៤:០៧:២២]

**ឆះ** --លោកគ្រូ តែរៀបមកមិនទាន់បញ្ជូនទៅភ្លាមទេ មកដល់អ៊ីចឹង ឲ្យខ្ញុំទៅរៀនថ្កោលទោសគេសិន ព្រោះយើង គេចាប់ពួកឧត្តរក្សត់។ ចាស រៀនថ្កោលទោសរួចប្រហែលមួយអាទិត្យ បានដកពួកខ្ញុំហ្នឹងទៅអប់រំកុមារនៅឫស្សីកែវ។ ពួកខ្ញុំក៏ទៅបង្រៀនកុមារនៅឯហ្នឹងទៅ។ ដល់ទៅរស់នៅនឹងកន្លែងឫស្សីកែវហ្នឹង វាស្ងាត់ពេក ស្រាប់តែមានយោធានៅកន្លែងស្ពានចុងស្ពាន គល់ស្ពានហ្នឹង ម្យប់ៗចេះតែទៅអុកឡុក ទៅលួចបាយ ទៅលួចស្អីៗ អង្ករអីក្នុងឃ្លាំងហ្នឹង ទោះបីចាក់សោម៉េចក៏វាឡើងតាមលើទៅលួចដែរ។ ដល់ថ្ងៃមួយចូលមកអុកឡុកកន្លែងពួកខ្ញុំដេក ឃើញក្រមាលួចក្រមា ឃើញស្បែកជើងយកស្បែកជើង យកតាំងពីកំសៀវទឹកឡើង អាយើងយកមកដាក់ទុកហូបប្រចាំពេលយប់ហ្នឹង វាលួចទៅអស់ទៅ។ ដល់ពេលហ្នឹងក៏ពួកខ្ញុំនៅកន្លែងហ្នឹងស្ងាត់ពេក ក៏អង្គការដកមកនៅទួលទំពូងវិញមក ៗអប់រំកុមារនៅទួលទំពូង។

**សះ** សូមអរគុណ។ ហើយតួនាទីចុងក្រោយនៅក្នុងកំណត់ត្រារបស់លោកស្រី គឺនៅខែតុលា ៧៧ គឺនៅប្រហែលជានៅថ្ងៃ១៦ ខែតុលា ៧៧ គឺគេចាត់តាំងលោកស្រីទៅកងចល័ត នៅក្នុង <ក្រសួង>ពាណិជ្ជកម្មដដែល។ <>លោកស្រីបានរៀបរាប់អំពីការងាររបស់លោកស្រីថា នៅក្នុងផ្នែកអង្គភាពជ្រើសរើសទំនិញ។ តើលោកស្រីអាចបញ្ជាក់បានទេថា នៅពេលដែលគេចាត់តាំងលោកស្រីទៅកងចល័តនៅក្នុងខែតុលា ៧៧ហ្នឹង តើលោកស្រីធ្វើការនៅទីកន្លែងណាដែរ? ហើយការិយាល័យដែលលោកស្រីធ្វើការហ្នឹងមានទីតាំងនៅម្តុំណាដែរ?

[១៤:០៩:២៤]

**ឆះ** កាលដែលខ្ញុំមកបង្រៀនកុមារនៅទួលទំពូងហ្នឹង មករយៈបានប្រហែល១ខែ ក៏គេដកខ្ញុំមកឲ្យនៅកងចល័ត។ ប៉ុន្តែកងចល័តហ្នឹងក៏នៅនឹងក្បែរវត្តទួលទំពូងដែរ ដល់មកនៅកន្លែងហ្នឹងទៅ គេឲ្យខ្ញុំហ្នឹងនៅខាងសម្រិតសម្រាំងអនុផល។ មានតាំងពីល្ង សណ្តែកដី មានតាំងពីផ្លែក្រវាញ ផ្លែដង្កោ សម្រិតសម្រាំងធ្វើម៉េចឲ្យតែស្អាត អុំផង បក់ផង ឲ្យស្អាតទៅច្រកបាវ ថាយកចេញទៅប្រទេសក្រៅ។ ពួកខ្ញុំខំសម្រិតសម្រាំងធ្វើទាំងយប់ទាំងថ្ងៃ តាំងពីឆ្អឹងដំរី ឆ្អឹងខ្លា ឆ្អឹងអីក៏ដោយ ឃើញតែដឹកយកមកឲ្យពួកខ្ញុំហ្នឹង សម្រិតសម្រាំងលាងដុសឲ្យស្អាត ច្រកឲ្យស្អាត យកទៅប្រទេសគេ ថាដឹកទៅកំពង់សោម។ តែពួកខ្ញុំក៏ឮគេបញ្ជាឲ្យធ្វើអ៊ីចឹង ក៏នាំតែគ្នាធ្វើឲ្យតែស្អាតហ្នឹងទៅ ប៉ុន្តែត្រង់ថា យកទៅណាមកណា ក៏មិន

ដឹងដែរ ឮតែប្រាប់ថា កំពង់សោមតែប៉ុណ្ណឹង។

**ស៖** លោកស្រីសាក្សី តើលោកស្រីអាចពន្យល់បានទេថា ទួលទំពូងហ្នឹងនៅកន្លែងណាដែរ នៅទីក្រុងភ្នំពេញ?

**ឆ៖** នៅកន្លែងណា ខ្ញុំមិនសូវស្គាល់ដែរ។ ខ្ញុំអត់សូវស្គាល់ដែរក្មួយ ទួលទំពូងហ្នឹង។ គ្រាន់តែស្គាល់ថា វត្តទួលទំពូង ហើយពួកខ្ញុំនៅខាងកើតវត្តទួលទំពូងហ្នឹង នៅតាមផ្ទះប្រជាជនយើងដែលគាត់បានជម្លៀសចេញទៅអស់ទៅហ្នឹង។

**ស៖** តើកន្លែងហ្នឹងនៅក្នុងទីក្រុងភ្នំពេញដែរឬទេ? ហើយតើវាមានចម្ងាយប្រហែលប៉ុន្មានដែរ ពីផ្សារថ្មី ឬក៏ពីសាលាដែលលោកស្រីអប់រំកុមារហ្នឹង វាមានចម្ងាយពីគ្នាប្រហែលប៉ុន្មានដែរ?

**ឆ៖** នៅឯទួលទំពូងហ្នឹង នៅឆ្ងាយពីផ្សារថ្មីប្រហែល១គីឡូដីហ្នឹងក្មួយ កាលហ្នឹង ពីព្រោះមិនដែលនេះដែរ ព្រោះធ្លាប់តែជិះកង់ឆ្លងកាត់ទៅមក វាងឆ្ងាយដែរ។

[១៤:១១:៥៧]

**ស៖** ចំណុចចុងក្រោយដែលខ្ញុំចង់បញ្ជាក់អំពីប្រវត្តិរបស់លោកស្រីហ្នឹង គឺថានៅក្នុងខែតុលា ៧៧នោះ គឺប្រវត្តិរូបមិនបានបញ្ជាក់អំពីកាលបរិច្ឆេទនោះទេ ប៉ុន្តែនៅក្នុងប្រវត្តិរូបបញ្ជាក់ថា ត្រឹមខែតុលា ៧៧នុ៎ង លោកស្រីនៅលីវនៅឡើយ។ <យើងនឹងនិយាយអំពីការរៀបការរបស់លោកស្រី។> ប៉ុន្តែតើវាជាការត្រឹមត្រូវដែរឬទេថា ត្រឹមខែតុលា ៧៧ហ្នឹង លោកស្រីនៅលីវនៅឡើយ ហើយលោកស្រីរៀបការនៅចុងរបបខ្មែរក្រហម តើអ៊ីចឹងមែនទេ?

**ឆ៖** កាលដែលខ្ញុំនៅកងចល័តហ្នឹង ខ្ញុំនៅតាំងពី៧៧ហ្នឹង មកទល់ចូល៧៨ មកដល់ខែ១១ ៧៨ហ្នឹង បានខ្ញុំមានគ្រួសារ រៀបទៅនៅខាងគ្រួសារខ្ញុំនៅឯខាងក្រសួងហិរញ្ញវត្ថុ។

**ស៖** ខ្ញុំនឹងសួរលោកស្រីនៅពេលបន្តិចទៀតនេះ អំពីការរៀបការរបស់លោកស្រី ប៉ុន្តែឥឡូវនេះ ខ្ញុំចង់សួរអំពីទួលទំពូងបន្តិចសិន ហើយនិងអំពីខាងពាណិជ្ជកម្ម គឺតួនាទីរបស់លោកស្រីនៅខាងពាណិជ្ជកម្មនោះ។ ក្នុងពេលដែលលោកស្រីធ្វើការនៅទួលទំពូង ពីឆ្នាំ៧៧ ដល់៧៨ តើផ្នែកដែលលោកស្រីធ្វើការហ្នឹង ស្ថិតនៅក្រោមក្រសួងពាណិជ្ជកម្មមែនទេ? ហើយប្រសិនបើដូច្នេះមែន តើអ្នកណាជាប្រធានផ្នែកពាណិជ្ជកម្មនោះ?

**ឆ៖** ខ្ញុំនៅកន្លែងសម្រិតសម្រាំងអនុផលនៅនឹងទួលទំពូងហ្នឹង កាលដែលខ្ញុំនៅ ជំនាន់ហ្នឹង ឈ្មោះ តាហុង គាត់គ្រប់គ្រងពួកខ្ញុំ។ ដល់ពេលខ្ញុំរៀបគ្រួសារទៅ ខ្ញុំទៅនៅខាងប្ដីខ្ញុំ មាន តារិទ្ធ គាត់អ្នក

គ្រប់គ្រងពីលើ តាហុង ហ្នឹងទៀត ប៉ុន្តែគាត់នៅខាងក្រសួងក្រៅប្រទេស គេថា គាត់នៅខាងក្រៅប្រទេស នៅខាងវាយបញ្ជីចេញបញ្ជីចូល។ តែពួកខ្ញុំកាលមិនទាន់រៀបគ្រួសារហ្នឹង នៅក្នុង គេហៅពាណិជ្ជកម្មក្នុងប្រទេសហ្នឹង ខាងសម្រិតសម្រាំងអនុផលនាំចេញ។

**ស៖** តើលោកស្រីដឹងទេថា តាហុង គាត់មានតួនាទីអ្វីដែរ?

**ឆ៖** *(មីក្រូហ្វូនមិនទាន់ប្រតិបត្តិការ)*

**ប្រធានអង្គជំនុំ៖**

លោកស្រីសាក្សី ចាំមីក្រូហ្វូនដំណើរការចេញភ្លើងពណ៌ក្រហម ចាំលោកស្រីឆ្លើយ។

**លោកស្រី ផាន់ ហ៊ីម៖**

**ឆ៖** កាលហ្នឹងគាត់ទទួលខុសត្រូវខាងក្នុងប្រទេសហ្នឹង គឺគាត់អនុ តារិទ្ធ។ តារិទ្ធ គាត់នៅក្រសួងក្រៅប្រទេសហ្នឹង គាត់ជាប្រធានគ្រប់គ្រងពីលើ តាហុង ហ្នឹងទៀត។

[១៤:១៥:២៨]

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** តើលោកស្រីដឹងថា តារិទ្ធ គាត់រាយការណ៍ទៅអ្នកណាដែរ? តើលោកស្រីដឹងថាថ្នាក់លើនៅក្នុងជួរបក្សដែលជាប្រធាន ដែលជាមេកោយរបស់ តារិទ្ធ ហ្នឹងជាអ្នកណា? គាត់រាយការណ៍ទៅឲ្យអ្នកណា?

**ឆ៖** ខ្ញុំអត់បានដឹងដែរ ព្រោះខ្ញុំជាមហាជន ព្រោះអត់ដែលដឹងពីប្រវត្តិគាត់ ដឹងរាយការណ៍ទៅលើពីណាទៀត ខ្ញុំអត់បានដឹង។

**ស៖** ខ្ញុំសូមអានសក្ខីកម្មរបស់ ស គឹមល្មុត ដែលគាត់នៅខាងផ្នែកពាណិជ្ជកម្មក្នុង និងក្រៅប្រទេសដែលជាអនុប្រធាននៃធនាគារ<ពាណិជ្ជកម្មក្រៅប្រទេស> ដែលបានផ្តល់សក្ខីកម្មនៅថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១២ គឺឯកសារ E1/79.1។ នៅម៉ោង<១៤:៣៣>រសៀល គាត់បាននិយាយថារបាយការណ៍ពីផ្នែកពាណិជ្ជកម្មនេះត្រូវរាយការណ៍<ពី> តារិទ្ធ <ទៅ វន វ៉េត> និង ខៀវ សំផន ហៅ ហែម។ នេះគឺអ្វីដែលគាត់បាននិយាយ សូមដកស្រង់៖ “តាមធម្មតាក្រសួងពាណិជ្ជកម្មត្រូវរាយទៅថ្នាក់លើ គឺមាន បងវន និង បងហែម។ ខ្ញុំចង់បញ្ជាក់ឲ្យច្បាស់ថា (សួរ) ដើម្បីឲ្យខ្ញុំយល់បានច្បាស់ មានន័យថា បងហែម និង បងវន គឺជាថ្នាក់លើនៅក្នុងក្រសួងពាណិជ្ជកម្ម ត្រឹមត្រូវដែរឬទេ? ឆ្លើយ៖ បាទ ត្រឹមត្រូវហើយ។” សំណួរទី១របស់ខ្ញុំ អ៊ីចេះលោកស្រីសាក្សី ស គឹមល្មុត ដែលបានមកផ្តល់សក្ខីកម្មនៅទីនេះ

តើលោកស្រីមានស្គាល់កម្មាភិបាលម្នាក់ឈ្មោះ ល្មុត ដែរឬទេនៅក្រសួងពាណិជ្ជកម្ម?

**ប្រធានអង្គជំនុំ៖**

លោកស្រីសាក្សី កុំទាន់អាលឆ្លើយ!

សូមអញ្ជើញលោកមេធាវីលោក ខៀវ សំផន!

[១៤:១៧:៥០]

**កញ្ញា អង់តា ហ្គីសសេ៖**

សូមអរគុណលោកប្រធាន។ ខ្ញុំមិនជំទាស់ទៅនឹងសំណួរទេ ប្រសិនបើបញ្ជាក់ឲ្យបានច្បាស់ថា ស គឹមល្មុត មិននិយាយពីរឿងអ្វីដែលគាត់ដឹងដោយខ្លួនឯងផ្ទាល់ទេ គឺគាត់និយាយតាមអ្វីដែលគាត់បានដឹងពីឯកសារដែលបានបង្ហាញជូនគាត់ដោយសហចៅក្រមស៊ើបអង្កេតនោះ។ <ចំណុចនេះ គឺច្បាស់ណាស់នៅក្នុងចម្លើយរបស់គាត់ នៅក្រោយការសម្ភាសគាត់> គឺថាគាត់មិនដឹងដោយខ្លួនឯងផ្ទាល់ទេ គឺគាត់គ្រាន់តែគាត់សន្និដ្ឋានតែប៉ុណ្ណោះ។ អ៊ីចឹងនៅពេលដែលដកស្រង់សម្ដីសាក្សីមក ហើយមកនិយាយថាគាត់ដឹងរឿងហ្នឹងនៅសម័យនោះ គឺមិនត្រឹមត្រូវទេ។

**សួរដោយលោក ខេល លីសាក់៖**

**ស៖** លោកស្រីសាក្សី ស គឹមល្មុត តើតាមរយៈប្ដីរបស់លោកស្រី នៅពេលដែលលោកស្រីនៅឯក្រសួងពាណិជ្ជកម្ម លោកស្រីស្គាល់មនុស្សម្នាក់ឈ្មោះ ស គឹមល្មុត នេះទេ?

**លោកស្រី ផាន់ ហ៊ីម៖**

**ឆ៖** កាលដែលខ្ញុំរៀបគ្រួសាររួចនៅខែ១១ ឆ្នាំ៧៨ហ្នឹង គេយកខ្ញុំទៅនៅកន្លែង តារិទ្ធ ហ្នឹងខ្ញុំធ្លាប់ស្គាល់គាត់។ ប៉ុន្តែមិនដឹងជាគាត់ហ្នឹងទទួលនាទីខាងអីទេ ព្រោះរស់នៅជាមួយគ្នាបានតិចដែរ បានប្រហែលៗជាបីបួនខែប៉ុណ្ណឹង ក៏យួនចូលហ្នឹងទៅ ក៏បែកបាក់គ្នាអស់ទៅ។ កាលពីមុនមក ក៏ខ្ញុំនៅឯណានេះដែរ នៅឯទួលទំពូងឯណោះ ខ្ញុំអត់ដឹងថាគាត់ហ្នឹងតួនាទីអីទេ។ ដល់ខ្ញុំមានគ្រួសារទៅនៅហ្នឹងទៅបានខ្ញុំគ្រាន់ស្គាល់ ស គឹមល្មុត ហ្នឹងគាត់នៅជាមួយ តារិទ្ធ ហ្នឹង ប៉ុន្តែមិនដឹងថាគាត់តួនាទីខាងអី ព្រោះបានទៅជួបគ្នាតិចតួចដែរ។

[១៤:១៩:៤៩]

**ស៖** នៅពេលដែលលោកស្រីរស់នៅជាមួយប្ដីរបស់លោកស្រី រហូតដល់ចុងបញ្ចប់នៃរបបនោះ គឺរស់នៅជាមួយនឹង តារិទ្ធ និង ល្មុត តើលោកស្រីធ្លាប់ឮអ្នកណានិយាយថា ខៀវ សំផន មានតួនាទីអ្វី

ដែរឬទេ ពាក់ព័ន្ធទៅនឹងក្រសួងពាណិជ្ជកម្មនេះ?

**ឆ៖** ខ្ញុំអត់ដែលឮគាត់ផង។ អត់ដែលឮថា ខៀវ សំផន ហ្នឹងទាក់ទងជាមួយ តាវិទ្ធ នៅខាងផ្នែកពាណិជ្ជកម្មហ្នឹងផង ខ្ញុំអត់ដែលដឹង។

**ស៖** តើលោកស្រីដឹងទេ នៅពេលដែលលោកស្រីធ្វើការនៅឯទួលទំពូង តើ ខៀវ សំផន គាត់ធ្លាប់បានទៅពិនិត្យមើលឃ្លាំងនៅទីនោះដែរឬទេ?

**ឆ៖** អត់ទេ អត់ដែលឃើញគាត់ទៅទេ។ ឃើញតែ តាវិទ្ធ ហ្នឹងគាត់អ្នកគ្រាន់តែទៅមើលត្រួតពិនិត្យមើលមួយភ្លែតអីអឺចឹងទៅ គាត់ក៏បកមកកន្លែងគាត់វិញមក បើថា តាខៀវ សំផន គឺខ្ញុំអត់ដែលឃើញ អត់ដែលស្គាល់គាត់តែម្តង។

**ស៖** ដើម្បីសួរបញ្ជាក់ឲ្យបានច្បាស់លាស់ ឈ្មោះបដិវត្តន៍របស់ ខៀវ សំផន គេហៅថា ហែម តើលោកស្រីធ្លាប់ដែលឮគេនិយាយថា បងហែម មកពិនិត្យឃ្លាំងរដ្ឋនៅឯទួលទំពូងនោះដែរឬទេ?

**ឆ៖** អត់ ៗដែលឮផង។ តាំងពីខ្ញុំចាប់ធ្វើការនៅកន្លែងសម្រិតសម្រាំងហ្នឹង អត់ដែលឮឈ្មោះ ហែម ហ្នឹងមកចូលរួមនៅកន្លែងហ្នឹងទេ ឃើញតែ តាហុង ហ្នឹង ហើយនិង តាវិទ្ធ ហ្នឹង។

**ស៖** លោកស្រីសាក្សី ឥឡូវនេះខ្ញុំសូមចូលទៅប្រធានបទថ្មីមួយ គឺការរៀបការ។ តើលោកស្រីអាចជម្រាបជូនតុលាការបានឬទេ ថាលោកស្រីត្រូវបានគេរៀបការឲ្យដោយរបៀបណាដែរ នៅក្នុងរបបនោះ?

[១៤:២២:១០]

**ឆ៖** ខ្ញុំសូមជម្រាបដល់អស់លោក ដែលខ្ញុំរៀបការនៅឆ្នាំ៧៨ ខែ១ អ៎! ខែ១១ហ្នឹង នាងខ្ញុំ មិត្តនៅក្នុងរួមនៅក្នុងក្រុមទាំងអស់ គេសុទ្ធតែមានចូលដណ្តឹងប្រហែល១ខែ២ខែមុន តែរូបខ្ញុំសួរពីល្ងាចព្រលឹមឡើងរៀប ហើយខ្ញុំក៏ប្រកែកថា មិនយកទេ។ រួចទៅគេថា មិត្តឯងមិនយក ក៏នៅតែអង្គការរៀបឲ្យដែរ មិត្តឯងមិនគោរពអង្គការវិន័យ មិត្តឯងប្រយ័ត្នខ្លួនបន្តិចទៅ។ ហើយខ្ញុំឯនេះ ក៏ឮអឺចឹងក៏ខ្ញុំមិនហ៊ានមាត់ដែរ។ ក៏ព្រលឹមឡើង ក៏គេយកខោអាវមកចែក ហើយក៏ទៅរៀបទៅ។ ក្នុងការរៀបហ្នឹង២១គូ ខ្ញុំចុងប៉ុចគេ។

**ស៖** លោកស្រីទើបតែបញ្ជាក់ដូចដែលលោកស្រីបញ្ជាក់នៅក្នុងកិច្ចសម្ភាសន៍របស់លោកស្រីដែរ ដែលថាមានគេប្រាប់លោកស្រីថាលោកស្រីត្រូវតែរៀបការ។ ហើយលោកស្រីបានបដិសេធ ប៉ុន្តែ <គេប្រាប់>លោកស្រី<ថា> ត្រូវតែរៀបការ។ តើអ្នកណាដែលបានប្រាប់លោកស្រីថា លោកស្រីត្រូវ

តែរៀបការ? <តើអ្នកប្រាប់ហ្នឹងមកពីពាណិជ្ជកម្មមែនទេ?>

**ឆ៖** អង្គាល់ហ្នឹង មានប្រធានរង ប្រធានកងឈ្មោះ មិត្តអ៊ីម នៅអីកន្លែងក្រសួងជាមួយ តាវិទ្ធ ហ្នឹង គាត់មកសួរខ្ញុំនៅពេលយប់។ ខ្ញុំក៏ប្រកែក ថាខ្ញុំអត់ទាន់យកទេ ព្រោះខ្ញុំនៅបំពេញការងារជូនបក្ស ខ្ញុំចេះតែប្រកែកថា មិនយកគ្រួសារអីចឹង។ គាត់ថា "សមមិត្តទោះបីសមមិត្តមិនយក ក៏នៅតែអង្គការ រៀបឲ្យដែរ"។ សមមិត្តមិនគោរពអង្គការវិន័យ ស្អីថា ឲ្យខ្ញុំសព្វគ្រប់ទៅ ខ្ញុំក៏មិនមាត់ដែរ។ ដល់ព្រលឹម ឡើងបានគេយក បើកឡានមកដឹកអាវសំពត់ ហើយនិងក្រមា មានថ្នាំដុសធ្មេញមួយដប សាប៊ូក្រអូប មួយដុំ ហើយនិងសាប៊ូម្សៅនោះមួយថង់ យកមកដើរចែកឲ្យតែប៉ុណ្ណឹង។ ហើយក៏ថ្ងៃរសៀលបន្តិចហ្នឹង ក៏បានហៅទៅកន្លែង គេធ្វើជាសាលាមួយសម្រាប់ប្រជុំអប់រំកម្មករហ្នឹង ក៏ទៅរៀបនៅកន្លែងហ្នឹងទៅ។ ទៅដល់ក៏គេហៅចូលទៅអង្គុយតម្រៀបជួរគ្នា បុរសដោយប្រុសទៅ ស្រីដោយស្រីទៅ ហើយគេឲ្យ យើងងើបគោរពទង់បក្ស តាំងពីតាវិទ្ធ តាំងពីតាហុង អីហ្នឹងទៅ គេឲ្យយើងគោរពទៅ ហើយបានគេ ហៅ ម្នាក់មួយគូ ម្នាក់មួយគូទៅចាប់ដៃគ្នា រួចទៅបានគេឲ្យមកអង្គុយជាប្តីប្រពន្ធមួយគូៗរៀងខ្លួនមក។ ដល់ពេលនេះទៅ ក៏គាត់អប់រំពីរឿងយើងរស់នៅមានជាគូស្វាមីហ្នឹងទៅ ឲ្យយើងហ្នឹងចេះសាមគ្គីគ្នា ចេះ ស្រឡាញ់គ្នា ខំប្រឹងធ្វើការងារជូនបក្សជូនប្រជាជនអីសព្វគ្រប់ទៅ បានឲ្យពួកខ្ញុំហ្នឹងចេញមកហូប បាយ។

[១៤:២៥:២៧]

**ស៖** តើ<នៅពេលណាដែល>លោកស្រីបានដឹងលើកដំបូងថា លោកស្រីត្រូវរៀបការជាមួយ អ្នកណា? តើ<គេប្រាប់>លោក<ស្រីនៅមួយយប់>មុន<រៀបការ ឬក៏>នៅពេលដែលលោកស្រីរៀប ការនោះតែម្តង<ដែល>លោកស្រីដឹងថាគេឲ្យរៀបការជាមួយអ្នកណា<>?

**ឆ៖** ដឹងនៅមុនថ្ងៃរៀបហ្នឹង។ សួរពីល្ងាច ព្រលឹមឡើងរៀបហ្នង។ រួចដល់ខ្ញុំប្រកែកទៅ ប្រកែកមិនឈ្នះគេ ក៏ខ្ញុំមិនមាត់ដែរ។ ព្រលឹមឡើងគឺបើគេដឹកអីវ៉ាន់ ខោអាវអីហ្នឹងយកមកចែកហ្នឹង គេ ប្រាប់ថា មិត្តឯងមិនបាច់ទៅធ្វើការងារទេថ្ងៃហ្នឹង មិត្តឯងទៅរៀបគ្រួសារ ក៏ឲ្យពួកខ្ញុំនៅដេកត្រៀមចាំ ហ្នឹង ម៉ោងប្រហែលពីរ បានគេហៅទៅកន្លែងសាលាអប់រំបង្រៀនហ្នឹង ទៅកន្លែងហ្នឹងទៅ។

**ស៖** ហើយបុរសដែលគេប្រាប់លោកស្រីថាត្រូវរៀបការជាមួយលោកស្រីហ្នឹង <តើ>ជាបុរស ម្នាក់ដែលលោកស្រី<ចង់រៀបការជាមួយទេ? តើជាអ្នកដែលលោកស្រី>បានធ្លាប់ស្គាល់ ហើយនិង ស្រឡាញ់ដែរឬអត់ទេ? <>

**ឆ៖** បុរសដែលខ្ញុំទទួលមកធ្វើជាស្វាមីខ្ញុំរាល់ថ្ងៃនេះ កាលដែលពេលនោះខ្ញុំអត់ដែលស្គាល់គាត់ គាត់ក៏អត់ដែលស្គាល់ខ្ញុំ។ គាត់នៅខាងក្រសួងជាមួយ តាវិទ្ធ នៅខាងវាយបញ្ចើ។ ខ្ញុំនៅខាងសម្រិតសម្រាំងអនុផលឯទួលទំពូងនេះ ប៉ុន្តែពេលដែលមកគេឱ្យមករៀនថ្ងៃ១០ ថ្ងៃ៣០អ៊ីចឹង ធ្លាប់ឃើញគាត់ដែរ។ ធ្លាប់ឃើញនឹង ដោយសារផ្ទុះសេខ្សែភ្លើង កង្ហារ រួចទៅ តាវិទ្ធ គាត់ស្រែកហៅ អ្ហ៎!មិត្តវ៉ាត់ មិត្តឯងឡើងទៅតភ្លើង។ គ្រាន់តែបានឃើញតែប៉ុណ្ណឹងទេ ប៉ុន្តែមិនបានចាប់អារម្មណ៍ពីនេះទេ កាលហ្នឹងក៏គាត់ក៏មិនទាន់មកស្នើខ្ញុំដែរ។

[១៤:២៧:៣៤]

**ស៖** លោកស្រីបានបញ្ជាក់ថា នៅពេលនេះ ថាលោកស្រីមិនចង់រៀបការជាមួយបុរសនោះទេ។ លោកស្រីប្រាប់ទៅអនុប្រធានលោកស្រីថា លោកស្រីមិនចង់រៀបការទេ។ តើលោកស្រីអាចជម្រាបជូនតុលាការបានឬទេ ថាហេតុអីបានជាលោកស្រី<ព្រមរៀបការ នៅពេលដែលលោកស្រី>មិនចង់រៀបការ? លោកស្រីបាននិយាយថា លោក<ស្រី>ខ្លាចណាស់អំពីថាខុសនឹងច្បាប់ ខុសនឹងវិន័យ។ អ៊ីចឹងតើលោកស្រីអាចជម្រាបបានទេ ថាមូលហេតុអីបានជាលោកស្រីត្រូវរៀបការនៅពេលដែលលោកស្រីមិនចង់រៀបការនោះ?

**ឆ៖** ខ្ញុំនឹកឃើញកាលនៅជំនាន់ហ្នឹង គឺខ្ញុំអត់ចង់បានគ្រួសារទេ បានជាខ្ញុំប្រកែក។ តាំងពី៧៥រហូតខ្ញុំប្រកែកផុតរហូត ទាល់តែដល់៧៨ហ្នឹង គឺប្រកែកគេលែងបាន។ ខ្ញុំចង់តែនៅម្នាក់ឯង ខ្ជិលចង់យកគ្រួសារ ខ្ញុំចេះតែប្រកែករហូតទៅ។ ទៅដល់ថ្ងៃនុំង គឺខ្ញុំប្រកែកទៅ គេសង្កត់ខ្ញុំជាប់។ គេថាទោះបីមិត្តមិនយក មិនរៀប ក៏ត្រូវតែអង្គការរៀបឱ្យដែរ។ មិត្តប្រកែកយ៉ាងណាក៏មិនបានដែរ មិត្តត្រូវតែគោរពអង្គការវិន័យ។ ខ្ញុំក៏លែងមាត់ត្រឹមហ្នឹងទៅ។

**ស៖** ខ្ញុំមានសំណួរពីរបី ពាក់ព័ន្ធទៅនឹងពិធីរៀបការ លោកស្រីបានបញ្ជាក់ថាគេបាននាំលោកស្រីទៅកាន់អគារធំមួយ។ តើលោកស្រីដឹងទេ អគារធំមួយដែលគេ<>នាំ<លោកស្រី>ទៅរៀបការហ្នឹងនៅឯ<ណា? តើនៅ>ទួលទំពូង ឬក៏ជាអគារនៅក្រសួងពាណិជ្ជកម្ម? តើគេនាំលោកស្រីទៅកាន់អគារធំមួយ ដើម្បីរៀបការហ្នឹងនៅត្រង់កន្លែងណា?

**ឆ៖** គឺមិនមែនអគារទេ គឺជាធ្វើជាសាលា សាលាបង្រៀនអប់រំពេលថ្ងៃ១០ ថ្ងៃ២០ ដែលពួកយើងជាកម្មករហ្នឹងធ្វើការហ្នឹងដល់ថ្ងៃ១០ គេឱ្យយើងទៅរៀន ដូចថារៀនជាវគ្គបណ្តុះបណ្តាលពីការងារ ពីការយើងធ្វើការហ្នឹងចំណេញអីខាតអ៊ីចឹងហ្នឹង គឺសាលាហ្នឹងនៅខាងកើតវត្តទួលទំពូង នៅ

ក្នុងភូមិប្រជាជន ក្បែរផ្ទះប្រជាជនហ្នឹង។

[១៤:៣០:១៣]

**ស៖** លោកស្រីបានឆ្លើយអម្បាញ់មិញនេះ ថាគូដែលរៀបការជាមួយលោកស្រីហ្នឹង គឺមានទាំងអស់២១គូ ហើយលោកស្រីបញ្ជាក់ថា <រដ្ឋមន្ត្រី>ក្រសួងពាណិជ្ជកម្ម តារិទ្ធ <និងអនុរបស់គាត់>ក៏មានវត្តមានក្នុងពិធីរៀបការនោះដែរ។ តើលោកស្រីដឹងថា មានកម្មាភិបាលណាចូលរួមក្នុងពិធីរៀបការនេះដែរឬទេ? ហើយបើដឹង តើមានអ្នកណាខ្លះដែរ?

**ឆ៖** ក្នុងពិធីរៀបការហ្នឹងមានតែ តារិទ្ធ ហើយនិង តាហុង ហ្នឹងទេ ដែលគាត់នៅក្ដោបក្ដាប់នៅកន្លែងហ្នឹង ហើយនិងមានដូចថាប្រធានកងខាងស្រីៗ ម្នាក់ពីរនាក់ដែរ ទៅចូលរួម។

**ស៖** តើឪពុកម្ដាយរបស់លោកស្រី ហើយនិងសាច់ញាតិរបស់លោកស្រីនោះ មានអ្នកណាខ្លះមានវត្តមាននៅក្នុងពិធីរៀបការនេះដែរឬទេ?

**ឆ៖** ពេលរៀបការហ្នឹងក្រុមគ្រួសារខ្ញុំអត់មានទេ ឪពុកម្ដាយខ្ញុំអត់ដឹងដែរ អត់ដឹងថាខ្ញុំរៀបទេ។ អត់មានជាសាច់ញាតិអីមួយទេ មានតែគ្រួសារហ្នឹង ហើយនិងគណៈដឹកនាំហ្នឹងតែម្ដង រៀបហ្នឹង អត់មានជាភ្ញៀវអីច្រើនមកចូលរួមទេ មានតែអ្នករៀប២១គូហ្នឹង ហើយនិង តារិទ្ធ ហើយនិង តាហុង ហើយនិងមេកងក្ដាប់ពីលើពួកខ្ញុំស្រីៗហ្នឹងពីរនាក់ទៀត។ ឪពុកម្ដាយខ្ញុំ គាត់អត់បានដឹងផង។

**ស៖** <តើអ្នកណាជាអ្នកដឹកនាំការរៀបការហ្នឹង?> តើអ្នកណាជាអ្នកឡើងថ្លែងនៅពេលដែលលោកស្រីរៀបការហ្នឹង ក្នុងពិធីហ្នឹងអ្នកណាឡើងថ្លែង?

[១៤:៣២:២៦]

**ឆ៖** មាន តារិទ្ធ គាត់អ្នកឡើងថ្លែងការណ៍។ គាត់ឡើងទៅនិយាយអប់រំឲ្យយើងគោរពបក្សគោរពវិន័យ គោរពអង្គការហ្នឹង មានតែ តារិទ្ធ ទេដែលគាត់ឡើងទៅនិយាយនៅកន្លែងពិធីរៀបការហ្នឹង។

**ស៖** តើលោកស្រីអាចជម្រាបជូនតុលាការបានទេ មានអ្វីកើតឡើងក្រោយពេលលោកស្រីរៀបការរួច?

**ឆ៖** ក្រោយពេលដែលខ្ញុំរៀបការរួច ខ្ញុំទៅនៅកន្លែង តារិទ្ធ ហ្នឹងនៅបានប្រហែលរយៈបីបួនខែហ្នឹង ក៏ទទួលដែលយួនចូលទៅ ក៏ពួកខ្ញុំក៏គាត់ឲ្យចេញទៅនៅភូមិភាគពាយ័ព្យ។ នៅពេលយប់ថ្ងៃទី០៦ ថ្ងៃទី០៧ គឺផ្ទុះពេញតែទីក្រុងភ្នំពេញ ខ្ញុំចេញទៅផុតទៅហើយ ទៅដល់ខេត្តកំពង់ឆ្នាំង ព្រលឹមឡើងផ្លាយ

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ទៅខេត្តពោធិ៍សាត់។

**ស៖** សូមទោស សំណួរខ្ញុំប្រហែលជាមិនច្បាស់លាស់គ្រប់គ្រាន់ទេ។ ខ្ញុំ<>និយាយអំពី<ថ្ងៃដែលលោកស្រីរៀបការ។> ក្រោយពេលលោកស្រីរៀបការហើយ តើគេមានប្រាប់លោកស្រីថាលោកស្រីត្រូវតែរស់នៅជាមួយនឹងប្តីដែរឬទេ? ហើយនៅថ្ងៃបន្ទាប់ពីថ្ងៃរៀបការហ្នឹង តើមានអ្វីកើតឡើងដែរចំពោះលោកស្រី?

**ឆ៖** កាលដែលពេលមកសួរខ្ញុំឱ្យខ្ញុំរៀបការហ្នឹងថា រៀបការរួច ពេលក្នុងរយៈមួយអាទិត្យបានឱ្យប្តីហ្នឹងមកលេងម្តង ស្រាប់តែពេលចាប់រៀបរួច ស្រាប់តែដេញពួកខ្ញុំឱ្យរៀបអីវ៉ាន់ហ្នឹងយកទៅនៅខាងប្តីហ្នឹងតែម្តង។ ចាស ដល់ពេលខ្ញុំទៅនៅខាងហ្នឹងទៅក៏ តារិទ្ធ ហ្នឹងក៏គាត់ចាត់តាំងខ្ញុំហ្នឹងនៅខាងដាំបាយ នៅខាងចង្ក្រានបាយ ខ្ញុំក៏នៅខាងដាំបាយទៅ ប្តីខ្ញុំក៏គាត់នៅខាងវាយបញ្ជើដដែលហ្នឹង។

**លោក ឌេល លីសាក់៖**

លោកប្រធានប្រហែលជាដល់ពេលអាចនឹងឈប់សម្រាកសិនហើយ។

**ប្រធានអង្គជំនុំ៖**

ឥឡូវដល់ពេលសម្រាកហើយ។ អង្គជំនុំជម្រះប្រកាសសម្រាក២០នាទី ចាប់ពីពេលនេះតទៅ។

*(សវនាការសម្រាកពីម៉ោង ១៤:៣៥ នាទី ដល់ម៉ោង ១៤:៥៤ នាទី)*

[១៤:៥៤:៥៥]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយ!

សូមអញ្ជើញលោកព្រះរាជអាជ្ញា មានសំណួរបន្ត។

**លោក ឌេល លីសាក់៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** លោកស្រីសាក្សី នៅក្នុងតុលាការនេះ នៅថ្ងៃ២៧ ឧសភា ២០១៣ យើងបានស្តាប់នូវចម្លើយដូចតទៅនេះ មកពី ខៀវ សំផន គឺម៉ោង១៤:៥៨ <E1/197.1>។ ខៀវ សំផន បាននិយាយដូចតទៅនេះ ខ្ញុំសូមដកស្រង់៖ “ចំពោះបញ្ហាការរៀបការដោយបង្ខំវិញ ខ្ញុំមិនដឹងអ្វីទាំងអស់ ពីព្រោះថាមន្ទីរទាំងអស់នៅជុំវិញភ្នំពេញ មិនមានហេតុការណ៍បែបនេះកើតឡើងនោះឡើយ។” សូមបញ្ចប់ការដក

ស្រង់។ ហើយលោកស្រីបានរៀបរាប់រួចហើយថា ក្រុមរបស់លោកស្រីបានរៀបការ។ ដូច្នេះខ្ញុំចង់សួរលោកស្រីអំពីបញ្ហាមួយចំនួន ថាតើមានការរៀបការផ្សេងៗទៀតនៅក្រសួង<ពាណិជ្ជកម្ម> ដែលលោកស្រីដឹងដែរឬទេ? ជាដំបូង ខ្ញុំចង់សួរថា នៅពេលដែលលោកស្រីធ្វើការនៅទួលទំពូង ពីឆ្នាំ៧៧ ដល់៧៨នោះ តើមានមនុស្សប្រហែលជាប៉ុន្មាននាក់ដែលធ្វើការរួមគ្នានៅឃ្លាំងនៅទួលទំពូងនោះ?

**លោកស្រី ផាន់ ហ៊ីមៈ**

**ឆៈ** រួមគ្នានៅធ្វើការនៅកន្លែងមន្ទីរទួលទំពូងហ្នឹង មានកងចល័តប្រុសប្រហែលមួយកងធំ កងចល័តស្រីហ្នឹងប្រហែលមួយកងធំដែរ លោកព្រះរាជអាជ្ញា នៅកន្លែងហ្នឹងរួមគ្នា។ តែកងចល័តប្រុសៗហ្នឹង គេឲ្យទៅខាងសម្រិតសម្រាំងខាងផ្លែគ នៅក្នុងវត្តទួលទំពូង។ មួយក្រុម ដកប្រហែលមួយក្រុមហ្នឹង ទៅខាងសម្រិតសម្រាំងអនុផលជាមួយពួកខ្ញុំ នៅខាងលីសែងឡើងឡាន។

[១៤:៥៧:២៩]

**សៈ** ខ្ញុំចង់បញ្ជាក់បន្តិច តើលោកស្រីធ្វើការនៅឃ្លាំងរដ្ឋ ឬក៏ថាកងចល័តរបស់លោកស្រីហ្នឹងគឺដាច់ចេញពីឃ្លាំងរដ្ឋនោះទេ?

**ឆៈ** ពួកខ្ញុំអត់មែននៅឃ្លាំងរដ្ឋទេ នៅខាងនេះហ្នឹង ខាងពាណិជ្ជកម្មក្នុងប្រទេសហ្នឹងតែម្ដង។ ចាស ពួកឃ្លាំងរដ្ឋ គេផ្សេង ពួកឃ្លាំងរដ្ឋ នៅខាងគីឡូលេខ៦ឯនេះ។

**សៈ** អ៊ីចឹងបានន័យថា លោកស្រីមិនដឹងថា មានឃ្លាំងស្តុកទំនិញនៅទួលទំពូងទេ តើលោកស្រីចង់និយាយអ៊ីចឹងមែនទេ?

**ឆៈ** អត់មាន មានឃ្លាំងស្តុកតែល្ង សណ្ដែកដី ហើយនិងឆ្អឹងឈើ -- អ្អេ! ឆ្អឹងសត្វតែប៉ុណ្ណឹងទេ អត់មានសម្ភារៈអីខុសពីហ្នឹងទៀតទេ។ មានតែល្ង សណ្ដែកដីដែលសម្រិតសម្រាំងហើយ នាំគ្នាយកទៅដាក់ឃ្លាំង ហើយដល់ពេលឡានមក លីចេញពីឃ្លាំង ដាក់ឡានយកទៅកំពង់សោម។ មានតែរបស់តែប៉ុណ្ណឹង ហើយនិងសំឡីគហ្នឹង។

**សៈ** សូមអរគុណដែលបានបញ្ជាក់។ លោកស្រីបាននិយាយអំពីការរៀបការរបស់លោកស្រីជាមួយនឹង២១គូ។ តើ<លោកស្រីមានដឹងអំពីការ>រៀបការ<របស់អ្នកផ្សេងទៀតទេ ដែលពួកគេជា>អ្នកដែលធ្វើការនៅទួលទំពូង ឬក៏<>អ្នក<ធ្វើការនៅកន្លែងផ្សេងទៀតក្នុងក្រសួងពាណិជ្ជកម្ម>?

[១៤:៥៩:៣៤]

**ឆៈ** រៀបការ២១គូហ្នឹង មានអ្នកមកពីកន្លែងគាត់ក្រៅប្រទេសហ្នឹង ពីរនាក់ដែរ ពីរនាក់ហ្នឹង

គាត់ មករៀបកន្លែងហ្នឹង។ ហើយកន្លែងក្រសួងជាមួយគាត់ហ្នឹង ក៏មកពីរបីនាក់ដែរ ដែលមករៀបនៅកន្លែងហ្នឹង។ កន្លែងគាត់ គាត់យក គាត់ស្នើក្នុងកន្លែងគាត់ហ្នឹង មករៀបនៅនឹងទួលទំពូងហ្នឹង ពីរបីនាក់ដែរ។ តែពួកខ្ញុំនៅឯទួលទំពូងណោះ ពីកន្លែងគាត់នៅកន្លែងហិរញ្ញវត្ថុហ្នឹង មកដណ្ដឹងពួកខ្ញុំនៅឯកន្លែងនេះណោះពីរនាក់ដែរ មករៀបទាំងអស់គ្នាហ្នឹង។ ហើយអ្នកនៅក្នុងកងនឹងទួលទំពូងហ្នឹង ក៏រៀបជាមួយគ្នាហ្នឹង ទាំងអស់សរុបទៅ២១គូ។

**ស៖** ប្រហែលជាខ្ញុំសួរមិនច្បាស់។ ខ្ញុំចង់សួរថា តើលោកស្រីដឹងអំពីពិធីរៀបការផ្សេងក្រៅពីការរៀបការ២១គូដែលគេរៀបចំឱ្យក្នុងក្រុមលោកស្រីហ្នឹង? តើក្រៅពីការរៀបការរបស់ក្រុមលោកស្រី ២១គូហ្នឹង លោកស្រីមានដឹងពីការរៀបការនៅខាងកន្លែងផ្សេងដែរឬទេ?

**ឆ៖** *(មីក្រូហ្វូនមិនទាន់ប្រតិបត្តិការ)*

**ប្រធានអង្គជំនុំ៖**

លោកស្រីឆ្លើយម្ដងទៀត ពីព្រោះពេលលោកស្រីឆ្លើយ មីក្រូហ្វូនមិនទាន់ប្រតិបត្តិការ។

**លោកស្រី ផាន់ ហ៊ីម៖**

**ឆ៖** ខ្ញុំអត់បានដឹងទេ ពីក្រសួងពីអង្គភាពផ្សេងៗខ្ញុំអត់ដែលដឹងដែរ។

[១៥:០១:១៤]

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** ឥឡូវនេះ ខ្ញុំនឹងលើកយកភស្តុតាងមួយចំនួនរបស់អតីតប្រធានឃ្លាំងរដ្ឋមួយរូបឈ្មោះ រស់ ស៊ុយ ដែលគាត់បានមកផ្ដល់សក្ខីកម្មនៅតុលាការនេះនាពេលកន្លងមក។ នៅក្នុងកិច្ចសម្ភាសន៍ជាមួយ ក.ស.ច.ស គាត់បានរៀបរាប់អំពីការដែលគាត់រៀបចំការរៀបការនៅឃ្លាំងរដ្ឋ។ លោក លោកស្រី គឺឯកសារ <E3/10620> គឺសំណួរចម្លើយ៧៥។ ហើយគាត់បានផ្ដល់សក្ខីកម្មដូចតទៅនេះ ខ្ញុំសូមដកស្រង់៖ "គឺមានផែនការដែលតម្រូវឱ្យកងនៅក្នុងឃ្លាំងរដ្ឋរៀបការមនុស្សឱ្យបាន១០០គូក្នុងមួយខែ។ អាយុរៀបការគឺចាប់ពី២០ឆ្នាំទៅ។" ហើយនៅសំណួរចម្លើយ៧៧, ៧៨ គឺបានសរសេរដូចតទៅនេះ៖ "ការរៀបការចាប់ផ្ដើមពីឆ្នាំ៧៦មក ប៉ុន្តែវិធានការម៉ឺងម៉ាត់ត្រូវចាប់ផ្ដើមនៅក្នុងឆ្នាំ៧៧ ប៉ុន្តែខ្ញុំមិនប្រាកដអំពីថ្ងៃខែនោះទេ។ សំណួរ៖ តើលោកមានន័យយ៉ាងម៉េចដែលថាវិធានការតឹងរ៉ឹងនោះ? ឆ្លើយ ខ្ញុំចង់មានន័យថា ១០០គូក្នុងមួយខែត្រូវរៀបការ។" សូមបញ្ចប់ការដកស្រង់។ ទាំងអស់នេះគឺជាចម្លើយរបស់ប្រធានឃ្លាំងរដ្ឋ។ ដូច្នេះខ្ញុំចង់សួរលោកស្រីថា លោកស្រីធ្លាប់ឮអំពីផែនការដែលថាគេត្រូវរៀប

ការមនុស្សឲ្យបាន១០០គូ ក្នុងមួយខែដែរឬទេ? ហើយថាតើលោកស្រីស្គាល់ឈ្មោះ ស៊ុយ នៅឃ្លាំងរដ្ឋ ដែរ ឬទេ?

[១៥:០៣:២២]

**ឆ៖** រឿងនេះ ខ្ញុំអត់ដឹងផង ព្រោះឃ្លាំងរដ្ឋនៅដាច់ឆ្ងាយពីកន្លែងពួកខ្ញុំ នៅឯគីឡូលេខ៦ឯណោះ ខ្ញុំអត់ដែលស្គាល់ផង។

**ស៖** ខ្ញុំសួរលោកស្រីមុននេះ ថាតើ ខៀវ សំផន ធ្លាប់ទៅទួលទំពូងដែរឬទេ។ ដូច្នេះតើលោកស្រីធ្លាប់ដឹងអំពីវគ្គរៀនសូត្រ ឬក៏វគ្គបណ្តុះបណ្តាលណាមួយដែលដឹកនាំដោយ ខៀវ សំផន សម្រាប់កម្មាភិបាលមកពីឃ្លាំង<រដ្ឋ ឬ>ក្រសួងពាណិជ្ជកម្មដែរឬទេ?

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោកមេធាវី ខៀវ សំផន!

**លោក គង់ សំអុន៖**

បាទ សូមអរគុណលោកប្រធាន។ ខ្ញុំសូមជំទាស់ចំពោះសំណួរនេះ ដោយហេតុថាសាក្សី គាត់មិនបានស្គាល់ ខៀវ សំផន រួចហើយ គាត់បានឆ្លើយបញ្ជាក់ចំណុចនេះ។ ដូច្នេះសកម្មភាពទាំងឡាយដែលទាក់ទងនឹង ខៀវ សំផន នោះគឺគាត់មិនអាចផ្តល់សក្ខីកម្មបានទេ ក្រៅតែពីការសន្និដ្ឋាននោះ។ បាទ សូមអរគុណ។

[១៥:០៤:៣៦]

**លោក ឌេល លីសាក់៖**

លោកប្រធាន នេះគឺជាចំណុចដែលខ្ញុំចង់សួរនោះហើយ។ ថាតើគាត់បានឮ ឬក៏បាន<ដឹងអ្វីមួយ>អំពីប្រធានបទ<ផ្សេងទៀត ខុសពីប្រធានបទ>ដែលខ្ញុំនិយាយរួចមកហើយ ដែលថាសួរថា <តើ>គាត់ធ្លាប់ឮអំពី ខៀវ សំផន ដឹកនាំការប្រជុំ ឬក៏វគ្គបណ្តុះបណ្តាលអ្វីនោះ?

**ប្រធានអង្គជំនុំ៖**

បដិសេធការជំទាស់។ អង្គជំនុំបន្តសំណួរ -- ព្រះរាជអាជ្ញាបន្តសំណួរ។

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** តើលោកស្រីធ្លាប់ឮថា ខៀវ សំផន ដឹកនាំវគ្គអប់រំរៀនសូត្រ ឬក៏វគ្គបណ្តុះបណ្តាលអ្វីដែរ ឬទេ<សម្រាប់កម្មករនៅក្រសួងពាណិជ្ជកម្ម>?

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**លោកស្រី ផាន់ ហ៊ីម៖**

**ផ៖** ខ្ញុំអត់ដែលបានដឹងផង។

**ស៖** ខ្ញុំចង់សួរលោកស្រីអំពីសក្ខីកម្មមួយចំនួន ដែលយើងបានស្តាប់ឮកាលពីម្សិលមិញ ក៏ដូចជានៅព្រឹកមិញមកពីដើមបណ្តឹងរដ្ឋប្បវេណីនារីម្នាក់ ដែលគាត់ធ្វើការនៅក្រសួងពាណិជ្ជកម្មដែរ ហើយគាត់ត្រូវបានគេបង្ខំឲ្យរៀបការ។ កាលពីម្សិលមិញនៅម៉ោង<១៣:៤៧ ទៅដល់១៣:៥០> គាត់បានផ្តល់សក្ខីកម្មអំពីវគ្គរៀនសូត្រមួយ ដែលដឹកនាំដោយ ខៀវ សំផន នៅវត្តខណ្ឌលោម ដែលនៅក្នុងការប្រជុំហ្នឹងគឺ ខៀវ សំផន បានប្រាប់ក្រុមបុរសស្ត្រីដូចតទៅនេះ ខ្ញុំសូមដកស្រង់៖ "គាត់បាននិយាយថា កម្មាភិបាលនារីទាំងអស់ត្រូវធ្វើការឲ្យរដ្ឋ។ ហើយអ្នកដែលមានអាយុចាប់ពី១៩ឆ្នាំឡើងទៅ <នៅគ្រប់ក្រសួងទាំងអស់>ចាំបាច់ត្រូវតែរៀបការ។ យើងមិនត្រូវទុកឲ្យពួកគាត់នៅលីវនៅឡើយ។ គាត់និយាយថា ពួកគេត្រូវរៀបការដើម្បីបង្កើតកូន ហើយនៅពេលដែលពួកគេបង្កើតកូន គឺយើងមានកងកម្លាំងដើម្បីការពារទឹកដីរបស់យើង។" សូមបញ្ចប់ការដកស្រង់។ លោកស្រីសាក្សី តើលោកស្រីធ្លាប់ឮអំពីគោលនយោបាយបែបនេះដែរឬទេ គឺថាធ្លាប់ឮពីមេដឹកនាំបក្ស ដែលធ្លាប់អាន ឧទាហរណ៍ថា <ពីតាវិទ្ធពី>ខៀវ សំផន ឬក៏អ្នកដទៃណា គេធ្លាប់អាន ឬក៏និយាយអំពីគោលនយោបាយបែបនេះដែរឬទេ? តើវាធ្វើឲ្យលោកស្រីអាចនឹកឃើញពីហេតុការណ៍ណាមួយទេ?

[១៥:០៧:១៤]

**ផ៖** រឿងអស់ទាំងនេះ ខ្ញុំអត់ដែលដឹងផង។

**ស៖** មុនពេលដែលខ្ញុំបន្តទៅប្រធានបទថ្មី។ ខ្ញុំចង់សួរអំពីប្រធានបទ អំពីចំណុចមួយទៀតដែលដើមបណ្តឹងរដ្ឋប្បវេណីម្នាក់បានផ្តល់សក្ខីកម្មកាលពីម្សិលមិញ ទាក់ទងទួលទំពូង។ ម្សិលមិញនៅប្រហែលជាម៉ោង១៤:០៤ នៅពេលរសៀល គាត់បានផ្តល់សក្ខីកម្មថា នៅយប់ដែលគាត់រៀបការនោះគាត់ ហើយនិងគូដទៃទៀត ត្រូវបានគេបញ្ជូនទៅស្នាក់នៅផ្ទះមួយនៅផ្សារទួលទំពូង ហើយគាត់បានរៀបរាប់អំពីអ្វីដែលកើតឡើងនៅយប់នោះថា ខ្ញុំសូមដកស្រង់៖ "នៅពេលដែលខ្ញុំទៅស្នាក់នៅនៅផ្សារទួលទំពូង មានមនុស្សម្នាក់ប្រាប់ខ្ញុំ ថាខ្ញុំត្រូវប្រយ័ត្នដោយសារគេតាមដានយើង។ បីគូ ស្នាក់នៅក្នុងផ្ទះផ្សេងៗ -- នៅបន្ទប់ផ្សេងៗគ្នា នៅផ្ទះមួយ ហើយនៅពេលយប់ខ្ញុំព្យាយាមលួចស្តាប់ ហើយខ្ញុំឮសូរសម្រិបជើង គឺពួកគេព្យាយាមឡើង -- គេឡើងតាមជណ្តើរមកលួចស្តាប់យើង ហើយពួកនោះគឺពួកឈ្លប"។ សូមបញ្ចប់ការដកស្រង់។ លោកស្រីសាក្សី តើលោកស្រីធ្លាប់ឮដែរឬទេ នៅពេលដែលលោក

ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។

ស្រីនៅទួលទំពូង តើលោកស្រីធ្លាប់ឮថា គេតាមដានប្ដីប្រពន្ធ គឺពួកឈ្លបតាមដានប្ដីប្រពន្ធក្រោយពេលរៀបការដែរឬទេ?

[១៥:០៨:៤៨]

**ឆ៖** ខ្ញុំអត់ដែលឮផង ព្រោះខ្ញុំរៀបរួច ខ្ញុំទៅនៅឯកន្លែងហិរញ្ញវត្ថុឯណោះបាត់ហើយ។

**ស៖** ២០គូទៀត ដែលគេរៀបការជាមួយលោកស្រីហ្នឹង តើ<មាននរណាមកស្នាក់នៅកន្លែងជាមួយលោកស្រីទេ ឬក៏>ពួកគេបន្តនៅទួលទំពូង<>?

**ឆ៖** ២១គូដែលរៀបជាមួយខ្ញុំហ្នឹង គឺមកនៅកន្លែងក្រសួងហិរញ្ញវត្ថុនេះបួនគូ ក្រៅពីហ្នឹងនៅនឹងវត្តទួលទំពូងហ្នឹងទាំងអស់ នៅនឹងខាងកើតវត្តទួលទំពូងហ្នឹង។ នៅនឹងកងចល័តហ្នឹង។

**ស៖** សូមអរគុណ។ ឥឡូវនេះខ្ញុំនឹងបន្តទៅប្រធានបទថ្មីមួយទៀត ទាក់ទងទៅនឹងអ្វីដែលលោកស្រីបានឆ្លើយនៅក្នុងកិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា។ តើលោកស្រីអាចប្រាប់បានទេថាលោកស្រីធ្លាប់ចូលរួមវគ្គរៀនសូត្រនយោបាយដែរឬទេ នៅក្នុងរបបនោះ ដែលនៅក្នុងវគ្គរៀនសូត្រនោះគឺ នួន ជា បានផ្ដល់នូវការណែនាំ? ហើយប្រសិនបើលោកស្រីធ្លាប់បានចូលកិច្ចប្រជុំបែបនេះ តើលោកស្រីអាចប្រាប់បានទេ ថាមានអ្វីកើតឡើងនៅក្នុងកិច្ចប្រជុំនោះ?

**ឆ៖** ការដែលខ្ញុំរស់នៅក្នុងរបបនុ៎ង គេហៅទៅប្រជុំនៅសាលាបុរីកីឡា ហើយមាន តានួន ជា ហ្នឹងគាត់ជាអ្នកបង្រៀនពីវគ្គបណ្ដុះបណ្ដាល ពីឲ្យយើងហ្នឹងខិតខំធ្វើការងារ ឲ្យយើងគោរពអង្គការវិន័យ គោរពបក្សគោរពអីហ្នឹង គ្រប់ពេលវេលាហ្នឹង ឲ្យខិតខំធ្វើការឲ្យបានល្អ បង្កើតផល។ ធ្វើ ដូចថាយើងធ្វើស្រែអីចឹង ១ហិកតាឲ្យបាន៣តោនគ្រប់ពេលវេលាឲ្យគាត់អីចឹង។ គាត់បាននិយាយអប់រំក្នុងសាលាហ្នឹង។

[១៥:១១:១៥]

**ស៖** ចំណុចមួយដែលខ្ញុំចង់ឲ្យបញ្ជាក់បន្តិច គឺថានៅ<រសៀល>នេះ គឺថា<លោកស្រី>បាននិយាយអំពីកិច្ចប្រជុំ<រយៈពេលមួយសប្ដាហ៍> ដែល<លោកស្រីហៅថា ជាវគ្គ>ប្រកាសអំពីពួកក្បត់ដែលពិធីប្រជុំហ្នឹង គឺកើតឡើងភ្លាមៗក្រោយពេលដែលលោកស្រីមកភ្នំពេញ គឺចេញជំរំកែប្រែ<វិញ។> ថាតើលោកស្រីនិយាយអំពីកិច្ចប្រជុំដែលដឹកនាំដោយ នួន ជា រយៈពេលមួយអាទិត្យហ្នឹង ឬមួយក៏កិច្ចប្រជុំផ្សេងទេ?

**ឆ៖** ដែលគាត់ហៅមកប្រជុំហ្នឹង ប្រជុំក្នុងពេលដែលខ្ញុំរៀបគ្រួសាររួចហើយ នៅឆ្នាំ៧៨នេះ។

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**សៈ** ខ្ញុំចង់ឲ្យលោកស្រីបញ្ជាក់បន្តិចគឺ កិច្ចប្រជុំ<នៅបុរីកីឡា>ដែល នួន ជា <និយាយ>នោះ គឺធ្វើឡើងក្រោយពេលលោកស្រីរៀបការហើយ។ តើអ៊ីចឹងមែនទេ?

**ផះ** ក្រោយពេលខ្ញុំរៀបការរួច។

**សៈ** តើ នួន ជា <នៅក្នុងអង្គប្រជុំនោះ>មានបាននិយាយអំពីការចាប់ខ្លួនជនក្បត់ឬទេ? ប្រសិនបើគាត់និយាយ តើគាត់និយាយយ៉ាងម៉េចខ្លះ?

**ផះ** ពីរឿងហ្នឹងយូរដែលហើយ ខ្ញុំភ្លេចខ្លះហើយ។ ខ្ញុំចាំបានថា គាត់គ្រាន់គាត់ថាឲ្យៗគោរពអង្គការវិន័យ ខំប្រឹងធ្វើការងារ បង្កបង្កើនផល ហើយឲ្យគោរពបក្ស គោរពអ្នកដឹកនាំហ្នឹង។

[១៥:១៣:៣១]

**សៈ** ឥឡូវនេះខ្ញុំសូមអានទូវសម្រង់របស់លោកស្រី ដែលលោកស្រីឆ្លើយជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជាអំពី<ការប្រជុំ>នេះគឺ នៅក្នុងកិច្ចសម្ភាសន៍ E3/9318 ខ្មែរមានលេខ 00058269 ដល់ 270, អង់គ្លេសមានលេខ <00679670>, បារាំងមានលេខ 00611552។ ខ្ញុំសូមដកស្រង់ គឺលោកស្រីបានឆ្លើយដូចតទៅនេះ៖ “សំណួរ៖ តើលោកស្រីធ្លាប់ចូលសន្និបាតកំណើតបក្សអីដែរទេ? លោកស្រីឆ្លើយថា៖ ខ្ញុំបានទៅម្តង។ <ខ្ញុំបានចូលរួមវគ្គ>ក្រោយពេលដែល<>ពួកក្បត់<នៅ>ខាងឧត្តរ<ត្រូវបានចាប់ខ្លួន។ ពួកគេនិយាយថា ពួកគេនឹងចាប់ផ្តើម>ចាប់<ខ្លួនមនុស្ស ដើម្បី>បោសសម្អាត<ពួកក្បត់ទាំង>អស់<>។ គេឲ្យយើងទៅប្រជុំនៅបុរីកីឡាហ្នឹង គេបើកជាវគ្គសន្និបាត ហើយគេឲ្យយើងស្តាប់គេប្រជុំ គេនិយាយពីការកសាងប្រទេស ពី១ហិកតា<១តោន ទៅ១ហិកតា>៣តោន។ គេចេះតែអប់រំយើងអ៊ីចឹងឲ្យយើងខំប្រឹងធ្វើទៅ។ ពួកអាក្បត់ដែលវាក្បត់ហ្នឹង គេចាប់អស់ហើយ យើងឈប់ភ័យឈប់ព្រួយអ៊ីចឹងទៅ។ សំណួរ៖ កាលនុំងពីណាគេមកប្រជុំ? <តើនរណាជាអ្នកថ្លែងសុន្ទរកថា>? ឆ្លើយ៖ នួន ជា គាត់ជាអ្នកប្រជុំ។ សំណួរ៖ កាលនុំងឆ្នាំណាទៅ? ឆ្លើយ៖ ឆ្នាំ៧៧។ សំណួរ៖ <តើអ្នក>ឧត្តរដែលគេថាក្បត់ហ្នឹងពីណាខ្លះទៅ មឹងមានចាំទេ? ឆ្លើយ៖ ពួក កុយ ធួន តាមរយៈឈ្មោះ អាញ៉ែម អីខ្លះទៀតទេ ខ្ញុំភ្លេចអស់ហើយ។” សូមបញ្ចប់ការដកស្រង់។ តើអ្វីដែលខ្ញុំអានជូនលោកស្រីហ្នឹង ធ្វើឲ្យលោកស្រីនឹកឃើញដែរឬទេ? តើលោកស្រីចាំទេថា នួន ជា បាននិយាយអំពីការចាប់ខ្លួនពួកក្បត់ដូចជាក្រុម កុយ ធួន ជាដើមនោះ?

**ផះ** ខ្ញុំភ្លេចអស់ទៅហើយ យូរដែរហើយ។

**សៈ** លោកស្រីបានប្រាប់<ឌី.ស៊ី.ខេម>ថា កិច្ចប្រជុំហ្នឹងឆ្នាំ៧៧ តើលោកស្រីចាំទេថា វា៧៧

ឬមួយក៏៧៨? អាចថាដោយសារលោកស្រីចាំមិនច្បាស់ គឺថាកិច្ចប្រជុំហ្នឹងធ្វើនៅ៧៧ ឬក៏៧៨?

[១៥:១៦:២៨]

**ឆ៖** កាលដែលចាប់ប្រជុំពួកឧត្តរក្បត់ហ្នឹង អាហ្នឹងពី៧៧។ ដល់ក្រោយមក ខ្ញុំរៀបគ្រួសាររួច ៧៨នេះ ប្រហែលៗកន្លះខែ រៀបរួចកន្លះខែ អាហ្នឹងទៅរៀនមួយសាទៀត ចាប់ឃួនចូលហ្នឹងតែម្ដង ហ្នឹង។ តែពីរវគ្គហ្នឹងទេ។

**ស៖** អ៊ីចឹងបានន័យថា មានការប្រជុំដែលគេប្រកាសពីពួកក្បត់នៅឧត្តរ។ ហើយការប្រជុំហ្នឹង ធ្វើឡើងនៅឆ្នាំ៧៧។ តើហ្នឹងគឺជាការប្រជុំដែលលោកស្រីនិយាយថា ជាការប្រជុំមួយសប្ដាហ៍ប្រកាសពី ពួកក្បត់មែនទេ? ប្រសិនបើ<អ៊ីចឹង>មែន<> តើ<>កិច្ចប្រជុំ<>ដែលគេនិយាយអំពីការចាប់ពួកក្បត់ នៅឧត្តរនោះ<គេរៀបចំកិច្ចប្រជុំនោះនៅឯណា>?

**ឆ៖** កាលដែលខ្ញុំទៅរៀនជាមួយគាត់នៅបុរីកីឡាឆ្នាំ៧២*(ស៊ីក)*ហ្នឹង អត់មានប្រកាសពីរឿង ពួកអា កុយ ឃួន ក្បត់ទេ។ តែខ្ញុំរៀននៅសាលា គេហៅសាលាក្រុងនៅនឹងផ្សារចាស់នេះអាហ្នឹងបានគេ ប្រកាសពីរឿង អាឃួន ក្បត់ – អាឃួន, អាញ៉ែម, អាឈឿន ដែលវាក្បត់ ដែលគេចាប់យកទៅអស់ ហ្នឹង។

**ស៖** តើអ្នកណាជាអ្នកដឹកនាំការប្រជុំ<នៅផ្សារចាស់> ដែលនិយាយអំពី កុយ ធួន ហើយនិង អ្នកដទៃទៀតនោះ?

**ឆ៖** ហ្នឹង តាហុង គាត់នៅបើកវគ្គនៅហ្នឹង។

**ស៖** ដើម្បីបញ្ជាក់ឲ្យបានច្បាស់ លោកស្រីនិយាយអំពី តាហុង ៗហ្នឹងគឺអនុប្រធាន តាវិទ្ធ នៅ ក្រសួងពាណិជ្ជកម្មហ្នឹងមែនទេ?

**ឆ៖** ចាស នៅក្រសួងពាណិជ្ជកម្មហ្នឹង។ តាហុង ហ្នឹងគាត់ក្ដាប់អង្គាល់ដែលគាត់មុននឹងទៅនៅ ឯទួលទំពូង គាត់នៅក្ដាប់នឹងផ្សារចាស់ហ្នឹង។

[១៥:១៩:០៦]

**ស៖** លោកស្រីបានរៀបរាប់អំពីវគ្គរៀនសូត្រ<នេះពីមុនមកថា មានរយៈពេល>មួយសប្ដាហ៍។ <> តើ តាហុង ជាមនុស្សម្នាក់ដែលមកនិយាយរហូតនៅក្នុងការប្រជុំហ្នឹង ឬក៏មានមនុស្សដទៃទៀត ឬ ក៏ថាមានថ្នាក់ដឹកនាំបក្សដទៃទៀតគេមកបង្រៀនដែរទេ?

**ឆ៖** មានតែ តាហុង ទេ ដែលគាត់ឡើងមកបង្រៀនហ្នឹង អត់មានអ្នកផ្សេងមកទេ។

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**សៈ** តើមានមនុស្សប៉ុន្មាននាក់ដែលចូលរួមនៅក្នុងការប្រជុំដឹកនាំដោយ តាហុង ដែលនិយាយអំពីពួកក្បត់នៅឧត្តរនោះ?

**ឆៈ** មានច្រើន គ្រប់ក្រសួងពាណិជ្ជកម្មក្រៅ ខាងផ្សារថ្មី និងក្រសួងពាណិជ្ជកម្មនៅនឹងផ្សារចាស់ហ្នឹង ចូលរួមគ្នាច្រើន។ កន្លែងផ្សារចាស់ហ្នឹង ក៏គេហៅកងចល័តដែរ ប៉ុន្តែពួកខ្ញុំមិនដែលទៅនៅចូលរួមជាមួយទេ ពួកខ្ញុំនៅឯផ្សារថ្មីនេះទេ ប៉ុន្តែចូលរួមប្រជុំហ្នឹង គឺច្រើន ពេញសាលា។ មិនដឹងក្រសួងណាខ្លះទេ ខ្ញុំអត់សូវដឹងដែរ។

**សៈ** ដូច្នេះដើម្បីបញ្ជាក់ឲ្យបានច្បាស់ថា ខ្ញុំយល់អ្វីដែលលោកស្រីចង់និយាយ គឺថាមានកិច្ចប្រជុំមួយដែលមានរយៈពេលមួយសប្តាហ៍ធ្វើឡើងក្នុងឆ្នាំ៧៧ ក្រោយពេលលោកស្រីត្រឡប់មកពីជំរំកែប្រែ ហើយការប្រជុំហ្នឹងដឹកនាំដោយ តាហុង។ ហើយបន្ទាប់មក មានការប្រជុំមួយទៀត ក្នុងឆ្នាំ៧៨ នៅបុរីកីឡា ដែលការប្រជុំហ្នឹង ដឹកនាំដោយ នួន ជា អ៊ីចឹងមែនទេ?

**ឆៈ** កាលហ្នឹងដឹកនាំដោយ តានួន ជា។

[១៥:២១:០៩]

**សៈ** តើវគ្គអប់រំរៀនសូត្រនៅបុរីកីឡាដឹកនាំដោយ នួន ជា មានរយៈពេលប៉ុន្មានថ្ងៃដែរ?

**ឆៈ** រៀនតែ១ថ្ងៃទេ។

**សៈ** តើអ្នកចូលរួមវគ្គរៀនសូត្រនុំង មានប៉ុន្មាននាក់ដែរ? ហើយពួកគាត់ហ្នឹងមកពីខាងណាដែរ?

**ឆៈ** កាលដែលចូលរួមរៀននៅវគ្គក្នុងពេលរយៈ១ថ្ងៃហ្នឹង មនុស្សច្រើនណាស់ពេញមួយសាលាបុរីកីឡាហ្នឹង ប៉ុន្តែមិនដែល ខ្ញុំអត់ដឹងថា មកពីក្រសួងណាខ្លះ។ ដឹងតែក្រសួងពាណិជ្ជកម្មក្នុងប្រទេសក្រៅប្រទេសហ្នឹងចូលទៅជាមួយគ្នា។

**សៈ** សូមអរគុណលោកស្រីសាក្សី។ ចំណុចមួយទៀតដែលខ្ញុំចង់សួរលោកស្រីផងដែរ មុននឹងខ្ញុំបន្តទៅប្រធានបទថ្មី គឺថាប្រធានឃ្លាំងរដ្ឋឈ្មោះ រស់ ស៊ុយ បានផ្តល់សក្ខីកម្មទាក់ទងទៅនឹងវគ្គរៀនសូត្រដែលគាត់ចូលរួមនៅបុរីកីឡាផងដែរ គឺជាការប្រជុំដែលដឹកនាំដោយ នួន ជា។ ហើយនៅក្នុងកំណត់ហេតុស្តាប់ចម្លើយរបស់គាត់ E3/469, ខ្មែរមានលេខ <00172052>, អង់គ្លេសមានលេខ 00205113 និងបារាំងមានលេខ 00524390 ដល់91។ គាត់បានឆ្លើយដូចតទៅនេះ ខ្ញុំសូមដកស្រង់៖ “នៅក្នុង<វគ្គរៀនសូត្រ>ឆ្នាំ៧៧ <> នួន ជា បានចាក់កាសែតដែលជាចម្លើយសារភាពរបស់ កុយ

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ធួន។” សូមបញ្ចប់ការដកស្រង់។ តើលោកស្រីនឹកឃើញដែរឬទេ ថានៅពេលដែលលោកស្រីចូលនៅក្នុងការប្រជុំមួយ គឺមានគេចាក់កាសែតឲ្យស្តាប់ពីចម្លើយសារភាពរបស់ កុយ ធួន ឬក៏ថា លោកស្រីបានស្តាប់ឮពីអ្នកដទៃនៅពាណិជ្ជកម្ម ដែលគេនិយាយអំពីការប្រជុំមួយដែលគេចាក់កាសែតឲ្យស្តាប់សំឡេងនោះ?

[១៥:២៣:៥០]

**ឆ៖** ខ្ញុំអត់បានដឹងផង រឿងគេចាក់កាសែតពី កុយ ឃួន ហ្នឹង។

**ស៖** ខ្ញុំមានសំណួរពីរបីទៀត ដើម្បីសាកសួរលោកស្រី ទាក់ទងទៅនឹងការចាប់ខ្លួន ឬក៏ការបាត់ខ្លួនរបស់កម្មាភិបាលដែលធ្វើការជាមួយលោកស្រី<នៅក្នុងរបបនោះ> ជាពិសេសក្នុងឆ្នាំ៧៧ ដល់ឆ្នាំ៧៨។ តើលោកស្រីអាចប្រាប់យើងខ្ញុំបានទេ ថានៅពេលដែលលោកស្រីនៅជំរំកែប្រែនៅជិតពោធិ៍ចិនតុង ឬក៏នៅពេលដែលលោកស្រីធ្វើការនៅពាណិជ្ជកម្មនៅភ្នំពេញហ្នឹង តើលោកស្រីធ្លាប់ឃើញគេយកមនុស្ស គេចាប់ខ្លួនយកមនុស្សទៅទេ? ប្រសិនបើលោកស្រីបានឃើញ សូមលោកស្រីរៀបរាប់អំពីហេតុការណ៍ទាំងនោះ?

**ឆ៖** ចាស ពេលដែលគេចាប់ពួកក្បត់អស់ទៅ រំលងបានប្រហែលខ្ញុំទៅរៀនបានប្រហែលមួយថ្ងៃពីរថ្ងៃអ៊ីចឹង ស្រាប់តែស្អែកឡើង កន្លែងផ្សារថ្មីពួកកន្លែងខ្ញុំនៅហ្នឹង ពេលយប់ម៉ោងប្រាំមួយឡើងស្រាប់ឃើញឡានមួយមក។ ហើយមកដល់ឃើញមានកាំភ្លើងមានអី ឃើញលោតពីលើឡានហ្នឹងព្រូសៗទៅ ឡើងទៅ ឃើញចាប់បន្តបន្ទាប់គ្នាទៅ មិនដឹងចាប់យកទៅខាងណា ខ្ញុំអត់ដឹងដែរ។ ពួកខ្ញុំក៏ឃើញអ៊ីចឹង ក៏អត់ហ៊ានចេញមកមើលដែរ នាំគ្នាចូលពួនក្នុងផ្ទះអស់វិញទៅ។ មិនដឹងគេចាប់យកទៅណាមកណា។

**ស៖** តើលោកស្រីអាចប្រាប់បានទេ ថាលោកស្រីឃើញគេចាប់មនុស្សដាក់ឡានហ្នឹង ឃើញនៅកន្លែងណាដែរ?

**ឆ៖** ឃើញៗនៅមុខមន្ទីរចាត់ការផ្សារថ្មីហ្នឹង ឃើញឡានមកដល់ឈប់ត្រង់ហ្នឹងទៅ ឃើញលោតចុះពីលើឡានប្រូសៗទៅ ឃើញឡើងទៅលើផ្ទះ ឡើងទៅ ពួកខ្ញុំគ្រាន់តែឃើញហេតុការណ៍អ៊ីចឹងក៏ខ្លាច ក៏អត់ហ៊ានមើល ក៏នាំគ្នារត់ចូលក្នុងផ្ទះបាត់អស់ទៅ ដឹងគេចាប់ទៅណាមកណាអត់ដឹង។

[១៥:២៦:១៤]

**ស៖** ហេតុការណ៍ហ្នឹង គឺកើតឡើងក្នុងពេលជាមួយគ្នានឹងការប្រជុំដែលលោកស្រីនិយាយថា

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

តាហុង ប្រកាសអំពីការចាប់ខ្លួនពួកក្បត់ហ្នឹង ឬមួយក៏ហេតុការណ៍ហ្នឹង វាកើតឡើងនៅពេលផ្សេងទេ មិនមែននៅក្នុងពេលជាមួយគ្នានឹងការប្រជុំដឹកនាំដោយ តាហុង នោះទេ?

**ឆ៖** ពេលហេតុការណ៍ហ្នឹងកើតឡើងនៅពេលដែលប្រជុំរួចបានមួយថ្ងៃពីរថ្ងៃ។ ដូចថានៅស្រាវជ្រាវ គេថាដូចថានៅតាមរយៈវាមិនទាន់អស់ ពួកខត្តរក្បត់ហ្នឹង ឮគេថាអីចឹង ក៏ស្រាប់យប់ឡើងឃើញឡានមកឈប់ទៅ ឃើញលោតព្រូសៗទៅ ឡើងទៅចាប់សុទ្ធតែពួកកម្មាភិបាលខាងគេហ្នឹង គេចាប់ដាក់ទៅ។ ក៏ពួកខ្ញុំក៏មិនប៉ាន មិនបានមើលដែរ ភ័យខ្លាចគ្រប់តែគ្នា នាំគ្នាចូលផ្ទះ បិទទ្វារបិទអីអស់ទៅ។

**សៈ** តើគេចាប់មនុស្សដាក់ឡានប៉ុន្មាននាក់ដែរលោកស្រី?

**ឆ៖** ពេលដែលព្រលឹមឡើងបានដឹងថាបាត់កម្មាភិបាលពីរនាក់ ឈ្មោះ អាភី មួយ, ឈ្មោះ អាឌឿន មួយ។ អាឌឿន ហ្នឹងនៅខាងកាន់បញ្ជីចែកចាយផ្សាររដ្ឋហ្នឹង។ ហើយ អាភី ហ្នឹងក្តាប់ពីលើហ្នឹងទៀត ក្តាប់ពីលើពាណិជ្ជកម្មហ្នឹង កាលពីដែលវានៅក្តាប់នឹងផ្សារថ្មីហ្នឹង។

**សៈ** តើអ្នកណាជាអ្នកប្រាប់លោកស្រីថា គេចាប់ខ្លួនមនុស្សពីរនាក់នេះ?

[១៥:២៨:០២]

**ឆ៖** ប្រពន្ធគាត់។ ព្រលឹមឡើងប្រពន្ធគាត់ថា យប់មិញគេចាប់ប្តីខ្ញុំទៅបាត់អស់ហើយ។ ខ្ញុំក៏អត់ប៉ានសួរវែកញែកអីដែរ ព្រោះកាលហ្នឹងកំពុងច្របូកច្របល់ ភ័យខ្លាចតែលាក់តែខ្លួនៗឯង អត់ប៉ានសួរគេដេញដោលទេ។

**សៈ** ឥឡូវនេះខ្ញុំចង់ឲ្យលោកស្រីបញ្ជាក់បន្តិច នៅក្នុងកំណត់ហេតុស្តាប់ចម្លើយជាមួយមជ្ឈ-មណ្ឌលឯកសារកម្ពុជា E3/9318 គឺខ្មែរមានលេខ <00058271>, អង់គ្លេសមានលេខ <00679 672> និងបារាំងមានលេខ 00611554។ ហើយនៅក្នុងផ្នែកនេះគឺលោកស្រីបានរៀបរាប់អំពី<រយៈពេលដែលលោកស្រីនៅក្នុង>ជំរំកែប្រែនៅជិតពោធិ៍ចិនតុង ខ្ញុំសូមដកស្រង់ នេះគឺជាអ្វីដែលលោកស្រីនិយាយ៖ “ខ្ញុំត្រូវបានគេអប់រំឲ្យ<លើក>ទំនប់ដីកប្រឡាយ ហើយយើងធ្វើការ<ក្នុងវាលស្រែ>នៅខាងជើងផ្លូវគឺនៅក្បែរផ្លូវរទេះភ្លើង។ ខ្ញុំឃើញគេដឹកមនុស្សចេញតាមឡានសឹងតែរាល់ថ្ងៃ។” សូមបញ្ចប់ការដកស្រង់។ តើអ្វីដែលខ្ញុំអានហ្នឹង ធ្វើឲ្យលោកស្រីនឹកឃើញដែរឬទេ ដែលថានៅពេលនោះ គឺថាមុនពេលដែលលោកស្រីត្រឡប់មកភ្នំពេញវិញហ្នឹង <តើ>លោកស្រីឃើញគេចាប់មនុស្សដាក់ឡាននៅក្នុងជំរំអប់រំកែប្រែនៅជិតពោធិ៍ចិនតុងនោះ<ទេ>?

**ឆ៖** កន្លែងហ្នឹងហើយ ដែលកន្លែងខ្ញុំទៅលត់ដំ។ គេចាប់នៅក្នុងកងពួកខ្ញុំហ្នឹងតែម្តង។ ល្ងាចឡើង ឡានឃ្លុបមួយមក មកដល់ ស្រាប់តែទាញក្រដាសមួយមកហៅឈ្មោះប្រុសៗទៅ គ្នារកតែរៀបចំខោអាវក៏មិនទាន់ដែរ ចេះតែបង្ខំលឿនៗ ប្រញាប់។ គ្នាទៅ ទាំងនេះនោះ អាខ្លះក៏ខោអាវនៅហាលអីមិនទាន់ អត់បានយកទៅ។ ចេះទៅម្តងមួយឡានហ្នឹង ឡានហ្នឹងមិនមែនឡានធំប៉ុន្មានទេ ឡានតូចដែរទេ ឡាន គេហៅឡានអង្គការ អាមានដាក់កង់ពីក្រោយហ្នឹង ក៏ឃ្លុបជិត។ ស្រាប់តែឡើងពេញទៅ ស្រាប់តែឃើញបើកទៅលិចបាត់ទៅ។ ហើយពួកខ្ញុំនេះចេះតែភ័យព្រួយ អើថ្ងៃណោះគេ ស្អែកយើងហើយមើលទៅ ចេះតែទន្ទេញអ៊ីចឹង។

[១៥:៣០:៤៨]

**ស៖** ហើយនៅក្នុងកិច្ចសម្ភាសន៍ជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា លោកស្រីឆ្លើយថា ហេតុការណ៍ហ្នឹងកើតឡើងសឹងតែរាល់ថ្ងៃ តើវាត្រឹមត្រូវដែរឬទេ?

**ឆ៖** ហេតុការណ៍នេះ កើតឡើងដូចខ្ញុំបានជម្រាបខាងលើអ៊ីចឹងថា វាឱ្យយើងស្ងប់ប្រហែលបួនប្រាំថ្ងៃហ្នឹង ស្រាប់ឡានមកដល់ទៀតហើយ ឱ្យព្រលប់ប្រហែលម៉ោងព្រាលៗ ម៉ោងប្រាំមួយម៉ោងប្រាំពីរហ្នឹង ឡានមកដល់ហើយ អាពេលស្ងាត់ហ្នឹង។ ដឹកទៅមួយជើងអ៊ីចឹងទៅ រំលងប្រហែលបួនប្រាំថ្ងៃហ្នឹង ឃើញឡានហ្នឹងមកទៀតហើយ។ ដល់ពេលចុងក្រោយហ្នឹងពួកខ្ញុំ វាហៅទៅឡើងឡានហ្នឹងទៅដល់ឡានពេញទៅ ក៏វាប្រាប់ថា ចាំជើងក្រោយទៅ។ រួចពួកខ្ញុំក៏សួរថា ចុះយកពួកខ្ញុំទៅខាងណាវិញ ពួកមិត្តយើងដែលដឹកទៅមុនៗហ្នឹង? ថាយកទៅកំពង់កន្ទួត យកកន្លែងមន្ទីរកំពង់កន្ទួតហ្នឹង បន្តិចទៀតគេដឹកយកទៅឱ្យជួបពុកម៉ែហើយ ថាអ៊ីចឹង។

**ស៖** សូមអរគុណលោកស្រីសាក្សី ខ្ញុំមានប្រធានបទមួយទៀតទេ។ ឥឡូវនេះខ្ញុំចូលទៅនិយាយអំពីកិច្ចប្រជុំមួយនៅឯបុរីកីឡាដែល នួន ជា ធ្វើជាអធិបតីភាព។ កិច្ចសម្ភាសន៍របស់លោកស្រី<ជាមួយ ឌី.ស៊ី.ខេម>គឺ E3/9318, អង់គ្លេស 00679667, ខ្មែរ 00058266, បារាំង 00611549 ដល់550។ នេះគឺលោកស្រីឆ្លើយពាក់ព័ន្ធទៅនឹងកិច្ចប្រជុំនៅឯបុរីកីឡា<ដឹកនាំដោយ> នួន ជា ដែលលោកស្រីបាននិយាយថា សូមដកស្រង់៖ “គេបានចែក<ក្រដាសអត្ថបទ>ឱ្យយើង” បញ្ចប់ការដកស្រង់។ តើ<លោកស្រីចាំទេ ក្រដាសអត្ថបទ>ដែលគេចែកជូននៅពេលដែលលោកស្រីប្រជុំជាមួយនឹង នួន ជា <នោះនិយាយអំពី>អ្វីដែរ?

[១៥:៣៣:០៣]

**ឆ៖** ខ្ញុំអត់បានទទួលផង កូនសៀវភៅហ្នឹង។ ក្រែងគេចែកមិនអស់ក៏មិនដឹង អីមិនដឹង ខ្ញុំអត់បានទទួល អារឿងកូនសៀវភៅហ្នឹង។

**ស៖** ប្រធានបទចុងក្រោយដែលខ្ញុំត្រូវសួរអ្នកស្រីនៅថ្ងៃនេះ គឺ<អ្វីៗដែលលោកស្រីបាននិយាយនៅក្នុង>កិច្ចសម្ភាសន៍របស់លោកស្រី។<> តើលោកស្រីនេះមានសាច់ញាតិដែលត្រូវបានចាប់ខ្លួន និងសម្លាប់ចោលនៅក្នុងរបបខ្មែរក្រហមដែរឬទេ?

**ឆ៖** ខ្ញុំមានបងបង្កើត មានបងជីដូនមួយ មានម្ដាយមីងនៅឯស្រុក គេចាប់យកទៅសម្លាប់ចោលនៅពេលនៅឆ្នាំ៧៧។ បងប្រុសខ្ញុំជាប់និន្នាការធ្វើទាហាន១ខែ។ ហើយម្ដាយមីងខ្ញុំច្រើនគ្រួសារ វាយកទៅបាត់អស់ ចោទគាត់ថា គាត់សុទ្ធតែពួកសក្ដិភូមិ យកគាត់ទៅសម្លាប់ទាំងពូជ។ កាលហ្នឹងខ្ញុំនៅទីក្រុងភ្នំពេញ ខ្ញុំអត់ដឹងទេ ដល់ពេលដាច់ទៅ ខ្ញុំទៅផ្ទះ បានដឹង។

**ស៖** បងប្រុសលោកស្រី ដែលត្រូវបានគេចោទប្រកាន់ថាធ្វើជាទាហាននោះ តើគាត់គឺជាទាហានរបប លន់ នល់ ឬ?

**ឆ៖** កាលហ្នឹងគាត់ធ្វើទាហាននៅរបប លន់ នល់ ហ្នឹង តែគេចាប់ទេ គាត់មិនបានស្ម័គ្រចិត្តចូលទេ។ ប៉ុន្តែចូលបានតែត្រឹមមួយខែ អត់ឃើញបើកប្រាក់ខែឲ្យ ដល់ពេលអ៊ីចឹងទៅ ក៏គាត់ទៅសួរឪពុកខ្ញុំថា ខ្ញុំធ្វើទាហានដើម្បីចិញ្ចឹមជិវិត បើគេអត់បើកលុយឲ្យអ៊ីចឹង តើពុកឲ្យខ្ញុំគិតអាម៉េច? ឪពុកខ្ញុំថា ដោះស្រាយខ្លួនឯងទៅធ្វើ ម៉េចឲ្យរួចខ្លួន។ គាត់ក៏គេចរត់ទៅ។

[១៥:៣៥:៤៤]

**ស៖** តើមានតែបងប្រុសរបស់លោកស្រីទេឬ ដែលត្រូវបានគេសម្លាប់ចោលហ្នឹង? ចុះប្រពន្ធរបស់គាត់ និងកូនប្រុសរបស់គាត់នេះយ៉ាងម៉េចដែរ?

**ឆ៖** ចាប់យកទៅទាំងអស់ តាំងពីកូន ហើយនៅក្នុងពោះក៏មាន។ ចាប់ទៅ បងថ្លៃខ្ញុំគាត់ឈឺពោះនៅលើឡានហ្នឹង វាអូសដៃឡើងទៅ គាត់ស្រែកថា “កុំអូសខ្ញុំខ្លាំងពេក ខ្ញុំកំពុងតែឈឺពោះ។” វាថា “ឈឺពោះក៏ដោយឡើងឲ្យផុតមក គង់តែទៅដល់កន្លែងមន្ទីរពេទ្យកើតទេ។” ដឹកដៃកូនឡើងទៅ វាអូសឡើងទៅដល់លើឡានទៅ បងជីដូនមួយខ្ញុំ ប្រាប់ប្រពន្ធឈឺពោះដែរ ក៏ចេះអូសគ្នាឡើងឡានទាំងអស់ហ្នឹងទៅ ហើយទាំងពូជហ្នឹង បីបួនគ្រួសារហ្នឹង។ ហើយម្ដាយមីងខ្ញុំហ្នឹង ក៏គាត់យកទៅប្រហែលបីបួនគ្រួសារដែរយកទៅហ្នឹង គាត់ទើបជម្លៀសចេញពីទីក្រុងភ្នំពេញទៅ។

[១៥:៣៦:៥៦]

**ស៖** លោកស្រីបានបញ្ជាក់នៅក្នុងកិច្ចសម្ភាសន៍មួយរបស់លោកស្រីថា បងប្រុសរបស់លោកស្រី និងប្រពន្ធរបស់គាត់ដែលមានផ្ទៃពោះ ហើយនិងកូនប្រុសម្នាក់ ក៏ត្រូវបានគេយកទៅសម្លាប់ចោលដែរ។ តើកូនប្រុសរបស់គាត់ដែលគេយកទៅបាត់ដែរហ្នឹងអាយុប៉ុន្មានឆ្នាំ?

**ឆ៖** ដឹង ខ្ញុំអត់សូវដឹង ព្រោះខ្ញុំចេញផុតមកនេះហើយ។

**ស៖** លោកស្រីក៏បាននិយាយរួចមកហើយ ថានេះគឺអ្វីដែលលោកស្រីបានដឹង នៅពេលលោកស្រីត្រឡប់ទៅផ្ទះនៅឯភូមិរបស់លោកស្រីក្រោយរបបនោះដួលរំលំទៅ។ តើអ្នកណាជាអ្នកដែលប្រាប់លោកស្រីថា បងប្រុសរបស់លោកស្រី ហើយនិងក្រុមគ្រួសារទាំងមូលរបស់គាត់បាត់ទៅ គឺត្រូវគេយកទៅសម្លាប់ចោល?

**ឆ៖** ម្ដាយខ្ញុំ។ ខ្ញុំទៅដល់ផ្ទះ បានម្ដាយគាត់ប្រាប់ពីរឿងប្រវត្តិបងហ្នឹង គេយកទៅសម្លាប់ចោលហ្នឹង។

**លោក ឌេល លីសាក់៖**

សូមអរគុណច្រើនការចំណាយពេលវេលាលោកស្រីសាក្សី។ អស់សំណួរហើយលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

អរគុណលោកព្រះរាជអាជ្ញា។

សូមអញ្ជើញមេធាវីនាំមុខដើមបណ្ដឹងរដ្ឋប្បវេណី!

[១៥:៣៨:៣៨]

**ការតាំងសំណួរដោយសហមេធាវីដើមបណ្ដឹងរដ្ឋប្បវេណី**

**សួរដោយលោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

**ស៖** សូមអរគុណលោកប្រធាន។ ជម្រាបសួរលោកស្រីសាក្សី ខ្ញុំឈ្មោះ ម៉ារី ហ្គីរ៉ូដ៍ ខ្ញុំតំណាងឱ្យក្រុមជនរងគ្រោះដែលបានដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿងនេះ។ ខ្ញុំមានសំណួរមួយចំនួនតូចដើម្បីសួរលោកស្រី ពាក់ព័ន្ធនឹងការរៀបអាពាហ៍ពិពាហ៍របស់លោកស្រីនៅឆ្នាំ១៩៧៨។ លោកស្រីបាននិយាយអំពីពិធីរៀបអាពាហ៍ពិពាហ៍ ហើយនិងការប្ដេជ្ញានៅថ្ងៃនោះ។ លោកស្រីបានបញ្ជាក់ថា តារិទ្ធ ជាអ្នករៀបចំពិធីនោះ។ តើមានអ្នកណាប្រាប់លោកស្រីទេនៅថ្ងៃរៀបការនោះថាលោកស្រីត្រូវតែរួមដំណេកជាមួយនឹងគ្រួសារលោកស្រី?

**លោកស្រី ផាន់ ហ៊ឹម៖**

**ឆ៖** អត់មានគេប្រាប់ផង ប៉ុន្តែគ្រាន់តែគេដឹកចេញពីកន្លែងទួលទំពូងទៅ ឲ្យទៅនៅខាងប្រុសហ្នឹង ខាងក្រសួងហិរញ្ញវត្ថុហ្នឹង។ គេធ្វើរៀបជាបន្ទប់មួយឲ្យ រួមរស់នៅជាមួយគ្នានៅក្នុងបន្ទប់ហ្នឹងទៅ អត់មានអ្នកណាគេទៅប្រាប់ពីរឿងអីចេះរឿងអីចុះផង។

**ស៖** លោកស្រីអាចជម្រាបជូនតុលាការបានទេថា ក្រោយពីរៀបការហើយ លោកស្រីនិងប្តីនុំង បានរួមដំណេកគ្នាទេ<ពេលដែលលោកស្រីបានចូលជាមួយគាត់ នៅក្នុងបន្ទប់តូចដែលគាត់រស់>នៅក្រសួងហិរញ្ញវត្ថុហ្នឹង?

**ឆ៖** ក្រោយពេលរៀបការរួចហើយ រូបខ្ញុំនិងគ្រួសារខ្ញុំក្នុងពេលដែលថ្ងៃរៀបហ្នឹង អត់ដែលបាននេះទេ ទាល់តែបានប្រហែលកន្លះអីបានៗរួមដំណេកគ្នា ព្រោះអង្កាល់ហ្នឹងអត់ទាន់ស្គាល់ចិត្តគ្នា អត់ស្រឡាញ់គ្នាផង។

[១៥:៤១:០៣]

**ស៖** សូមអរគុណដែលលោកស្រីបានឆ្លើយបញ្ជាក់។ ពេលដែលលោកស្រីសម្រេចចិត្តរួមដំណេកជាមួយប្តីលោកស្រីកន្លះខែ<ឬមួយខែ>ក្រោយមកនោះ ពេលនុំងគឺថាមានការព្រមព្រៀងគ្នាជាមួយនឹងប្តីលោកស្រីមែនទេ?

**ឆ៖** ចាស កាលនោះគាត់ចេះតែនិយាយពីប្រវត្តិគាត់នៅផ្ទះ បងប្អូនគាត់បែកបាក់គ្នាពីម្តាយគាត់ អត់បាយហូបស្លាប់អស់ ទៅក៏ខ្ញុំ ក៏ចេះតែមានចិត្តនឹកឃើញអាណិតគាត់ ក៏បានរួមរស់ជាមួយគ្នាទៅ។

**ស៖** ក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ តើលោកស្រីមានផ្ទៃពោះទេ?

**ឆ៖** ខ្ញុំអត់មានទេ។ ដល់ខ្ញុំមាន ៗមកទៅនៅក្នុងជំរំទៅហើយបានខ្ញុំមាន។

**ស៖** ពេលដែលលោកស្រីរួមរស់ជាមួយស្វាមីនៅឆ្នាំ៧៨ នៅក្រសួងហិរញ្ញវត្ថុហ្នឹង លោកស្រីមាន<បានឮការកត់សម្គាល់ ឬក៏សំណួរអីទេ ព្រោះច្បាស់ណាស់ថា លោកស្រីអត់មានផ្ទៃពោះផង? តើ>មានការណែនាំ <នៅក្នុងពេលប្រជុំទាក់ទងនឹងស្ត្រីដែលរៀបការហើយ ហើយ>មិនមានផ្ទៃពោះ<ទេ>?

**ឆ៖** អត់មានទេ អត់មានអ្នកណាគេថា គេណែនាំគេអប់រំអីទេ ព្រោះយើងរៀបទៅ ក៏អ្នកខ្លះក៏គ្នាយូរទៅ ខ្លះក៏វាឆាប់មានទៅ អត់មានគេណែនាំអីផង។

**ស៖** នេះជាសំណួរចុងក្រោយរបស់ខ្ញុំ ហើយខ្ញុំនឹងប្រគល់វេទិកាជូនសហភាគីរបស់ខ្ញុំ។ តើ

ក្រោយពីរៀបការហើយហ្នឹង លោកស្រីបានរួមរស់ជាមួយប្តីហ្នឹងបានរយៈពេលប៉ុន្មានខែដែរ?

[១៥:៤៣:៥៦]

**ឆ៖** រយៈពេល៣ខែជាង រៀបតាំងពីខែ១១ ដល់ពេលយើងខែ១យួនចូលហ្នឹង រត់ទៅបែកគ្នារហូត ទាល់តែដល់រត់ទៅជិតចូលថៃហើយបានជួបគ្នាវិញ។

**ស៖** ហើយក្រោយពីរបបខ្មែរក្រហមឆ្នាំ៧៩ហ្នឹង លោកស្រីនៅរួមរស់ជាមួយប្តីលោកស្រីទេ?

**ឆ៖** ក្រោយពីរបបខ្មែរក្រហម ដែលខ្ញុំរត់ចេញផុតទៅហ្នឹង ទៅបានទៅជួបគ្នាទៅនៅក្នុងដែនដីថៃហើយ បានជួបជាប្តីគ្នា រស់នៅជាមួយគ្នាហ្នឹង។

**លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

សូមអរគុណលោកស្រីសាក្សី។ ខ្ញុំអស់សំណួរហើយ លោកប្រធាន ក៏ប៉ុន្តែសហភាតារបស់ខ្ញុំ លោកមេធាវី ឡោ ជុនធី គាត់មានសំណួរមួយចំនួនតូចទៀត លោកប្រធាន។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវីដើមបណ្តឹងរដ្ឋប្បវេណី!

**លោក ឡោ ជុនធី៖**

បាទ អរគុណលោកប្រធាន។ សូមគោរពអង្គជំនុំជម្រះទាំងមូល។ ខ្ញុំបាទ ឡោ ជុនធី ខ្ញុំមកពីអង្គការជំនួយផ្នែកច្បាប់នៅកម្ពុជា ក៏ជាមេធាវីដើមបណ្តឹងរដ្ឋប្បវេណីដែរ។

**សួរដោយលោក ឡោ ជុនធី៖**

**ស៖** តទៅនេះ ខ្ញុំបាទសុំសួរសំណួរបន្តពី ម៉ារី បន្តិច គឺចង់បញ្ជាក់លោកស្រីថា នៅមុនថ្ងៃដែលរៀបការហ្នឹង តើលោកស្រីបានដូចថា យល់ព្រមមុន ឬមួយដឹងមុន ក្នុងរយៈពេលប៉ុន្មាន? ប៉ុន្មានថ្ងៃមុន ឬមួយយ៉ាងម៉េច ដឹងពេលវេលាមុនម៉េចដែរ?

[១៥:៤៦:១៩]

**លោកស្រី ផាន់ ហ៊ឹម៖**

**ឆ៖** មុនដែលពេលខ្ញុំរៀបការហ្នឹង ក្រៅពីអ្នកដទៃផ្សេងទៀត ដែល២០គូនោះ គេអាចដឹងមុនមួយខែ តែចំពោះរូបខ្ញុំ សួរពីល្ងាច ព្រលឹមឡើងរៀបតែម្តង។

**ស៖** បាទ អរគុណ។ ថាតើគេៗបានប្រាប់លោកស្រីថាម៉េច បានថាបើមិនគោរពគេ ឬមួយគេបានជម្រាបថាយ៉ាងម៉េច ពាក្យដែលគេជម្រាបហ្នឹងថា គោរពអង្គការវិន័យ ឬមួយគោរពយ៉ាងម៉េច

បានយើងអាចរៀបការទៅកើត?

**ឆ៖** រយៈពេលនុ៎ង គាត់ហៅខ្ញុំសួរថា “អង្គការឲ្យមិត្តឯងមានគ្រួសារ តើមិត្តឯងថាម៉េចដែរ?” ខ្ញុំថា “ខ្ញុំអត់ទាន់យកទេគ្រួសារ”។ ទៅគាត់ថា “ពេលនេះ បើមិត្តមិនយក ក៏នៅតែអង្គការរៀបឲ្យដែរ។ មិត្តមិនគោរពអង្គការវិន័យទេឬ?” ខ្ញុំក៏ថា “អង្គការវិន័យ ខ្ញុំគោរព ប៉ុន្តែចំពោះគ្រួសារខ្ញុំអត់ទាន់យកទេ។” គាត់ថា “ត្រូវតែយក។ ព្រលឹមឡើងសមមិត្តរៀបខ្លួនទៅ ខ្ញុំដឹកខោអាវយកមកឲ្យ។” ខ្ញុំក៏មិនហ៊ានប្រកែកនឹងគេ ក៏ព្រលឹមឡើង ឃើញគេដឹកខោអាវយកមកឲ្យមែន។

**ស៖** បាទ អរគុណ។ តើលោកស្រីអាចជម្រាបបានទេ ទៅអង្គជំនុំជម្រះថា អ្វីដែលគេរំឭកថាជា “អង្គការវិន័យ”ហ្នឹង មានអត្ថន័យយ៉ាងម៉េច?

[១៥:៤៨:១០]

**ឆ៖** គេប្រាប់ថា ឲ្យគោរពអង្គការវិន័យហ្នឹង គេថាឲ្យយើងហ្នឹងគោរពអង្គការវិន័យហ្នឹង អង្គការវិន័យហ្នឹង គឺជាច្បាប់ទម្លាប់របស់បក្សដែលគេកំណត់ឲ្យយើងដើរតាមមាគ៌ាហ្នឹង គេថាអ៊ីចឹង។

**ស៖** ចុះនៅក្នុងពេលហ្នឹងអ្នកស្រីត្រូវតែគោរពតាម ដោយមានការភ័យខ្លាចពីរឿងអ្វីដែរអត់ទេ?

**ឆ៖** ពេលហ្នឹងខ្ញុំក៏គោរពតាម ព្រោះខ្លាចដែរ ខ្លាចតែគេយកយើងទៅធ្វើបាប។

**ស៖** ខ្ញុំចង់ជម្រាបសួរថា ពេលដែលរៀបការ២១គូហ្នឹង ពេលដែលរៀបការរួច អ្នកស្រីបានលើកឡើងហើយថា មានការរួមរស់នៅជាមួយគ្នា ប៉ុន្តែគូដទៃទៀត គេនៅខាងទួលទំពូង។ ថាតើចំពោះគូដទៃទៀតហ្នឹង អ្នកស្រីបានទទួលព័ត៌មានទេថា តើពួកគាត់ហ្នឹងរួមរស់នៅជាមួយគ្នាដោយស្រួលទៅដែរ ឬមួយអត់ទេ?

**ឆ៖** តាំងពីខ្ញុំរស់នៅចាប់រៀបការមក ពួកអ្នកនៅក្នុងទួលទំពូងដែលរៀបជាមួយគ្នាហ្នឹង គឺគេសុខស្រួលជាមួយគ្នាគ្រប់គ្នា ពេលដែលរត់យួនទៅហ្នឹង រត់ជាមួយគ្នា ទៅដល់ដីថៃទាំងអស់គ្នាហ្នឹង។

**ស៖** បាទ អរគុណ។ ខ្ញុំសូមត្រឡប់ទៅក្រោយបន្តិច ថាអ្នកស្រីបានធ្វើអ្នកលក់ៗនៅពាណិជ្ជកម្ម ខ្ញុំចង់ដឹងថាក្នុងសម័យកម្ពុជាប្រជាធិបតេយ្យហ្នឹង គេៗលក់ៗយ៉ាងម៉េចដែរ? គេលក់ហ្នឹង មានអីលក់ដូរជាលុយ ជាកាក់ ឬមួយលក់យ៉ាងម៉េច?

**ឆ៖** ខ្ញុំសូមសួរពី សួរខ្ញុំហ្នឹងថាលក់កាលពីខ្ញុំទើបចូល ឬមួយលក់នៅទីក្រុងផ្សារថ្មី?

**ស៖** សូមទោស លក់នៅផ្សារថ្មី ក្រោយហើយ។

[១៥:៥១:០៨]

**ឆ៖** ពេលដែលខ្ញុំរស់នៅក្នុងឃ្លាំងផ្សារថ្មីនេះ គឺអត់មានលក់ទេ ចែកជូនកម្មករទូទាំងប្រទេស ប៉ុន្តែរបស់របរអស់ហ្នឹង គឺមានកន្លែងចិញ្ចឹម ដូចជាគោ ដូចជាជ្រូកហ្នឹង កន្លែងជ្រូកគឺចិញ្ចឹមនៅឯច្រាំងចំរេះឯណោះ គេហៅក-៣១ កន្លែងជ្រូក។ បើកន្លែងគោ បែបនៅឯច្រាំងចំរេះហ្នឹងដែរ ព្រោះខ្ញុំមិនសូវដឹងដែរ។ ប៉ុន្តែដល់ពេល ថាដូចថាថ្ងៃចែក អាហ្នឹងឡានគេទៅដឹកយកមក ព្រលឹមឡើងហ្នឹងឡានមកដល់តែម្ដង។ មកដល់ទៅ ថ្លឹងឲ្យយើងទៅ យើងកត់អីរួចទៅ ដល់ពេលកម្មករមកចែក យកប័ណ្ណមក ដូចថានៅក្នុងមួយរោងចក្រហ្នឹង សាច់ជ្រូកប៉ុន្មាន សាច់ជ្រូក២០គីឡូ ឬមួយសាច់គោ១៥គីឡូ ឬមួយត្រីឆ្អើរ ឬមួយត្រីងៀតអីអ៊ីចឹងទៅ ពួកខ្ញុំនៅក្នុងផ្នែកនេះហ្នឹង ចាំថ្លឹងដាក់ឲ្យគ្រប់កន្លែងទៅ គេយកទៅអង្គភាពគេគ្រប់គ្នាអស់ទៅ។ ដល់ពេលបើថារាងសល់ យកមកម៉ាស៊ីនត្រជាក់ពោធិ៍ចិនតុងនេះ យកមកដាក់ក្នុងម៉ាស៊ីនត្រជាក់ហ្នឹង ឲ្យតែរបស់ដែលសាច់សល់ សាច់ជ្រូក សាច់គោអីហ្នឹង ត្រីស្រស់ត្រីអីហ្នឹង យកមកដាក់នៅក្នុងនេះហ្នឹង។ ដល់ពេលបើកវគ្គក្រោយទៀត មកដឹកអាហ្នឹងខ្លះទៅ បើកអាកាប់មកបន្ថែមទៀតមក យកចែកទៀតទៅ។ អត់មានជាលុយជាកាក់អី អត់ឃើញមានលុយអីផង។

**ស៖** បាទ អរគុណ។ ចំណុចមួយទៀត ថាតើលោកស្រីមានពេលមួយនោះ លោកស្រីបានទៅបង្រៀនកុមារ។ ខ្ញុំចង់សូមឲ្យជម្រាបថា ទៅអង្គជំនុំជម្រះថាតើបង្រៀនកុមារហ្នឹង បង្រៀនយ៉ាងម៉េចបង្រៀនមានសៀវភៅអីគ្រប់គ្រាន់បង្រៀន? ហើយបង្រៀនកុមារហ្នឹងប៉ុន្មាននាក់ដែរ?

**ឆ៖** កាលដែលខ្ញុំបង្រៀនកុមារនៅមន្ទីរស្រុកដំបូង មានសៀវភៅមួយក្បាល សៀវភៅហ្នឹងគេហៅសៀវភៅសម្រាប់មេរៀនអក្សរខ្មែរយើង ពីស្រះ "ា" ពី "ក, ខ" អីហ្នឹងទៅ មានបំបែកទៅរហូតទៅអ៊ីចឹងទៅ។ មានតែមួយក្បាលហ្នឹង។ តែកូនសិស្សមានតែក្ដារទេ អត់មានសៀវភៅសរសេរទេ។

[១៥:៥៣:២៧]

**ស៖** តើលោកស្រីដឹងថា កុមារហ្នឹងមកពីណាដែរ កូនខាងណា? កូនកម្មាភិបាល ឬមួយកូនប្រជាជនយើងនៅម្ដុំហ្នឹង?

**ឆ៖** កាលហ្នឹងខ្ញុំអត់សូវដឹងដែរ ប៉ុន្តែកុមារខ្លះនៅកូនអ្នកជម្លៀស ដែលគេជម្លៀសទៅអ៊ីចឹងដូចថាបាត់ស្លាប់ម្ដាយស្លាប់អីទៅ គេយកទៅដាក់កន្លែងកុមារហ្នឹង។ អ្នកខ្លះទៀត ដូចថាម្ដាយឪពុកចូលក្នុងជួរហ្នឹង ក៏ដកកុមារហ្នឹងទៅដាក់កន្លែងមន្ទីរកុមារហ្នឹងដែរ។ ចាស ខ្ញុំដឹងតែប៉ុណ្ណឹង។

**ស៖** អរគុណ។ ខ្ញុំសួរពីរសំណួរទៀត។ សំណួរទី១ ពាក់ព័ន្ធទៅនឹងប្រវត្តិលោកស្រីដែរថា លោកស្រីបានចេញពីស្រុកភូមិមក សួរថាតើចេញពីស្រុកភូមិរហូតទៅដល់កម្ពុជាប្រជាធិបតេយ្យហ្នឹង

ដំណើរការនៅក្នុង១៩៧៥ ដល់៧៩ហ្នឹង ថាបានទៅលេងផ្ទះដែរអត់ទេ?

**ឆ៖** ពី៧៩ដែលដាច់ទៅហ្នឹង ខ្ញុំបានទៅលេងផ្ទះម្ដង។ ទៅហ្នឹងជំនាន់ហ្នឹង ខ្ញុំទៅដល់នៅតែឪពុកម្ដាយខ្ញុំចាស់ៗនៅនឹងផ្ទះ ហើយប្អូនខ្ញុំចូលកងចល័ត បងស្រីខ្ញុំក៏គាត់ចូលកងចល័តអស់ដែរ។ តែជំនាន់ហ្នឹងខ្ញុំទៅដល់ គាត់មិនទាន់ហូបបាយរួមទេ គាត់នៅហូបបាយតាមផ្ទះ កាល៧៥ហ្នឹង ដែលខ្ញុំទៅលេងហ្នឹង។

**ស៖** អ៊ីចឹងមានន័យថា ពេលក្រោយទៀត គឺមិនបានទៅលេងទេ ហើយពេលដែលអ្នកស្រីរៀបការហ្នឹង ក៏ពួកគាត់ក៏មិនបានមកចូលរួមដែរ?

[១៥:៥៥:៣៦]

**ឆ៖** ពេលក្រោយមក កាលពីមុន ក្រោយដែលពេលខ្ញុំទៅហ្នឹង ខានទៅ ដល់ពេលឆ្នាំ៧០ ដែលខ្ញុំទៅនៅនឹងក-៩ហ្នឹង មិនដឹងឆ្នាំណាផងទេនេះ នេះឆ្នាំ៧៥ដែរ តែឈ្មោះ បងឡេង ហ្នឹងគាត់ឆ្លួត។ កាលហ្នឹងគាត់ឲ្យ គេឲ្យទៅរៀននៅវត្តឧណ្ណាលោម ដល់ពេលគាត់ទៅរៀនទៅ គាត់ដូចម៉េចទេ និយាយអត់ដឹងខុសអត់ដឹងត្រូវទេ កាលហ្នឹងចាស។ គាត់ធ្វើខោអាវនឹងគេ ជាមួយគេអ្នកទៅរៀនហ្នឹង អ្នកប្រុសហ្នឹងប្រធានឈ្មោះ អាពី ហ្នឹងប្រធានក្ដាប់នៅកន្លែងហ្នឹង។ ចាស ដល់ពេលគាត់យកទៅ ដល់ពេលគាត់យកខោអាវពី អាពី ហ្នឹងមករៀបទៅងូតទឹក ឃើញពស់នៅក្នុងខោអាវ។ តាំងពីហ្នឹងមក គាត់ចាប់និយាយរវើរវាយរហូត។ ដល់ពេលគាត់មកវិញ គាត់មកវិញ គាត់ចេះតែមកហៅខ្ញុំ។ មើលមិត្តឯង ខ្ញុំទៅរៀន ខ្ញុំឡើងឋានៈ ខ្ញុំបក្សយុវកកអីឯណាឯណី ស្រេចនឹងគាត់ថាអ៊ីចឹងទៅ។ គាត់ថាខ្ញុំនេះ អង្គការចាត់តាំងគាត់ឲ្យធ្វើនីរសារ ថាអ៊ីចឹង។ គាត់និយាយអត់ដឹងអ៊ីចឹងណា។ ចាស ដល់ពេលថ្ងៃមួយ ឈ្មោះអាឡាញ ហ្នឹងគេប្រធាននៅក្ដាប់ហ្នឹង គាត់ឮនិយាយមិនដឹងអ៊ីចឹង ក៏គាត់ស្មានថា គាត់ថា ចង់ចោទបងឡេង ហ្នឹងទៅជាសន្តិសម្ព័ន្ធ ថាខ្មាំងអ៊ីចឹងណា។ ដល់ពេលនេះទៅ ក៏គាត់ឡើងទៅ។ ដល់ឡើងទៅ ខ្ញុំណេះក៏នៅឯហ្នឹងដែរ នៅក្នុងផ្ទះហ្នឹងដែរ ក៏គាត់ថា មើលមិត្តឡេង មិត្តឯងចេះម៉េច បានមិត្តឯងនិយាយមិនដឹងអ៊ីចឹង? ក៏គាត់លើកជើងគងអន្ទាក់ខ្លាវីប ម៉េច អាឡាញ អ្អែងចង់ម៉េច អញគណៈសន្តិ អង្គការបំពាក់អញគណបក្សយុវកក ថាអ៊ីចឹង អ្អែងចង់ធ្វើម៉េច ថាអ៊ីចឹង។ ដល់នេះទៅ ថាស្ទុះរឹងមក មកច្របាច់ក អាឡាញ ហ្នឹង។ ដល់នេះខ្ញុំណេះក៏ទៅឱបគាត់ពីក្រោយ ឱបទៅ ខ្ញុំស្រែកឲ្យ ឡាញ ហ្នឹងចុះចេញទៅណា។ ខ្ញុំថា បងឡាញ ឯងចុះទៅ ចុះឲ្យបាត់ទៅ។ ដល់ពេលចុះបាត់ទៅ គាត់មកក្រញីខ្ញុំ។ ដល់មកក្រញីខ្ញុំ ខ្ញុំក៏គ្រវែងគាត់ដួលទៅ ខ្ញុំក៏រត់ដែរទៅ។

[១៥:៥៧:២៦]

ទៅចាប់វក់តាំងពីហ្នឹងទៅ។ ដល់ចាប់វក់ទៅ ខ្ញុំចេះតែថា គាត់ហ្នឹងឆ្កួតហើយ កុំធ្វើបាបគាត់ អាពួកនេះហ្នឹងចេះចោទគាត់ ថាគាត់ហ្នឹងខ្លាំង គាត់ហ្នឹងដូចថាចង់ធ្វើធំអីចឹងណ៎ា ទៅជារវើរវាយ ចោទគាត់ថាសន្តិសម្ព័ន្ធថាអីចឹងណ៎ា។ ទៅក៏ខ្ញុំចេះតែប្រាប់គាត់ថា អ៊ី! កុំអាលចោទគាត់អីចឹងអី មើលគាត់សិនទៅ ថាអីចឹង។ ដល់ពេលនេះទៅ គាត់វក់ខ្លាំងទៅ គាត់ទៅជាស្រាតខោស្រាតអាវ យកគាត់ទៅដាក់នៅលើឡៅហ្នឹង ខែហ្នឹងខែរងារផង កាល៧៥ហ្នឹង។ គាត់ស្រែកហៅឲ្យខ្ញុំហ្នឹងយកអីៗទៅឲ្យគាត់ ព្រោះខ្ញុំមិនហ៊ានទៅទេ ព្រោះខ្លាចគាត់វ៉ៃនោះ។ ដល់ពេលនេះទៅ ក៏សម្រេចចិត្តថាយកទៅពេទ្យ១៧។ ថាយកទៅពេទ្យ១៧ ទៅដល់ពេទ្យ១៧ហ្នឹង ស្រាប់តែពួកខ្ញុំប្រាប់ថា បងឡេង ឯងមកពេទ្យ បងឯងនៅឲ្យស្ងៀមទៅ បើពេទ្យមកចាក់ ឲ្យពេទ្យចាក់ផង។ អឺ ថាឲ្យខ្ញុំអីចឹង។ ដល់ពេលខ្ញុំមកវិញផុត ពេទ្យយកបាយ យកថ្នាំទៅចាក់ វ៉ៃពេទ្យផ្អើលពេញមន្ទីរពេទ្យហ្នឹង។ ស្រាប់ហើយទៅពេទ្យគេចាក់សោ ចាក់សោដាក់ច្រវាក់ទៀត។ ទៅដល់ពេលនេះ ក៏គេមកហៅកន្លែងខ្ញុំវិញ ថាឲ្យមកយកអ្នកជំងឺហ្នឹងមកវិញមក។ ដល់ពេលនេះ ពួកខ្ញុំទៅយក ដល់ខ្ញុំទៅយកទៅ គ្រាន់តែបើកទ្វារទៅ ខ្ញុំហៅ ពួកហ្នឹងអត់ហ៊ានចូលទេ ហ៊ានតែខ្ញុំមួយទេ។ ទៅខ្ញុំហៅ បងឡេង គ្រាន់តែឮមាត់ខ្ញុំ គាត់ស្ទុះរឹងមកឱបខ្ញុំ អើយអូនអើយ មិត្តឯងធ្វើនីរសារខ្ញុំ មិត្តឯងអត់យកបាយឲ្យខ្ញុំហូបអីចឹង។ គេបង្អត់បាយខ្ញុំ ខ្ញុំថាបងឯងវ៉ៃគេបានគេបង្អត់បាយខ្ញុំថាអីចឹងណ៎ា។ ឥឡូវតោះទៅកន្លែងយើងវិញ។ អឺ! តោះទៅកន្លែងវិញ។ ក៏ខ្ញុំបណ្ដើរមក។ ពួកពេទ្យអ្នកជំងឺអីរត់ឡើងលើឡៅអស់ ខ្លាចគាត់វ៉ៃ។ ដល់ខ្ញុំយកមកដល់កន្លែងវិញ អាពី ហ្នឹងយកទៅដាក់លើឡៅហ្នឹងទៀត ដាក់ចាក់សោគាត់ចោលនៅលើឡៅហ្នឹង។

[១៥:៥៩:០៧]

**ស៖** សូមទោស រឿងហ្នឹងដូចជាវែង ប៉ុន្តែរឿងកាត់ចុងក្រោយ តើយ៉ាងម៉េចរឿងហ្នឹង?

**ឆ៖** ខ្ញុំបានយកទៅ គេថាឲ្យយកគាត់ទៅមើលនៅវត្តព្រៃចារ នៅស្រុកខ្ញុំហ្នឹង។ ក៏ឲ្យខ្ញុំហ្នឹងជូនគាត់ទៅ។ បានទៅបានអើតផ្ទះម្ដង ក្នុងនុំងដែរ ពីរដង បានទៅមួយភ្លែតទេ អាសាក្រោយហ្នឹង គ្រាន់ជូនទៅ ដាក់គាត់នៅកន្លែងវត្តគ្រូដែលមើលហ្នឹងទៅ ខ្ញុំត្រឡប់មកវិញ ខ្ញុំបានឆៀងចូលផ្ទះមួយភ្លែត។ ហើយបានត្រឡប់មកវិញហ្នឹង បានពីរដងហ្នឹង។ ចាស សាក្រោយហ្នឹង អត់បានយូរទេ បានតែមួយភ្លែតទេ គ្រាន់តែចូលទៅអើតឃើញម៉ែឪនេះហ្នឹង ប៉ុនហ្នឹងគេហូបបាយរួមហើយ។

**លោក ឡោ ជុនធី៖**

អរគុណលោកប្រធាន។ ខ្ញុំអស់សំណួរហើយ។

**ប្រធានអង្គជំនុំ៖**

អរគុណលោកមេធាវី។ ឥឡូវដល់ពេលឈប់សម្រាក់ហើយ អង្គជំនុំជម្រះប្រកាសផ្អាកកិច្ចដំណើរសវនាការសម្រាប់ថ្ងៃនេះត្រឹមនេះ ហើយសវនាការនឹងបន្តធ្វើនៅថ្ងៃស្អែក ថ្ងៃព្រហស្បតិ៍ ទី០១ ខែកញ្ញា ឆ្នាំ២០១៦ ចាប់ផ្តើមពីម៉ោងប្រាំបួនព្រឹក។ លោកស្រី ផាន់ ហ៊ីម សវនាការស្តាប់សក្ខីកម្មរបស់លោកស្រីនៅមិនទាន់ចប់នៅឡើយទេ។ ហើយអង្គជំនុំជម្រះកោះអញ្ជើញលោកស្រី និងបុគ្គលិកអង្គការ ធី.ភី.អូ មកបន្តផ្តល់សក្ខីកម្មនៅថ្ងៃស្អែកទៀត។ សវនាការនៅថ្ងៃស្អែក អង្គជំនុំជម្រះនឹងធ្វើសវនាការស្តាប់សក្ខីកម្មសាក្សី ផាន់ ហ៊ីម បញ្ចប់ ហើយអង្គជំនុំជម្រះសូមរំឭកដល់ភាគីថា នៅស្អែកនេះបន្ទាប់ពីបញ្ចប់ការស្តាប់សក្ខីកម្មសាក្សី ផាន់ ហ៊ីម អង្គជំនុំជម្រះនឹងស្តាប់សារណាផ្ទាល់មាត់របស់ភាគីពាក់ព័ន្ធទៅនឹងការកោះហៅបុគ្គលដែលមានរហស្សនាម 2-TCE-93 សូមភាគីជ្រាប និងអញ្ជើញចូលរួមតាមពេលវេលាកំណត់។

បង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទទាំងពីររូប លោក នួន ជា និងលោក ខៀវ សំផន ត្រឡប់ទៅកាន់មន្ទីរឃុំឃុំឃាំងនៃអ.វ.ត.កវិញចុះ និងបង្គាប់ឲ្យនាំខ្លួនគាត់ត្រឡប់ចូលរួមសវនាការនៅថ្ងៃព្រហស្បតិ៍ ទី០១ ខែសីហា ឆ្នាំ២០១៦ ឲ្យបានមុនម៉ោងប្រាំបួនព្រឹក។

សូមអញ្ជើញសម្រាក៕

*(សវនាការផ្អាកនៅម៉ោង ១៦:០១ នាទី)*